សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# ពាណិជ្ជកម្មអេឡិចត្រូនិកក្រោមក្របខណ្ឌច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកកម្ពុជា

សរសេរសារណាពីថ្ងៃទី២៧ ខែមេសា ឆ្នាំ ២០២១ ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ ២០២១

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ **សឿន និត្ថា**

សាស្ត្រាចារ្យណែនាំ
លោក **ជ័យ រិទ្ធី**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី ២១

ឆ្នាំចូលសិក្សា ២០១៧
ឆ្នាំសរសេរសារណា ២០២១

# **សេចក្តីធានាអះអាង**

នាងខ្ញុំឈ្មោះ **សឿន និត្តា** ជាភាសាឡាតាំង SOUERN NITA កើតនៅថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០០០ មានទីកន្លែងកំណើតនៅឃុំសំរោង ស្រុក សូទ្រនិគម ខេត្ត សៀមរាប និងមានអាសយដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ១៩ ផ្លូវលេខ ៤៨៨ សង្កាត់វង្វង់មូលផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ។ បច្ចុប្បន្ននាងខ្ញុំជានិស្សិតនៃថ្នាក់បរិញ្ញាបត្រ ជំនាន់ទី២១ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ ព្រមទាំងជាបេក្ខភាពដែលនឹងត្រូវការពារសារណាបញ្ចប់ការសិក្សាថ្នាក់នីតិសាស្ត្រ ផ្នែកនីតិសាស្ត្រ ឆ្នាំសិក្សា ២០២០-២០២១។

នាងខ្ញុំសូមសំដែងការធានាអះអាងចំពោះ រាល់ខ្លឹមសារអត្ថន័យនៃសារណាបញ្ចប់ការសិក្សាផ្នែកនីតិសាស្ត្រលើប្រធានបទ « **ពាណិជ្ជកម្មអេឡិចត្រូនិកក្រោមច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកកម្ពុជា** » គឺពិតជាត្រូវបានរៀបចំ ស្រាវជ្រាវ ប្រកបដោយភាពជាក់លាក់ មានអំណះអំណាងដកស្រង់ចេញពីឯកសារយោងដែលណែនាំដោយសាស្ត្រាចារ្យ ព្រមទាំងមានប្រភពគួរឱ្យទុកចិត្ត។ ចំពោះឯកសារសារណាបញ្ចប់ការសិក្សានេះផងដែរ គឺត្រូវបានសរសេរឡើងដោយឆ្លងកាត់ការសិក្សា និងឱ្យយោបល់ដោយសាស្ត្រាចារ្យណែនាំ ហើយចំនុណដែលបានដកស្រង់ចេញពីឯកសារផ្សេងគឺត្រូវបានយោងប្រភពច្បាស់លាស់។

នាងខ្ញុំនឹងទទួលខុសត្រូវនូវរាល់ចំណុចមិនត្រឹមត្រូវចំពោះឯកសារសារណានេះ។

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ **សឿន និត្តា** ជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ជំនាន់ទី២១ ថ្នាក់ L4A1 ក្នុងឆ្នាំសិក្សា ២០២០- ២០២១ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមលំឱនកាយក្រាបប្រណម្យគោរពថ្លែងនូវ ការដឹងគុណប្រកបដោយភាពកតញ្ញូដ៏ប្រសើរក្រៃបំផុត ជូនចំពោះ **លោកឪពុក អ្នកម្តាយ បង្កើត** ដែលលោកទាំងពីរអង្គបាន ផ្តល់កំណើត ផ្តល់ក្តីអាណិតស្រលាញ់ជាអនេក អប់រំទូន្មាន ប្រៀនប្រដៅ តម្រង់ទិសហាត់ពត់ លត់ដំ ព្រមទាំងឈរជាខ្នងបង្អែកដ៏កក់ក្តៅសម្រាប់កូននូវគ្រប់កាលៈទេសៈ និងបានលះបង់សព្វបែបយ៉ាងមិនថាធានធាន ក៏ដូចជាស្មារតីកម្លាំងចិត្ត ដើម្បីផ្គត់ផ្គង់កូនឱ្យទទួលបានការអប់រំ ចំណេះដឹង ប្រកបដោយគុណធម៌ ចាប់តាំងពីថ្នាក់មេត្តេយ្យសិក្សា រហូតដល់បានបញ្ចប់ការសិក្សា ថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ ជាមួយគ្នានេះក៏សូមគោរពដឹងគុណជូនចំពោះ **អ្នកម្តាយធម៌** ដែលលោកបានចំណាយពេលវេលា និងទឹកចិត្តដ៏មហាធំផេងជួយចិញ្ចឹមបីបាច់ថែរក្សា ណែនាំ កូនប្រកបដោយក្តីស្រឡាញ់ និងការចិត្តទុកដាក់ខ្ពស់។ ចំពោះគុណូបការៈដ៏លើសលប់ របស់លោកទាំងបីបានចូលរួមចំណែកខ្លាំងក្លាបំផុតសម្រាប់ជីវិតកូនដែលមិនអាចនឹងរ៉ាយរ៉ាប់អស់ឡើយ។

សូមថ្លែងអំណរគុណជូនចំពោះ **ឯកឧត្តម សាកលវិទ្យាធិការ សាកលវិទ្យាធិការរង** និង **លោក/លោកស្រី សាស្ត្រាចារ្យ** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច គ្រប់រូបដែលបានបង្ហាត់បង្រៀន ផ្ទេរចំណេះដឹង សីលធម៌ និងបង្ហាញពីទិដ្ឋភាពនៃសង្គម ដល់នាងខ្ញុំក្នុងអំឡុងពេលសិក្សា។

សូមថ្លែងអំណរគុណជាពិសេសជូនចំពោះ លោកសាស្ត្រាចារ្យ **ជ័យ រិទ្ធី** ដែលជាសាស្ត្រាចារ្យណែនាំចំពោះកិច្ចការសារណាលើប្រធានបទ« **ពាណិជ្ជកម្មអេឡិចត្រូនិកក្រោមច្បាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកកម្ពុជា**» ដោយលោកបានចំណាយពេលវេលាដ៏មានតម្លៃ បង្ហាញទិសដៅ និងកែសម្រួល ចាប់តាំងពីពេលចាប់ផ្តើមរហូតដល់បានបញ្ចប់កិច្ចការសារណានេះ មិនតែប៉ុណ្ណោះលោកថែមទាំងបានណែនាំនូវផ្លូវល្អៗសម្រាប់ថ្ងៃអនាគតទៀតផង។

ជាចុងបញ្ចប់នាងខ្ញុំសូមគោរពជូនពរដល់ **លោកអ្នកមានគុណ សាកលវិទ្យាធិការ សាកលវិទ្យាធិការរង** និង**សាស្ត្រាចារ្យគ្រប់រូប** សូមទទួលបានសេចក្តីសុខ ភាពជោគជ័យ និងសូមទទួលបាននូវពុទ្ធពរទាំងបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

នៅក្រោយពេលដែលទទួលបានការសិក្សាអប់រំនៅក្នុងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចអស់រយៈពេលជិត៤ឆ្នាំ នាងខ្ញុំកត់សម្គាល់ខ្លួនឯងបានថាមានចំណាប់អារម្មណ៍ទៅមុខវិជ្ជា នីតិពាណិជ្ជកម្ម។ នាងខ្ញុំមានបំណងប៉ងទុកមកថា នៅពេលដែលសាលាតម្រូវឱ្យសរសេរជាអត្ថបទសារណាបញ្ចប់ឆ្នាំ នោះនាងខ្ញុំប្រាដកក្នុងចិត្តថានឹងរើសយកប្រធានបទទាំងឡាយណាដែលស្ថិតក្រោមក្របខណ្ឌនៃនីតិពាណិជ្ជកម្ម។ បន្ថែមពីនេះដោយសង្កេតឃើញថាបច្ចុប្បន្នប្រទេសកម្ពុជា ក៏ដូចជាបណ្តាប្រទេសនានាក្នុងតំបន់ និងអន្តរជាតិកំពុងដើរលើមាគ៌ាសេដ្ឋកិច្ចឌីជីថលផង បូករួមជាមួយការលើកទឹកចិត្តពីសំណាក់សាស្ត្រាចារ្យណែនាំផង នាងខ្ញុំក៏សម្រេចចិត្តជ្រើសរើសប្រធានបទមួយដែលសិក្សាទៅលើ ពាណិជ្ជកម្មកម្ពុជាក្រោមក្របខណ្ឌច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកកម្ពុជា។

ចំពោះប្រធានបទសារណានេះជាប្រភេទប្រធានបទសិក្សាស៊ីជម្រៅទៅលើក្របខណ្ឌច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកកម្ពុជា ដែលទាមទារឱ្យអ្នកអានមានមូលដ្ឋានលើផ្នែកពាណិជ្ជកម្ម និងផ្នែកច្បាប់ព្រមទាំងការវិវត្តថ្មីៗក្នុងវិស័យឌីជីថលផងដែរ ពីព្រោះថាប្រធានបទនេះត្រូវបានបកស្រាយយ៉ាងស៊ីចង្វាក់ពីចំណុចមួយទៅចំនុចមួយដោយមានទំនាក់ទំនងរួមផ្សំរវាងនៃសកម្មភាពពាណិជ្ជកម្មអេឡិចត្រូនិក និងតួនាទីរបស់ច្បាប់។ នៅក្នុងការសរសេរប្រធានបទនេះទៀតសោតថ្វីបើអាចដើរទាន់សភាពការនៃភាពរីចម្រើននៃវិស័យពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកក៏ពិតមែន ក៏ប៉ុន្តែនាងយល់ថានៅអាចមានចំនុចខ្វះខាតមួយចំនួនដែលនៅចន្លោះដោយសារកត្តាសមត្ថភាពរបស់នាងខ្ញុំក្នុងការបកស្រាយ ព្រមជាមួយកង្វះខាតនៃព័ត៌មានជាភាសាជាតិពាក់ព័ន្ធនឹងប្រធានបទនេះ។

ជាចុងបញ្ចប់ នាងខ្ញុំសូមទទួលយកនូវ ការរិះគន់ពីសំណាក់ លោក លោកស្រីសាស្ត្រាចារ្យ សិស្ស និស្សិតគ្រប់មជ្ឈដ្ឋានទាំងអស់ដើម្បីស្ថាបនា ដោយក្តីគោរព និងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ដើម្បីធានាយ៉ាងណាឱ្យសារណាមួយនេះមានគុណភាពកាន់តែល្អប្រសើរឡើង។ នាងខ្ញុំសូមធ្វើការអភ័យទោសជាមុនក្នុងករណីមានកំហុសឆ្គងដោយប្រការណាមួយមិនថាជាទម្រង់ ឬខ្លឹមសារនៃការបកស្រាយ ហើយនាងខ្ញុំក៏សង្ឃឹមថានឹងអាចទទួលបាននូវការយោគយល់អធ្យាស្រ័យពីសំណាក់លោក លោកស្រីសាស្ត្រាចារ្យ សិស្ស និស្សិត ព្រមអ្នកមិត្តអ្នកអានដោយក្តីមេត្តាអនុគ្រោះ។

# មាតិកា


**តារាងសម្គាល់អក្សរកាត់** .... VI

**សេចក្តីផ្តើម** .... ១

**ជំពូកទី១ ដំណើរវិវត្តនៃច្បាប់ ពាណិជ្ជកម្មអេឡិចត្រូនិកកម្ពុជា** .... ៥

**១.១ ក្របខណ្ឌគតិយុត្ត គោលនយោបាយអន្តរជាតិ តំបន់ និងកម្ពុជា** .... ៥

**១.១.១ លិខិតបទដ្ឋានគតិយុត្តនៃអង្គការសហប្រជាជាតិ** .... ៥

**១.១.២ លិខិតបទដ្ឋានគតិយុត្តរបស់អាស៊ាន** .... ៨

**១.១.៣ ក្របខណ្ឌគោលនយោបាយ** .... ៩

**១.១.៤ ក្របខណ្ឌច្បាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកកម្ពុជា** .... ១៥

**១.២ វិសាលភាព និងសុពលភាពនៃប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក** .. ១៧

**១.២.១ អភិបាលកិច្ចអេឡិចត្រូនិក** .... ១៨

**១.២.២ ទំនាក់ទំនងគតិយុត្តអេឡិចត្រូនិក** .... ២៤

**១.២.៣ ហត្ថលេខាអេឡិចត្រូនិក** .... ២៩

**១.២.៤ លក្ខខណ្ឌដើម្បីកំណត់តម្លៃភស្តុតាងអេឡិចត្រូនិក** .... ៣២

**ជំពូកទី២ តួនាទីច្បាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកក្នុងអាជីវកម្ម . រៃប៉ូរ! ញ៉ាក់មារក ឡូត ដចេិនដេ។**

**២.១ ការគ្រប់គ្រងលើអាជីវកម្ម** .... ៣៧

**២.១.១ ការគ្រប់គ្រងលើប្រតិបត្តិករ** .... ៣៨

**២.១.២ កិច្ចគ្រប់គ្រងលើការទូទាត់ប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក** ................................ ៤២

**២.១.៣ កិច្ចគ្រប់គ្រងលើកម្មសិទ្ធិបញ្ញា**................................................................................ ៤៧

**២.២ កិច្ចការពារអ្នកប្រើប្រាស់ និង ដំណោះស្រាយវិវាទ**...................................................... ៤៩

**២.២.១ កិច្ចការពារលើការផ្តល់ព័ត៌មាន**................................................................................ ៤៩

**២.២.២ កិច្ចការពារទិន្នន័យអ្នកប្រើប្រាស់** ........................................................................... ៥១

**២.២.៤ ការដោះស្រាយវិវាទ**............................................................................................... ៥៣

**សេចក្តីសន្និដ្ឋាន**............................................................................................................. ៥៦

**អនុសាសន៍**..................................................................................................................... ៥៨

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# តារាងសម្គាល់អក្សរកាត់

| | |
|---|---|
| 3PL | ការដឹកជញ្ជូនដោយភាគីទី៣/ Third-Party Logistics |
| ASEAN | សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍/ Association of Southeast Asian Nations |
| B2B | ធុរកិច្ចទៅធុរកិច្ច/ Business to Business |
| B2C | ធុរកិច្ចទៅអ្នកប្រើប្រាស់/ Business to Consumer |
| CA | វិញ្ញាធរហត្ថលេខាឌីជីថល/ Certificate Authority |
| CO | វិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ/ Certificate of Origin |
| FinTech | បច្ចេកវិទ្យាហិរញ្ញវត្ថុ/ Financial Technology |
| G2B | រដ្ឋាភិបាលដើម្បីធុរកិច្ច/ Government to Business |
| ICT | បច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍/ Information and Communication Technology |
| MOC | ក្រសួងពាណិជ្ជកម្ម/ Ministry of Commerce |
| MPTC | ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍/ Ministry of Posts and Telecommunications |
| SME | សហគ្រាសធុនតូច និងមធ្យម/ Small & Medium Enterprises |
| WTO | អង្គការពាណិជ្ជកម្មពិភពលោក/ World Trade Organization |

# សេចក្តីផ្តើម

ក្នុងបរិបទនៃសកលភាវូបនីយកម្មបូករួមជាមួយដំណើរនៃបដិវត្តឧស្សាហកម្ម៤.0 ធ្វើឱ្យការវិវត្តរបស់ពិភពលោកមានភាពជឿនលឿនឆាប់រហ័សដែលជាពិសេសប្រទេសនានាមានទំនាក់ទំនងគ្នាកាន់តែច្រើនដើម្បីស្វែងរកការអភិវឌ្ឍជាបន្តបន្ទាប់សម្រាប់សេដ្ឋកិច្ចប្រទេសជាតិរៀងៗខ្លួន។ ការប្រើប្រាស់ និងអភិវឌ្ឍន៍នៃបច្ចេកវិទ្យាក្លាយជាឧបករណ៍សំខាន់សម្រាប់ទ្រទ្រង់ដល់ការរីកចម្រើនលើគ្រប់វិស័យនៃប្រទេសនីមួយៗ រាប់ចាប់តាំងពីការរស់ប្រចាំថ្ងៃធម្មតារបស់ប្រជាពលរដ្ឋ រហូតដល់ការគ្រប់គ្រងរចនាសម្ព័ន្ធប្រទេសដូចយ៉ាង ការអនុវត្តនូវអភិបាលកិច្ចអេឡិត្រូនិក (E-governance) ជាដើម។ សម្រាប់ការអភិវឌ្ឍនេះទៀតសោតវាបានធ្វើឱ្យការធ្វើពាណិជ្ជកម្មកាន់តែសម្បូរបែបក្នុងនោះដែរ វាមានតម្រូវការកាន់តែច្រើនឡើងៗ នៃការប្រើប្រាស់បច្ចេកវិទ្យា ជាពិសេសពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។ ចំណែកឯនៅក្នុងប្រទេសកម្ពុជាបច្ចុប្បន្នវិញ ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកក្លាយជាពាណិជ្ជកម្មដ៏ពេញនិយម និងជួយសម្រួលដល់ការរស់នៅរបស់ប្រជាជនកម្ពុជាផងដែរ ហើយនេះក៏ព្រោះឥទ្ធិពលនៃបច្ចេកវិទ្យាដែលចូលមកប្រទេសកម្ពុជាកាន់តែច្រើនឡើងៗ ព្រមជាមួយនិងការបិទខ្ទប់ទីក្រុងដោយសារវិបត្តិនៃជម្ងឺកូវីដ-19ដែលត្រូវបានប្រកាសថាជាជម្ងឺឆ្លងសកលកាលពីថ្ងៃទី១១ខែមីនា ឆ្នាំ២០២០។[1] ដូចដែលបានដឹងស្រាប់ ជម្ងឺរាតត្បាតនេះបង្កឱ្យមានភាពរអាក់រអួលក្នុងវិស័យសេដ្ឋកិច្ចមួយផ្នែកធំដោយហេតុថាវាជាករណីប្រធានសក្តិដែលកើតឡើងដោយមិនបានព្រៀងទុក និងមិនអាចព្យាករណ៍បាន ក៏ប៉ុន្តែវាបានពន្លឿនការដាក់ឱ្យដំណើរការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិចដែលជាមធ្យោបាយចម្បងមួយដែលមានតម្រូវការខ្លាំងពីសំណាក់អ្នកប្រើប្រាស់។[2] ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិច ក្លាយទៅជាវិធីសាស្ត្រទំនើបក្នុងការធ្វើពាណិជ្ជកម្ម ដោះដូរទំនិញ ឬសេវាកម្មជូនដល់អតិថិជន តាមប្រព័ន្ធអេឡិចត្រូនិកដែលដំណើរការដោយការប្រើប្រាស់សេវាអ៊ីនធឺណិត។[3] ចំពោះWTO បានឱ្យនិយមន័យពាណិជ្ជកម្មអេឡិចត្រូនិក ជាពាក្យដែលត្រូវបានគេយល់ថាជា ការផលិត ការចែកចាយ ការលក់ ឬការផ្តល់ទំនិញ និងសេវាកម្មតាមមធ្យោបាយអេឡិចត្រូនិក។

[1] World Health Organization: https://bit.ly/3kt0yxt , ចូលមើលនៅថ្ងៃទី០១ខែមិថុនា ឆ្នាំ២០២១

[2] ETrade for all Connecting Dots: Covid-19 and E-Commerce: Global Review, United Nation, 2021

[3] Zhen Qin, Introduction to E-Commerce, Springer-Verlag Berlin Heidelberg, Tsinghua University Press, 2009

បើយោងតាមច្បាប់នៃពាណិជ្ជកម្មអេឡិចត្រូនិកកម្ពុជាឆ្នាំ២០១៩ ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក (Electronic Commerce) សំដៅដល់សកម្មភាពទិញ លក់ ជួល ផ្លាស់ប្តូរទំនិញ ឬសេវា ដោយរាប់បញ្ចូលទាំងសកម្មភាពពាណិជ្ជកម្ម និងរដ្ឋប្បវេណីព្រមទាំងសកម្មភាព និងប្រតិបត្តិការនានារបស់រដ្ឋតាមប្រព័ន្ធអេឡិចត្រូនិច។ ពាណិជ្ជកម្មអេឡិចត្រូនិក ឬ E-commerce នៅកម្ពុជាបច្ចុប្បន្ន មានការរីកដុះដាលជាច្រើនជាពិសេសនៅក្នុងវិស័យឯកជនដែលក្នុងនោះរួមមានដូចជា ការប្រើប្រាស់កម្មវិធីទូរសព្ទ ឬវេបសាយសម្រាប់កម្ម៉ង់ទិញទំនិញ ម្ហូបអាហារ សម្លៀកបំពាក់ កក់ការធ្វើដំណើរ ការគិតលុយតាមទូរស័ព្ទព្រមទាំងសកម្មភាពប្រចាំថ្ងៃនានាជាដើម។ បើក្រលេកទៅមើលទម្រង់នៃពាណិជ្ជកម្មអេឡិចត្រូនិកវិញ វាមានលក្ខណៈយ៉ាងប្រទាក់ក្រឡាគ្នារវាង អតិថិជន (C=Consumer) ធុរកិច្ច (B=Businesses) ឬជាមួយរាជរដ្ឋាភិបាល (G=government)។ ចំពោះទំនាក់ទំនងរវាងធុរកិច្ច និងរាជរដ្ឋាភិបាល (Business-to-government, B2G) អាចកើតមានឡើងតាមរយៈការជួយសម្របសម្រួលការធ្វើពាណិជ្ជកម្មរបស់ពាណិជ្ជករដោយរាប់ចាប់តាំងពីការរៀបចំមាគ៌ាបើកផ្លូវសម្រាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិច ការបង្កើតក្របខណ្ឌច្បាប់ គោលនយោបាយនានា ដើម្បីជួយគ្រប់គ្រងសុវត្ថិភាពព្រមទាំងធានាកិច្ចការពារសម្រាប់ពាណិជ្ជករ។ បន្ថែមពីនេះពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកដែលមានទំនាក់ទំនាក់រវាងធុរកិច្ចទៅកាន់អតិថិជន (Businesses-to-Consumer, B2C) ដែលពាណិជ្ជករអាចដាក់លក់នូវទំនិញ ឬសេវាកម្មជូនទៅអតិថិជនផ្ទាល់ដោយមិនចាំមានការលក់បន្តសម្រាប់ដំណើរការបញ្ជារទិញពីអតិថិជន។[4] ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកម្យ៉ាងទៀត ត្រូវធ្វើឡើងតាមរយៈទំនាក់ទំនងធុរកិច្ច និងធុរកិច្ច (Businesses-to-Businesses, B2B) ដែលធុរជនមានទំនាក់ទំនងគ្នាទៅវិញទៅមកសម្រាប់ការបញ្ជូនទំនិញ ឬសេវាកម្មពីភាគីធុរជនម្ខាងទៅភាគីធុរជនម្ខាងទៀតដើម្បីដាក់លក់ទំនិញ ឬសេវាកម្មទៅកាន់អតិថិជន។

ភាពងាយស្រួល និងពេញនិយមនៃពាណិជ្ជកម្មអេឡិចត្រូនិកធ្វើឱ្យចំនួនអ្នកប្រើប្រាស់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកមានការកើនឡើងជានិច្ច តួយ៉ាងក្នុងឆ្នាំ២០២០ មានប្រជាជនទូទាំងពិភពលោកច្រើនជាង២ប៊ីលាននាក់បានបញ្ជាទិញទំនិញ ឬសេវាកម្មតាមប្រព័ន្ធអនឡាញ[5]។ នៅបណ្តាប្រទេសអភិវឌ្ឍន៍ ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកជារឿងសាមញ្ញដោយហេតុថា បណ្តាប្រទេសទាំងនោះ មានបច្ចេកវិទ្យាជឿនលឿន ព្រមទាំងមានក្របខណ្ឌច្បាប់រឹងមាំក្នុងការគ្រប់គ្រងរាល់សកម្មភាពពាណិជ្ជកម្មទាំងនោះ។ ហើយចំពោះប្រទេសដែលមានបច្

[4] OECDilibrary, https://bit.ly/3jfMok7 , ចូលមើលថ្ងៃ២០ ខែមិថុនា ឆ្នាំ២០២១

[5] Statista, https://bit.ly/3ygQFrS , ចូលមើលនៅថ្ងៃទី០៧ខែមិថុនា ឆ្នាំ២០២១

ចេកវិទ្យាកម្រិតទាបអាចជួបនូវបញ្ហាមួយចំនួនដែលជាពិសេសនោះគឺ ការគ្រប់គ្រងកិច្ចពាណិជ្ជកម្មអេឡិចត្រូនិក ដែលវាជាចាំបាច់ត្រូវតែមានការបង្កើតច្បាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកដើម្បីធ្វើយ៉ាងសំដៅកាត់បន្ថយ ការទាញយកផលចំនេញហួសហេតុជាលក្ខណៈបុគ្គលផ្ទាល់ខ្លួនពីសំណាក់ពាណិជ្ជករដែលជ្រើសរើសយកបច្ចេកវិទ្យាសម្រាប់ពាណិជ្ជកិច្ចរបស់ពួកគេ។ មិនតែប៉ុណ្ណោះ ការបង្កើតនិងអនុម័តច្បាប់នេះក៏ស្របទៅតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិឆ្នាំ២០១៩-២០៣០ ក៏ដូចជាយុទ្ធសាស្ត្រចតុកោណ មុំទី៣នៃចតុកោណទី២ ដែលមានទិសដៅដើម្បីជម្រុញការធ្វើពិពិធកម្មសេដ្ឋកិច្ច រាជរដ្ឋាភិបាលកម្ពុជាបានជួយសម្របសម្រួលការធ្វើពាណិជ្ជកម្ម។ ហើយនៅក្នុងប្រធានបទនេះមានលក្ខណៈពិសេស បង្ហាញឱ្យឃើញពីភាពជាប់ទាក់ទងគ្នារវាងបញ្ញត្តិច្បាប់ ការគ្រប់គ្រងសម្របសម្រួលពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិករបស់រាជរដ្ឋាភិបាល ជាមួយពាណិជ្ជករដែលរកទទួលទានតាមប្រព័ន្ធអេឡិចត្រូនិក។

ការអនុម័តច្បាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកធានាជួយធ្វើឱ្យការគ្រប់គ្រងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក មានលក្ខណៈច្បាស់លាស់ជាងមុន។ ហើយដោយហេតុដែលបានលើកអធិប្បាយលើ ប្រធានបទអំពី« ពាណិជ្ជកម្មអេឡិចត្រូនិកក្នុងក្របខណ្ឌច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកកម្ពុជា » ត្រូវឆ្លើយតបនូវសំនួរចម្បងចំនួន២គឺទីមួយថាតើលិខិតបទដ្ឋានគតិយុត្តមានការវិវត្តដូចម្តេចមុននឹងឈានដល់ការអនុម័តច្បាប់ ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកកម្ពុជា? ចំណែកចំពោះសំនួរទីពីរគឺ តើច្បាប់ពាណិជ្ជកម្មអេឡិចត្រូនិកនៅកម្ពុជាមានឥទ្ធិពលទៅគ្រប់គ្រងលើប្រតិបត្តិករក្នុងវិស័យនេះ និងផ្តល់កិច្ចការពារអ្វីខ្លះដល់អ្នកប្រើប្រាស់?

ចំពោះគោលបំណងនៃការស្រាវជ្រាវលើប្រធានបទស្តីអំពី « ពាណិជ្ជកម្មអេឡិចត្រូនិកក្នុងក្របខណ្ឌច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកកម្ពុជា » គឺដើម្បីចូលរួមចំណែកលើកកម្ពស់ក្នុងការសិក្សាបន្ថែម អំពីបទដ្ឋានគតិយុត្តថ្មីមួយរបស់កម្ពុជាយើងគឺច្បាប់ពាណិជ្ជកម្មអេឡិចត្រូនិកកម្ពុជា អនុម័តកាលពីថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៩ ដែលច្បាប់នេះមានសារៈសំខាន់ជាចាំបាច់ណាស់ ចំពោះអ្នកច្បាប់ទូទៅ ហើយជាពិសេសអ្នកធ្វើធុរកិច្ចដោយមានការជាប់ទាក់ទងនឹងផ្នែកពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។ ម្យ៉ាងនៅប្រទេសកម្ពុជាយើងបច្ចុប្បន្ន ថ្វីបើមានការហូរចូល និងកំណើននៃការប្រើប្រាស់បច្ចេកវិទ្យា អេឡិចត្រូនិចក៏ពិតមែន ប៉ុន្តែការសិក្សាស្រាវជ្រាវប្រធានបទដែលមានខ្លឹមសារជាប្រភេទច្បាប់គឺនៅមានចំនួនខ្វះខាតនៅឡើយ។ បន្ថែមពីនេះ ប្រធាននេះអាចពង្រីកវិសាលភាពនៃការអនុវត្តច្បាប់នេះបានមួយកម្រិតបន្ថែមទៀតដោយហេតុថា នៅពេលដែលមានការសិក្សាស្រាវជ្រាវច្រើនអំពីច្បាប់

នេះ នោះនឹងនាំឱ្យការអនុវត្តច្បាប់កាន់តែទទួលបាននូវភាពត្រឹមត្រូវ ព្រមទាំង បញ្ចៀសបាននូវបញ្ហានានា ដែលនាំឱ្យខាតបង់ និងអាចបំពេញភាពខ្វះចន្លោះលើផ្នែកណាមួយនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

ចំណែកទំហំនៃប្រធានបទនេះវិញត្រូវបានកំណត់ស្របទៅតាមបញ្ញត្តិដែលបានចែងក្នុងច្បាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៃព្រះរាជាណាចក្រកម្ពុជា ឯវិធីសាស្ត្រនៃការស្រាវជ្រាវពឹងផ្អែកទាំងស្រុងទៅលើប្រភពទិន្នន័យទី២(Secondary Data) ដែលក្នុងនោះមានច្បាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៃព្រះរាជាណាចក្រកម្ពុជាជាប្រភពចម្បង និង ប្រភពបន្ទាប់បន្សំមានដូចជា ច្បាប់ជាតិ ច្បាប់អន្តរជាតិ អនុក្រឹត្យ ប្រកាស គោលនយោបាយ សៀវភៅ អត្ថបទបោះផ្សាយ គេហទំព័រ និងសារព័ត៌មានដែលគួរឱ្យទុកចិត្តបំផុត។

ក្នុងប្រធានបទស្តីអំពី « ពាណិជ្ជកម្មអេឡិចត្រូនិកក្នុងក្របខណ្ឌច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកកម្ពុជា » មានលក្ខណៈប្រទាក់ក្រឡាក្នុងការបកស្រាយ ហើយដើម្បីជាជំនួយក្នុងការបកស្រាយនូវប្រធានបទនេះឱ្យមានលក្ខណៈត្រឹមត្រូវ រៀបរយ ព្រមជាមួយខ្លឹមសារបកស្រាយគ្រប់ជ្រុងជ្រោយប្រកបដោយសក្តិភាពជាក់លាក់ ជាចាំបាច់សារណានេះត្រូវបែងចែកជាពីរជំពូកសំខាន់ៗ គឺ ជំពូកទី១ បង្ហាញអំពីដំណើរវិវត្តនៃច្បាប់ស្តីពីពាណិជ្ជកម្មអេឡិចត្រូនិកកម្ពុជា និងជំពូកទី២ បង្ហាញអំពី តួនាទីច្បាប់ពាណិជ្ជកម្មអេឡិចត្រូនិកកម្ពុជាក្នុងអាជីវកម្ម។

# ជំពូកទី១ ដំណើរវិវត្តនៃច្បាប់ ពាណិជ្ជកម្មអេឡិចត្រូនិកកម្ពុជា

ការរីកចម្រើនទៅមុខនៃពិភពលោកមានឥទ្ធិពលមកលើប្រទេសកម្ពុជាយើងតួយ៉ាងដូចជាការប្រើប្រាស់បច្ចេកវិទ្យាជាដើមរហូតដល់មានលំហូរចូលនៃអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិកទៀតផង។ ក្រលេកមកមើលចំពោះទិដ្ឋភាពច្បាប់សម្រាប់ធានាការអនុវត្តវិញក៏ស្រដៀងគ្នានេះដែរ ពោលគឺមានមូលដ្ឋានពីក្របខណ្ឌគតិយុត្ត ក៏ដូចជាគោលនយោបាយនានារបស់ថ្នាក់អន្តរជាតិ និងតំបន់។ ជាការពិតណាស់ចំពោះការវិវត្តនៃច្បាប់ពាណិជ្ជកម្មអេឡិចត្រូនិកកម្ពុជា ទទួលបានធាតុចូលរួមមកពីក្របខណ្ឌគតិយុត្តអង្គការសហប្រជាជាតិ ក៏ដូចជាអាស៊ាន រហូតឈានដល់មានវិសាលភាពនៃការអនុវត្តនៅក្នុងប្រទេស។ នៅក្នុងជំពូកទីមួយនេះមានពីរផ្នែកដែលត្រូវបកស្រាយ ពោលផ្នែកទីមួយ (១) ក្របខណ្ឌគតិយុត្ត គោលនយោបាយអន្តរជាតិ តំបន់ និងកម្ពុជា រីឯផ្នែកទីពីរ(២) វិសាលភាព និងសុពលភាពនៃប្រតិបត្តិការ។

## ១.១ ក្របខណ្ឌគតិយុត្ត គោលនយោបាយអន្តរជាតិ តំបន់ និងកម្ពុជា

ការអភិវឌ្ឍនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ទាមទារឱ្យមានការរៀបចំក្របខណ្ឌគោលនយោបាយ និងច្បាប់ជាក់លាក់ទាំងក្នុងក្របខណ្ឌជាតិ និងអន្តរជាតិ។ ចំពោះបទដ្ឋានគតិយុត្តដែលជាប់ពាក់ព័ន្ធទៅនឹងដំណើរវិវត្តនៃច្បាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកកម្ពុជា សង្កេតឃើញថាមានប្រភពច្រើនមកពីស្ថាប័នខុសៗពីគ្នា។ ដូចនេះដើម្បីស្វែងយល់ធ្វើយ៉ាងណាឱ្យបានកាន់តែស៊ីជម្រៅ នោះជាចាំបាច់ត្រូវដឹងពីប្រភពផ្សេងៗដែល បានគូសវាសអំពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកជាបន្តបន្ទាប់ទៅនេះ៖

### ១.១.១ លិខិតបទដ្ឋានគតិយុត្តនៃអង្គការសហប្រជាជាតិ

នៅពេលដែលនិយាយពីការបង្កើតច្បាប់ ឬបទដ្ឋានគតិយុត្តនោះគេត្រូវនឹកដល់ប្រភពនានាដែលជាគំរូដែលមានធាតុផ្សំចូលរួមក្នុងការបង្កើតច្បាប់នោះ យ៉ាងណាមិញច្បាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកកម្ពុជាក៏ដូចនោះដែរ ពោលគឺមានប្រភពនៃការបង្កើតស្របទៅតាមបទដ្ឋានអន្តរជាតិត្រឹមត្រូវដែលសមស្របទៅតាមស្ថានភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ក្នុងក្របខណ្ឌគតិយុត្តនៃអង្គការសហប្រជាជាតិ ច្បាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកកម្ពុជាបានទទួលធាតុចូលពី UNCITRAL Model Law On Electronic Commerce (MLEC) ដែលជាគំរូច្បាប់ស្នូលមួយទាក់ទងនឹងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។ ចំពោះគំរូច្បាប់ UNCITRAL Model Law On Electronic Commerce (MLEC) ត្រូវបានបង្កើតដំបូងដោយ The United Nation Commission On

International Trade Law ឬដែលហៅកាត់ថា UNCTRAL ជានីតិបុគ្គលដ៏សំខាន់មួយក្នុងប្រព័ន្ធរបស់អង្គការសហប្រជាជាតិធ្វើការលើផ្នែកច្បាប់ទាក់ទងទៅនឹងជំនួញអន្តរជាតិ ដែលត្រូវបានបង្កើតឡើងដោយមហាសន្និបាតអង្គការសហប្រជាជាតិក្នុងឆ្នាំ១៩៦៦។ នីតិបុគ្គលជំនាញផ្នែកច្បាប់ជំនួញអន្តរជាតិ UNCTRAL មានបទពិសោធក្នុងកិច្ចការកំណែទម្រង់ច្បាប់ពាណិជ្ជកម្មទូទាំងពិភពលោកជាង៥០ឆ្នាំ ព្រមទាំងបានជួយធ្វើទំនើបនីយកម្ម និងសម្របសម្រួលវិធាននានាក្នុងដំណើរនៃពាណិជ្ជកម្មអន្តរជាតិ ។[6]

គំរូច្បាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក The Model Law On Electronic Commerce (MLEC) បង្កើតឡើងដើម្បីចូលរួមចំណែកក្នុងការដាក់ឱ្យដំណើរការ និងសម្របសម្រួលដល់ពាណិជ្ជកម្មទាំងឡាយណាដែលប្រព្រឹត្តឡើងទៅតាមប្រព័ន្ធអេឡិចត្រូនិក។ ក្នុងន័យម្យ៉ាងទៀតគឺវាផ្តល់ជាវិធានដល់ការបង្កើតច្បាប់ជាតិនីមួយៗដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ ដើម្បីដោះស្រាយបញ្ហានានាក៏ដូចជាចងទុកជាមុនដើម្បីគ្រប់គ្រងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកក្នុងគោលដៅជំរុញសកម្មភាពជំនួញជាលក្ខណៈអន្តរជាតិ។[7] ចំពោះគំរូច្បាប់(MLEC) ត្រូវបានសង្កេតឃើញថាមានចំនួន៣ ដែលវិវត្តស្របទៅតាមបរិបទនៃការពេញនិយមប្រើប្រាស់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដូចជា UNCITRAL Model Law on Electronic Commerce (1996), UNCITRAL Model Law on Electronic Signatures (2001), UNCITRAL Model Law on Electronic Transferable Records (2017)។

**ក. UNCITRAL Model Law on Electronic Commerce (1996)**

នៅក្នុង UNCITRAL Model Law on Electronic Commerce (1996) ដែលជាគំរូច្បាប់គ្រឹះនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវបានចែកចេញជា២ផ្នែកធំៗគឺទីមួយមានបង្ហាញពី UNCITRAL Model Law on Electronic Commerce និងទីពីរមានបង្ហាញពីមគ្គុទេសន៍ក្នុងការអនុម័តនៃ UNCITRAL Model Law on Electronic Commerce។ ក្នុងផ្នែកទីមួយជាផ្នែកសម្រាប់ផ្តល់ជាគំរូដល់ច្បាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកដោយផ្អែកទៅតាមមាត្រា១ នៃគំរូច្បាប់នេះ វិសាលភាពនៃការអនុវត្ត ត្រូវបានកំណត់ថា វាអាចអនុវត្តបានលើគ្រប់

[6] UNCITRAL, https://bit.ly/3knNr0B , ចូលមើលថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២១

[7] UNICITRAL, https://bit.ly/3BajcB6 , ចូលមើលថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២១

ទម្រង់នៃទិន្នន័យសារដែលត្រូវបានប្រើប្រាស់ក្នុងបរិបទនៃសកម្មភាពអាជីវកម្ម។ [8] ចំពោះផ្នែកទីពីរនៃគំរូច្បាប់នេះវិញ វាបានជួយសម្រួលដល់នីតិវិធីក្នុងការបង្កើតក៏ដូចជាអនុម័តនូវច្បាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ជាក់ស្តែងផ្អែកតាមចំណុចទី១៣ នៃផ្នែកD នីតិវិធីនៃការធ្វើឱ្យច្បាប់ដែលជាកិច្ចព្រមព្រៀងមានលក្ខណៈពេញលេញអាចអនុវត្តបាន។

**ខ. UNCITRAL Model Law on Electronic Signatures (2001)**

ចំពោះ UNCITRAL Model Law on Electronic Signatures (2001) វិញ ជាគំរូច្បាប់មួយដែលចូលរួមក្នុងការបង្កើតច្បាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកលើក្នុងទំនាក់ទំនងអេឡិចត្រូនិចក្នុងគោលបំណងធ្វើអាជីវកម្ម និងដែលជាពិសេសគឺនីតិវិធីសុវត្ថិភាពនៃការប្រើប្រាស់ហត្ថលេខាអេឡិចត្រូនិក។ ផ្អែកតាមមាត្រា២ នៃ UNCITRAL Model Law on Electronic Signatures (2001) ហត្ថលេខាអេឡិចត្រូនិក(Electronic Signature) មានន័យសំដៅដល់ ទិន្នន័យក្នុងទម្រង់អេឡិចត្រូនិកដែលជាប់ពាក់ព័ន្ធនឹង ទិន្នន័យសារ ដែលត្រូវបានប្រើប្រាស់ដើម្បីបង្ហាញពីអត្តសញ្ញាណនៃហត្ថលេខីនឹងទិន្នន័យសារ និងបញ្ជាក់ពីការអនុម័តរបស់ហត្ថលេខីនៃព័ត៌មានដែលផ្ទុកក្នុងទិន្នន័យសារនោះ។ ចំពោះច្បាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកកម្ពុជា ក្នុងជំពូក៤ មាត្រា២០ ហត្ថលេខាអេឡិចត្រូនិកដែលមានសុវត្ថិភាព ហត្ថលេខាអេឡិចត្រូនិកដែលមានសុវត្ថិភាព លុះត្រាតែគោរពទៅតាមលក្ខខណ្ឌខាងក្រោម៖

ក, ផ្សារភ្ជាប់ទៅកាន់ហត្ថលេខីតែម្នាក់គត់

ខ, កំណត់បានអត្តសញ្ញាណរបស់ហត្ថលេខី

គ, ត្រូវបានបង្កើតឡើងដោយប្រើប្រាស់មធ្យោបាយដែលស្ថិតក្រោមការគ្រប់គ្រងរបស់ហត្ថលេខី

ឃ, បញ្ជាក់អំពីពេលវេលា និងកាលបរិច្ឆេទនៃការចុះហត្ថលេខា។ និង

ង, បញ្ជាក់អំពីស្ថានភាពដើមនៃសារ ឬកំនត់ត្រាអេឡិចត្រូនិកដែលត្រូវបានផ្សារភ្ជាប់ដោយហត្ថលេខានោះ។

**គ. UNCITRAL Model Law on Electronic Transferable Records (2017)**

---

[8] UNCITRAL Model Law on Electronic Commerce with guide to enactment1996 with additional article5 bis as adopted in1998, United Nation 1999

ចំណែកឯ UNCITRAL Model Law on Electronic Transferable Records (2017) ជាក៏គំរូច្បាប់ដែលមានប្រភពចេញពី UNCITRAL ជានាលើកំណត់ត្រាតាមប្រព័ន្ធអេឡិចត្រូនិកដែលអាចផ្ទេរបាន ដើម្បីរក្សាទុកនូវកំណត់ត្រាទាំងនោះជាភស្តុតាង។ ក្នុងគំរូច្បាប់នេះបានចងនូវគំរូនៃកំណត់ត្រាអេឡិចត្រូនិចដែលក្នុងនោះមានទាំងលក្ខខណ្ឌតម្រូវជាលាយលក្ខណ៍អក្សរ និងលក្ខខណ្ឌតម្រូវចំពោះហត្ថលេខា។ [9]ចំពោះច្បាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកកម្ពុជា ក្នុងជំពូកទី២ ក៏បានចែងដោយអនុលោមទៅតាមគំរូច្បាប់នេះផងដែរ តួយ៉ាងដូចជា មាត្រា៦ លក្ខខណ្ឌតម្រូវជាលាយលក្ខណ៍អក្សរ

១,នៅពេលដែលបទប្បញ្ញត្តិណាមួយ តម្រូវឲ្យផ្តល់ព័ត៌មានជាលាយលក្ខណ៍អក្សរ ឬធ្វើកំណត់ត្រាជាលាយលក្ខណ៍អក្សរ ត្រូវចាត់ទុកថា លក្ខខណ្ឌតម្រូវនេះត្រូវបានបំពេញប្រសិនបើព័ត៌មាននេះធ្វើឡើងក្នុងទម្រង់អេឡិចត្រូនិក ហើយអាចចូលប្រើប្រាស់បាន និងអាចទាញយកទៅប្រើប្រាស់នៅពេលក្រោយបាន។

២, នៅពេលដែលលក្ខខណ្ឌក្នុងបញ្ញត្តិនៃកថាខណ្ឌទី១ខាងលើ ត្រូវយកមកអនុវត្តលក្ខខណ្ឌតម្រូវឲ្យតាមច្បាប់ដែលទាមទារឲ្យបុគ្គលណាមួយផ្តល់សំណៅចម្លងច្រើនច្បាប់ក្នុងពេលតែមួយស្តីអំពីព័ត៌មានណាមួយ ឬកិច្ចការណាមួយទៅឲ្យបុគ្គលមួយផ្សេងទៀត បុគ្គលដែលផ្តល់អាចបំពេញលក្ខខណ្ឌនេះដោយគ្រាន់តែផ្តល់ក្រោមទម្រង់អេឡិចត្រូវនិកតែមួយច្បាប់បាន។

### ១.១.២ លិខិតបទដ្ឋានគតិយុត្តរបស់អាស៊ាន

ក្រៅតែពីគំរូច្បាប់របស់អង្គការសហប្រជាជាតិ ក្របខណ្ឌច្បាប់ក្នុងសមាគមប្រជាជាតិអាស៊ានបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការបង្កើតច្បាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកកម្ពុជាផងដែរ។ មិនតែប៉ុណ្ណោះនៅក្នុងរង្វង់នៃសមាគមប្រជាជាតិអាស៊ាន ក៏ត្រូវបានសង្កេតឃើញថាមាននូវកិច្ចព្រមព្រៀង ក៏ដូចជាផែនការនានាសម្រាប់គូសវាសផ្លូវច្បាប់នៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកផងដែរ។ តួយ៉ាងដូចជា កិច្ចព្រមព្រៀងស្តីពីអាស៊ានE-ASEAN ឆ្នាំ២០០០, កិច្ចព្រមព្រៀងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ASEAN Agreement on Electronic Commerce ឆ្នាំ២០១៨ ព្រមទាំងផែនការលំអិតសហគមន៍សេដ្ឋកិច្ចអាស៊ាន AEC Blueprint 2025ជាដើម។ កិច្ចព្រមព្រៀងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ASEAN Agreement On Electronic Commerce គឺជាកិច្ចព្រមព្រៀងរួមនៃបណ្តាប្រទេសដែលជាសមាជិកអាស៊ាន ក្នុងនោះរួមមានទាំងកម្ពុជាផងដែរ(សូមមើលក្នុងឧបសម្ព័ន្ធទី១)

[9] UNCITRAL Model Law on electronic Transferable Records, United Nation, New York, 2018

។ ចំពោះកិច្ចព្រមព្រៀងនេះត្រូវបានធ្វើឡើងនៅទីក្រុងហានណូយ ប្រទេសវៀតណាម កាលពីឆ្នាំ២០១៩ ដែលមានកម្មវត្ថុចំនួនបីសំខាន់ៗគឺៈ

- កម្មវត្ថុទីមួយ ដើម្បីសម្របសម្រួលដល់ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកឆ្លងកាត់ព្រំដែនក្នុងតំបន់អាស៊ាន
- កម្មវត្ថុទីពីរ ដើម្បីចូលរួមចំណែកបង្កើតនូវបរិយាកាសប្រកបដោយភាពជឿទុកចិត្តគ្នាក្នុងការប្រើប្រាស់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ទៅវិញទៅមកក្នុងតំបន់អាស៊ាន
- កម្មវត្ថុទីបី ជំរុញកិច្ចសហប្រតិបត្តិការជាមួយបណ្ដាប្រទេសជាសមាជិក ដើម្បីអភិវឌ្ឍន៍ការប្រើប្រាស់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកឱ្យកាន់តែខ្លាំងឡើងដើម្បីបង្កើនភាពរីកចម្រើនរួមគ្នា និងបន្ថយគម្លាតនៃការអភិវឌ្ឍក្នុងតំបន់អាស៊ាន។

ផ្អែកតាមកិច្ចព្រមព្រៀងនេះទៀតសោត បានចងនូវកាតព្វកិច្ចក្នុងកិច្ចសហប្រតិបត្តិការមួយចំនួនដែលតម្រូវឱ្យ មានហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យា ICT ការអប់រំ និងការប្រកួតប្រជែងផ្នែកបច្ចេកវិទ្យា កិច្ចការពារអ្នកប្រើប្រាស់តាមប្រព័ន្ធអនឡាញ ការបង្កើតច្បាប់ និងបទដ្ឋានគតិយុត្តលើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក សុវត្ថិភាពនៃការផ្ទេរតាមប្រព័ន្ធអេឡិចត្រូនិក និងការការពារព័ត៌មានផ្ទាល់ខ្លួនតាមប្រព័ន្ធអេឡិចត្រូនិក ការទូទាត់តាមប្រព័ន្ធអេឡិចត្រូនិក និងការដោះស្រាយវិវាទ ការសម្របសម្រួលការធ្វើជំនួញ សិទ្ធិកម្មសិទ្ធិបញ្ញា ការប្រកួតប្រជែង សុវត្ថិភាពបច្ចេកវិទ្យា ភស្តុភារសម្របសម្រួលពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។ បន្ថែមពីនេះសមាជិកនៃកិច្ចព្រមព្រៀងត្រូវមាន ការចែករំលែកព័ត៌មាន បទពិសោធន៍ទាក់ទងនឹងការអនុវត្តដែលល្អ ព្រមទាំងបង្កើតនូវកម្មវិធី ឬគម្រោងនានាដែលអាចជួយសមាជិកដទៃទៀតតាមរយៈការបង្កើនច្បាប់សម្រាប់គ្រប់គ្រងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកក្នុងស្រុកឱ្យបានកាន់តែទូលំទូលាយ។ សមាជិកនៃកិច្ចព្រមព្រៀងក៏ត្រូវរៀបចំឱ្យមាននូវអាជ្ញាធរដើសមស្របមួយសម្រាប់ជួយសម្របសម្រួល តាមដានស៊ើបអង្កេត រកដំណោះស្រាយក្នុងករណីមានវិការៈទាក់ទិននឹងE-commerce Transactions។

### **១.១.៣ ក្របខណ្ឌគោលនយោបាយ**

ដើម្បីអភិវឌ្ឍសេដ្ឋកិច្ចឱ្យមានកំណើនទៅមុខ ព្រមទាំងធានាបានភាពធន់ កម្ពុជាបានដាក់ចេញនូវក្របខណ្ឌគោលនយោបាយជាច្រើនដូចជា យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម២០១៥-២០២៥ ដែលជាក្របខ័ណ្ឌយុទ្ធសាស្ត្រចម្បងៗ

ក្នុងការពង្រឹងពង្រីកទំហំសេដ្ឋកិច្ចនៃព្រះរាជាណាចក្រកម្ពុជា ក្នុងនោះដែរចំពោះវិស័យឌីជីថល មាននូវក្របខណ្ឌគោលនយោបាយមួយដែលជាគោលនោះគឺក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ចឌីជីថល និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥ ។ ចំណែកពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិច ក៏មានគោលនយោបាយក៏ដូចជាយុទ្ធសាស្ត្រសម្រាប់គាំទ្រដល់ការអនុវត្តច្បាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកដែលនោះគឺ យុទ្ធសាស្ត្រពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដែលជាឯកសារសំខាន់មួយសម្រាប់ការអនុវត្តក្នុងបរិបទនៃបច្ចេកវិទ្យាទំនើបស្របតាមនិន្នាការរបស់តំបន់ និងពិភពលោក ជាពិសេសវាក៏ជាយន្តការជំហានដំបូងដ៏សំខាន់សម្រាប់ឱ្យកម្ពុជាឆក់យកនូវផលចំណេញផ្នែកសេដ្ឋកិច្ចដែលទទួលបានមកពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។ បន្ថែមពីនេះ នៅក្នុងយុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មកម្ពុជាឆ្នាំ២០១៩-២០២៣ដែលមានទិសដៅចង្អុលបង្ហាញអំពីយន្តការនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅកម្ពុជាផងដែរ។

**ក. គោលនយោបាយសេដ្ឋកិច្ចឌីជីថល និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥**

ក្របខណ្ឌវិនិយោគគ្រប់ជ្រុងជ្រោយនឹងត្រូវបានរៀបចំឡើង ដើម្បីគាំទ្រដល់ផែនការវិនិយោគនៅក្នុងវិស័យឌីជីថល ជាពិសេសក្រោមក្របខណ្ឌគោលនយោបាយ នេះ និង ផែនការមេអភិវឌ្ឍន៍វិស័យឌីជីថលកម្ពុជា។ ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា មានចក្ខុវិស័យ "កសាងសេដ្ឋកិច្ច និង សង្គមឌីជីថលរស់រវើកតាមរយៈការរៀបចំមូលដ្ឋានគ្រឹះជំរុញការទទួលយក និង បរិវត្តកម្មឌីជីថលនៅក្នុង គ្រប់តួអង្គសង្គម ទាំងរដ្ឋ ទាំងពលរដ្ឋ និង ទាំងធុរជន ដើម្បីជំរុញសមុះកំណើនសេដ្ឋកិច្ចថ្មី និង លើកកម្ពស់ សុខុមាលភាពសង្គម តាមគន្លងប្រក្រតីភាពថ្មី" ។ ត្រង់ចំនុចនេះសបង្ហាញថាសករាជនៃកិច្ចពាណិជ្ជកម្ម បានបើកទ្វាសម្រាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកកាន់តែធំលាយ ព្រមទាំងប្រកបដោយការគាំទ្រ ជ្រោមជ្រែងពីសំណាក់លិខិតបទដ្ឋានគតិយុត្ត ព្រមជាមួយផែនការគោលនយោបាយច្បាស់លាស់។ ក្នុងន័យនេះដែរធុរិកិច្ចតាមប្រព័ន្ធអេឡិចត្រូនិក នឹងត្រូវបានពង្រឹងតាមរយៈការយកចិត្តទុកដាក់លើការប្រើប្រាស់បច្ចេកវិទ្យានៅក្នុងសហគ្រាស ការអភិវឌ្ឍប្រព័ន្ធអេកូឡូស៊ីសហគ្រិនភាព/ធុរកិច្ចថ្មី និង ការជំរុញឱ្យមានការតភ្ជាប់នឹងខ្សែច្រវាក់តម្លៃឌីជីថលតំបន់និងសកល។[10]

**ខ. យុទ្ធសាស្ត្រពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក**

---

[10] ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ, ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថល ខែឧសភា ឆ្នាំ២០២១

យុទ្ធសាស្ត្រពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ជាយុទ្ធសាស្ត្រត្រូវបានរៀបចំចងក្រងឡើងដោយដោយ អន្តរក្រសួងស្ថាប័នជាតិចំនួន១៨ ស្ថាប័នឯកជន គ្រឹះស្ថានបណ្ដុះបណ្ដាលនិងដៃគូអភិវឌ្ឍន៍សរុបចំនួន៦០ ក្រោមជំនួយពីស្ថាប័នពង្រឹងសមាហរណកម្មពាណិជ្ជកម្មនៃ Enhanced Integrated Framework (EIF)។ យុទ្ធសា ស្ត្រមានគោលបំណងចំពោះការពង្រឹងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកកម្ពុជាតាមរយៈគោលដៅយុទ្ធសាស្ត្រចំនួន៤ដូចទៅ៖

**គោលដៅយុទ្ធសាស្ត្រទី១៖ លើកកម្ពស់បរិយាកាសធុរកិច្ច ក្របខ័ណ្ឌបទប្បញ្ញត្តិ និងការសម្របសម្រួលស្ថាប័ន[11]**

គោលដៅយុទ្ធសាស្ត្រនេះមានគោលបំណងធ្វើឱ្យប្រសើរឡើងនូវបរិយាកាសធុរកិច្ចទាំងមូល និងក្របខ័ណ្ឌបទប្បញ្ញត្តិសម្រាប់សហគ្រាសពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ទាំងក្នុងដំណើរការទាក់ទងនឹងការចុះបញ្ជី និងការផ្តល់ អាជ្ញាប័ណ្ណដល់អាជីវកម្មជាពិសេសសហគ្រាសធុនតូច និងមធ្យម ការទទួលបានព័ត៌មាន លទ្ធភាពទទួលបានហិរញ្ញវត្ថុ និងបញ្ហាផ្សេងៗទៀត។ ហើយក្របខ័ណ្ឌអភិវឌ្ឍន៍សហគ្រាសធុនតូច និងមធ្យមនឹងពិនិត្យឡើងវិញដើម្បីស្វែងយល់អំពីបញ្ហាប្រឈមដែលទាមទារឱ្យមានការកែលម្អលើបទប្បញ្ញត្តិ និងការលើកទឹកចិត្តសម្រាប់សហគ្រាសពាណិជ្ជកម្មតាមប្រព័ន្ធ អេឡិចត្រូនិក។ នៅកម្រិតស្ថាប័ន ការយល់ដឹងអំពីវិស័យពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនឹងត្រូវបានពង្រឹងដើម្បី ផ្តល់នូវការគាំទ្រដែលមានប្រសិទ្ធភាពខ្ពស់ដល់សហគ្រាសពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

**គោលដៅយុទ្ធសាស្ត្រទី២៖ បង្កើនសមត្ថភាពសហគ្រាសធុនតូច និងមធ្យម និងបង្កើនការសម្របសម្រួលនៅក្នុងខ្សែច្រវាក់តម្លៃ**

គោលដៅយុទ្ធសាស្ត្រនេះមានគោលបំណងធ្វើឱ្យប្រសើរឡើងនូវសមត្ថភាពផ្នែកខាងតម្រូវការសម្រាប់សហគ្រាស ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងអ្នកតំណាងវិស័យឯកជនដូចជាសភាពាណិជ្ជកម្ម និងសមាគមវិស័យឯកជន ដើម្បីយល់ច្បាស់អំពីឱកាស និងនិន្នាការនៅក្នុងវិស័យនេះ សម្រាប់ចូលរួមក្នុងការពិគ្រោះយោបល់ជាមួយ និងផ្តល់ អនុសាសន៍ជាជំហររួមជាទៀងទាត់ដល់អ្នកបង្កើតគោលនយោបាយ។ នៅក្នុងការងារនេះ សភាពាណិជ្ជកម្ម និង សមាគមវិស័យឯកជន ចាំបាច់ត្រូវអភិវឌ្ឍជំហររបស់ខ្លួនសម្រាប់វិស័យពាណិជ្ជកម្មតាមប្រព័ន្ធអេ

[11] ក្រសួងពាណិជ្ជកម្ម,យុទ្ធសាស្ត្រពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, ខែវិច្ឆិកា ២០២០

ឡិចត្រូនិក និងសេដ្ឋកិច្ច ឌីជីថលដែលមានលក្ខណៈទូលំទូលាយតាមរយៈការរៀបចំសៀវភៅស ឬការចូលរួមជាទៀងទាត់ក្នុងការពិគ្រោះយោបល់ សាធារណៈ និងឯកជន។

**គោលដៅយុទ្ធសាស្ត្រទី៣៖ លើកកម្ពស់ការដឹកជញ្ជូនក្នុងស្រុកនិងឆ្លងកាត់ព្រំដែន**

ការសិក្សាលើភស្តុភារកម្មនៅក្នុងយុទ្ធសាស្ត្រនេះគឺ ផ្តោតលើការដឹកជញ្ជូនក្នុងស្រុក តាមរយៈការជួយដល់សហគ្រាសពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកអភិវឌ្ឍសមត្ថភាពក្នុងសហគ្រាសផ្ទាល់ និងកាត់ បន្ថយភាពបែកខ្ញែកនៃការផ្តល់សេវាដឹកជញ្ជូនជាភាគីទីបី ដោយបង្កើនសមត្ថភាព និងកិច្ចសហការគ្នា។ មួយ វិញទៀត ដោយទទួលស្គាល់ពីបញ្ហាប្រឈមនឹងអាសយដ្ឋានរូបវន្ត ដំណោះស្រាយផ្សេងៗដូចជាអាសយដ្ឋាននិមិត្តរូប អាចត្រូវបានពិនិត្យ និងយកទៅអនុវត្ត ហើយការធ្វើវិសិដ្ឋកម្មសមត្ថភាពរបស់ប្រៃសណីយ៍កម្ពុជាក៏ជាការងារអាទិភាព មួយបន្ថែមលើការជំរុញភាពប្រកួតប្រជែងសម្រាប់អ្នកផ្តល់សេវាដឹកជញ្ជូនកញ្ចប់អីវ៉ាន់ក្នុងស្រុក។ សម្រាប់ភស្តុភារកម្ម ឆ្លងកាត់ព្រំដែនគឺស្របតាមចក្ខុវិស័យក្នុងការជំរុញពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកឆ្លងកាត់ព្រំដែនដើម្បីធានាបាននូវកំណើនពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកយូរអង្វែងនៅកម្ពុជា ហើយទាក់ទងនឹងការងារនេះ ការងារសំខាន់ៗមួយ ចំនួននឹងត្រូវអនុវត្តដូចជា ការអភិវឌ្ឍសមត្ថភាពនៅក្នុងកិច្ចព្រមព្រៀង កិច្ចសម្រួលពាណិជ្ជកម្ម ជាពិសេសការធ្វើពាណិជ្ជកម្មឆ្លងកាត់ព្រំដែនដោយគ្មានក្រដាសស្នាម អភិវឌ្ឍន៍ធនធានមនុស្ស និងការប្តេជ្ញា ចិត្តដែលបានព្រមព្រៀងនៅក្នុងកិច្ចព្រមព្រៀងអាស៊ានស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។ អ្វីដែលសំខាន់ផង ដែរគឺការអនុវត្តគំនិតផ្តួចផ្តើមច្រកចេញចូលតែមួយ ដែលនឹងធ្វើឱ្យប្រសើរឡើងនូវខ្សែច្រវាក់តម្លៃពាណិជ្ជកម្មឆ្លងកាត់ ព្រំដែនទាំងមូល ដោយសម្រួលដល់ការដាក់និងពិនិត្យឯកសារមានលក្ខណៈស្តង់ដារ ដែលមានចំណុចចូលតែមួយ ដើម្បីបំពេញរាល់ការនាំចេញ នាំចូល និងតម្រូវការទាក់ទងនឹងបទប្បញ្ញត្តិដឹកទំនិញឆ្លងកាត់។[12]

**គោលដៅយុទ្ធសាស្ត្រទី៤៖ ពង្រឹងហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ ការទទួលបានហិរញ្ញ ប្បទាន ដោយបរិយាប័ន្ន និងអក្ខរកម្មឌីជីថលដើម្បីឱ្យពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិករីកដុះដាលទូទាំងប្រទេស**

គោលដៅយុទ្ធសាស្ត្រនេះផ្តោតលើការជំរុញប្រព័ន្ធអេកូឡូហ្ស៊ីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកទាំងមូលដើម្បីពង្រីកទៅកាន់តំបន់ជនបទ។ គោលដៅរួមនៃគោលដៅយុទ្ធសាស្ត្រនេះគឺធ្វើការកែលម្អអត្រាអក្ខរកម្មឌីជីថលនៅ ទូទាំងប្រទេស ស្របពេលដែលគំនិតផ្តួចផ្តើម ពង្រីក និងធ្វើទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាន

[12] ក្រសួងពាណិជ្ជកម្ម, យុទ្ធសាស្ត្រពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, ខែវិច្ឆិកា ២០២០

និង ទូរគមនាគមន៍ ការបង្កើនការទទួលបានហិរញ្ញប្បទាន និងការអប់រំប្រកបដោយបរិយាប័ន្ននៅក្នុងតំបន់ដែលកំពុងអភិវឌ្ឍន៍ បាននឹងកំពុងតែអនុវត្ត។ អ្វីដែលគួរកត់សម្គាល់គឺបញ្ហាគម្លាតរវាងទីក្រុង និងទីជនបទ ដូច្នេះការខិតខំប្រឹងប្រែងជាមុខ ព្រួញរួមបញ្ចូលគ្នាដោយក្រុមហ៊ុនបច្ចេកវិទ្យាហិរញ្ញវត្ថុ ស្ថាប័នមីក្រូហិរញ្ញវត្ថុ ធនាគារពាណិជ្ជប្រតិបត្តិករបណ្តាញ ទូរស័ព្ទចល័ត និងតួអង្គផ្សេងទៀត គឺជាការចាំបាច់ក្នុងការធានាថា អ្នកប្រើប្រាស់នៅតាមជនបទអាចទទួលបាននូវ ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ដែលមានប្រសិទ្ធភាព និងក្នុងអត្រាសមស្រប និងអាចប្រើប្រាស់ឧបករណ៍ហិរញ្ញវត្ថុ ចល័តដែលសមស្របនឹងតម្រូវការរបស់ពួកគាត់។

**គោលដៅយុទ្ធសាស្ត្រទី៥៖ អភិវឌ្ឍន៍ហេដ្ឋារចនាសម្ពន្ធ័ជំនាញដែលមានភាពឆ្លើយតបសម្រាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក**

គោលដៅយុទ្ធសាស្ត្រនេះបានចែកជាពីរផ្នែកក្នុងការជួយមូលដ្ឋានអភិវឌ្ឍន៍ជំនាញមួយសមស្រប និងមានភាព បត់បែនសម្រាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅកម្ពុជា។ ទីមួយគឺមានគោលបំណងកាត់បន្ថយបញ្ហាជំនាញ មិនសមស្របនឹងតម្រូវការទីផ្សារដែលមានស្រាប់នៅក្នុងវិស័យពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដោយបង្កើតជា យន្តការផ្តល់យោបល់ត្រឡប់មកវិញរវាងអ្នកបណ្តុះបណ្តាលជំនាញ អ្នកបង្កើតគោលនយោបាយ និងវិស័យឯកជន។ ទីពីរគឺបង្កើនកិច្ចខិតខំប្រឹងប្រែងក្នុងការធ្វើឱ្យប្រសើរឡើងនូវការគាំទ្រសហគ្រិនភាពឌីជីថលសម្រាប់អាជីវកម្មថ្មីតាម ប្រព័ន្ធអេឡិចត្រូនិក ជាពិសេសយុវជន និងស្រ្តី ដោយក្នុងនោះការគាំទ្រតាមរយៈការផ្តល់ឱកាសឱ្យពួកគាត់ចូលរួមក្នុង ការអភិវឌ្ឍគោលនយោបាយ និងយកពួកគាត់ជាអ្នកអភិវឌ្ឍន៍គំនិតផ្តួចផ្តើមនានា គឺមានសារៈសំខាន់ ជាពិសេសក្នុង ការគាំទ្រផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេស។ ការងារនេះគឺពាក់ព័ន្ធនឹងការពង្រីកបណ្តាញនៅក្រៅរាជធានីទៅកាន់ទីក្រុង លំដាប់ទីពីរដូចជាខេត្តសៀមរាប និងខេត្តបាត់ដំបង ព្រមទាំងតំបន់ជនបទដោយផ្អែកលើការសិក្សាជាក់លាក់ដែលធ្វើ ឡើងដោយអ្នកបង្កើតប្រព័ន្ធអេកូឡូហ្សីនវានុវត្តន៍។ [13]

ផ្អែកតាមយុទ្ធសាស្ត្រពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកដដែលនេះ វាអាចចូលរួមលើកកម្ពស់ការសម្របសម្រួលស្ថាប័ន និងយុទ្ធសាស្ត្រគោលនយោបាយ តាមរយៈ ការបន្តធ្វើសមាហរណកម្មពាណិជ្ជកម្មតាមប្រព័ន្ធអេឡិត្រូនិក និងសេដ្ឋកិច្ចឌីជីថលក្នុងរបៀបវារៈអភិវឌ្ឍន៍ជាតិ ពង្រឹងយន្តការសម្របសម្រួលស្ថាប័នដែលគាំទ្រវិស័យពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។ ចំពោះក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិ យុទ្ធសាស្ត្រនេះបំពេញក្របខ័ណ្ឌច្បាប់អ៊ីនធឺណិត( Cyber Law) របស់កម្ពុជាដោយបញ្ចូលចំណុចពាក់ព័ន្ធនឹងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកទៅ

[13] ក្រសួងពាណិជ្ជកម្ម, យុទ្ធសាស្ត្រពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, ខែវិច្ឆិកា ២០២០

ក្នុងសេចក្តីព្រាងច្បាប់នេះ ហើយវាអាចផ្តល់ការយល់ដឹងដល់អ្នកប្រើប្រាស់ និងវិស័យឯនជនរួមទាំងវិនិយោគិន លើក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។ ឯសហគ្រាសធុនតូច និងមធ្យមក៏នឹងត្រូវបានជួយលើកកម្ពស់តាមរយៈការពង្រឹងក្របខណ្ឌនិយ័តកម្ម និងបន្ថែមភាពច្បាស់លាស់ សម្រាប់សហគ្រាសពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ពង្រឹងផ្នែកសម្របសម្រួលរវាងវិស័យឯកជន និងលើកកម្ពស់វិស័យនេះឱ្យរីកចម្រើន ពង្រឹងសមត្ថភាពសហគ្រាស/ក្រុមហ៊ុនឱ្យស្របតាមការប្រែប្រួលនៃគោលនយោបាយ និងនិយតកម្មនានា ព្រមទាំងអភិវឌ្ឍន៍ឧបករណ៍ ជំនួយ និងមានឯកទេសលើSME។ លើសពីនេះ យុទ្ធសាស្ត្រពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក អាចអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាជំនាញឌីជីថល តាមរយៈការធ្វើវិសិដ្ឋហេដ្ឋារចនាសម្ព័ន្ធជំនាញក្នុងវិស័យពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកក្នុងបរិបទថ្នាក់ជាតិ ដើម្បីដោះស្រាយបញ្ហាជំនាញមិនស៊ីគ្នាដែលមាននាពេលបច្ចុប្បន្ន និងអនាគត ហើយបង្កើនការគាំទ្រដល់វិស័យសហគ្រិនភាពផ្នែកឌីជីថលសហគ្រាសថ្មីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកជាពិសេសដោយយុវជន និងស្ត្រី ព្រមទាំងលើកកម្ពស់ចំណេះដឹងផ្នែកឌីជីថលក្នុងចំណោមភាគីពាក់ព័ន្ធ និងពង្រីកទំហំភូមិសាសស្ត្រនៃការគាំទ្រ។ ក្រៅពីនេះ ប្រព័ន្ធទូទាត់ ក៏នឹងត្រូវបានសម្របសម្រួលផងដែរតាមរយៈ ការលើកកម្ពស់ការចូលរួមក្នុងហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់ដើម្បីជំរុញអន្តរប្រតិបត្តិការ ការពង្រឹងក្របខណ្ឌគតិយុត្តិដើម្បីគាំទ្រដល់ប្រព័ន្ធអេកូឡូហ្សីនៃ FinTech ការពង្រីកវិសាលភាព និងគុណភាពអក្ខរកម្មហិរញ្ញវត្ថុជាមួយនឹងកិច្ចខិតប្រឹងប្រែងរួមគ្នាដើម្បីបែងចែកការទទួលខុសត្រូវច្បាស់លាស់ និងបង្កើនការចូលរួម រួមជាមួយការលើកកម្ពស់យល់ដឹងអំពីភាពចម្រុះ និងលទ្ធផលនៃជម្រើសទូទាត់ប្រាក់ដល់ក្រុមហ៊ុនពាណិជ្ជកម្មតាមប្រព័ន្ធតាមប្រព័ន្ធអេឡិត្រូនិក។ ជាមួយគ្នា យុទ្ធសាស្ត្រនេះនឹងការគាំទ្រ លើកកម្ពស់ភស្តុភារកម្មពាណិជ្ជកម្មក្នុងស្រុក តាមរយៈការធ្វើឱ្យប្រសើរឡើងនូវអាសយដ្ឋានជាក់លាក់ និងដាក់សាកល្បងដំណោះស្រាយផ្សេងសម្រាប់ជំនួស ការធ្វើឱ្យប្រសើរឡើងនូវសមត្ថភាពរបស់ប្រៃសណីយ៍កម្ពុជា វិជ្ជាជីវៈនីយកម្មវិស័យសេវាដឹកជញ្ជូន វិនិយោគលើភស្តុភារបៃតង។

ចំពោះសកម្មភាពពាណិជ្ជកម្មឆ្លងកាត់ព្រំដែន 3PL នឹងត្រូវបានសម្របសម្រួលតាមរយៈ ការព្យាករណ៍កំណើននៃប្រតិបត្តិការឆ្លងកាត់ព្រំដែន ស្របតាមផែនការភស្តុភារកម្ម ការអភិវឌ្ឍក្របខ័ណ្ឌច្បាប់ និងបញ្ញត្តិទាក់ទងនឹងពាណិជ្ជកម្មឆ្លងកាត់ព្រំដែន ការបន្តអភិវឌ្ឍ និងដាក់ឱ្យដំណើរការប្រព័ន្ធបញ្ជរតែមួយជាតិ និងប្រព័ន្ធពាណិជ្ជកម្មដោយមិនប្រើក្រដាសស្នាម ការអភិវឌ្ឍបណ្តាញហេដ្ឋារចនាសម្ព័ន្ធរឹង និងសេវាកម្មដែលចាំបាច់ សម្រាប់ពាណិជ្ជកម្មឆ្លងព្រំដែន បង្កើនសមត្ថភាព និងប្រសិទ្ធភាពរបស់សហគ្រាសសម្រាប់ការធ្វើពាណិជ្ជកម្មឆ្លងកាតព្រំដែន ព្រមទាំង

ការគិតគូរលើពន្ធសម្រាប់ប្រតិបត្តិពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកក្រៅផ្លូវការ។ ជាមួយគ្នានេះដែលយុទ្ធសាស្ត្រពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ក៏នឹងចូលរួមដោះស្រាយផ្នែកហិរញ្ញប្បទាន ដោយដាក់ចេញ គោលដៅយុទ្ធសាស្ត្រ ការអភិវឌ្ឍន៍ និងជំរុញការប្រើប្រាស់ឧបករណ៍ហិរញ្ញវត្ថុសម្រាប់ក្រុមហ៊ុនពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិច ការជំរុញយន្តការហិរញ្ញប្បទាននៅទៀតនិងធ្វើឱ្យប្រសើរឡើងនៃការវិនិយោគរបស់សហគ្រាសដើម្បីទាក់ទាញការវិនិយោគ ការធ្វើអោយប្រសើរឡើងភាពគួរអោយទុកចិត្តបាននៃក្រុមហ៊ុនពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិច។ ចំពោះយុទ្ធសាស្ត្រចុងក្រោយនោះគឺ ផ្នែកព័ត៌មានពាណិជ្ជកម្ម និងការគាំទ្រទីផ្សារ តាមរយៈគោលបំណងយុទ្ធសាស្ត្រដូចជា ការដាក់ឱ្យដំណើលការជាផ្លូវការនៃមុខងារជំរុញពាណិជ្ជកម្មសម្រាប់សហគ្រាសធុនតូច និងមធ្យម ការកែលម្អសមត្ថភាពរបស់សហគ្រាសលើព័ត៌មានទីផ្សារ និងការជំរុញពាណិជ្ជកម្ម។

### ១.១.៤ ក្របខណ្ឌច្បាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកកម្ពុជា

ច្បាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកកម្ពុជាឆ្នាំ២០១៩ ត្រូវបានចែកចេញជា១២ ជំពូក និង៦៧មាត្រា ដែលក្នុងនោះជំពូកទី១ បទបញ្ញត្តិទូទៅ ជំពូកទី២ សុពលភាពទំនាក់ទំនង ជំពូកទី៣ ដំណើរការនៃទំនាក់ទំនងអេឡិចត្រូនិក ជំពូកទី៤ កំណត់ត្រាអេឡិចត្រូនិក និងហត្ថលេខាអេឡិចត្រូនិកដែលមានសុវត្ថិភាព ជំពូកទី៥ អន្តរការី និងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ជំពូកទី៦ កិច្ចការពារអ្នកប្រើប្រាស់ ជំពូកទី៧ សកម្មភាព និងប្រតិបត្តិការរបស់រដ្ឋតាមប្រព័ន្ធអេឡិចត្រូនិក ជំពូកទី៨ ភស្តុតាងអេឡិចត្រូនិក ជំពូកទី៩ ការទូទាត់ និងការផ្ទេរប្រាក់តាមអេឡិចត្រូនិក ជំពូកទី១០ នីតិវិធីនៃការផាកពិន័យ និងការប្តឹងតវ៉ា ជំពូកទី១១ ទោសប្បញ្ញត្តិ និងជំពូកចុងក្រោយ គឺជំពូកទី១២ អវសានប្បញ្ញត្តិ (សូមមើលក្នុងឧបសម្ព័ន្ធទី២)។ ច្បាប់នេះមានគោលបំណងសំខាន់បី គឺ

**គ្រប់គ្រងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកក្នុងព្រះរាជាណាចក្រកម្ពុជា និងជាមួយអន្តរជាតិ:** ការកំណត់សិទ្ធិ ការទទួលខុសត្រូវ ក្រមសីលធម៌វិជ្ជាជីវៈ និងបទប្បញ្ញត្តិនានាសម្រាប់អន្តរការី និងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។ ការផ្តល់លិខិតអនុញ្ញាត ឬអាជ្ញាបណ្ណ កាតព្វកិច្ចពន្ធ ការលើកទឹកចិត្ត និងការអនុគ្រោះសម្រាប់អន្តរការី និងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិត្រូនិក។ ការផ្តល់លិខិតអនុញ្ញាត ឬអាជ្ញាប័ណ្ណ និងការទទួលខុសត្រូវរបស់បុគ្គលសេវាទូទាត់ប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក។

**ការបង្កើតភាពប្រាកដប្រជាផ្នែកគតិយុត្តក្នុងប្រតិបត្តិការពាណិជ្ជកម្ម និងរដ្ឋប្បវេណី តាមប្រព័ន្ធអេឡិចត្រូនិក:** ការបង្កើតភាពប្រាកដប្រជាផ្នែកគតិយុត្ត និងការទទួលស្គាល់យថាភូត (Authenticity) សុក្រឹត្យភាព(Integrity) ភាពអាចជឿទុកចិត្តបាន (Reliability) និងភាពអាចអនុវត្តបាន (Enforceability) នៃទម្រង់អេឡិចនិក ទំនាក់ទំនងអេ

ឡិចត្រូនិក និងកិច្ចសន្យាដែលធ្វើឡើងតាមប្រព័ន្ធអេឡិចត្រូនិក។ ការលុបបំបាត់របាំង និងលក្ខខណ្ឌតម្រូវមិនចាំបាច់ ដែលជាឧបសគ្គដល់ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

**ផ្តល់ទំនុកចិត្តដល់សាធារណៈជនក្នុងការប្រើប្រាស់ទំនាក់ទំនងអេឡិក្ត្រូនិក:** ការកំណត់អំពីលក្ខខណ្ឌតម្រូវ និងលក្ខខណ្ឌសន្ទត់សម្រាប់កំណត់ត្រា និងហត្ថលេខាអេឡិចនិកដែលមានសុវត្ថិភាព។ ការទទួលយក និងការកំណត់លក្ខខណ្ឌសុពល និងសុក្រឹត្យភាពរបស់ភស្តុតាងអេឡិចត្រូនិក។ ស្ថាប័នមានសមត្ថកិច្ចក្នុងការគ្រប់គ្រងនីតិវិធីសុត្តិភាពសម្រាប់កំណត់ត្រា និងហត្ថលេខាអេឡិចត្រូនិកដែលមានសុវត្ថិភាព។

នៅចាប់តាំងពីពេលដែលប្រទេសកម្ពុជាយើងបានចុះអនុស្សារណៈយោគយល់ជាមួយធនាគារពិភពលោក World Bank កាលពីឆ្នាំ២០១០ ហើយពីរឆ្នាំក្រោយមកទៀតក្រុមការងាររៀបចំសេចក្តីព្រៀងច្បាប់កម្ពុជាបានទទួលអ្នកជំនាញការពីធនាគារពិភពលោកដើម្បីចូលរួមក្នុងការរៀបចំច្បាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

**ក. ដំណើរការនៃការរៀបចំច្បាប់តាមប្រព័ន្ធអេឡិចត្រូនិក**

ក្នុងកិច្ចនៃការរៀបចំច្បាប់នេះ កម្ពុជាទទួលបានអ្នកជំនាញការពីធនាគារអភិវឌ្ឍន៍អាស៊ីក្នុងឆ្នាំ២០១៦ ហើយសេចក្តីព្រៀងច្បាប់ក៏ត្រូវបានដាក់បញ្ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រីលើកទីមួយកាលពីថ្ងៃទី១២ ខែមករា ឆ្នាំ២០១៧ និងលើកទីពីរកាលពីថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៨ ដែលនាំឱ្យមានកិច្ចប្រជុំពិភាក្សាកម្រិតបច្ចេកទេសលើកទីមួយកាលពីថ្ងៃទី០៦-០៧ ខែធ្នូ ឆ្នាំ២០១៨ និងបញ្ចប់ការប្រជុំបច្ចេកទេសទាំងប្រាំមួយលើកនៅក្នុងខែមេសា ឆ្នាំ២០១៩។ ចំពោះសេចក្តីព្រាងច្បាប់នេះបានឆ្លងកិច្ចប្រជុំកម្រិតបច្ចេកទេស និងកម្រិតថ្នាក់ដឹកនាំជាមួយក្រសួងយុត្តិធម៌ ចំនួន០៣លើកដែលជាចុងក្រោយត្រូវបានឯកភាពទាំងស្រុងនៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩។ វាត្រូវបានទទួលការអនុម័តពីរដ្ឋសភានាសម័យប្រជុំពេញអង្គសភាលើកទី៣ នីតិកាលទី៦ កាលពីថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៩ បន្ទាប់មកបានឆ្លងអន្តរគណៈកម្មាធិការព្រឹទ្ធសភា និងទទួលបានការអនុម័តពីព្រឹទ្ធសភាកាលពីថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៩ នាសម័យប្រជុំវិសាមញ្ញ នីតិកាលទី៤។ ជាចុងក្រោយច្បាប់នេះត្រូវបានព្រះមហាក្សត្រឡាយព្រះហត្ថលេខាប្រកាសឱ្យប្រើកាលពីថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩ ។ ក្នុងការបង្កើតច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក សេចក្តីព្រាងនៃច្បាប់នេះបានគោរពគោលការណ៍ជាសកលចំនួនពីរសំខាន់ៗគឺ

- គោលការណ៍សមមូលនៃមុខងារ (Principle of the Functional Equivalent) នៃឯកសារ កំណត់ត្រា ឬលិខិតស្នាមក្នុងទម្រង់ជាឯកសារលាយលក្ខណ៍អក្សរ ជាមួយឯកសារ កំណត់ត្រា ឬលិខិតស្នាមក្នុងទម្រង់អេឡិចត្រូនិក។

- គោលការណ៍អព្យាក្រឹត្យភាពបច្ចេកវិទ្យា (Principle of the Technological Neutrality) ដែលតម្រូវឱ្យមាន មានការប្រើប្រាស់បច្ចេកស័ព្ទ ដែលលក្ខណៈទូទៅ ទូលំទូលាយ ព្រមទាំងមានសុពលភាពជានិច្ចថ្វីបើទោះជាបច្ចេកវិទ្យាអភិវឌ្ឍន៍រីកចម្រើន ទាំងពេលបច្ចុបន្ន និងទាំងពេលអនាគត ក៏បច្ចេកស័ព្ទនៅតែមានមូលដ្ឋានគ្រឹះរឹងមាំដែលអាចអនុវត្ត ប្រើប្រាស់បានតទៅមុខជានិច្ច។

**ខ. អត្ថប្រយោជន៍**

ដូចដែលបានដឹងអំពីការវិវត្តទៅមុខជានិច្ចដ៏លឿនស្លេវនៃបច្ចេកវិទ្យា កម្ពុជាមានកំណើននៃការប្រើប្រាស់បច្ចេកវិទ្យាក្នុងការប្រើប្រាស់ប្រចាំថ្ងៃតាមរយៈការប្រើប្រាស់ ការចរាចរណ៍នៃទំនិញតាមប្រព័ន្ធអេឡិចត្រូនិកមានសភាពពេញនិយមជាខ្លាំងបី។ ក្នុងការបង្កើតឱ្យមាននូវច្បាប់រឹងមាំមួយសម្រាប់ធានាការប្រើប្រាស់គឺពិតជាមានសារៈសំខាន់ណាស់ដើម្បីធ្វើយ៉ាងណាឱ្យហានិភ័យក៏ដូចជាចំនួននៃការប្រព្រឹត្តបទល្មើសធ្លាក់ចុះ។ ចំពោះច្បាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកផ្ទាល់ ជាវិធានមួយដែលជួយគ្រប់គ្រងសម្របសម្រួលដល់ការអភិវឌ្ឍប្រព័ន្ធពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក (E-Commerce Ecosystem) ក្នុងប្រទេសកម្ពុជាយើងដែលកំពុងតែមានសន្ទុះគួរឱ្យកត់សម្គាល់។ មិនតែប៉ុណ្ណោះក្នុងសម័យកាលនៃការប្រើប្រាស់បច្ចេកវិទ្យាជាជម្រើសអាទិភាព ច្បាប់នេះចូលរួមចំណែកក្នុងការលើកកំពស់ធ្វើឱ្យប្រសើរឡើងនូវក្របខណ្ឌច្បាប់ ដើម្បីពង្រឹងសមត្ថភាពការពារសកម្មភាពប្រតិបត្តការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកឌីជីថល ព្រមទាំងត្រៀមលក្ខណៈសម្បត្តិក្នុងការឈោងចាប់កាលានុវត្តភាពនៃបដិវត្តឧស្សាហកម្ម៤.០។ ជាមួយគ្នានេះដែរការពង្រឹងក្របខណ្ឌច្បាប់ ឬបទដ្ឋានគតិយុត្តនានាអាចចូលរួមចំណែកមួយភាគធំក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចឌីជីថលនៅកម្ពុជាដែលជាកត្តាសំខាន់សម្រាប់ទ្រទ្រង់ជីវភាពនៃសេដ្ឋកិច្ចកម្ពុជាបច្ចុប្បន្ន និងនៅថ្ងៃខាងមុខ។ អ្វីដែលជាពិសេសនៃការបង្កើតឱ្យមាននូវច្បាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅកម្ពុជា វាជាចំណុចទាក់ទាញមួយនៃលក្ខណៈសេដ្ឋកិច្ចកម្ពុជាទៅកាន់ទីផ្សារពាណិជ្ជកម្មអេឡិចត្រូនិកអន្តរជាតិក្នុងការបង្កើននូវចំនួនវិនិយោគបរទេសនៅក្នុងវិស័យនេះផងដែរ។

## ១.២ វិសាលភាព និងសុពលភាពនៃប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

ច្បាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិចកម្ពុជាជាយន្តការមួយដែលមិនត្រឹមតែជួយជំរុញការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិចប៉ុន្នោះទេ វាក៏ចូលរួមចំណែកដ៏សំខាន់ក្នុងការលើកកម្ពស់ប្រសិទ្ធិភាពរបស់ស្ថាប័នរដ្ឋក្នុងកិច្ចការបម្រើសេវាសាធារណៈតាមប្រព័ន្ធអេឡិចត្រូនិកជូនដល់ប្រជាជនដូចយ៉ាង ការអនុវត្តយន្តការ អភិបាល

កិច្ចអេឡិចត្រូនិក (E-Governance) ជាដើម។ យោងតាមមាត្រា ៣នៃច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក មានវិសាលភាព ត្រូវអនុវត្តលើសកម្មភាព ឯកសារ និងប្រតិបត្តិការពាណិជ្ជកម្មនិងរដ្ឋប្បវេណីទាំងអស់ដែលធ្វើឡើងតាមប្រព័ន្ធអេឡិចត្រូនិក លើកលែងតែសកម្មភាព ឯកសារ និងប្រតិបត្តិការទាក់ទងនឹង ៖

១-ការបង្កើតឬការអនុវត្តលិខិតប្រគល់សិទ្ធិ។

២-ការបង្កើតឬការចុះហត្ថលេខាលើមរតកសាសន៍ លិខិតកែមរតកសាសន៍ ឬបញ្ហាផ្សេងៗទៀតទាក់ទិននឹងសន្តតិកម្ម។

៣-រាល់កិច្ចសន្យាសម្រាប់ការលក់ ការផ្ទេរ ឬការបោះបង់សិទ្ធិលើអចលនទ្រព្យឬផលប្រយោជន៍ផ្សេងៗទៀតក្នុងទ្រព្យនោះ។

៤-ការផ្ទេរអចលនវត្ថុឬផលប្រយោជន៍ណាមួយដែលពាក់ព័ន្ធនឹងអចលនវត្ថុនោះ។

៥-ករណីលើកលែងផ្សេងទៀតដែលត្រូវកំណត់ដោយអនុក្រឹត។

បន្ថែមពីនេះវាមានវិសាលភាពអនុវត្តនៅលើការធានា សកម្មភាព ឯកសារ និងប្រតិបត្តិការពាណិជ្ជកម្ម និងរដ្ឋប្បវេណី ទាំងអស់ដែលប្រព្រឹត្តឡើងតាមប្រព័ន្ធអេឡិចត្រូនិក ដែលមានដូចជា សកម្មភាពអេឡិចត្រូនិច(Electronic Transactions) យថាភូតភាពអេឡិចត្រូនិក (Electronic Authentication) ហត្ថលេខាអេឡិចត្រូនិក (Electronic Signatures) ហើយវាក៏បានចូលរួមក្នុងតួនាទីរបស់រាជរដ្ឋាភិបាលក្នុងការផ្តល់លិខិតអនុញ្ញាត ឬអាជ្ញាប័ណ្ណពីស្ថាប័នមានសមត្ថកិច្ចផងដែរ។

### ១.២.១ អភិបាលកិច្ចអេឡិចត្រូនិក

នៅពេលនិយាយដល់អភិបាលកិច្ចអេឡិចត្រូនិកនៅកម្ពុជា គឺក្រសួងស្ថាប័នធ្វើយ៉ាងណាឱ្យមាននូវអក្ខរកម្មព័ត៌មានវិទ្យាដើម្បីលើកកម្ពស់ការបម្រើសេវាសាធារណៈអោយមានភាពទំនើបដែលអាចឆ្លើយតបទាន់តម្រូវការរបស់អ្នកប្រើប្រាស់ពោលគឺប្រជាជនកម្ពុជា។ ពាក្យ អភិបាលកិច្ចអេឡិចត្រូនិក (E-Governance)ជា ត្រីវិស័យចង្អុលទិសដល់រដ្ឋាភិបាលឆ្ពោះទៅរកការអភិវឌ្ឍលើវិស័យនានា និងវិស័យរដ្ឋបាលដើម្បីធានាការអនុវត្តសេវាសាធារណៈអេឡិចត្រូនិកប្រកបដោយភាពជោគជ័យ។ វាមានចង្កោមទំនាក់ទំនងជាច្រើនការដាក់ឱ្យអនុវត្តប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន ICTs ទៅនឹងរដ្ឋាភិបាលនៃប្រទេសមួយ ហើយក្នុងនោះដែរ រដ្ឋាភិបាលអេឡិចត្រូនិក(E-Government) ជាផ្នែកមួយនៃអភិបាលកិច្ចអេឡិចត្រូនិកដែលដើរតួក្នុងការអភិវឌ្ឍវិស័យណាមួយជាក់លាក់ឱ្យក្លាយទៅក្នុងទម្រង់អេឡិចត្រូនិច។ ចំណែកឯរបបនៃច្បាប់ពាណិជ្ជកម្មអេឡិចត្រូនិកវិញ មានការចែងអំពីតួនាទីនៃស្ថាប័នរដ្ឋដែលត្រូវ

សម្របសម្រួលដល់កិច្ចពាណិជ្ជកម្មដល់ធុរជន ដោយអនុលោមទៅតាមមាត្រា៣៤ ការទទួលស្គាល់ទំនាក់ទំនងអេឡិចត្រូនិកដោយស្ថាប័នរដ្ឋ

១- ក្រសួងឬស្ថាប័នរដ្ឋនានាអាចប្រើប្រាប់ទម្រង់អេឡិចត្រូនិកសម្រាប់សកម្មភាពនិងប្រតិបត្តិការ ដូចខាងក្រោម៖

ក- ការទទួលចុះបញ្ជីឯកសារ ឬការបំពេញលក្ខខណ្ឌតម្រូវ សម្រាប់បង្កើតឬរក្សាទុកឯកសារ។

ខ- ការចេញអាជ្ញាបណ្ណឬលិខិតអនុញ្ញាត។

គ- ការកំណត់មធ្យោបាយឬលិខិតអនុញ្ញាត។

ឃ- សកម្មភាពផ្សេងទៀតដែលកំណត់ដោយក្រសួង ឬស្ថាប័នរដ្ឋ។

២- នៅពេលដែល ក្រសួង ឬស្ថាប័នរដ្ឋសម្រេចប្រើប្រាស់ទំនាក់ទំនងអេឡិចត្រូនិកសម្រាប់សកម្មភាព ឬប្រតិបត្តិការណាមួយ ដូចមានចែងក្នុងបញ្ញត្តិនៃកថាខណ្ឌទី១ខាងលើ ក្រសួងឬស្ថាប័ននោះអាចបញ្ជាក់៖

ក- របៀបនិងទម្រង់ដែលព័ត៌មានក្នុងទំនាក់ទំនងអេឡិចត្រូនិកត្រូវទទួលចុះបញ្ជី បង្កើតរក្សាទុក ឬបោះផ្សាយ។

ខ- ប្រភេទនៃហត្ថលេខាដែលតម្រូវឱ្យធ្វើនៅពេលដែលមានការតម្រូវឱ្យចុះហត្ថលេខាក្នុងទំនាក់ទំនងអេឡិចត្រូនិកនោះ។

គ- របៀបនិងទម្រង់ដែលហត្ថលេខានោះត្រូវភ្ជាប់ក្នុងទំនាក់ទំនងអេឡិចត្រូនិក។

ឃ- ដំណើរការគ្រប់គ្រងនិងនីតិវិធីដែលសមស្របដើម្បីធានាសុក្រឹតភាព សុវត្ថិភាពនិងការរក្សាការសម្ងាត់នៃទំនាក់ទំនងអេឡិចត្រូនិក ឬការទូទាត់ប្រាក់ និង

ង- លក្ខខណ្ឌកំណត់ផ្សេងទៀតដែលផ្តល់តម្លៃសមមូលរវាងឯកសារ ឬការទូទាត់ក្នុងទម្រង់អេឡិចត្រូនិក ជាមួយនឹងឯកសារ ឬការទូទាត់ក្នុងទម្រង់ជាលាយលក្ខណ៍អក្សរ។

**ក. រដ្ឋាភិបាលអេឡិចត្រូនិក(E-Government)**

ក្រោមមូលន័យនៃអភិបាលកិច្ចអេឡិចត្រូនិក (E-Governance) រដ្ឋាភិបាលអេឡិចត្រូនិក(E-Government) តួយ៉ាង ការបម្រើសាធារណៈរបស់រដ្ឋជូនដល់ប្រជាពលរដ្ឋដូចជា ប្រព័ន្ធចុះបញ្ជីអេឡិចត្រូនិក ប្រព័ន្ធ

បង់ពន្ធតាមអនឡាញ ជាដើម។ [14] លើសពីនេះរដ្ឋាភិបាលអេឡិចត្រូនិក(E-Government) សំដៅជាការវិវត្តនៃសកម្មភាពផ្តល់ជូនប្រជាពលរដ្ឋនូវសេវានានាដោយអនុលោមទៅតាមគោលគំនិតនៃ Online Government Service ទៅជា ការដោះដូរទៅវិញទៅមកនៃព័ត៌មាន និងសេវាកម្មក្រោមទម្រង់អេឡិចត្រូនិកជាមួយប្រជាពលរដ្ឋ ធុរកិច្ច និងភ្នាក់ងារនានាដែលធ្វើការជិតស្និតនឹងរដ្ឋាភិបាល។ ក្នុងបរិបទចាស់ រដ្ឋាភិបាលអេឡិចត្រូនិក(E-Government) ត្រូវបានគេកត់សម្គាល់តែម្យ៉ាងគត់គឺការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន(ICTs) ដើម្បីធ្វើយ៉ាងណាឱ្យមន្ត្រីរបស់រដ្ឋបម្រើសេវាកម្មបានកាន់តែមានប្រសិទ្ធិភាព និងប្រសិទ្ធិផល។ ប៉ុន្តែក្រោយមកក្របខណ្ឌគតិយុត្តនៃ រដ្ឋាភិបាលអេឡិចត្រូនិក(E-Government) បានពង្រីងវិសាលភាពនៃការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន(ICTs) ក្នុងការធ្វើយ៉ាងណាឱ្យកាន់តែកៀកកិតជាមួយប្រជាពលរដ្ឋ និងធុរជន ហើយដែលជាពិសេសគឺការបើកទ្វារនៃការប្រើប្រាស់ទិន្នន័យរបស់រដ្ឋាភិបាល ជាមួយគ្នានឹងបច្ចេកវិទ្យាព័ត៌មាន(ICTs) ដើម្បីបង្កើតឱ្យមាននូវនវានុវត្តន៍ក្នុង អភិបាលកិច្ចរបស់រដ្ឋ។[15] ម្យ៉ាងនៅក្នុងច្បាប់រដ្ឋធម្មនុញ្ញកម្ពុជាមាត្រា៦១ រដ្ឋជំរុញការអភិវឌ្ឍន៍សេដ្ឋកិច្ចគ្រប់វិស័យ ជាពិសេសវិស័យកសិកម្ម សិប្បកម្ម ឧស្សាហកម្ម ចាប់ពីតំបន់ដាច់ស្រយ៉ាលដោយយកចិត្តទុកដាក់ទៅលើ នយោបាយទឹក ភ្លើង ផ្លូវ និងមធ្យោបាយដឹកជញ្ជូន បច្ចេកទេសទំនើប និងប្រព័ន្ធឥណទាន។ [16]ដែលនេះគឺរាជរដ្ឋាភិបាលកម្ពុជាត្រូវចូលរួមលើកកម្ពស់កិច្ចពាណិជ្ជកម្មរបស់ប្រជាពលរដ្ឋធ្វើយ៉ាងណាឱ្យប្រជាពលរដ្ឋកក់ក្តៅក្នុងការធ្វើសកម្មភាពពាណិជ្ជតាមបច្ចេកទេសទំនើបដើម្បីធ្វើឱ្យកំណើនសេដ្ឋកិច្ចនៅក្នុងប្រទេស។ ជាមួយគ្នានេះដែរ រាជរដ្ឋាភិបាលកម្ពុជាក្នុងន័យឆ្លើយតបនឹងជម្ងឺកូវីត-១៩ ផង និងដំណើរវិវត្តនៃពិភពលោកទៅរកឌីជីថល កម្ពុជាត្រូវតែប្រែពីប្រព័ន្ធចាស់បុរាណទៅប្រព័ន្ធឌីជីថលជំនួសវិញហើយត្រូវចាប់ផ្តើមពីផ្នែករដ្ឋបាលទៅ។ ផ្អែកតាមប្រសាសន៍របស់អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ *«ការធ្វើកំណែទម្រង់នេះគួរតែជាកំណែទម្រង់ស៊ីជម្រៅ និងគ្របដណ្តប់ទាំងវិស័យសាធារណៈ និងប្រព័ន្ធរបស់រាជរដ្ឋាភិបាលទាំងមូល»*។ តាមរយៈការចាប់យកកាលានុវត្តភាពនៃ

[14] Geospatial World, Advancing Knowledge for sustainability, https://bit.ly/3DljM0X ,ចូលមើលថ្ងៃទី០១ ខែសីហា ឆ្នាំ២០២១

[15] United Nation, E-Governement Knowledgebase , https://bit.ly/3ykj7cn , ចូលមើលថ្ងៃទី០១ ខែសីហា ឆ្នាំ២០២១

[16] មាត្រា៦១នៃ ច្បាប់រដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

ឌីជីថល ក្រសួងស្ថាប័នដែលបានចាប់ផ្តើមបម្រើសេវាកម្មអនឡាញ នឹងអាចផ្តល់សេវាកម្មប្រកបដោយតម្លាភាព ចំណេញពេលវេលា និងអាចលុបបំបាត់អំពើពុករលួយ។[17]

**ខ. បម្រើសេវាសាធារណៈពាណិជ្ជកម្មកម្ពុជារបស់ក្រសួងពាណិជ្ជកម្ម**

ក្រសួងពាណិជ្ជកម្មកម្ពុជា ដែលជានីតិបុគ្គលសាធារណៈដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់សេវាកម្មផ្នែកពាណិជ្ជកម្មជូនដល់ធុរជនជាតិ និងអន្តរជាតិដែលធ្វើធុរកិច្ចក្នុងដែនដីកម្ពុជា។ ក្នុងពេលដែលលំហូរ និងតម្រូវការនៃបច្ចេកវិទ្យាមិនទាន់មានសន្ទុះខ្លាំងក្នុងសង្គម សេវាសាធារណៈរបស់រដ្ឋលើវិស័យពាណិជ្ជកម្មត្រូវបានធ្វើឡើងដោយផ្ទាល់តាមរយៈភ្នាក់ងារមន្ត្រីបម្រើសេវាកម្មរបស់ក្រសួងពាណិជ្ជកម្ម។ សេវាពាណិជ្ជកម្មសំខាន់ៗ ដែលក្រសួងពាណិជ្ជកម្មផ្តល់ជូនមានចំនួន៣ ដូចជា ការចេញវិញ្ញាបនបត្រប្រភពដើមទំនិញ (Certificate of Origin, CO) ការចុះបញ្ជីពាណិជ្ជកម្ម(Company registration) ការចុះបញ្ជីពាណិជ្ជសញ្ញា(Trade Mark Registration)។ ស្របពេលដែលកម្ពុជាលើកទិសដៅចក្ខុវិស័យសេដ្ឋកិច្ចរបស់ខ្លួនឱ្យជាប្រទេសដែលមានចំណូលកម្រិតមធ្យមត្រឹមឆ្នាំ ២០៣០ និងចំនូលកម្រិតខ្ពស់ក្នុងឆ្នាំ២០៥០ ព្រមទាំងការរីករាតត្បាតទូទាំងសកលលោកនៃជម្ងឺកូវីដ-១៩ ក្រសួងពាណិជ្ជកម្មបានពន្លឿនការដាក់ឱ្យដំណើរការប្រព័ន្ធអេឡិចត្រូនិកសម្រាប់ ការចេញវិញ្ញាបនបត្រប្រភពដើមទំនិញ CO ការចុះបញ្ជីពាណិជ្ជកម្ម(Company registration) ការផ្តល់លិខិតអនុញ្ញាត ឬអជ្ញាបណ្ណពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក( E-Commerce Licensing) ការចុះបញ្ជីពាណិជ្ជសញ្ញា(Trade Mark Registration)។

**ការចេញវិញ្ញាបនបត្រប្រភពដើមទំនិញ (Certificate of Origin, C/O)៖** វិញ្ញាបនបត្រ បញ្ជាក់ប្រភពដើមទំនិញ គឺជាឯកសារផ្លូវការមួយ ប្រើដើម្បីបញ្ជាក់ ពីប្រភពដើមទំនិញដែលបានផលិត ឬបានទទួលទាំងស្រុង នៅក្នុងប្រទេសមួយ។ ជាទូទៅឯកសារនេះ គឺជាផ្នែកស្នូលនៃឯកសារ នាំចូល ដែលប្រទេសនាំចូលបានតម្រូវ។ នៅពេលអនុវត្តទម្រង់ការទាំងឡាយ សម្រាប់នាំចេញទំនិញ ក្រោមប្រព្រឹត្តិកម្ម អនុគ្រោះ អ្នកនាំចេញ ឬតំណាងទទួលសិទ្ធិរបស់ខ្លួនត្រូវដាក់ពាក្យ ជាលាយលក្ខណ៍អក្សរ ស្នើសុំវិញ្ញាបនបត្រ បញ្ជាក់ប្រភពដើមទំនិញដោយភ្ជាប់មកជាមួយ នូវឯកសារគាំទ្រ ត្រឹមត្រូវ ដែលបង្ហាញថា ទំនិញដែលត្រូវនាំចេញ មានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ការចេញ វិញ្ញាបន

[17] Khmer times, Government declares e-governance now a top priority amid pandemic, https://bit.ly/3yfQ1L3 ,ចូលមើលថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២១

បត្រ បញ្ជាក់ប្រភពដើមទំនិញ។ វិញ្ញាបនបត្រ បញ្ជាក់ប្រភពដើមទំនិញ មានពីរប្រភេទគឺ៖ មិនទទួលបានភាពអនុគ្រោះពន្ធ និងទទួលបានភាពអនុគ្រោះពន្ធ។

- ប្រទេសដែលតម្រូវឲ្យមានវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញCO:

– វិញ្ញាបនបត្របញ្ជាក់ ប្រភពដើមទំនិញ ទទួលបានអត្រាពន្ធអនុគ្រោះ ក្នុងទម្រង់ផ្សេងៗ ដែលចេញដោយកម្ពុជា។

– អាស៊ាន-អូស្រ្តាលី-ញ៉ូវហ្ស៊ីលែន៖ វិញ្ញាបនបត្រ បញ្ជាក់ប្រភពដើមទំនិញ ទម្រង់ AANZ

– ចិន: វិញ្ញាបនបត្រ បញ្ជាក់ប្រភពដើមទំនិញទម្រង់ AC

– ឥណ្ឌា: វិញ្ញាបនបត្រ បញ្ជាក់ប្រភពដើមទំនិញទម្រង់ AI

– កូរ៉េ: វិញ្ញាបនបត្រ បញ្ជាក់ប្រភពដើមទំនិញទម្រង់ AK

– ជប៉ុន: វិញ្ញាបនបត្រ បញ្ជាក់ប្រភពដើមទំនិញទម្រង់ AJ

– វៀតណាម: វិញ្ញាបនបត្រ បញ្ជាក់ប្រភពដើមទំនិញទម្រង់ S

– ប្រព័ន្ធអនុគ្រោះទូទៅ ផ្នែកពាណិជ្ជកម្ម (LDC និង LLDC): វិញ្ញាបនបត្រ បញ្ជាក់ប្រភពដើមទំនិញទម្រង់A

– អត្រាពន្ធមិនអនុគ្រោះ អាចចេញបាន ដោយប្រើ វិញ្ញាបនប័ត្រ បញ្ជាក់ប្រភពដើមទំនិញ ទម្រង់ N

- របៀបដាក់ពាក្យស្នើសុំ វិញ្ញាបនបត្រ បញ្ជាក់ប្រភពដើមទំនិញ CO: អ្នកនាំចេញចាំបាច់ ត្រូវដាក់ពាក្យស្នើសុំ វិញ្ញាបនបត្រ បញ្ជាក់ប្រភពដើមទំនិញ នៅនាយកដ្ឋាន នាំចេញ-នាំចូល ក្រសួងពាណិជ្ជកម្ម។ នីតិវិធីនៃការដាក់ពាក្យ ស្នើសុំវិញ្ញាបនបត្រ បញ្ជាក់ប្រភពដើមទំនិញ អាចរកបាននៅ ក្នុងប្រកាសលេខ១១២ MOC/SM 2013 ស្តីពីការកែប្រែ នីតិវិធី ចេញវិញ្ញាបនបត្រ បញ្ជាក់ប្រភពដើមទំនិញ។

**ការចុះបញ្ជីពាណិជ្ជកម្ម(Company registration)៖** ការចុះបញ្ជីក្រុមហ៊ុនពាណិជ្ជកម្ម ត្រូវបានផ្តល់ជូនចំពោះទម្រង់អាជីវកម្មដែលមានដូចជា ក្រុមហ៊ុនសហគ្រាសឯកបុគ្គល ក្រុមហ៊ុនសហកម្មសិទ្ធិ(ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត) ក្រុមហ៊ុនមូលធន (ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត) ក្រុមពាណិជ្ជកម្មបរទេស (សាខាក្រុមហ៊ុនពាណិជ្ជកម្ម ការិយាល័យតំណាងពាណិជ្ជកម្ម) និងសហគ្រាសសាធារណៈ។ ចំពោះការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មត្រូវធ្វើឡើងយ៉ាងតិចបំផុត១៥ថ្ងៃ មុនពេលចាប់ផ្តើមបើកធ្វើពាណិជ្ជកម្មផ្ទាល់ខ្លួន ពាណិជ្ជករត្រូវចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មដែលធ្វើឡើងតាមរយៈប្រព័ន្ធស្វ័យប្រវត្តកម្មលើគេហទំព័រ ដោយភ្ជាប់ជាមួយនូវឯកសារមួយចំនួនដូចមានក្នុងប្រកាសលេខ២១៣ពណ.ចបព.

ប្រក ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៦ ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធស្វ័យប្រវត្តកម្ម។ រីឯការចុះបញ្ជីនេះដំបូងត្រូវក្នុងប្រព័ន្ធស្វ័យប្រវត្តកម្មលើគេហទំព័រ www.businessregistration.moc.gov.kh ចំពោះក្រុមហ៊ុន-សហគ្រាសថ្មីត្រូវចូលតាមគេហទំព័រថ្មី www.registrationservice.gov.kh បន្ទាប់មកត្រូវរងចាំរយៈពេល៣ទៅ៥នៃថ្ងៃធ្វើការ ហើយការបង់កម្រៃសេវាអ្នកចុះបញ្ជីអាចបង់តាមអនឡាញ ឬ នៅតាមធនាគារដែលជាដៃគូរបស់ក្រសួង និងជាចុងក្រុមហ៊ុន/សហគ្រាស នឹងទទួលបានវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មក្រោមទម្រង់អេឡិចត្រូនិក។[18]

**ការផ្តល់លិខិតអនុញ្ញាត ឬអាជ្ញាបណ្ណពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក( E-Commerce Licensing)៖** ក្នុងកិច្ចការបម្រើសេវាកម្មដើម្បីសម្របសម្រួលពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិករាជរដ្ឋាភិបាលកម្ពុជាក្រសួងពាណិជ្ជកម្មកម្ពុជាបានយកចិត្តទុកដាក់ព្រមទាំងអភិវឌ្ឍន៍ការបម្រើសេវាកម្មតាមប្រព័ន្ធស្វ័យប្រវត្តិកម្មដើម្បីបង្កលក្ខណៈងាយស្រួល និងតបតាមបរិបទនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។ ក្រសួងក៏បានរៀបចំសិក្ខាសាលាក៏ដូចជាផ្សព្វផ្សាយយ៉ាងសកម្មអំពីច្បាប់ អនុក្រឹត្យ និងសេចក្តីប្រកាសផ្សេងរបស់ក្រសួងដែលបានអនុវត្តជូនចំពោះអាជីវករដែលធ្វើអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិចជាច្រើន ហើយក្រសួងក៏បានណែនាំព្រមទាំងអំពាវនាវឲ្យសហគ្រាសឯកបុគ្គលនីតិបុគ្គលនិងសាខាក្រុមហ៊ុនបរទេសដែលមានអាជីវកម្មតាមប្រព៌ន្ធអេឡិចត្រូនិកទាំងអស់ដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតឬអាជ្ញាប័ណ្ណពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម ឬតាមគេហទំព័រ www.ecommercelisencing.moc.gov.kh ។ ក្នុងករណីដែលសហគ្រាសឯកបុគ្គល នីតិបុគ្គល និងសាខាក្រុមហ៊ុនបរទេសធ្វើប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកដោយគ្មានលិខិតអនុញ្ញាតឬអាជ្ញាប័ណ្ណនោះនឹងត្រូវបញ្ឈប់សកម្មភាពព្រមទាំងរងពិន័យជាប្រាក់ដូចមានចែងជាធរមានចំពោះមុខច្បាប់។[19]

**ការបង្កើតថ្នាលពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក៖** អនុលោមទៅតាមគោលគំនិតនៃ Government to Business ក្រសួងពាណិជ្ជកម្មបានកែទម្រង់ការងារចុះបញ្ជីពាណិជ្ជកម្មដែលបង្កើតប្រព័ន្ធចុះបញ្ជីថ្មីតាមរយៈថ្នាលបច្ចេកវិទ្យាព័ត៌មានវិទ្យារបស់រាជរដ្ឋាភិបាល (CamDX) ដែលអាចឲ្យជួយសម្រួលការចុះបញ្ជីពាណិជ្ជកម្មបានលឿនជាមុននូវ

[18] ប្រកាសលេខ២១៣ពណ.ចបព.ប្រក ខែមិថុនា ឆ្នាំ២០១៦

[19] សេចក្តីជូនដំណឹងលេខ ១១៤៣ ព.ណ ចបព ស្តីពី ការផ្តល់លិខិតអញ្ញាត ឬអាជ្ញាបណ្ណពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ខែឧសភា ឆ្នាំ២០២១

បានតភ្ជាប់ព័ត៌មានជាមួយអគ្គនាយកដ្ឋានពន្ធដារនិងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ព្រមទាំងបានកាត់បន្ថយកម្រៃសេវាចុះបញ្ជីពាណិជ្ជកម្មចំនួន៣ប្រភេទ គឺ១.) ការចុះបញ្ជីក្រុមហ៊ុនថ្មី ២.) ការចុះបញ្ជីសហគ្រាសថ្មី ៣.) ការពិនិត្យនាមករណ៍។[20] មិនតែប៉ុណ្ណោះក្រសួងក៏បានជំរុញសកម្មភាពពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិចតាមរយៈការបើកឱ្យដំណើរការទីផ្សារអនឡាញ ឬដែលហៅថា វេទិកាទីផ្សារខេមបូឌាត្រេដ http://CambodiaTrade.com ដែលដំណើរការដោយក្រសួងពាណិជ្ជកម្មកម្ពុជាដើម្បីបម្រើដល់សហគ្រាសធុនតូចនិងមធ្យមនៅកម្ពុជាដើម្បីលក់ផលិតផលរបស់ពួកគេតាមអ៊ីនធឺណេតដល់អតិថិជនសក្តានុពលនៅក្នុងទីផ្សារក្នុងស្រុកនិងឆ្លងកាត់ព្រំដែន។ ទីផ្សារនេះត្រូវបានបង្កើតឡើងដោយមានការគាំទ្រផ្នែកហិរញ្ញវត្ថុពីក្របខ័ណ្ឌសមាហរណកម្មក្រោមគម្រោង Go4eCAM ដោយមានគោលបំណងសំខាន់ក្នុងការយល់ដឹងអំពីអត្ថប្រយោជន៍នៃពាណិជ្ជកម្មតាមអេឡិចត្រូនិកសម្រាប់សហគ្រាសធនតូចនិង មធ្យម ។ ចក្ខុវិស័យចំបងនៃវេទិកាទីផ្សារខេមបូឌាត្រេដ B2B B2C គឺដើម្បីបង្កើនឱកាសសេដ្ឋកិច្ចសម្រាប់សហគ្រាសធុនតូចនិងមធ្យមនៅកម្ពុជាដើម្បីចូលរួមទាំងពាណិជ្ជកម្មអេឡិចត្រូនិកក្នុងស្រុកឬឆ្លងដែននិងសេដ្ឋកិច្ចឌីជីថល។

### ១.២.២ ទំនាក់ទំនងគតិយុត្តអេឡិចត្រូនិក

ជាទូទៅទំនាក់ទំនងពាណិជ្ជកម្មមានសកម្មភាពទៅវិញទៅមករវាងភាគីដែលជាដៃគូធ្វើពាណិជ្ជកម្មហើយក្នុងទំនាក់ទំនងនេះក៏មិនអាចរំលងឡើយនូវការបង្កើតនូវកិច្ចសន្យាដែលជាចំណងភ្ជាប់ទំនាក់ទំនងរវាងភាគីម្ខាងនិងភាគីម្ខាង។ យោងតាមមាត្រា៣១១ នៃក្រមរដ្ឋប្បវេណីកម្ពុជា និយមន័យនៃកិច្ចសន្យា កិច្ចសន្យាគឺជាកិរិយាដែលបុគ្គលពីរនាក់ ឬច្រើននាក់មានឆន្ទៈត្រូវគ្នាព្រមបង្កើតកែប្រែ ឬរំលត់នូវកាតព្វកិច្ច។[21] នៅពេលដែលកិច្ចសន្យាត្រូវបានព្រមព្រៀងបង្កើតដោយគូភាគីនោះវានាំឱ្យមាននូវសិទ្ធិ និងកាតព្វកិច្ចដែលទាមទារឱ្យគូភាគីទាំងសងខាងគោរពហើយដូចដែលបានដឹងមកហើយថា កាតព្វកិច្ចគឺជាទំនាក់ទំនងគតិយុត្តដែលចងបុគ្គលពីរម្នាក់ ដោយអោយបុគ្គលម្នាក់ដែលបានកំណត់មានករណីកិច្ចមួយចំនួន ចំពោះបុគ្គលដែលបានកំណត់ម្នាក់ទៀត។[22] ចំពោះកិច្ចសន្យានេះទៀតសោតវាមានអានុភាពនៅពេលដែលសំណើ និងស្នើការត្រូវគ្នា ហើយវាក៏ត្រូវចាត់ទុកថាកើតមានកិច្ចសន្យាផង

[20] ក្រសួងពាណិជ្ជកម្ម របាយការណ៍ បូកសរុបលទ្ធផលការងារពាណិជ្ជកម្ម ឆ្នាំ២០២០ និងទិសដៅការងារពាណិជ្ជកម្ម ឆ្នាំ២០២០, ខែមីនា ឆ្នាំ២០២១

[21] មាត្រា៣១១ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ខែធ្នូ ឆ្នាំ២០០៨

[22] មាត្រា៣០៨ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ខែធ្នូ ឆ្នាំ២០០៨

ដែរនៅពេលដែលដំណឹងអំពីស្វីការបានមកដល់អ្នកស្នើ។[23] ចំណែកទំនាក់ទំនងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ក៏មាននូវកិច្ចសន្យាដែលបង្កើតនូវកាតព្វកិច្ចផងដែរគ្រាន់តែនៅក្រោមទម្រង់ជាកិច្ចសន្យាលើប្រព័ន្ធអេឡិចត្រូនិក។ **ជាឧទាហរណ៍** ប្រសិនបើបុគ្គល «ក» ដែលជាម្ចាស់រោងចក្រសម្លៀកបំពាក់មួយរូបដែលបានផលិតនូវខោអាវសាច់ក្រណាត់ល្អលេខមួយ ហើយមានបំណងចង់បោះដុំដល់ធុរជនម្នាក់ទៀតដែលជាបុគ្គល «ខ» ដើម្បីយកទៅលក់បន្តឱ្យទៅអតិថិជនប្រើប្រាស់ផ្ទាល់ ក្នុងរូបភាពនេះក្របខ័ណ្ឌពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក គេកំណត់ថាជាពាណិជ្ជកម្មរវាងធុរកិច្ច និងធុរកិច្ច (B2B)។ ជាចាំបាច់បុគ្គល «ក» និងបុគ្គល «ខ» ត្រូវមានកិច្ចសន្យាមានឈ្មោះមួយនោះគឺកិច្ចសន្យាលក់ទិញខោអាវសាច់ក្រណាត់ល្អលេខមួយ។ ផ្អែកតាមវាក្យខណ្ឌទី១ នៃមាត្រា៥១៦ ការបង្កើតកិច្ចសន្យាលក់ទិញ ដោយមានការព្រមព្រៀងគ្នារវាងភាគីទាំងសងខាងប៉ុណ្ណោះ លើកលែងតែក្នុងករណីដែលមានបទបញ្ញត្តិពិសេសក្នុងច្បាប់។[24] ចំណែកក្នុងករណីនៃការបង្កើតកិច្ចសន្យានេះបុគ្គលទាំងពីរសុទ្ធតែជាសមត្ថជន កម្មវត្ថុនៃកិច្ចស្របច្បាប់ហើយបានព្រមព្រៀងគ្នាលក់ និងទិញខោអាវសាច់ក្រណាត់ល្អលេខមួយដែលកិច្ចសន្យារវាងភាគីនៃកិច្ចសន្យានេះត្រូវបានធ្វើឡើងក្នុងប្រព័ន្ធអេឡិចត្រូនិក ហើយវាមានក៏មានអានុភាពចំពោះគូភាគីទាំងពីរត្រូវគោរពតាម។ នៅពេលដែលកិច្ចសន្យាត្រូវបានបង្កើតឡើងទោះបីជាត្រូវបានធ្វើឡើងក្នុងប្រព័ន្ធអេឡិចត្រូនិកក៏ដោយក៏ភាគីទាំងសងខាង និងភាគីដ៏ទៃផ្សេងទៀតមិនអាចមិនគោរពតាមកម្មវត្ថុនៃកិច្ចសន្យាក្រោមហេតុផលថាវាជាកិច្ចសន្យាក្នុងប្រព័ន្ធអេឡិចត្រូនិកឡើយ។

**ក. ទំនាក់ទំនងអេឡិចត្រូនិកដែលមានសុពលភាព**

ទំនាក់ទំនងដែលប្រព្រឹត្តិឡើងតាមរយៈប្រព័ន្ធអេឡិត្រូនិកត្រូវបានទទួលស្គាល់ថាមានសុពលភាពដូចក្នុងមាត្រា៥ នៃច្បាប់ស្តីពីពាណិជ្ជកម្មអេឡិចត្រូនិក ដែលចែងអំពីការទទួលស្គាល់លក្ខណៈគតិយុត្តនៃទំនាក់ទំនងអេឡិចត្រូនិកថា គ្មានបុគ្គលណាម្នាក់អាចបដិសេធមិនទទួលស្គាល់សុពលភាព អានុភាពគតិយុត្ត ភាពអាចទទួលយកបានឬភាពដែលអាចយកទៅអនុវត្តបាននៃទំនាក់ទំនងអេឡិចត្រូនិក ដោយគ្រាន់តែសម្អាងលើមូលហេតុថាវាធ្វើឡើងក្នុងទម្រង់អេឡិចត្រូនិកឡើយ។[25] ជាការពិតណាស់នៅពេលដែលនិយាយអំពីទំនាក់ទំនងអេឡិចត្រូនិកក្នុង

[23] សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី ភាគ១ រៀបរៀងដោយក្រុមការងារនៃអនាគតគ្រូបណ្តុះបណ្តាលនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ខែមេសា ឆ្នាំ២០១៣

[24] មាត្រា ៥១៦ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ខែធ្នូ ឆ្នាំ២០០៩

[25] មាត្រា៥ នៃច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកកម្ពុជា ខែវិច្ឆិកា ឆ្នាំ២០១៩

ប្រព័ន្ធអេឡិចត្រូនិក ជាចាំបាច់ព័ត៌មាន ឬឯកសារពាក់ព័ន្ធ អាចឱ្យគូភាគីទាំងសងខាងនៃទំនាក់ទំនងអេឡិចត្រូនិក ចូលទៅពិនិត្យ ប្រើប្រាស់ ព្រមទាំងទាញយកទុកជាកម្មសិទ្ធសម្រាប់ប្រើប្រាស់ អះអាងក្នុងពេលមានករណីណាមួយ ចាំបាច់ដែលទាមទារឱ្យមានអំណះអំណាងបញ្ជាក់អំពីទំនាក់ទំនង។ ហើយក្នុងករណីប្រសិនបើមានការតម្រូវ ឱ្យមានការផ្តល់នូវសំណៅជាច្រើនច្បាប់ នោះបុគ្គលដែលមានសិទ្ធិផ្តល់ជូននូវសំណៅនោះ អាចយកព័ត៌មាន ក៏ដូចជាកិច្ចសន្យាដែលធ្វើក្រោមទម្រង់ជាអេឡិចត្រូនិកតែទៅផ្តល់ជូនតែមួយច្បាប់ ភាគីពាក់ព័ន្ធបានដូចចែងក្នុងមាត្រា៦ លក្ខខណ្ឌតម្រូវជាលាយលក្ខណ៍អក្សរ

១-នៅពេលដែលបទប្បញ្ញត្តិណាមួយ តម្រូវឲ្យផ្តល់ព័ត៌មានជាលាយលក្ខណ៍អក្សរ ឬធ្វើកំណត់ត្រាជា លាយលក្ខណ៍អក្សរ ត្រូវចាត់ទុកថា លក្ខខណ្ឌតម្រូវនេះត្រូវបានបំពេញប្រសិនបើព័ត៌មាននេះធ្វើឡើងក្នុង ទម្រង់អេឡិចត្រូនិក ហើយអាចចូលប្រើប្រាស់បាន និងអាចទាញយកទៅប្រើប្រាស់នៅពេលក្រោយបាន។

២-នៅពេលដែលលក្ខខណ្ឌក្នុងបញ្ញត្តិនៃកថាខណ្ឌទី១ខាងលើ ត្រូវយកមកអនុវត្តលក្ខខណ្ឌតម្រូវឲ្យតាម ច្បាប់ដែលទាមទារឲ្យបុគ្គលណាមួយផ្តល់សំណៅចម្លងច្រើនច្បាប់ក្នុងពេលតែមួយស្តីអំពីព័ត៌មានណា មួយឬកិច្ចការណាមួយទៅឲ្យបុគ្គលមួយផ្សេងទៀត បុគ្គលដែលផ្តល់អាចបំពេញលក្ខខណ្ឌនេះដោយគ្រាន់ តែផ្តល់ក្រោមទម្រង់អេឡិចត្រូនិកតែមួយច្បាប់បាន។

បន្ថែមពីនេះហត្ថលេខាអេឡិចត្រូនិចជាយន្តការមួយសំខាន់ដែលត្រូវបានកំណត់ថាអាចធ្វើឱ្យទំនាក់ទំនងអេឡិចត្រូនិកមានសុពលភាពបាន ប្រសិនបើហត្ថលេខាអេឡិចត្រូនិកនោះមានភាពស្របច្បាប់ក្នុងការបង្កើតដែលអាចកំណត់ពីអត្តសញ្ញាណរបស់អ្នកប្រើប្រាស់ជាក់លាក់។[26] ក្នុងមាត្រា២ នៃ UNICITRAL Model law on Electronic Signature ហត្ថលេខាអេឡិចត្រូនិកសំដៅដល់ទិន្នន័យក្នុងទម្រង់អេឡិចត្រូនិកដែលភ្ជាប់ ជាមួយទិន្នន័យសារដែលត្រូវបានគេប្រើដើម្បីកំណត់អត្តសញ្ញាណហត្ថលេខីក្នុងទំនាក់ទំនងសម្រាប់បញ្ជាក់ពីសច្ចានុមតិរបស់ហត្ថលេខី នៃព័ត៌មានដែលផ្ទុកក្នុងទិន្នន័យសារ។[27]ការប្រើប្រាស់ហត្ថលេខាអេឡិចត្រូនិចក្នុងបរិបទនៃទំនាក់ទំនងអេឡិចត្រូនិក គឺអាចបង្កើនចំណងនៃការគោរពតាមកិច្ចសន្យាដែលបានព្រមព្រៀងលក់ទិញទំនិញ ឬសេវាកម្ម

[26] មាត្រា៦ នៃច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកកម្ពុជា ខែវិច្ឆិកា ឆ្នាំ២០១៩

[27] UNICITRAL Model law on Electronic Signatures with Guide to enactment, United Nation, Vienna, Austria, 2001

ដ៏សំខាន់ដោយហេតុថាការប្រើប្រាស់ហត្ថលេខាអេឡិចត្រូនិកនេះវាបានបញ្ជាក់ពីឆន្ទៈនៃគូភាគីរៀងៗខ្លួនព្រមទាំងមានការទទួលស្គាល់ដោយអាជ្ញាធរមានសមត្ថកិច្ច។

ទំនាក់ទំនងអេឡិចត្រូនិចដែលមានសុពលភាពមួយក៏ត្រូវតែមានការរក្សានូវទម្រង់ដើមនៃទំនាក់ទំនងដែលមានសុវត្ថិភាពផងដែរ ហើយទម្រង់ដើមដែលមិនមែនជាទម្រង់អេឡិចត្រូនិកក៏អាចត្រូវបានរក្សាទុកក្នុងប្រព័ន្ធអេឡិចត្រូនិក និងអាចយកមកប្រើប្រាស់បានផងដែរ ប្រសិនបើទម្រង់អេឡិចត្រូនិកដែលប្រើប្រាស់សម្រាប់រក្សាទុកនោះមានភាពសុវត្ថិភាព ជឿទុកចិត្តបាន។ នេះបើផ្អែកតាមមាត្រា៨ លក្ខខណ្ឌតម្រូវសម្រាប់រក្សាព័ត៌មានតាមទម្រង់ដើម លក្ខខណ្ឌគតិយុត្តក្នុងការរក្សាព័ត៌មានដែលមិនត្រូវបានធ្វើឡើងក្នុងទម្រង់អេឡិចត្រូនិកអាចត្រូវបានបំពេញដោយការរក្សាព័ត៌មាននោះក្រោមទម្រង់អេឡិចត្រូនិក ប្រសិនបើ៖

១-ទម្រង់អេឡិចត្រូនិកនោះជាមធ្យោបាយដែលអាចជឿទុកចិត្តបានដើម្បីកំណត់ភាពពេញលេញរបស់ព័ត៌មាននោះ។ និង

២-ព័ត៌មាននោះអាចចូលយកបានងាយស្រួល សម្រាប់យកទៅប្រើប្រាស់បានពេលក្រោយ។

**ខ. កិច្ចសន្យាក្នុងទំនាក់ទំនងអេឡិចត្រូនិក**

ដូចដែលបានដឹងមកហើយកិច្ចសន្យាជាក់ស្តែងកើតមានឡើងនៅពេលដែលសំណើ និងស្ទីការត្រូវគ្នាហើយនៅក្នុងច្បាប់តាមប្រព័ន្ធអេឡិចត្រូនិកមិនត្រឹមតែទទួលស្គាល់ពីអានុភាពនៃការបង្កើតសំណើ និងស្ទីការប៉ុណ្ណោះទេ តែក៏ទទួលស្គាល់កិច្ចសន្យាទម្រង់អេឡិចត្រូនិកផងដែរ។ មុននឹងកើតមានកិច្ចសន្យាដែលជាការព្រមព្រៀងរវាងគូភាគីគឺការទៅដល់នៃសំណើ និងការត្រឡប់នៃស្ទីការស្របតាមគតិយុត្ត។ យោងតាមមាត្រា ៣៣៧ និយមន័យនៃសំណើ និងស្ទីការ ១-សំណើគឺជាការសុំបង្កើតកិច្ចសន្យាដែលធ្វើឡើងដោយមានឆន្ទៈភ្ជាប់ខ្លួនជាមួយនឹងចំណងគតិយុត្តក្នុងករណីដែលមានស្ទីការរបស់ភាគីម្ខាងទៀតចំពោះសំណើរនេះ។ ២-សំណើត្រូវមានអានុភាពនៅពេលដែលសំណើនោះបានដល់ភាគីម្ខាងទៀតប៉ុន្តែប្រសិនបើដំណឹងអំពីការដកសំណើវិញ ដល់ភាគីម្ខាងទៀត នៅពេលព្រមគ្នានឹងពេលសំណើដល់ នោះអានុភាពសំណើមិនត្រូវកើតឡើងឡើយ។ [28]ចំពោះករណីនេះប្រសិនបើបុគ្គលណាម្នាក់ចង់ធ្វើសំណើ តាមប្រព័ន្ធអេឡិចត្រូនិកនោះមានន័យថាបុគ្គលនោះបង្ហាញឆន្ទះចង់បង្កើតកិច្ចសន្យាតែម្តង។ **ឧទាហរណ៍** បុគ្គល«គ» ម្នាក់បានដាក់លក់ឡានរបស់ខ្លួនក្នុងគេហទំព័រមួយ ហើយបុគ្គល«ឃ» ក៏បានឆែតទៅ

[28] មាត្រា៣៣៧ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ខែធ្នូ ឆ្នាំ២០០៩

បុគ្គល«គ» ដើម្បីចចារថ្លៃ និងបង្កើតកិច្ចសន្យា។ សកម្មភាពរបស់បុគ្គល«ឃ»នេះ គឺគាត់បានបង្ហាញឆន្ទៈក្នុងការបង្កើតឱ្យមានកាតព្វកិច្ចក្នុងកិច្ចសន្យាដែលវាជារូបភាពនៃការដាក់សំណើ ហើយប្រសិនបើការមានការចរចាត្រូវគ្នានោះនាំឱ្យមានស្ទីការត្រលប់មកវិញពីសំណាក់បុគ្គល«គ» នោះកិច្ចសន្យាអេឡិចត្រូនិកចាប់ផ្ដើមកើតមានឡើង។ ប៉ុន្តែបើនិយាយត្រឡប់ក្រោយបន្តិចចំពោះសកម្មភាពរបស់បុគ្គល«គ»វិញ ការណ៍ដែលគាត់បង្ហោះនូវរូបភាពឡានរបស់គាត់ក្នុងគេហទំព័ររបស់គាត់នោះសកម្មភាពរបស់គាត់ហៅថាជាការអញ្ជើញឱ្យធ្វើសំណើបង្កើតកិច្ចសន្យា។ ផ្អែកតាមមាត្រា១៦នៃច្បាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកសំណើបង្កើតកិច្ចសន្យា រាល់ការស្នើសុំចុះកិច្ចសន្យាតាមរយៈទំនាក់ទំនងអេឡិចត្រូនិកដែលមិនសំដៅតែដល់បុគ្គលណាមួយជាក់លាក់ផ្សេងទៀត ត្រូវបានចាត់ទុកថាជាការអញ្ជើញឲ្យធ្វើសំណើបង្កើតកិច្ចសន្យាតែប៉ុណ្ណោះ។ ការស្នើសុំនេះបានបង្ហាញឲ្យឃើញច្បាស់អំពីឆន្ទៈរបស់ខ្លួនថានឹងត្រូវជាប់កាតព្វកិច្ចនៅពេលមានស្ទីការពីភាគីម្ខាងទៀត។ ចំពោះការអញ្ជើញឱ្យធ្វើសំណើបង្កើតកិច្ចសន្យា នេះខុសពីការដាក់សំណើបង្កើតកិច្ចសន្យាត្រង់ថា ការដាក់បង្ហាញទំនិញតាមប្រព័ន្ធអេឡិចត្រូនិកធ្វើឱ្យទាក់ទាញដល់អតិថិជន អាចធ្វើឱ្យអតិជនមានឆន្ទៈឬគ្មានក្នុងការបង្កើតការសំណើរបង្កើតកិច្ចសន្យាទៅអាជីវករ សំណើរបង្កើតកិច្ចសន្យាវិញគឺអតិថិជនមានឆន្ទៈចង់ទិញទំនិញ ហើយដាក់សំណើមកអាជីវករ និងព្រមអនុវត្តនូវកាតព្វកិច្ចដែលត្រូវគោរពក្រោយការបង្កើតកិច្ចសន្យា។ ចំពោះអានុភាពនៃសំណើវិញក្រមរដ្ឋប្បវេណីកម្ពុជាបានបញ្ជាក់ថា ការអានុភាពនៃសំណើកើតមានឡើងនៅពេលដែលវាបានទៅភាគីម្ខាងទៀត តែប្រសិនបើក្នុងកំឡុងពេលនៃការបញ្ជូនសំណើមិនទាន់បានទៅដល់អ្នកទទួល ឬមានការជូនដំណឹងអំពីការដកសំណើទៅដល់មុនឬដំណាលគ្នានឹងការជូនដំណឹងនៃសំណើនេះ គឺភាគីខាងសំណើអាចដកសំណើវិញបានក្នុងករណីដែលភាគីទទួលសំណើម្ខាងទៀតមិនទាន់ធ្វើស្ទីការត្រលប់ និងមិនបានធ្វើឱ្យខូចប្រយោជន៍ភាគីម្ខាងទៀតនោះ។ ចំណែកនៅក្នុងប្រព័ន្ធអេឡិចត្រូនិក ប្រសិនបើការផ្ញើរចេញនូវព័ត៌មានក៏ដូចជាសំណើបង្កើតកិច្ចសន្យាត្រូវបានផ្ញើទៅភាគីម្ខាងតែមិនទាន់ចេញពីប្រព័ន្ធរបស់អ្នកផ្ញើនោះក៏ត្រូវចាត់ទុកថាបានបញ្ជូនចេញដែរនោះនៅក្នុងករណីដែលអ្នកទទួលបានទទួលពេលក្រោយ។ នេះដោយអនុលោមតាមន័យរបស់កថាខណ្ឌទី១មាត្រា១៥ នៃច្បាប់តាមប្រព័ន្ធអេឡិចត្រូនិកកម្ពុជា ដែលចែងថា ពេលវេលានិងទីកន្លែងនៃការបញ្ជូនចេញនិងការទទួលព័ត៌មានក្នុងទំនាក់ទំនងអេឡិចត្រូនិក ព័ត៌មានក្នុងទំនាក់ទំនងអេឡិចត្រូនិកមួយត្រូវចាត់ទុកថាបានបញ្ជូនចេញនៅពេលដែល៖

ក-ព័ត៌មាននោះ បានចាកចេញពីប្រព័ន្ធព័ត៌មានដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់អ្នកផ្ញើឬរបស់ភាគីដែលផ្ញើជំនួសក្នុងនាមជាអ្នកផ្ញើ។ ឬ

ខ-ក្នុងករណីដែលព័ត៌មាននោះ ត្រូវបានបញ្ជូនតែមិនទាន់បានចាកចេញពីប្រព័ន្ធព័ត៌មានដែលស្ថិតក្រោមការគ្រប់គ្រងរបស់អ្នកផ្ញើឬរបស់អ្នកផ្ញើជំនួសព័ត៌មានត្រូវចាត់ទុកថា បានបញ្ជូននៅពេលដែលព័ត៌មាននោះត្រូវបានទទួលក្នុងពេលណាមួយ។

លើសពីនេះក្នុងករណីដែលអ្នកផ្ញើ បង្កើតកំហុសដោយមិនមានចេតនាចង់សំណើបង្កើតកិច្ចសន្យាទេ ហើយប្រព័ន្ធស្វ័យប្រវត្តរបស់អ្នកទទួលមិនមានកន្លែងមុខងារសម្រាប់លុប ឬកែប្រែព័ត៌មានដែលខុសទេនោះ អ្នកផ្ញើក៏មានសិទ្ធិកែប្រែ ឬដកចេញនូវសំណើបង្កើតកិច្ចសន្យាបាន ដោយត្រូវជូនព័ត៌មានទៅដល់អ្នកទទួលអំពីកំហុសនោះឱ្យបានឆាប់បំផុត ហើយអ្នកផ្ញើនោះក៏មិនទទួលបានផលប្រយោជន៍ណាមួយដោយសារកំហុសហើយថែមទាំងមិនប៉ះពាល់ដល់អ្នកទទួល ឬតតិយជន។[29] ជាមួយគ្នានេះដែរ ការបង្កើតកិច្ចសន្យាតាមរយៈប្រព័ន្ធស្វ័យប្រវត្តិក៏ត្រូវរាប់ថាមានសុពលភាពផងដែរទោះបីជាម្ចាស់នៃបង្កើតកិច្ចសន្យាតាមរយៈប្រព័ន្ធស្វ័យប្រវត្តនោះមិនបានចូលរួមផ្ទាល់ក៏ដោយ។ ផ្អែកតាម មាត្រា១៧នៃច្បាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកការប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តសម្រាប់បង្កើតកិច្ចសន្យា កិច្ចសន្យាដែលបង្កើតឡើងដោយអន្តកម្មរវាងប្រព័ន្ធស្វ័យប្រវត្តនៃបុគ្គលមួយ ជាមួយរូបវន្តបុគ្គលណាមួយឬជាមួយប្រព័ន្ធស្វ័យប្រវត្តនៃបុគ្គលផ្សេងទៀត មិនអាចត្រូវបានបដិសេធអំពីសុពលភាព អានុភាពគតិយុត្ត ឬភាពអាចអនុវត្តបាននៃកិច្ចសន្យានោះឡើយ ដោយសម្អាងលើហេតុផលអវត្តមាននៃរូបវន្តបុគ្គលក្នុងការពិនិត្យឬក្នុងការចូលធ្វើសកម្មភាពដោយផ្ទាល់ក្នុងប្រព័ន្ធស្វ័យប្រវត្តឬក្នុងការបង្កើតកិច្ចសន្យា ។

### ១.២.៣ ហត្ថលេខាអេឡិចត្រូនិក

ហត្ថលេខាអេឡិចត្រូនិចគឺជាមធ្យោបាយបញ្ជាក់អត្តសញ្ញាណនៃបុគ្គលណាម្នាក់ និងបំណងនៃបុគ្គលនោះដើម្បីបង្ហាញការផ្តល់សច្ចានុមតិ ឬដើម្បីបង្កើតទំនាក់ទំនងលើកំនត់ត្រាអេឡិចត្រូនិក។ ហត្ថលេខាអេឡិចត្រូនិក (Electronic Signature) សំដៅដល់រាល់ហត្ថលេខាដែលត្រូវបានបង្កើតឡើងតាមមធ្យោបាយអេឡិចត្រូនិកសម្រាប់ប្រើប្រាស់កំណត់អត្តសញ្ញាណរបស់ហត្ថលេខីដែលរួមមាន ហត្ថលេខាឌីជីថល ហត្ថលេខាជីវមាត្រ និងហត្ថលេខាដទៃទៀត(សូមមើលក្នុងឧបសម្ព័ន្ធទី៣)។[30] នៅប្រទេសកម្ពុជាយើងបន្ទាប់ពីបានអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងអាស៊ានស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅរដ្ឋធានីហាណូយនៃសាធារណរដ្ឋសង្គមនិយមវៀតណាមនានៅថ្ងៃទី ២២ ខែមករា ឆ្នាំ២០១៩ នាំឱ្យការហត្ថលេខាអេឡិចត្រូនិកមានលក្ខណៈត្រឹមត្រូវស្របតាមច្បាប់ និងអាចប្រើប្រាស់

[29] មាត្រា១៨ នៃច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកព្រះរាជាណាចក្រកម្ពុជា ខែវិច្ឆិកា ឆ្នាំ២០១៩

[30] មាត្រា៤ នៃអនុក្រឹត្យស្តីពីហត្ថលេខាឌីជីថល លេខ២៤៦ អនក្រ.បក ខែធ្នូ ឆ្នាំ២០១៧

បានក្នុងវិស័យពាណិជ្ជកម្មអេឡិចត្រូនិក។ នៅពេលដែលឯកសារអ្វីមួយត្រូវបានចុះហត្ថលេខានោះវានឹងត្រូវគេចាត់ទុកថាបានការហើយអាចយកទៅប្រើប្រាស់ ឬអះអាងបាន ហើយហត្ថលេខាគឺចាំបាច់ណាស់ដើម្បីអោយឯកសារមួយមានអានុភាពដោយសារតែវាអាចបញ្ជាក់បានពីបំណងនៃហត្ថលេខី។ ថ្វីត្បិតតែហត្ថលេខាអេឡិចត្រូនិចជាប្រភេទហត្ថលេខាបែបថ្មី ទំនើប ក៏ពិតមែនតែវាតួនាទីសំខាន់បំផុតរបស់វាក៏មិនខុសប្លែកអ្វីពីហត្ថលេខាធម្មតាទូទៅដែរ ពោលគឺបញ្ជាក់ពីអត្តសញ្ញាណនៃអ្នកប្រើប្រាស់វា។ ជាទូទៅតួនាទីនៃហត្ថលេខាអេឡិចត្រូនិកដូចជា៖

- កំណត់អត្តសញ្ញាណបុគ្គល
- ផ្តល់ព័ត៌មានផ្ទាល់ខ្លួនដ៏ជាក់លាក់នៃបុគ្គលដែលបានចុះហត្ថលេខា
- ភ្ជាប់ទំនាក់ទំនងរវាងបុគ្គល នឹងឯកសារដែលបានចុះ។[31]

ហត្ថលេខាអេឡិចត្រូនិកអាចកំណត់បានថាតើសារអេឡិចត្រូនិកមានប្រភពមកណា ហើយត្រឹមត្រូវឬទេ មិនតែប៉ុណ្ណោះវាអាចឱ្យភាគីក្នុងទំនាក់ទំនងអេឡិចត្រូនិកដឹងបានពីអត្តសញ្ញាណនៃភាគីនីមួយៗរបស់ខ្លួនបាន ដែលនាំឱ្យភាគីធានាបាននូវភាពអាចទុកចិត្តបានរវាងគ្នា និងគ្នាហើយឈានទៅរកភាពជោគជ័យក្នុងដំណើរការពាណិជ្ជកម្មអេឡិចត្រូនិក។ លើសពីនេះទៅទៀតហត្ថលេខាអេឡិចត្រូនិកត្រូវបានគេយកទៅប្រើប្រាស់ក្នុងកិច្ចការពាណិជ្ជកម្មជាក់ស្តែងដូចជាក្នុងកិច្ចសន្យាជាដើម ដែលជាពិសេសនោះគឺ កិច្ចសន្យាលក់-ទិញ។ ក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកកិច្ចសន្យាអាចបង្កើត និងមានសុពលភាពទៅបានកាលណា ១.សំណើ ស្វីការ និងកិច្ចសន្យា អាចធ្វើឡើងតាមរយៈមធ្យោបាយអេឡិចត្រូនិកបាន។ ២.កិច្ចសន្យាក្នុងទម្រង់អេឡិចត្រូនិកដូចមានចែងក្នុងបញ្ញត្តិនៃកថាខណ្ឌទី១ខាងលើមានសុពលភាព អានុភាពគតិយុត្ត និងអនុវត្តបាននៅពេលដែលសំណើរ និងស្វីការត្រូវគ្នា។[32] សង្កេតឃើញថាកិច្ចសន្យាដែលបានធ្វើឡើងក្រោមទម្រង់ជាអេឡិចត្រូនិកក៏ជាកិច្ចសន្យាដែលតម្រូវឱ្យមានសំណើរ និងស្វីការត្រូវគ្នារវាងគូភាគីដូចជាកិច្ចសន្យាទូទៅដែរ។ ក្នុងកិច្ចសន្យាដែលមានហត្ថលេខាអេឡិចត្រូនិក អាចសបង្ហាញថាភាគីមានសិទ្ធិ និងកាតព្វកិច្ចរៀងខ្លួនដោយហេតុថាភាគីនីមួយៗបានប្រើប្រាស់ហត្ថលេខាអេឡិចត្រូនិកដើម្បីផ្តល់សច្ចានុមតិលើកិច្ចសន្យានោះ។

---

[31] UNICITRAL Model law on Electronic Signatures with Guide to enactment, United Nation, Vienna, Austria, 2001

[32] មាត្រា១២នៃច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកព្រះរាជាណាចក្រកម្ពុជា ខែវិច្ឆិកា ឆ្នាំ២០១៩

**ក.ហត្ថលេខាឌីជីថលដែលមានសុវត្ថិភាព**

នៅក្នុងកម្ពុជាហត្ថលេខាឌីជីថលមានចំនួនមនុស្សតិចតួចដែលដឹងលឺ ក៏ប៉ុន្តែវាជាយន្តការមួយដែលសំខាន់ក្នុងការចូលរួមចំណែកធ្វើឱ្យចំណងទំនាក់ទំនងក្នុងកិច្ចពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកមានសុក្រឹត្យភាព និងត្រឹមត្រូវតាមច្បាប់។ ដើម្បីទទួលបានហត្ថលេខាឌីជីថលដែលស្របច្បាប់ជាចាំបាច់គេត្រូវតែមានការស្នើរសុំពីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ឱ្យបានត្រឹមត្រូវទៅតាមលក្ខខ័ណ្ឌដែលបានកំណត់ពោលគឺត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអគ្គនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន។ ជាជំហានដំបូង គេត្រូវស្នើសុំ អាជ្ញាបណ្ណវិញ្ញាតកម្មហត្ថលេខាឌីជីថល(license) ដើម្បីធ្វើជាវិញ្ញាធរហត្ថលេខាឌីជីថល (Certificate Authority CA) បន្ទាប់មកអ្នកដែលបានទទួលបានសិទ្ធិជាវិញ្ញាធរហត្ថលេខាឌីជីថល (CA) អាចធ្វើការលក់នូវហត្ថលេខាឌីជីថលនោះបន្តអោយទៅរូបវន្តបុគ្គល ឬនីតិបុគ្គល ក្រុមហ៊ុន ធនាគារ ហើយអ្នកមានបំនងចង់ប្រើប្រាស់ហត្ថលេខាឌីជីថលដែលមានភាពស្របច្បាប់ត្រឹមត្រូវនោះអាចទៅទិញពី (CA) បាន។[33] ចំពោះបុគ្គលដែលមានបំណងស្នើរសុំអាជ្ញាបណ្ណវិញ្ញាតកម្មហត្ថលេខាឌីជីថល ត្រូវមានជំនាញបច្ចេកទេស ធនធានហិរញ្ញវត្ថុ ប្រាក់តម្កល់ធានាអាជីវកម្ម គ្រឿងបរិក្ខារបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន និងគុណវឌ្ឍិផ្សេងទៀតស្របតាមការកំណត់ដោយប្រកាសរបស់ក្រសួងប្រៃសនីយ៍ និងទូរគមនាគមន៍[34] ហើយអជ្ញាបណ្ណវិញ្ញាតកម្មហត្ថលេខាឌីជីថលមានរយៈពេល១០ឆ្នាំគិតពីថ្ងៃចេញអាជ្ញាបណ្ណ។[35] រូបវន្តបុគ្គល ឬនីតិបុគ្គលអាចធ្វើការទិញវិញ្ញាបនបត្រហត្ថលេខាឌីជីថល ពីវិញ្ញាធរហត្ថលេខាឌីជីថល(CA) ដែលមានអាជ្ញាបណ្ណវិញ្ញាតកម្មហត្ថលេខាឌីជីថលចេញដោយអគ្គនាយកដ្ឋានបច្ចេកវិទ្យាទូរគមនាគមន៍ និងពត៌មាននៃក្រសួង ប្រៃសណីយ៍និងទូរគមនាគមន៍។

យោងតាមមាត្រា២០នៃច្បាប់ស្តីពីពាណិជ្ជកម្មអេឡិចត្រូនិកបានបញ្ញត្តិថា ហត្ថលេខាអេឡិចត្រូនិកដែលមានសុវត្ថិភាព លុះត្រាតែគោរពទៅតាមលក្ខខ័ណ្ឌដូចខាងក្រោមៈ

ក.ផ្សារភ្ជាប់ទៅកាន់ហត្ថលេខីតែម្នាក់គត់។

ខ.កំនត់បានអត្តសញ្ញាណរបស់ហត្ថលេខី។

---

[33] ប្រសាសន៍របស់លោកអ៊្ហ ជាណារិទ្ធ ប្រធាននាយកដ្ឋានសន្តិសុខបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាននៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ក្នុងសិក្ខាសាលាផ្សព្វផ្សាយអនុក្រឹត្យស្តីពីហត្ថលេខាឌីជីថលនាព្រឹកថ្ងៃទី៣០ខែមករា ឆ្នាំ២០១៨ ក្នុងស្ថានីយទូរទស្សន៍ប៉ុស្តិ៍ BTV

[34] មាត្រា១៥នៃអនុក្រឹត្យស្តីពីហត្ថលេខាឌីជីថលលេខ២៤៦ អនក្រ.បក ខែធ្នូ ឆ្នាំ២០១៧

[35] មាត្រា១៧នៃអនុក្រឹត្យស្តីពីហត្ថលេខាឌីជីថលលេខ២៤៦ អនក្រ.បក ខែធ្នូ ឆ្នាំ២០១៧

គ.ត្រូវបានបង្កើតឡើងដោយប្រើប្រាស់មធ្យោបាយដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ហត្ថលេខី។

ឃ.បញ្ជាក់អំពីពេលវេលានិងកាលបរិច្ឆេទនៃការចុះហត្ថលេខា។និង

ង.បញ្ជាក់អំពីស្ថានភាពដើមនៃសារ ឬកំណត់ត្រាអេឡិចត្រូនិកដែលត្រូវបានផ្សារភ្ជាប់ដោយហត្ថលេខានោះ។

**ខ. ស្ថាប័នមានសមត្ថកិច្ចលើហត្ថលេខាឌីជីថល**

ចំពោះក្រសួងពាណិជ្ជកម្មមានសមត្ថកិច្ចក្នុងការផ្តល់លិខិតប្រកបអនុញ្ញាត ឬអាជ្ញាបណ្ណរួមមាន លិខិតអនុញ្ញាតប្រកបអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិកសម្រាប់រូបវន្តបុគ្គល និង អាជ្ញាបណ្ណឱ្យប្រតិបត្តិការសេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកសម្រាប់នីតិបុគ្គល។ [36] ហើយចំពោះហត្ថលេខាឌីជីថល MPTC (ក.ប.ទ) ជាស្ថាប័នមានសមត្ថកិច្ចក្នុងការគ្រប់គ្រងលើហត្ថលេខាឌីជីថល និងផ្តល់វិញ្ញាបនបត្រហត្ថលេខាឌីជីថលដល់ក្រសួង ស្ថាប័ន និងអាជ្ញាធរថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ អគ្គនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន (អ.ប.គ.ព) ជាសេនាធិការរបស់ MPTC ក្នុងការគ្រប់គ្រង ការផ្តល់ ការត្រួតពិនិត្យ និងការតាមដានការអនុវត្តអាជ្ញាបណ្ណវិញ្ញាតកម្មហត្ថលេខាឌីជីថល ស្របតាមអនុក្រឹត្យស្តីពីហត្ថលេខាឌីជីថល និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត។[37] លើសពីនេះ ទម្រង់បែបបទនៃការពិន័យ និងការគ្រប់គ្រងប្រាក់ដែលបានមកពីការពិន័យ ព្រមទាំងកម្រៃសេវាសម្រាប់ដោះស្រាយវិវាទរវាងវិញ្ញាធរហត្ថលេខាឌីជីថល និងវិញ្ញាធរហត្ថលេខាឌីជីថល វិញ្ញាធរហត្ថលេខាឌីជីថល និងកម្មសិទ្ធករវិញ្ញាបនបត្រហត្ថលេខាឌីជីថល ត្រូវកំណត់ដោយប្រកាសរួមរវាងក្រសួងប្រៃសនីយ៍ និងទូរគមនាគមន៍ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**១.២.៤ លក្ខខណ្ឌដើម្បីកំណត់តម្លៃភស្តុតាងអេឡិចត្រូនិក**

ភស្តុតាងជាបញ្ហាដ៏សំខាន់ក៏ប៉ុន្តែវា មិនសូវមានច្បាប់ចែង ឬការសិក្សាអំពីភស្តុតាងច្រើននោះទេ។ ចំពោះកម្រិតនៃភស្តុតាងមានពីរប្រភេទយ៉ាងតិចប្រភេទទៅតាមប្រភេទនៃរឿងក្តី គឺទីមួយ សមតុល្យនៃលទ្ធភាពដែលអាចកើតមាន (Balance of Probability of the Evidence) ក្នុងរឿងរដ្ឋប្បវេណី និងទីពីរ ហួសពីវិមតិសង្ស័យ (Beyond

[36] មាត្រា២៦នៃច្បាប់ស្តីពីពាណិជ្ជកម្មអេឡិចត្រូនិកព្រះរាជាណាចក្រកម្ពុជា ខែវិច្ឆិកា ឆ្នាំ២០១៩

[37] មាត្រា៥នៃអនុក្រឹត្យស្តីពីហត្ថលេខាឌីជីថលលេខ២៤៦ អនក្រ.បក ខែធ្នូ ឆ្នាំ២០១៧

Reasonable Doubt) ក្នុងរឿងព្រហ្មទណ្ឌ។ [38] ចំពោះភស្តុតាងជាលាយលក្ខណ៍អក្សរមានតួនាទីសំខាន់ក្នុងការបង្ហាញអំពីការពិតនៅពីក្រោយសកម្មភាពពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដោយហេតុថាវាអាចជួយគូភាគីនៅក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកទទួលបានយុត្តិធម៌ និងសុក្រឹត្យភាព។ មិនតែប៉ុណ្ណោះ ដំណើរការនៃសកម្មភាពនីមួយៗក្នុងប្រព័ន្ធអេឡិចត្រូនិកគឺត្រូវបានថតទុកដោយប្រព័ន្ធទាំងពេលវេលាក៏ដូចជាខ្លឹមសារ ហើយក្នុងនោះដែរកំណត់ត្រាអេឡិត្រូនិកក៏ជាភស្តុតាងរឹងមាំមួយសម្រាប់ការអះអាងចំពោះគូភាគី នៅមុខផ្លូវច្បាប់។ នៅក្នុងគំរូច្បាប់ UNCITRAL Model Law on Electronic Transferable Records (2017) ត្រង់មាត្រា៨ ក៏បានបង្ហាញថាកំណត់ត្រាជាលាយលក្ខណ៍អក្សរ ធ្វើឡើងដោយអាចឱ្យព័ត៌មានក្នុងកំណត់ត្រានេះអាចយកទៅប្រើប្រាស់បានជាឯកសារយោងនៅពេលក្រោយ។[39] ចំណែកនៅក្នុង មាត្រា១៩ នៃច្បាប់ស្ដីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិត្រូនិកកម្ពុជា កំណត់ត្រាអេឡិចត្រូនិកមួយត្រូវបានចាត់ទុកថាជាកំណត់ត្រាអេឡិចត្រូនិកដែលមានសុវត្ថិភាព លុះត្រាតែបានអនុវត្តស្របតាមនីតិវិធីសុវត្ថិភាពត្រឹមត្រូវ ដែលធានាបានថាកំណត់ត្រាអេឡិចត្រូនិកនោះ មិនត្រូវបានកែប្រែ គិតចាប់ពីពេលវេលាកំណត់ជាក់លាក់ណាមួយរហូតដល់ពេលធ្វើការពិនិត្យផ្ទៀងផ្ទាត់។ ក្នុងចំណុចនេះគឺថា កំណត់ត្រាអេឡិត្រូនិកក៏ត្រូវបានចាត់ទុកថាជាភស្តុតាងមិនអាចបដិសេធបានផងដែរសម្រាប់ការតវ៉ាតាមផ្លូវច្បាប់ មិនថាវាស្ថិតនៅក្នុងទម្រង់ដើមឬឯកសារថតចម្លងនោះទេ។ ភស្តុតាងអេឡិត្រូនិកទទួលបានមកពីកំណត់ត្រាអេឡិចត្រូនិក ផ្អែកតាមមាត្រា៣៥ ការទទួលយកជាទូទៅនូវភស្តុតាងអេឡិចត្រូនិក គ្មានបទប្បញ្ញត្តិនៃវិធានស្តីពីភស្តុតាងណាមួយដែលយកមកអនុវត្ត ដើម្បីបដិសេធក្នុងការទទួលយកជាទូទៅនូវកំណត់ត្រាអេឡិចត្រូនិកនោះឡើយ ទោះបីជាភស្តុតាងនោះមិនស្ថិតក្នុងទម្រង់ដើមក៏ដោយ។ នេះមានន័យថា កំណត់ត្រាអេឡិចត្រូនិកគឺជាភស្តុតាងដែលរឹងមាំមួយ ហើយទោះជាយ៉ាងនេះក្តីភស្តុតាងអេឡិចត្រូនិកក៏ត្រូវតែជាភស្តុតាងមានសុក្រឹត្យភាពផងដែរទើបចាត់ទុកថា ភស្តុតាងអេឡិចត្រូនិកមានសុពលភាព។ ប្រសិនបើមិនមានភស្តុតាងថ្មីណាមួយផ្ទុយអំពីភស្តុតាងអេឡិចត្រូនិកដើមទេ នោះភស្តុតាងអេឡិចត្រូនិកចាស់នៅតែអាចត្រូវបានគេយកមកប្រើប្រាស់ក្នុងដំណើការនិតិវិធីបានដដែល ហើយភស្តុតាងអេឡិចត្រូនិកនោះត្រូវស្របលក្ខខណ្ឌមួយចំនួនដូចជា សុក្រឹត្យភាពនៃប្រព័ន្ធអេឡិចត្រូនិក សុក្រឹត្យភាពនៃព័ត៌មានទម្រង់ឯកសារបោះពុម្ពចេញ។

[38] បណ្ឌិត មាស បូរ៉ា និងលោក វឌ្ឍា ពិសិដ្ឋ ៖ កម្រិតភស្តុតាង និងបន្ទុកនៃភស្តុតាង ក្នុងរឿងព្រហ្មទណ្ឌ នៅក្នុងការផ្សព្វផ្សាយរបស់សមាគមត្រាជូ ខែកក្កដា ឆ្នាំ ២០១៨

[39] UNCITRAL Model Law on Electronic Transferable Records, United Nations, Vienna, Austria, 2017

**ក.សុក្រឹត្យភាពនៃប្រព័ន្ធអេឡិចត្រូនិក**

ចំពោះប្រព័ន្ធអេឡិចត្រូនិកដែលយកមកប្រើប្រាស់សម្រាប់កត់ត្រាក៏ដូចជារក្សាទុកកំណត់ត្រាអេឡិចត្រូនិក ដែលមានសុក្រឹត្យភាពនិងជំរុញកំណត់ត្រាអេឡិចត្រូនិកឱ្យក្លាយជាភស្តុតាងអេឡិត្រូនិកលុះត្រាតែះ

- ក្នុងករណីមានភស្តុតាងគាំទ្រដល់អង្គហេតុណាមួយដែលបញ្ជាក់ថាប្រព័ន្ធអេឡិចត្រូនិកឬឧបករណ៍ស្រដៀងគ្នាផ្សេងទៀត បានដំណើរការជាប្រក្រតីនៅពេលដែលកំណត់ត្រាអេឡិចត្រូនិកនោះត្រូវបានកត់ត្រាឬរក្សាទុកឬនៅពេលដែលយកទៅធ្វើជាភស្តុតាង ឬក្នុងករណីដែលប្រព័ន្ធអេឡិចត្រូនិក ឬឧបករណ៍ ស្រដៀងគ្នាផ្សេងទៀតនោះមិនបានដំណើរការជាប្រក្រតី ឬឈប់ដំណើរការទាំងស្រុង ប៉ុន្តែមិនធ្វើឲ្យប៉ះពាល់ដល់សុក្រឹតភាពនៃកំណត់ត្រានោះ។
- ក្នុងករណីមានភស្តុតាងអាចបង្ហាញបានថា កំណត់ត្រាអេឡិចត្រូនិកត្រូវបានកត់ត្រាឬរក្សាទុក ដោយភាគីដែលមានផលប្រយោជន៍ផ្ទុយគ្នាទៅនឹងភាគីម្ខាងទៀតដែលប្រើប្រាស់កំណត់ត្រាអេឡិចត្រូនិកនោះជាភស្តុតាងក្នុងដំណើរការនីតិវិធីតាមផ្លូវច្បាប់។ ឬ
- នៅពេលដែលមានភស្តុតាងអាចបង្ហាញបានថា កំណត់ត្រាអេឡិចត្រូនិកត្រូវបានកត់ត្រាឬរក្សាទុកជាប្រក្រតីក្នុងគោលបំណងអាជីវកម្មធម្មតាដោយបុគ្គលដែលមិនមែនជាភាគីក្នុងដំណើរការនីតិវិធីតាមផ្លូវច្បាប់ ហើយបុគ្គលនោះមិនបានកត់ត្រាឬរក្សាទុកនូវកំណត់ត្រាអេឡិចត្រូនិកក្រោមការគ្រប់គ្រងរបស់ភាគីដែលប្រើប្រាស់កំណត់ត្រាអេឡិចត្រូនិកនោះជាភស្តុតាងក្នុងដំណើរការនីតិវិធីតាមផ្លូវច្បាប់។[40]

**ខ. សុក្រឹត្យភាពនៃព័ត៌មាន**

ចំពោះសុក្រឹត្យភាពនៃព័ត៌មាន ត្រូវគោរពទៅតាមសេចក្តីដែលមានចែងក្នុងមាត្រា៣៧ នៃច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិត្រូនិកកម្ពុជា ដូចជាះ

១- កំណត់ត្រាអេឡិចត្រូនិកដែលបានកត់ត្រាឬរក្សាទុកនៅក្នុងប្រព័ន្ធអេឡិចត្រូនិកត្រូវបានសន្មតថាមានសុក្រឹតភាពនៅក្នុងដំណើរការនីតិវិធីតាមផ្លូវច្បាប់ ប្រសិនបើកំណត់ត្រាអេឡិចត្រូនិកនោះ៖

- នៅពេញលេញនិងគ្មានកែប្រែក្រៅពីការធ្វើបដិ្ឋលេខបន្ថែមណាមួយ ឬការផ្លាស់ប្តូរដែលមិនសំខាន់ណាមួយដែលកើតឡើងនៅក្នុងដំណើរការជាប្រក្រតីនៃទំនាក់ទំនងការរក្សាទុកឬការបង្ហាញ។

[40] មាត្រា៣៦ នៃច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិត្រូនិកព្រះរាជាណាចក្រកម្ពុជា ខែវិច្ឆិកា ឆ្នាំ២០១៩

- ត្រូវបានបញ្ជាក់ឬចុះហត្ថលេខានៅក្នុងទម្រង់អេឡិចត្រូនិក តាមរយៈមធ្យោបាយដែលផ្តល់ឲ្យដោយអ្នកផ្តល់នីតិវិធីសុវត្ថិភាពដែលមានអាជ្ញាបណ្ណត្រឹមត្រូវ។
- មានសុក្រឹតភាពនិងមានខ្លឹមសារដែលត្រូវបានបញ្ជាក់ដោយក្រសួងឬស្ថាប័នមានសមត្ថកិច្ច។
- ត្រូវបានកត់ត្រាទុកនៅក្នុងឧបករណ៍រក្សាទុកឬតាមមធ្យោបាយអេឡិចត្រូនិកផ្សេងទៀតដែលមិនអនុញ្ញាតឲ្យមានការកែប្រែទៅលើកំណត់ត្រាអេឡិចត្រូនិក។
- ត្រូវបានត្រួតពិនិត្យនិងបញ្ជាក់ពីសុក្រឹតភាព ដោយអ្នកជំនាញដែលត្រូវបានតែងតាំងដោយតុលាការ។
- នៅពេលដែលមានភស្តុតាងគាំទ្រដល់អង្គហេតុណាមួយ ដែលបញ្ជាក់ថាប្រព័ន្ធអេឡិចត្រូនិកឬឧបករណ៍ស្រដៀងគ្នាផ្សេងទៀតបានដំណើរការជាប្រក្រតីនៅគ្រប់រយៈពេលសំខាន់ៗ ឬក្នុងករណីដែលប្រព័ន្ធអេឡិចត្រូនិកឬឧបករណ៍ស្រដៀងគ្នាផ្សេងទៀតនោះមិនបានដំណើរការជាប្រក្រតីឬឈប់ដំណើរការទាងស្រុង តែសុក្រឹតភាពនៃកំណត់ត្រាមិនរងការប៉ះពាល់ដោយចោទជាមន្ទិលសង្ស័យលើសុក្រឹតភាពនៃកំណត់ត្រានោះឡើយ។ ឬ
- នៅពេលដែលមានផស្តុតាងអាចបង្ហាញបានថាកំណត់ត្រាអេឡិចត្រូនិកបានកត់ត្រាឬរក្សាទុកដោយភាគីដែលចូលរួមនៅក្នុងដំណើរការនីតិវិធីតាមផ្លូវច្បាប់នោះហើយដែលភាគីមានទំនាស់ផលប្រយោជន៍ផ្ទុយគ្នាទៅនឹងភាគីម្ខាងទៀត ដែលមានបំណងប្រើប្រាស់កំណត់ត្រាអេឡិចត្រូនិកនោះ។

២- នៅពេលដែលមានភស្តុតាងអាចបង្ហាញបានថាកំណត់ត្រាអេឡិចត្រូនិកត្រូវបានកត់ត្រាឬរក្សាទុកតាមធម្មតានិងក្នុងគោលបំណងអាជីវកម្មធម្មតា ដោយបុគ្គលដែលមិនមែនជាភាគីនៅក្នុងដំណើរការនីតិវិធីតាមផ្លូវច្បាប់ហើយបុគ្គលនោះមិនបានកត់ត្រាឬរក្សាទុកនូវកំណត់ត្រាអេឡិចត្រូនិក ក្រោមការគ្រប់គ្រងរបស់ភាគីដែលមានបំណងប្រើប្រាស់កំណត់ត្រាអេឡិចត្រូនិកនោះ។

**គ. ឯកសារបោះពុម្ពចេញ**

ឯកសារដែលបានបោះពុម្ពចេញត្រឹមត្រូវស្របបនឹងខ្លឹមសារដើមចេញពីកំណត់ត្រាអេឡិចត្រូនិកអាចយកមកប្រើប្រាស់ជាភស្តុតាងបានក្នុងដំណើរការនីតិវិធីតាមផ្លូវច្បាប់។[41]

**ឃ. ភស្តុតាងដែលមានយថាភូតភាព**

យថាភូតភាពនៃកំណត់ត្រាអេឡិចត្រូនិកមួយដើម្បីធ្វើជាភស្តុតាង អាចត្រូវបានស្នើសុំភស្តុតាងនោះពីអ្នកជំនាញពាក់ព័ន្ធនឹងយថាភូតភាពនៃកំណត់ត្រាអេឡិចត្រូនិកនោះក្រោមទម្រង់ជាលិខិតបញ្ជាក់ពីក្រសួង ស្ថាប័នមានសមត្ថកិច្ច ជាក់ស្តែងដូចជាក.ប.ទជាដើម ឬបុគ្គលដែលទទួលខុសត្រូវពាក់ព័ន្ធនឹងប្រតិបត្តិការ ឬការគ្រប់គ្រងអ្នកបង្កើតនីតិវិធីសុវត្ថិភាពជាក់លាក់ណាមួយ ឬអ្នកបង្កើតនីតិវិធីសុវត្ថិភាពដែលទទួលស្គាល់ដោយតុលាការ។ ហើយបុគ្គលដែលមានសមត្ថកិច្ចទាំងនោះក៏ មិនត្រូវក្លែងឬចេញលិខិតបញ្ជាក់យថាភូតភាពនៃកំណត់ត្រាឬភស្តុតាងអេឡិចត្រូនិកមិនពិតដែរ។[42]

បន្ថែមពីនេះកំណត់ត្រាអេឡិចត្រូនិកក៏អាចយកមកធ្វើជាភស្តុតាងអេឡិចត្រូនិកផងដែរក្នុងករណីដែលកំណត់ត្រាអេឡិចត្រូនិកនោះ មានការបញ្ជាក់ដោយសាការីឬស្ថាប័នមានសមត្ថកិច្ច កំណត់ត្រាអេឡិចត្រូនិកដែលមិនអនុញ្ញាតឲ្យនរណាម្នាក់ការកែប្រែបាន និងលទ្ធផលកោសល្យវិច័យលើប្រព័ន្ធអេឡិចត្រូនិកតាមការរកឃើញរបស់យុត្តាធិការតុលាការ។

ចំណែកឯកំណត់ត្រាអេឡិចត្រូនិកពីបរទេសវិញក៏ត្រូវចាត់ទុកថាជាភស្តុតាងអេឡិចត្រូនិកដែរបើសិនណាប្រព័ន្ធដែលធានាដំណើរការអេឡិចត្រូនិកនោះបានបញ្ជាក់ដោយក្រសួង ឬស្ថាប័នបរទេស ហើយមានសុក្រឹត្យភាពស្របតាមលក្ខខណ្ឌរបស់ភស្តុតាងអេឡិចត្រូនិកកម្ពុជា។ ចំពោះព័ត៌មានក្នុងទម្រង់អេឡិចត្រូនិកវិញដើម្បីអាចកំណត់ថាជាព័ត៌មាននោះជាព័ត៌មាន ដែលអាចទទួលយកបានសម្រាប់ធានាកំណត់ត្រាអេឡិចត្រូនិកដើម្បីយកមកធ្វើជាភស្តុតាងអេឡិចត្រូនិកនោះគឺមិនចាំបាច់ពិនិត្យពីទីតាំងដែលផ្ញើចេញនោះទេ ពោលគឺត្រូវពិនិត្យថាតើវាអាចទាញយកមកប្រើប្រាស់បានឬអត់ក្នុងទឹកដីដែនសមត្ថកិច្ចកម្ពុជា។[43]

[41] មាត្រា៣៨ នៃច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិត្រូនិកព្រះរាជាណាចក្រកម្ពុជា ខែវិច្ឆិកា ឆ្នាំ២០១៩

[42] មាត្រា៤១ នៃច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិត្រូនិកព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩

[43] មាត្រា៤៤ និង ៤៥ នៃច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិត្រូនិកព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩

# ជំពូកទី២ តួនាទីច្បាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកក្នុងអាជីវកម្ម

ទិន្នន័យ Networked Readiness index12 បានមកពីវេទិកាសេដ្ឋកិច្ចពិភពលោក បានបង្ហាញថាកម្ពុជាជាប្រទេសទទួលបានចំណាត់ថ្នាក់ទី១១៨ ក្នុងចំណោម១៣៣ប្រទេសដែលមានលិខិតបទដ្ឋានគតិយុត្តទាក់ទងទៅនឹងព័ត៌មានបច្ចេកវិទ្យា កាលពីឆ្នាំ២០១០ ហើយ៥ឆ្នាំក្រោយមកក្នុងឆ្នាំ២០១៥ កម្ពុជាបានទទួលចំណាត់ថ្នាក់កាន់តែប្រសើរពោលគឺនៅលេខរៀង១០៩ ក្នុងចំណោម១៣៩។ ចំណាត់ថ្នាក់នេះផងដែរក៏ត្រូវបានគេប៉ានស្មានថានឹងទទួលបានចំណាត់ថ្នាក់កាន់តែល្អប្រសើរក្នុងករណីដែលកម្ពុជាមានច្បាប់ក៏ដូចជាលិខិតបទដ្ឋានគតិយុត្តកាន់តែច្រើនទាក់ទងជាមួយ ទូរគមនាគមន៍ ក៏ដូចជា ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកជាដើម។[44] ការដាក់នូវចំណាត់ថ្នាក់នេះ បង្ហាញពីការយកចិត្តទុកដាក់ចំពោះការរៀបចំច្បាប់ ហើយវាជាការចាំបាច់ណាស់ដែលតួនាទីនៃច្បាប់ត្រូវលើកយកមកពិភាក្សា ជាពិសេសគឺ តួនាទីនៃច្បាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនេះផ្ទាល់។ ម្យ៉ាងវាជារឿងដែលប្រកែកមិនបានដែលច្បាប់តាមប្រព័ន្ធអេឡិចត្រូនិកត្រូវបានបង្កើតឡើងដើម្បីការពារអាជីវករតាមប្រព័ន្ធអេឡិចត្រូនិក ក៏ដូចជាអាជីវកម្មរបស់ពួកគេ ព្រមទាំងអតិថិជនដែលជាប្រើប្រាស់សេវាទិញដូរតាមប្រព័ន្ធអេឡិចត្រូនិក។ ក្នុងជំពូកទី២ នេះ នឹងបង្ហាញអំពីតួនាទីនៃច្បាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិត្រូនិកកម្ពុជាតាមរយៈការបែងចែកទៅជា២ផ្នែក ដែលផ្នែកទី១ អំពី ការគ្រប់គ្រងលើអាជីវកម្មនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងផ្នែកទី២ អំពីកិច្ចការពារអ្នកប្រើប្រាស់ និងការដោះស្រាយវិវាទ។

## ២.១ ការគ្រប់គ្រងលើអាជីវកម្ម

សកម្មភាពអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិក នៅក្នុងប្រទេសកម្ពុជា និងសកម្មភាពអាជីវកម្មតាមប្រព័ន្ធអេឡិត្រូនិកដែលនៃកម្ពុជាជាមួយអន្តរជាតិ ត្រូវបានគ្រប់គ្រងដោយច្បាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៃព្រះរាជាណាចក្រកម្ពុជា។[45] ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកជាក់ស្តែងគឺបានកំណត់ដោយច្បាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកកម្ពុជា ក៏ដូចជាបទដ្ឋានគតិយុត្តសំខាន់ៗ មួយចំនួនដែលពាក់ព័ន្ធ ដើម្បីរក្សាបាននូវរបៀបរៀបរយផ្នែកគតិយុត្តសម្រាប់ការពារនូវការសកម្មភាពចរាចរណ៍លក់ដូរទំនិញ មិនថាក្រោមរូបភាពនៃការផ្គត់ផ្គង់ទំនិញ ឬសេវាកម្មពីអាជីវកម្មពីអាជីវកម្មទៅអាជីវកម្ម(B2B) ក៏ដូចជា ការផ្គត់ផ្គង់ទំនិញ ឬសេវាកម្មពីអាជីវកម្មពី

[44] UNITED NATIONS CONFERENCE ON TRADE AND DEVELOPMENT, UNCTAD: Cambodia Rapid Trade Readiness Assessment, United Nation, New York and Geneva, 2017

[45]មាត្រា០១ នៃច្បាប់ស្តីពីពាណិជ្ជកម្មអេឡិចត្រូនិកព្រះរាជាណាចក្រកម្ពុជា ខែវិច្ឆិកា ឆ្នាំ២០១៩

អាជីវកម្មទៅអ្នកប្រើប្រាស់(B2C)។ ជាមួយគ្នានេះដែរច្បាប់នេះមានតួនាទីគ្រប់គ្រងលើប្រតិបត្តករ ការទូទាត់ប្រាក់ កម្មសិទ្ធិបញ្ញាដែលស្ថិតក្រោមក្របខ័ណ្ឌនៃច្បាប់នេះ។

### ២.១.១ ការគ្រប់គ្រងលើប្រតិបត្តិករ

ប្រតិបត្តករនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកជាអ្នកដែលធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ក្នុងនោះមានដូចជាអន្តរការី និងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។ ចំពោះអន្តរការី អាចជាភ្នាក់ងារជួមសម្របសម្រួលផ្នែកបច្ចេកទេសសម្រាប់ដំណើរការនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ជាឧទាហរណ៍ដូចជាក្រុមហ៊ុនផ្ទុកទិន្នន័យ Data Center ក្រុមហ៊ុនផ្តល់សេវាទូរគមនាគមន៍ ក្រុមហ៊ុនផ្តល់សេវាទីផ្សារអនឡាញ និងក្រុមហ៊ុនធានាលើការទូទាត់ប្រាក់។ អន្តរការីពាណិជ្ជកម្មជាតួអង្គដែលធ្វើការងារលើការធ្វើការសម្រេចចិត្តទាក់ទងនឹងការប្រើប្រាស់យន្តការអេឡិចត្រូនិកក្នុងទីផ្សារ ព្រមទាំងធានាលើទំនាក់ទំនងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដោយឈរលើភាពស្មោះត្រង់ ភាពជឿទុកចិត្ត និងស្របច្បាប់។ ការប្រើប្រាស់អន្តរការីសម្រាប់កិច្ចពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក អាចជួយឱ្យការផ្ទេរទំនិញ និងការទូទាត់ប្រាក់ អាចជួយសម្របសម្រួលទៅលើការធ្វើទីផ្សារសម្រាប់អ្នកធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ។[46]

អន្តរការី ឬ Intermediary សំដៅដល់បុគ្គលដែលផ្តល់សេវាផ្ញើ ទទួល បញ្ជូន ឬរក្សាទុក ជាបណ្តោះអាសន្ន ឬជាអចិន្ត្រៃយ៍នូវទំនាក់ទំនងអេឡិក្រូនិកនោះ ឬផ្តល់សេវាផ្សេងទៀតដែលពាក់ព័ន្ធនឹងទំនាក់ទំនងអេឡិក្រូនិក ដែលរាប់បញ្ចូលនូវបុគ្គលដូចជា៖

- បុគ្គលដែលតំណាងឱ្យអ្នកផ្ញើ អ្នកទទួល អ្នកបញ្ជូន ឬអ្នករក្សាទុក
- បុគ្គលផ្តល់សេវាទូរគមនាគមន៍
- បុគ្គលផ្តល់សេវាបណ្តាញនានា
- បុគ្គលផ្តល់សេវាអ៊ីធឺណិត
- បុគ្គលផ្តល់មធ្យោបាយស្វែងរកទិន្នន័យណាមួយតាមប្រព័ន្ធអេឡិចត្រូនិក
- បុគ្គលផ្តល់សេវាទូទាត់តាមអនឡាញ
- បុគ្គលផ្តល់សេវាដេញថ្លៃតាមអនឡាញ

[46] Hyuksoo Cho Patriya Tansuha, Electronic intermediaries: research and practice of electronic intermediaries in export marketing, 2021: https://bit.ly/3zj33Zv , ចូលមើលថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២១

– បុគ្គលផ្តល់សេវាទីផ្សារតាមអនឡាញ និងសេវាពាណិជ្ជកម្មតាមបណ្តាញអ៊ីនធឺណិត។

ចំណែកបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក សំដៅដល់បុគ្គលដែលប្រើប្រាស់មធ្យោបាយអេឡិចត្រូនិកដើម្បីផ្គត់ផ្គង់ទំនិញឬសេវាកម្មលើកលែងគ្រឹះស្ថានធានារ៉ាប់រង។[47] ជាឧទាហរណ៍នៃបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកមានដូចជា Amazon.com, Alibaba.com, Pass App, Grabជាដើម។ ជារួមអន្តរការី និងបុគ្គលផ្តល់សេវាពាណិជ្ជកមម្មតាមប្រព័ន្ធអេឡិចត្រូនិក មានទំនាក់ទំនងគ្នាយ៉ាងស្អិតរមួតក្នុងការធ្វើប្រតិបត្តិការពាណិជ្ជកម្មព្រោះបុគ្គលម្ខាងជាអ្នកជំនាញខាងបច្ចេកទេសដែលបង្កើតជាថ្នាលសម្រាប់ផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក រីឯម្ខាងទៀតជាអ្នកដែលប្រើប្រាស់សេវាតាមប្រព័ន្ធអេឡិចត្រូនិក ដើម្បីភ្ជាប់ជាមួយអតិថិជនផ្ទាល់។

**ក.ការទទួលខុសត្រូវនៃអន្តរការី និងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក**

ក្នុងបរិបទនៃការពេញនិយមការប្រើប្រាស់ពានៅក្នុងសកម្មភាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក អន្តរការី និងបុគ្គលផ្តល់សេវាពាណិជ្ជកមម្មតាមប្រព័ន្ធអេឡិចត្រូនិក ទទួលបាននូវចំណេញតាមរយៈការបម្រើសេវាកម្មរបស់ពួកគេ។ អន្តរការី និងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកមានការទទួលខុសត្រូវសម្រាប់សកម្មភាពរបស់ខ្លួន ហើយមិនទទួលខុសត្រូវឡើយចំពោះសកម្មភាពដែលខ្លួនមិនបានធ្វើ ដូចជាការផ្ញើកំណត់ត្រាអេឡិចត្រូនិកជាដើម។ លើសពីនេះទៅទៀត អន្តរការី និងបុគ្គលផ្តល់សេវាពាណិជ្ជកមម្មតាមប្រព័ន្ធអេឡិចត្រូនិកក៏មិនទទួលខុសត្រូវផ្នែករដ្ឋប្បវេណី ឬព្រហ្មទណ្ឌឡើយក្នុងករណីដែលខ្លួនមិនបានដឹងថាព័ត៌មាននោះខុសច្បាប់។ ដូចដែលបានលើកឡើងខាងលើ អន្តរការី និងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក គឺមានតួនាទីគ្រាន់តែបញ្ជូននូវទិន្នន័យ ព័ត៌មាន ក៏ដូចជាកំណត់ត្រាជូនចំពោះអ្នកប្រើប្រាស់តែប៉ុន្នោះពោលគឺមិនមែនជាអ្នកដែលមានឆន្ទៈផ្ទាល់ក្នុងទំនាក់ទំនងអេឡចត្រូនិកឡើយ។ ហើយច្បាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកកម្ពុជាក៏មិនបានតម្រូវឱ្យ អន្តរការី និងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកតាមដានត្រួតពិនិត្យនូវកំណត់ត្រាអេឡិត្រូនិកណាមួយដែលខ្លួនគ្រប់គ្រងជូនអតិថិជនឡើយទោះបីជាកំណត់ត្រា ឬដំណើរការនៃប្រព័ន្ធអេឡិចត្រូនិកនោះអាចបង្កើតជាបទល្មើសក៏ដោយ។ ក៏ប៉ុន្តែនេះក៏មិនមែនមានន័យថា អន្តរការី និងបុគ្គលផ្តល់សេវាពាណិជ្ជកម្ម

[47] ឧបសម្ព័ន្ធនិយមន័យនៃច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ព្រះរាជាណាចក្រកម្ពុជា ខែវិច្ឆិកា ឆ្នាំ២០១៩

តាមប្រព័ន្ធអេឡិចត្រូនិកអាចរួចផុតពីកាតព្វកិច្ចតាមលិខិតបទដ្ឋានគតិយុត្តនានា កាតព្វកិច្ចពីអាជ្ញាធរមានសមត្ថកិច្ច ឬតុលាការ និងកាតព្វកិច្ចតាមកិច្ចសន្យារបស់ខ្លួនដែលធ្វើឡើងជាមួយអតិថិជនរបស់ខ្លួន។

លើសពីនេះក្នុងករណីថាប្រសិនបើ អន្តរការី និងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកបាន ដឹងថាព័ត៌មានក្នុងកំណត់ត្រាអេឡិចត្រូនិកមានកំហុស ឬអាចមានកំហុសដែលនាំទៅរការទទួលខុសត្រូវរដ្ឋប្បវេណី ឬព្រហ្មទណ្ឌ នោះ អន្តរការី និងបុគ្គលផ្តល់សេវាពាណិជ្ជកមម្មតាមប្រព័ន្ធអេឡិចត្រូនិកត្រូវដកព័ត៌មាននោះចេញ និង ឈប់ផ្ញើចេញ ហើយរក្សាទុកភស្តុតាងនោះសម្រាប់ប្រគល់ជូនដល់ក.ប.ទ និងស្ថាប័នមានសមត្ថកិច្ច។ ស្របតាម ច្បាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ក្រោយពេលដែល ក.ប.ទ ទទួលបានព័ត៌មានដែលបានមកពី អន្តរការី និងបុគ្គលផ្តល់សេវាពាណិជ្ជកមម្មតាមប្រព័ន្ធអេឡិចត្រូនិក ក.ប.ទ អាចបញ្ជារទៅ អន្តរការី និងបុគ្គលផ្តល់សេវា ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវដកព័ត៌មាននោះចេញពីប្រព័ន្ធរបស់ខ្លួន ឈប់ផ្តល់សេវាដល់បុគ្គលដែល មានបំនងចង់ផ្ទេរព័ត៌មានខុសច្បាប់ ឬ អន្តរការី និងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកត្រូវផ្អាកឬ ឈប់ផ្តល់សេវានៃកំណត់ត្រាអេឡិចត្រូនិក។[48]

មិនតែប៉ុណ្ណោះ អន្តរការី និងបុគ្គលផ្តល់សេវាពាណិជ្ជកមម្មតាមប្រព័ន្ធអេឡិចត្រូនិកក៏ត្រូវទទួលខុសត្រូវលើ ក្រមសីលធម៌វិជ្ជាជីវៈនៃ អន្តរការី និងបុគ្គលផ្តល់សេវាពាណិជ្ជកមម្មតាមប្រព័ន្ធអេឡិចត្រូនិក។ មាត្រា២៧ ក្រមសីល ធម៌វិជ្ជាជីវៈនិងបទប្បញ្ញត្តិសម្រាប់អន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមអេឡិចត្រូនិក

១- អន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេលីចត្រូនិកត្រូវអនុវត្តតាមក្រុមសីលធម៌វិជ្ជាជីវៈ និងបទប្បញ្ញត្តិនានាពាក់ព័ន្ធនឹងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកដែលកំណត់ដោយប្រកាសអន្តក្រសួងរវាង ក្រសួងពាណិជ្ជកម្មនិងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។

២- ក្រមសីលធម៌វិជ្ជាជីវៈ ដែលបានលើកឡើងក្នុងបញ្ញត្តិនៃកថាខណ្ឌទី១ខាងលើត្រូវកំណត់និងរៀបរៀង ឡើងដោយក្រសួងពាណិជ្ជកម្មនិងក្រសួងប្រៃសណីយ៍និងទូរគនាគមន៍ដោយសហការជាមួយក្រសួង ស្ថាប័ននិងភា គីពាក់ព័ន្ធ។

**ខ. កាតព្វកិច្ចនៃអន្តរការី និងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក**

[48] មាត្រា២៥ នៃច្បាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ព្រះរាជាណាចក្រកម្ពុជា ខែវិច្ឆិកា ឆ្នាំ២០១៩

អន្តរការី និងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកអាចធ្វើសកម្មភាពពាណិជ្ជកម្មរបស់ខ្លួនបានលុះត្រាតែមានលិខិតអនុញ្ញាត ឬអាជ្ញាបណ្ណត្រឹមត្រូវ។ តាមមាត្រា២៦នៃច្បាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ការផ្តល់លិខិតអនុញ្ញាតឬអាជ្ញាបណ្ណ អន្តរការីនិងបុគ្គលផ្តល់សេវាកម្មពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវស្នើសុំការអនុញ្ញាតឬអាជ្ញាបណ្ណពីក្រសួងពាណិជ្ជកម្ម។ ផ្អែកតាមមាត្រា៤ នៃអនុក្រឹត្យលេខ១៣៤ អនក្រ.បក ក្រសួងពាណិជ្ជកម្ម ជាស្ថាប័នមានសមត្ថកិច្ចក្នុងការគ្រប់គ្រង និងផ្តល់លិខិតអនុញ្ញាតឬអាជ្ញាបណ្ណ ដល់អន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងវិញ្ញាបនបត្រសម្គាល់ ទំនុកចិត្តពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក(សូមមើលក្នុងឧបសម្ព័ន្ធទី៤)។ [49] អន្តរការី និងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកដែលនឹងធ្វើសកម្មភាពនៅព្រះរាជាណាចក្រកម្ពុជមិនថាជាក្រុមហ៊ុនសញ្ជាតិកម្ពុជា ឬសាខាក្រុមហ៊ុនបរទេសគឺត្រូវស្នើសុំលិខិតអនុញ្ញាតប្រសិនបើកិច្ចពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិករបស់ខ្លួនធ្វើឡើងដោយរូបវន្តបុគ្គល និងត្រូវស្នើសុំអាជ្ញាបណ្ណពីក្រសួងពាណិជ្ជកម្មប្រសិនបើកិច្ចពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិករបស់ខ្លួនធ្វើឡើងដោយនីតិបុគ្គល។

**ចំពោះរូបវន្តបុគ្គល៖** រូបវន្តបុគ្គលឬសហគ្រាស ដែលនឹងប្រកបអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិកក្នុងព្រះរាជាណាចក្រកម្ពុជា និងរូបវន្តបុគ្គលឬសហគ្រាសដែលប្រើ ប្រាស់បណ្តាញសង្គមឬប្រព័ន្ធអេឡិចត្រូនិកជាមធ្យោបាយក្នុងការផ្គត់ផ្គង់ឬទិញ-លក់ទំនិញនិង/ឬសេវា។ លិខិតអនុញ្ញាតមានសុពលភាពចំនួន២ឆ្នាំ គិតចាប់ពីថ្ងៃផ្តល់លិខិតអនុញ្ញាតដោយក្រសួងពាណិជ្ជកម្ម និងអាចបន្តសុពលភាពបាន ហើយចំពោះរយៈពេលផ្តល់សេវាលិខិតអនុញ្ញាតចាប់ពី៣ ទៅ៥ថ្ងៃ នៃថ្ងៃធ្វើការ (សូមមើលឧបសម្ព័ន្ធ)។

**ចំពោះនីតិបុគ្គល៖** អាជ្ញាបណ្ណសម្រាប់ប្រតិបត្តិការផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវផ្តល់ឱ្យនីតិបុគ្គល និង សាខាក្រុមហ៊ុនបរទេស ដែលនឹងធ្វើប្រតិបត្តិការ និងសកម្មភាពពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដូចខាងក្រោម៖

- សេវាគេហទំព័រពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក
- សេវាថ្នាលពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក
- សេវាទីផ្សារអនឡាញ
- សេវាគេហទំព័រដេញថ្លៃអនឡាញ

[49] មាត្រា ៤ អនុក្រឹត្យលេខ ១៣៤ អនក្រ.បក ស្តីពី ការកំណត់ប្រភេទ បែបបទ និងនីតិវិធីនៃការផ្តល់លិខិតអនុញ្ញាឬអាជ្ញាបណ្ណដល់អន្តរការី និងបុគ្គលផ្តល់សេវាពាណិជ្ជតាមប្រព័ន្ធអេឡិចត្រូនិក និងការលើកលែង ខែសីហា ឆ្នាំ២០២០

– សេវាស្រដៀងគ្នាផ្សេងទៀតដែលផ្តល់តាមរយៈកម្មវិធីកុំព្យូទ័របុឧបករណ៍វៃឆ្លាតសម្រាប់ការជំរុញធ្វើ ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។[50]

ចំពោះករណីប្រតិបត្តិការដោយគ្មានការអនុញ្ញាត ស្របតាមមាត្រា៥៦នៃច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកកម្ពុជា ត្រូវបញ្ឈប់សកម្មភាពឬប្រតិបត្តិការអាជីវកម្មនិងត្រូវទទួលកាផាកពិន័យជាប្រាក់មិនលើស១០០០០០០០(ដប់លាន)រៀល ចំពោះបុគ្គលតាំងឡាយណាដែលប្រព្រឹត្តផ្ទុយ និងបញ្ញាតិនៃកថាខណ្ឌទី១នៃមាត្រា២៦។

ក្នុងករណីធ្លាប់ទទួលរងនូវវិធានការដូចមានចែងក្នុងកថាខណ្ឌតី១ជាស្ថាពររួចហើយបានប្រព្រឹត្តបទល្មើសដដែលនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគាពី១(មួយ)ឆ្នាំទៅ៣(បី)ឆ្នា និងត្រូវពិន័យជាប្រាក់ពី២ ០០០ ០០០(ពីរលាន)រៀលពី៦ ០០០ ០០០(ប្រាំមួយលាន)រៀល។

### ២.១.២ កិច្ចគ្រប់គ្រងលើការទូទាត់ប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក

ក្នុងកិច្ចពាណិជ្ជកម្មអេឡិចត្រូនិកត្រូវបានមើលឃើញថាមានវិធីសាស្ត្រច្រើនដើម្បីអាចទូទាត់ប្រាក់ ក៏ដូចជាថ្លៃចំណាយនានាបានតួយ៉ាងដូចជាការទូទាត់តាមរយៈភ្នាក់ងារដឹកជញ្ជូន និងការទូទាត់តាមប្រព័ន្ធអេឡិចត្រូនិក។ ការទូទាត់តាមរយៈភ្នាក់ងារដឹកជញ្ជូន គឺធ្វើឡើងនៅពេលដែលទំនិញត្រូវបានប្រគល់ជូនដល់អតិថិជនហើយអតិថិជនធ្វើការបង់ប្រាក់ផ្ទាល់ជាមួយភ្នាក់ងារដឹកជញ្ជូន។ ចំណែកឯការទូទាត់តាមអេឡិចត្រូនិកវិញ អាចត្រូវបានកំណត់ដោយសាមញ្ញថាជាការទូទាត់ថ្លៃទំនិញឬសេវាកម្មតាមអ៊ីនធឺណិត។ វារួមបញ្ចូលទាំងប្រតិបត្តិការហិរញ្ញវត្ថុទាំងអស់ដោយប្រើឧបករណ៍អេឡិចត្រូនិកដូចជាកុំព្យូទ័រស្មាតហ្វូនឬថេប្លេត ហើយការទូទាត់តាមអេឡិចត្រូនិកអាចប្រព្រឹត្តទៅបានតាមរយៈការប្រើប្រាស់កាតឥណទានឬឥណពន្ធ( Credit or Debit Card), កាបូបអេឡិចត្រូនិច(E-wallets) និងការផ្ទេរប្រាក់តាមរយៈធនាគារ។ ការទូទាត់ប្រាក់តាមប្រព័ន្ធឌីជីថលនេះផ្តល់ភាពងាយស្រួល ឆាប់រហ័ស នឹងមានសុវត្ថិភាព ព្រោះគ្រប់ការទូទាត់ទាំងត្រូវបានឆ្លងកាត់ប្រព័ន្ធឌីជីថល។[51] ផ្អែកតាមធនាគារជាតិនៃប្រទេសកម្ពុជា បញ្ជាទូទាត់សងប្រាក់អេឡិចត្រូនិកមានប្រតិបត្តិការចំនួន៣ប្រភេទ ដូចជា៖

---

[50] ប្រកាសលេខ២៩០ ព.ណចបព.ប្រក ស្តីពី ការផ្តល់លិខិតអនុញ្ញាត ឬអាជ្ញាបណ្ណពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ខែតុលា ឆ្នាំ២០២០

[51] SecurionPay: How to define E-Payment, https://bit.ly/3ziJ4u7 , ចូលមើលថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៨

- ការផ្ទេរឥណទាន (Credit Remittance) ៖ ការផ្ទេរឥណទានត្រូវបានប្រើសម្រាប់ការទូទាត់សងប្រាក់ដែលផ្តើមឡើងដោយអ្នកសងប្រាក់(Payer)ទៅអ្នកទទួលផល។ ធនាគារពាណិជ្ជផ្តល់ សេវាផ្ទេរឥណទានតាមរយៈសាខាម៉ាស៊ីនទូទាត់ដោយស្វ័យប្រវត្តិ(ATM) អ៊ីនធឺណែត កុំព្យូទ័រ និងទូរស័ព្ទចល័ត។
- ឥណទានផ្ទាល់ (Direct Credit) ៖ ទូទាត់សងប្រាក់តាមយៈឥណទានផ្ទាល់ផ្តើមឡើងដោយអ្នកសងប្រាក់តែម្នាក់ទៅអ្នកទទួលផលមួយឬច្រើននាក់តាមចំនួនប្រាក់និងពេលវេលាដែលបានកំណត់។ ឥណទានផ្ទាល់ត្រូវបានប្រើជាទូទៅសម្រាប់ការបើកប្រាក់បៀវត្សរ៍។
- ឥណពន្ធផ្ទាល់ (Direct Debit) ៖ ឥណពន្ធផ្ទាល់មានពីរទម្រង់ គឺប្រភេទឥណពន្ធផ្ទាល់ដោយបង្គំនិងដោយសំណើ។ ឥណពន្ធផ្ទាល់ដោយបង្គំ ជាការទាមទារឱ្យទូទាត់សងប្រាក់នៅពេលអ្នកទទួលផលបង្ហាញបញ្ជានេះទៅអ្នកសងប្រាក់។ ឥណពន្ធផ្ទាល់ដោយសំណើ ជាទម្រង់មួយនៃសារបញ្ជាទូទាត់សងប្រាក់ដែលមិនមានផ្ទុកតម្លៃ (Non Value Payment Order Massage)។ ឥណពន្ធផ្ទាល់នេះត្រូវទទួលយកក្រោមរូភាពជាសំណើ និងដំណើរការគ្រានតែជាសារជូនដំណឹងសម្រាប់ទូតាត់សងប្រាក់ប៉ុណ្ណោះ។[52]

រីឯដំណើរការនៃទូទាត់តាមអេឡិចត្រូនិកគឺមានបីជំហានដូចតទៅ៖ ទី១ ការចាប់ផ្តើមទូទាត់៖ ដំណើរការចាប់ផ្តើមនៅពេលអតិថិជនចូលមើលគេហទំព័ររបស់ ផលិតផលឬសេវាកម្មដែលពួកគេចង់បញ្ជាទិញ។ បន្ទាប់មកអតិថិជនត្រូវបំពេញបែបបទទូទាត់ជាមួយព័ត៌មានជាក់លាក់ដូចជា លេខកាត, កាលបរិច្ឆេទផុតកំណត់,លេខកូដ CVV នឹងអាស័យដ្ឋាន។ អតិថិជននឹងត្រូវបានបញ្ជូនបន្តទៅគេហទំព័ររបស់ធនាគារឬបន្តការទូទាត់នៅលើគេហទំព័រក្នុងកម្មវិធីអាស្រ័យលើវិធីបង់ប្រាក់ដែលអតិថិជនបានជ្រើសរើស។ ទី២ ការផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃការទូទាត់៖ នៅក្នុងជំហាននេះប្រតិបត្តិករត្រូវធ្វើការផ្ទៀងផ្ទាត់ព័ត៌មានដែលអតិថិជនបានផ្ញើរួមជាមួយព័ត៌មានលម្អិតផ្សេងទៀតដូចជាព័ត៌មានទូទាត់ នឹងព័ត៌មានគណនីរបស់អតិថិជន។ ប្រសិនបើអ្វីៗត្រឹមត្រូវគ្រប់ជ្រុងជ្រោយអស់ហើយ ដំណើរការនឹងបន្ត ហើយប្រតិបត្តករនឹងរាយការណ៍អំពីភាពជោគជ័យនៃប្រត្តិបត្តការនោះ។ បន្ទាប់មក អតិថិជននឹងទទួលបានការបញ្ជាក់ពីការទូទាត់ ហើយការជូនដំណឹងនឹងត្រូវបានបង្ហាញជូនតាមពេលវេលាជាក់ស្តែង ផ្ទុយទៅវិញប្រសិនបើមានបញ្ហាណាដែលទាក់ទងការផ្ទៀងផ្ទាត់ភាពត្រឹមត្រូវណាមួយ ប្រតិបត្តិការនោះនឹងបរាជ័យ។ ទី៣ ការទូទាត់៖ បន្ទាប់ពីដំណើរនៃការផ្ទៀងផ្ទាត់បានជោគជ័យ ការទូទាត់របស់អតិថិជនត្រូវបានផ្ទេរទៅក្នុងគណនីរបស់អាជីវករដោយអ្នក

[52] ធនាគារជាតិនៃកម្ពុជា, បញ្ជារទូទាត់តាមប្រព័ន្ធអេឡិចត្រូនិក, https://bit.ly/3ylu5yd ,ចូលមើលថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៨

ផ្តល់សេវាកម្មទូទាត់តាមអ៊ីនធឺណិត។[53] ប្រតិបត្តិការទូទាត់ប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក ផ្តល់ភាពងាយស្រួលដល់អតិថិជនក្នុងការទូទាត់ថ្លៃទំនិញ ឬសេវាកម្ម ហើយការទូទាត់ប្រាក់តាមប្រព័ន្ធអេឡិចត្រូនិកនេះទៀតសោតបានធ្វើឱ្យមានទំនាក់ទំនងរវាងអតិថិជន បុគ្គលប្រើប្រាស់ប្រតិបត្តិការប្រព័ន្ធទូទាត់ ឬផ្តល់សេវាទូទាត់ ហេតុដូចនេះអតិថិជនបុគ្គលប្រើប្រាស់ប្រតិបត្តិការប្រព័ន្ធទូទាត់ត្រូវទទួលខុសត្រូវចំពោះការទូទាត់របស់ខ្លួន។

**ក. ការទទួលខុសត្រូវរបស់ប្រតិបត្តិករ**

ចំពោះរាល់សកម្មភាពនៃដំណើការប្រតិបត្តិការនៃការទូទាត់តាមប្រព័ន្ធអេឡិចត្រូនិក ជាចាំបាច់ត្រូវតែមានការអនុញ្ញាត ព្រមទាំងទទួលបានអញ្ញាបណ្ណពីធនាគារជាតិនៃកម្ពុជា។ ផ្អែកទៅតាម មាត្រា៤៦នៃច្បាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកកម្ពុជា ប្រតិបត្តិការទូទាត់តាមប្រព័ន្ធអេឡិចត្រូនិក

១- បុគ្គលណាដែលធ្វើប្រតិបត្តិការប្រព័ន្ធទូទាត់ ផ្តល់សេវាទូទាត់ ចេញផ្សាយឧបករណ៍ទូទាត់ប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក ឬផ្តល់មធ្យោបាយទូទាត់ប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក ឬធ្វើប្រតិបត្តិការណាដែរត្រូវបានចាត់ទុកថាជាការផ្តល់ការទូទាត់សងប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក ដល់សាធារណជនត្រូវស្នើសុំការអនុញ្ញាតឬអាជ្ញាបណ្ណជាមុនពីធនាគាជាតិនៃកម្ពុជា។

២- ធនាគាជាតិនៃកម្ពុជាជាស្ថាប័នមានសមត្ថកិច្ចក្នុងការរៀបចំបទបញ្ញត្តិទាក់ទងនឹងការទូទាត់ប្រាក់តាមអេឡិចត្រូនិក។

បុគ្គលផ្តល់សេវាទូទាត់ត្រូវចៀសវាងចំពោះការផ្តល់ជូនអតិថិជននូវប្រតិបត្តិការដែលអតិថិជនមិនបានអនុញ្ញាតយល់ព្រមនោះទេ ហើយបុគ្គលផ្តល់សេវាទូទាត់ត្រូវទទួលខុសត្រូវនូវរាល់ប្រតិបត្តិការទូទាត់ប្រាក់ដែលកើតឡើងក្នុងករណីដែលបុគ្គលផ្តល់សេវាទូទាត់ធ្វើឱ្យមានការដកយកថវិការបស់អតិថិជនតាមរយៈប្រតិបត្តិតាមប្រព័ន្ធអេឡិចត្រូនិក។ ផងដែរនោះបុគ្គលផ្តល់សេវាទូទាត់ក៏ត្រូវទទួលខុសត្រូវចំពោះករណីដែលបុគ្គលផ្តល់សេវាទូទាត់បានដឹងថាមានការក្លែងបន្លំ បាត់បង់ ឬមានចោរកកម្មដែលនាំឱ្យមានការខាតបង់ជាមុន។ មិនតែប៉ុណ្ណោះបុគ្គលផ្តល់សេវាទូទាត់ ត្រូវទទួលខុសត្រូវក្នុងករណីដែលមានអតិថិជនជូនដំណឹងអំពីភាពមិនប្រក្រតីដែល បានកើតឡើងក្នុងរយៈពេលមិនលើសពី២ថ្ងៃ។ ភាពមិនប្រក្រតីអាចកើតមានឡើងដូចជា ចោរកម្ម ការលួចចូលយកទិន្នន័យជាដើម ភាពមិនប្រក្រតីក៏អាចមានក្នុងបញ្ហាបច្ចេកទេសដែរ ហើយបុគ្គលផ្តល់សេវាទូទាត់ត្រូវតែយកចិត្តទុកដាក់ខ្ពស់បំផុតចំពោះផ្នែក

[53] GoCardless: The Basic of online payment processing, https://bit.ly/2UTNSHu ,ចូលមើលថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៨

បច្ចេកទេសទូទាត់ព្រោះវាអាចនាំឱ្យមានការទទួលខុសត្រូវ។ ជាឧទាហរណ៍ប្រសិនបើក្នុងពេលមានប្រតិបត្តិការទូទាត់សាច់ប្រាក់ មានការលួចចូលHack គណនេយ្យនោះអតិថិជនត្រូវទាក់ទងប្រាប់ទៅបុគ្គលដែលផ្តល់សេវាទូទាត់ឱ្យបានដឹង ហើយបុគ្គលផ្តល់សេវាទូទាត់ត្រូវដោះស្រាយជូនអតិថិជន ក៏ប៉ុន្តែប្រសិនបើកំហុសឆ្គងនៃការទូទាត់កើតមានឡើងដោយសារអតិថិជននោះបុគ្គលផ្តល់សេវាទូទាត់មិនចាំបាច់ត្រូវទទួលខុសត្រូវឡើយនេះឡើយ។ យោងតាមមាត្រា ៤៧នៃច្បាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ការទទួលខុសត្រូវរបស់បុគ្គលផ្តល់សេវាទូទាត់

១- បុគ្គលផ្តល់សេវាទូទាត់មិនត្រូវផ្តល់ជូនអតិថិជននូវឧបករណ៍ទូទាត់ ដែលអតិថិជនមិនបានស្នើសុំនោះទេ លើកលែងតែករណីដែលបណ្ណទូទាត់នោះជាបណ្ណទូទាត់ហួសរយៈពេលប្រើប្រាស់ ឬដល់ពេលត្រូវផ្លាស់ប្តូរ។

២- មុនពេលធ្វើប្រតិបត្តិការផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក បុគ្គលផ្តល់សេវាត្រូវបញ្ជាក់ឲ្យបានច្បាស់ពីអត្តសញ្ញាណរបស់អតិថិជននិងផ្ទៀងផ្ទាត់ឡើងវិញនូវភាពត្រឹមត្រូវនៃការផ្ទេរប្រាក់ តាមប្រព័ន្ធអេឡិចត្រូនិក។បុគ្គលផ្តល់សេវាទូទាត់ត្រូវទទួលខុសត្រូវលើករណីដូចខាងក្រោម៖

ក- ប្រតិបត្តិការកើតឡើងដោយគ្មានការអនុញ្ញាតពីអតិថិជន។

ខ- ប្រតិបត្តិការកើតឡើងបន្ទាប់ពីដឹងថាមានការបន្លំ បាត់បង់ ឬចោរកម្មនៃ ឧបករណ៍ផ្ទេប្រាក់តាមអេឡិចត្រូនិក។

គ- ប្រតិបត្តការកើតឡើងបន្ទាប់ពីមានការជូនដំណឹងពីអតិថិជនដូចមានចែងមាត្រា៤៨ខាងក្រោម។

ឃ- ការខកខានមិនបានប្រតិបត្តិតាមបញ្ជារបស់អតិថិជនឬការប្រតិបត្តិខុសពីបញ្ជារបស់អតិថិជន។ឬ

ង- ភាពមិនប្រក្រតីនៃប្រព័ន្ធបច្ចេកទេស កំហុសក្នុងការប្រើប្រាស់ប្រព័ន្ធបច្ចេកទេស ឬឧបករណ៍ផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក។

៣- បុគ្គលផ្តល់សេវាទូទាត់ត្រូវទទួលខុសត្រូវបានតែក្នុងករណីប្រធានស័ក្តិ ឬជាកំហុសរបស់អតិថិជនផ្ទាល់ប៉ុណ្ណោះ។

៤- ក្នុងករណីដែលបុគ្គលផ្តល់សេវាទូទាត់ត្រូវទទួលខុសត្រូវ បុគ្គលផ្តល់សេវាទូទាត់ត្រូវសងថ្លៃខូចខាតជូនអតិថិជនក្នុងរយៈពេលមិនអោយលើសពី៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលការជូនដំណឹងពីអតិថិជនដូចមានចែងក្នុងមាត្រា៤៨នៃច្បាប់នេះ នូវកម្រៃប្រតិបត្តិការដែរបានខាតបង់សាហ៊ុយ និងការពិន័យក្នុងការបង់ប្រាក់យឺតយ៉ាវដែលអាចកើតឡើងចំពោះអតិថិជន។

៥- បុគ្គលទាំងឡាយមិនត្រូវចេញផ្សាយបណ្ណទូទាត់ ឬកែប្រែបណ្ណទូទាត់ទៅជាទម្រង់ណាមួយដែលខុសពីទម្រង់ដើម ដោយគ្មានការអនុញ្ញាតក្នុងគោលបំណងទុច្ចរិត ឆបោក ក្លែងបន្លំ ដែលនាំអោយមានព្យសនកម្មដល់បុគ្គលមួយណាផ្សេងទៀតឡើយ។

ចំពោះអំពើល្មើសនៃប្រតិបត្តិការតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវផ្តន្ទាទោសដាក់ពន្ធនាគាពី១ឆ្នាំ ទៅ៥ឆ្នាំ និងព្រមទាំងត្រូវពិន័យជាទឹកប្រាក់ពីមួយលានរៀលទៅដប់លានរៀលក្នុងករណីល្មើសនឹងបញ្ញត្តិមាត្រា៤៦នៃច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកកម្ពុជាដែលមានដូចជា ដាក់ដំណើរការប្រតិបត្តិការទូទាត់សងប្រាក់តាមប្រព័ន្ធអេឡិចត្រូនិកដោយមិនបានធ្វើការស្នើសុំអនុញ្ញាតពីធនាគារជាតិនៃកកម្ពុជា។ មិនតែប៉ុណ្ណោះ បុគ្គលផ្តល់សេវាទូទាត់តាមប្រព័ន្ធអេឡិចត្រូនិកណាដែលមិនបានគោរពតាមបញ្ញត្តិកថាខណ្ឌទី២ នៃមាត្រា៤៧ដែលបានលើកឡើងអំពីការទូទាត់ប្រាក់តាមប្រព័ន្ធអេឡិចត្រូនិកដែលអតិថិជនមិនបានស្នើសុំឱ្យមានការទូទាត់នៅចំណុចខាងលើ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពីមួយឆ្នាំ ទៅ៣ឆ្នាំ និងត្រូវពិន័យជាប្រាក់ពីមួយលានរៀល ទៅដប់លានរៀល។ បន្ថែមពីនេះក្នុងករណីដែលមានអំពើល្មើសទាក់ទងជាមួយការក្លែងបន្លំឧបករណ៍ទូទាត់សងប្រាក់ជាអេឡិចត្រូនិក **ជាឧទាហរណ៍** ដូចជា ការចេញបណ្ណទូទាត់ក្លែងក្លាយក្នុងបំណងទុច្ចរិតដែលនាំឱ្យមានការខូចខាត នោះបុគ្គលដែលបានប្រព្រឹត្តិល្មើសនឹងត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពីមួយឆ្នាំ ទៅបីឆ្នាំ និងត្រូវពិន័យជាទឹកប្រាក់ពីពីរលានរៀលទៅប្រាំមួយលានរៀល។

**ខ. ការទទួលខុសត្រូវរបស់អតិថិជន**

ការទទួលខុសត្រូវមិនត្រឹមតែមានចំពោះប្រតិបត្តិករដែលជាបុគ្គលផ្តល់សេវាទូទាត់ប៉ុណ្ណោះទេ ក៏ប៉ុន្តែអតិថិជនដែលប្រើប្រាស់សេវាទូទាត់ដើម្បីទូទាត់សងប្រាក់តាមប្រព័ន្ធអេឡិចត្រូនិកក៏ត្រូវចូលរួមទទួលខុសត្រូវក្នុងករណីដែលខ្លួនមានជួបប្រទះនឹងភាពមិនប្រក្រតីក្នុងការទូទាត់ ផ្អែកតាមបញ្ញត្តិនៃមាត្រា៤៨នៃច្បាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ការទទួលខុសត្រូវរបស់អតិថិជន

១- អតិថិជនត្រូវជូនដំណឹងដល់បុគ្គលិកផ្តល់សេវា អំពីប្រតិបត្តិការដែរកើតឡើងដោយគ្មានការអនុញ្ញាតកំហុសឆ្គង ឬភាពមិនត្រឹមត្រូវផ្សេងទៀតនៅក្នុងគណនីរបស់ខ្លួន។

២- អតិថិជនត្រូវជូនដំណឹងដល់បុគ្គលផ្តល់សេវាទូទាត់ឬគ្រឹះស្ថានដែរទទួលបានការអនុញ្ញាតពីបុគ្គលផ្តល់សេវាទូទាត់អំពីករណីបាត់បង់ ឬអំពីចោរកម្មលើឧបករណ៍/ មធ្យោបាយផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក ឬការលួចយកទិន្នន័យយកទៅប្រើប្រាស់ជាមួយឧបករណ៍ទូទាត់។ ការជូនដំណឹងនេះអាចធ្វើឡើងជាលាយលក្ខណ៍អក្សរឬ

តាមមធ្យោបាយអេឡិកត្រូនិកណាមួយដែរទទួលយកដោយបុគ្គលផ្តល់សេវាទូទាត់ ហើយជូនដំណឹងជាបន្ទាន់តាមលទ្ធភាពដែលអាចធ្វើទៅបាន ឬមិនអោយលើសរយៈពេល២(ពីរ)ថ្ងៃ បន្ទាប់ពីបានដឹងថាមានករណីចោរកម្ម ឬបាត់បង់ឧបករណ៍ទូទាត់កើតឡើង។

៣- ក្នុងករណីមានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថាមានការបាត់បង់ឬខូចខាត ក្នុងករណីខាងលើថាកំហុសអតិថិជន បុគ្គលផ្តល់សេវាទូទាត់មានសិទ្ធទាមទារអោយអតិថិជនទទួលខុសត្រូវទាំងស្រុងចំពោះការបាត់បង់ឬការខូចខាតនោះ។

៤- ក្នុងករណីមិនមានភស្តុតាងអំពីកំហុសរបស់អតិថិជនទេ បុគ្គលផ្តល់សេវាទូទាត់ត្រូវតែទួលខុសត្រូវទាំងស្រុងចំពោះការបាត់បង់ឬការខូចខាតនោះ ដោយឥតលក្ខខណ្ឌ។

### ២.១.៣ កិច្ចគ្រប់គ្រងលើកម្មសិទ្ធិបញ្ញា

កម្មសិទ្ធិបញ្ញា(Intellectual Property Rights) សំដៅទៅលើការបង្កើតគំនិតបញ្ញា ដូចជា គក្កកម្មស្នាដៃអក្សរសាស្ត្រ និងសិល្បៈ និមិត្តសញ្ញា រូបភាព និងគំនូដែលប្រើប្រាស់ក្នុងពាណិជ្ជកម្ម។ កម្មសិទ្ធិបញ្ញាត្រូវបានចែកចេញជា២ប្រភេទគឺ កម្មសិទ្ធិបញ្ញាឧស្សាហកម្ម សិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល។ ចំណែកឯសិទ្ធិអ្នកនិពន្ធ រួមមានស្នាដៃអក្សរសាស្ត្រ និងសិល្បៈទាំងឡាយដូចជារឿងប្រលោមលោក កំណាព្យ និងល្ខោន ជាពយន្តស្នាដៃតន្ត្រី គំនូរ រូបថត ចម្លាក់ និងស្ថាបត្យកម្មជាដើម។ សិទ្ធិប្រហាក់ប្រហែល គឺសំដៅលើសិទ្ធិរបស់អ្នកសម្តែងផលិតករហ្វូណូក្រាមនិងអង្គភាពទូរផ្សាយ។ ក្នុងនោះដែលសង្កេតឃើញថា កម្មសិទ្ធិបញ្ញាមានការគាំពារទៅលើម៉ាកហើយក្រសួងពាណិជ្ជកម្មគឺជាស្ថាប័នមានសមត្ថិច្ចក្នុងការធានាការចុះបញ្ជីម៉ាក។ ម៉ាក គឺជាសញ្ញាដែលមើលឃើញហើយអាចសំគាល់លក្ខណៈខុសគ្នានៃទំនិញ ឬសេវា នៃសហគ្រាសនីមួយៗ ដែលប្រើប្រាស់សំរាប់ទំនិញហៅថាពាណិជ្ជសញ្ញា ហើយម៉ាកដែលប្រើប្រាស់សំរាប់ សេវាហៅថា សេវាសញ្ញា។ ម៉ាកអាចមានលក្ខណៈជាពាក្យ អក្សររូបភាព រូបសញ្ញា(ឡូហ្គោ) និមិត្តសញ្ញា ពណ៌ បង្គុំនៃពណ៌ ឬបង្គុំសញ្ញាទាំងនេះ។ មិនមែនគ្រប់ម៉ាកទាំងអស់ សុទ្ធតែអាចចុះបញ្ជីដើម្បីទទួលបានកិច្ចការពារនោះទេ។ តាមមាត្រា៤នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ កំណត់ពីម៉ាកមួយចំនួនដែលមិនអាចចុះបញ្ជីបាន ដូចខាងក្រោម៖

ក. ម៉ាកដែលមិនអាចសម្គាល់លក្ខណៈខុសគ្នានៃទំនិញ ឬសេវា របស់សហគ្រាសមួយទៅនឹងសហគ្រាសមួយផ្សេងទៀត។

ខ. ម៉ាកដែលបណ្តាលឱ្យប៉ះពាល់សណ្តាប់ធ្នាប់សាធារណៈ សីលធម៌ ឬប្រពៃណីល្អរបស់ជាតិ

គ.ម៉ាកដែលនាំឱ្យសាធារណជន ឬមជ្ឈដ្ឋានពាណិជ្ជកម្មភាន់ច្រឡំទៅនឹងប្រភពភូមិសាស្ត្រទំនិញ ឬសេវាពាក់ព័ន្ធ ឬធាតុដើម ឬលក្ខណៈខាងក្រៅរបស់ទំនិញ ឬសេវានោះ។

ឃ. ម៉ាកដែលដូចគ្នា និងឬត្រាប់តាម ឬមានចំណុចណាមួយដូច សញ្ញាជាតិ ទង់ជាតិ និងនិមិត្តរូបផ្សេងៗ ឈ្មោះ ឬឈ្មោះសង្ខេប ឬអក្សរកាត់ ឬសញ្ញា ឬត្រាជាផ្លូវការ ដែលអនុម័ត ដោយរដ្ឋណាមួយ អង្គការអន្តររដ្ឋាភិបាល ឬអង្គការដែលបានបង្កើតដោយអនុសញ្ញាអន្តរជាតិណាមួយ លើកលែងតែមានការអនុញ្ញាត ពីអាជ្ញាធរមានសមត្ថកិច្ច នៃរដ្ឋនោះ ឬអង្គការនោះ។

ង. ម៉ាកដែលដូច ឬប្រហាក់ប្រហែលគ្នា ដែលនាំឱ្យច្រឡំនឹងម៉ាកពាណិជ្ជនាមមួយដែលល្បីក្នុងព្រះរាជាណាចក្រកម្ពុជា ឬបង្កើតការបកប្រែនៃម៉ាក ឬពាណិជ្ជនាមដែលល្បីនោះ សម្រាប់ទំនិញ ឬសេវាដូចគ្នា ឬប្រហាក់ប្រហែលគ្នានៃសហគ្រាសមួយទៀត។

ច. ម៉ាកដែលដូចគ្នា ឬប្រហាក់ប្រហែលគ្នាដែលនាំឱ្យច្រឡំ នឹងម៉ាក ឬពានិជ្ជនាមមួយដែលល្បី ឬការបង្កើតពីការបកប្រែនៃម៉ាក ឬពាណិជ្ជនាមដែលល្បីនោះ ហើយដែលបានចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា សម្រាប់ទំនិញ ឬសេវាដែលមិនដូចគ្នា ឬមិនប្រហាក់ប្រហែលគ្នា ដោយការប្រើប្រាស់ម៉ាកនោះ ធ្វើឱ្យប្រយោជន៍របស់ម្ចាស់ម៉ាកល្បី។

ឆ. ម៉ាកដែលដូច ឬស្ទើរតែដូចគ្នាទាំងស្រុងទៅនឹងម៉ាកដែលជាកម្មសិទ្ធិរបស់ម្ចាស់ផ្សេង ដែលបានចុះបញ្ជីរួចហើយ ឬបានដាក់ពាក្យស្នើសុំចុះបញ្ជីមុន ឬបានអាទិភាពចុះបញ្ជីមុន នៅឯបរទេស ចំពោះទំនិញ ឬសេវាដែលពាក់ព័ន្ធគ្នាយ៉ាងជិតស្និត។

ផ្អែកតាមការចុះផ្សាយរបស់គេហទំព័រ Ipleader Intelligent legal solution ដែលមានមូលដ្ឋាននៅប្រទេសឥណ្ឌាបានលើកឡើងថា សម្រាប់ក្របខណ្ឌនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក កម្មសិទ្ធិបញ្ញាអាចត្រូវបានការពារលើផ្នែកខ្លះនៃគេហទំព័រដែលដំណើរការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។ ការការពារប្រព័ន្ធអេឡិចត្រូនិកម៉ាស៊ីនស្វែងរកឬឧបករណ៍អ៊ិនធឺណិតបច្ចេកទេសផ្សេងទៀតត្រូវបានផ្តល់ការការពារក្រោមប៉ាតង់ឬគំរូឧបករណ៍ប្រើប្រាស់។ ការការពារលើ សូហ្វវែររួមបញ្ចូលកូដ HTML ដែលមានមូលដ្ឋានលើអត្ថបទដែលត្រូវបានប្រើនៅក្នុងគេហទំព័រ។ ការការពារលើ ការរចនាគេហទំព័រត្រូវបានការពារក្រោមការរក្សាសិទ្ធិ។ ការការពារលើ ខ្លឹមសារគេហទំព័រទាំងអស់ក្នុងទំរង់សម្ភារៈសរសេររូបថតក្រាហ្វិចតន្ត្រីនិងវីដេអូត្រូវបានការពារនៅក្រោមច្បាប់រក្សាសិទ្ធិ។ ការការពារលើ មូលដ្ឋានទិន្នន័យអេឡិចត្រូនិក។ ការការពារលើ ឈ្មោះពាណិជ្ជកម្មនិមិត្តសញ្ញាឈ្មោះផលិតផលឈ្មោះ

ដូមេន( Domain) និងសញ្ញាផ្សេងទៀតដែលបានបង្ហោះនៅលើគេហទំព័រត្រូវបានគ្របដណ្តប់ក្រោមស្លាកយីហោ។ ការការពារលើ ការបង្កើតនិមិត្តសញ្ញាក្រាហ្វិក ការការពារទិដ្ឋភាពដែលលាក់នៃគេហទំព័រ។ [54]

## ២.២ កិច្ចការពារអ្នកប្រើប្រាស់ និង ដំណោះស្រាយវិវាទ

ក្នុងការគ្រប់គ្រងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៃច្បាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកមិនត្រឹមតែសម្រប សម្រួលកិច្ចពាណិជ្ជកម្មប៉ុន្នោះទេ តែព្រមទាំងធានាបាននូវកិច្ចការពារជូនដល់បុគ្គលដែលប្រើប្រាស់វាផងដែរ។ បន្ថែមពីនេះ ច្បាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកក៏ជាគ្រឹះគោលមួយសម្រាប់ឱ្យភាគីក៏ដូចជាស្ថាប័នមានសមត្ថកិច្ចអាចពឹងផ្អែកក្នុងការ ស្វែងរកដំណោះស្រាយប្រកបយុត្តិធម៌ត្រឹមត្រូវមួយ។ កិច្ចការពារអ្នកប្រើប្រាស់អាចជួយអ្នកប្រើប្រាស់ពាណិជ្ជកម្មតាមប្រព័ន្ធអេ ឡិចត្រូនិក ពីការខាតបង់ផលប្រយោជន៍ មិនថាជាប្រាក់កាស ឬសុវត្ថិភាពឯកជនរបស់អ្នកប្រើប្រាស់។

### ២.២.១ កិច្ចការពារលើការផ្តល់ព័ត៌មាន

ការផ្សព្វផ្សាយទំនិញ ឬសេវាកម្មទៅកាន់អ្នកប្រើប្រាស់តាមរយៈប្រព័ន្ធអេឡិចត្រូនិក អាជីវករត្រូវផ្តល់ ព័ត៌មាន ច្បាស់លាស់ដើម្បីជាភាពងាយស្រួលជូនដល់អតិថិជន ដើម្បីឱ្យអតិថិជនអាចយល់ដឹងអំពីទំនិញ ឬសេវា កម្ម ហើយធ្វើការសម្រេចចិត្តតាមក្រោយ។ ចំពោះព័ត៌មានដែលអាជីវករត្រូវផ្តល់ទៅអោយអតិថិជនជាធម្មតាមានដូច ជាឈ្មោះ ទីតាំងនៃអាជីវកម្មស្របច្បាប់ដែលបានចុះបញ្ជីរួចព្រមទាំងនីតិវិធីក្នុងការទទួល-ប្រគល់ទំនិញ ឬសេវាកម្ម ក៏ដូចជាការទូទាត់ប្រាក់ជាដើម ហើយត្រូវមានមធ្យោបាយសម្រាប់ការទំនាក់ទំនងដែលអាចយកជាការបានរវាងអ្នក លក់ និងអ្នកទិញ។ មិនតែប៉ុណ្ណោះអាជីវករក៏ត្រូវបង្ហាញអតិថិជនអំពីការលុបការបញ្ជាទិញក្នុងករណីណាមួយជា ឧទាហរណ៍ អ្នកលក់មិនមានទំនិញនៅក្នុងស្តុកសម្រាប់អ្នករៀបចំដាក់ឱ្យអតិថិជន ឬខាងភាគីអតិថិជនប្តូរចិត្តមិន ទិញជាដើម នោះគឺសុទ្ធសឹងតែត្រូវបង្ហាញភ្ជាប់ជាមួយព័ត៌មានអំពីផលិតផល ឬសេវាជាក់លាក់ពិតប្រាកដ។ នេះបើ ផ្អែកតាមមាត្រា២៩ ព័ត៌មានអប្បបរមាក្នុងពាណិជ្ជកម្មអេឡិចត្រូនិក

១- បុគ្គលដែលប្រើប្រាស់ទំនាក់ទំនងតាមអេឡិចត្រូនិកដើម្បីលក់ទំនិញឬសេវាទៅឱ្យអ្នកប្រើប្រាស់ត្រូវផ្តល់ មានព័ត៌ត្រឹមត្រូវ ច្បាស់លាស់ និងងាយយល់បាន ហើយត្រូវមានព័ត៌មានយ៉ាងតិចដូចខាងក្រោម៖

- ក- ឈ្មោះឬនាមករណ៍ស្របច្បាប់របស់បុគ្គល អាសយដ្ឋានអាជីវកម្មដែលបានចុះបញ្ជីនិងមធ្យោបាយ អេឡិចត្រូនិកសម្រាប់ទំនាក់ទំនងឬលេខទូរសព្ទ។

---

[54] Ipleader Intelligent legal solution, https://bit.ly/3gSgwk7 , ចូលមើលថ្ងៃទី៥ ខែសីហា ឆ្នាំ២០២១

ខ- ទម្រង់ទំនាក់ទំនងដែលរហ័ស ងាយស្រួល និងមានប្រសិទ្ធភាពរវាងអ្នកប្រើប្រាស់ជាមួយអ្នកលក់។

គ- ខចែង លក្ខខណ្ឌ និងសោហ៊ុយរបស់ទំនិញឬសេវានានាដែលពាក់ព័ន្ធនឹងប្រតិបត្តិការពាណិជ្ជកម្មជាពិសេស ខចែង លក្ខខណ្ឌ និងមធ្យោបាយទូទាត់ប្រាក់ និងព័ត៌មានសម្ព័ពាក់ព័ន្ធនឹងការដកឬលុបចោលការបញ្ជាទិញ ការបញ្ឈប ការប្រគល់ និងការប្តូរទំនិញ និងការសងប្រាក់មកវិញ។ និង

ឃ- ទំនិញនិងសេវាជាក់ស្តែងដែលដាក់លក់។

២- ព័ត៌មានដែលមានចែងក្នុងបញ្ញត្តិនៃកថាខណ្ឌទី១ខាងលើ ចាំបាច់ត្រូវមានលក្ខណៈគ្រប់គ្រាន់ ដើម្បីឲ្យអ្នកប្រើប្រាស់អាចធ្វើការសម្រេចចិត្តលើប្រតិបត្តិការពាណិជ្ជកម្មនិងរក្សាទុកជាព័ត៌មាន។

៣- បញ្ញត្តិនៃមាត្រានេះមិនយកមកអនុវត្តចំពោះវិស័យមូលបត្រនិងធានារ៉ាប់រងឡើយ។

ចំពោះករណីដែលអាជីវករមិនអនុវត្តតាមបទបញ្ញតិស្តីពីព័ត៌មានអប្បបរមាក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក នោះនឹងត្រូវទទួលខុសត្រូវចំពោះមុខច្បាប់តាមរយៈមាត្រា៥៧នៃច្បាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវទទួលការព្រមានជាលាយលក្ខណ៍អក្សរ ចំពោះបុគ្គលណាដែលប្រព្រឹត្តអំពើផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី១ និងកថាខណ្ឌទី២នៃ២៩។ ក្នុងករណីទទួលរងការព្រមានជាលាយលក្ខណ៍អក្សរម្តងរួចហើយ នៅតែប្រព្រឹត្តល្មើសដូចមានចែងក្នុងកថាខណ្ឌទី១ ខាងលើនេះ ត្រូវព្យួរ ឬដកហូតអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតជាបុគ្គលផ្តល់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

បន្ថែមពីនេះប្រសិនបើអាជីវករប្រើប្រាស់វិធីសាស្ត្រផ្ញើទំនាក់ទំនងជាណិជ្ជកម្មដែលអតិជនមិនបានស្នើសុំដើម្បីឱ្យខ្លួនទទួលបានកំណើនការលក់ទំនិញ ឬសេវាកម្មរបស់ខ្លួននោះទំនាក់ទំនងពាណិជ្ជកម្មនោះត្រូវតែជាវិធីសាស្ត្រដ៏មានសុវត្ថិភាពសម្រាប់អតិថិជនរបស់ខ្លួន។ ទំនាក់ទំនងមិនបានស្នើសុំ (Spam or Unsolicited Massage) គឺការផ្ញើសារដែលចែកចាយព័ត៌មានជាសារទៅអ្នកប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិក បានយ៉ាងលឿនក្នុងរយៈពេលតែមួយដោយមិនចាំបាច់មានការយល់ព្រមពីទទួលអ្នកប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិក។[55] ចំពោះការប្រើប្រាស់ទំនាក់ទំនងមិនបានស្នើសុំនេះដែរ អាជីវករត្រូវបង្កើតព្រមមកជាមួយជម្រើសសម្រាប់ឱ្យអតិថិជនឬអ្នកប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិក អាចទទួលយក ឬបដិសេធមិនទទួលយកសារនោះបាន។ មាត្រា៣០នៃច្បាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ទំនាក់ទំនងពាណិជ្ជកម្មដែលមិនបានស្នើសុំ បុគ្គលណាក៏ដោយ ទោះបីជាមានទីតាំងអាជីវកម្មក្នុងឬ

[55]Ecommercenew, https://bit.ly/3DfcxaR ,ចូលមើលថ្ងៃ១០ ខែសីហា ឆ្នាំ២០២១

ក្រៅព្រះរាជាណាចក្រកម្ពុជាដែលផ្ញើរទំនាក់ទំនងពាណិជ្ជកម្មដែលមិនបានស្នើរសុំទៅកាន់អ្នកប្រើប្រាស់ដែលស្ថិតនៅក្នុងឬក្រៅព្រះរាជណាចក្រកម្ពុជា តាមរយៈប្រព័ន្ធផ្សព្វផ្សាយ ឬតាមរយៈអន្តរការី ឬអ្នកផ្តល់សេវាទូរគមនាគមន៍ត្រូវផ្តល់ជម្រើសច្បាស់លាស់និងាយស្រួលសម្រាប់ឲ្យអ្នកប្រើប្រាស់អាចធ្វើការបដិសេធមិនទទួលទំនាក់ទំនងពាណិជ្ជកម្មដែលមិនបានស្នើសុំនោះ។ តាមរយៈមាត្រា៥៨ នៃច្បាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកបានចែងថា អំពើល្មើសលើការផ្ញើទំនាក់ទំនងពាណិជ្ជកម្មដែលមិនបានស្នើសុំ ត្រូវទទួលការព្រមានជាលាយលក្ខណ៍អក្សរចំពោះបុគ្គលណាដែលប្រព្រឹត្តអំពើផ្ទុយ នឹងបញ្ញាត្តិនៃមាត្រា៣០។ ក្នុងករណីទទួលរងការព្រមានជាលាយលក្ខណ៍អក្សរម្តងរួចហើយ នៅតែបន្តប្រព្រឹត្តល្មើស ដូចមានចែងក្នុងកថាខណ្ឌទី១ ខាងលើ ត្រូវព្យួរ ឬដកហូតអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតជាអន្តរការី ឬបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រប័ន្ធអេឡិចត្រូនិក ឬបិទមិនឲ្យដំណើរការនូវប្រព័ន្ធផ្សព្វផ្សាយមធ្យោបាយអេឡិចត្រូនិករបស់អ្នកផ្ញើ។

លើសពីនេះទៅទៀតទាំងអាជីវករ បុគ្គលផ្តល់សេវាតាមប្រព័ន្ធអេឡិចត្រូនិក និងអតិថិជន មិនត្រូវប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិក ដើម្បីធ្វើឱ្យយល់ច្រលំហើយទាញយកផលប្រយោជន៍អំពីការយល់ច្រលំនោះឡើយ។ ផ្អែកតាមមាត្រា៣១ នៃច្បាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ការបង្កើតប្រព័ន្ធអេឡិចត្រូនិកក្លែងបន្លំនិងកូដព្យាបាទ

១- បុគ្គលទាំងឡាយមិនត្រូវបង្កើតប្រព័ន្ធអេឡិចត្រូនិក ក្នុងគោលបំណងក្លែងបន្លំឬបង្កការភាន់ច្រំឡំ ដើម្បីទាញយកផលប្រយោជន៍ ឬក្នុងគោលបំណងទាក់ទាញឲ្យមានការប្រើប្រាស់ឬធ្វើប្រតិបត្តិការ ហើយនាំឲ្យមានព្យសនកម្មដល់បុគ្គលដែលប្រើប្រាស់នោះឬតតិយជនឡើយ។

២- បុគ្គលទាំងឡាយមិនត្រូបង្កើត ផ្តល់ បង្កលទ្ធភាព ចែកចាយ ឬបញ្ជូននូវលេខកូដចម្លងមេរោគ ក្នុងគោលបំណងទុច្ចរិត តាមមធ្យោបាយអេឡិចត្រូនិក ទៅក្នុងឧបករណ៍ឬប្រព័ន្ធអេឡិចត្រូនិករបស់បុគ្គលផ្សេងទៀតឡើយ។

### ២.២.២ កិច្ចការពារទិន្នន័យអ្នកប្រើប្រាស់

ដូចដែលបានរៀបរាប់នៅក្នុងជំពូកទី១ ក្នុងកិច្ចពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកជាទូទៅតែងតែមានទំនាក់ទំនងអេឡិចត្រូនិករវាងភាគី អ្នកលក់ និងអ្នកទិញ ហើយចំពោះទំនាក់ទំនងនេះគឺប្រាកដជាមានព័ត៌មានសំខាន់ៗដែលត្រូវរក្សារទុកសម្រាប់ប្រើប្រាស់នៅពេលក្រោយ។ ហេតុដូចនេះបុគ្គលដែលជាអាជីវករដែលប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិកដើម្បីធ្វើជាមធ្យោបាយសម្រាប់អាជីវកម្មរបស់ខ្លួន ត្រូវធានាយ៉ាងណាថាប្រព័ន្ធអេឡិចត្រូនិកដែលខ្លួនប្រើប្រាស់នោះមានសុវត្ថិភាពចំពោះអតិថិជន ហើយចំពោះបុគ្គលដែលជាអ្នកទទួលខុសលើព័ត៌មានអ្នកប្រើប្រាស់

ប្រព័ន្ធអេឡិចត្រូនិក ដើម្បីទំនាក់ទំនងក៏មិនអាចឱ្យព័ត៌មាននោះលេចធ្លាយ ឬយកព័ត៌មានរបស់អ្នកប្រើប្រាស់ទៅផ្សព្វផ្សាយបានដែរ លុះត្រាម្ចាស់ដើមនៃព័ត៌មានអនុញ្ញាតទើបបាន។ ផ្អែកតាមមាត្រា៣២នៃច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ការការពារទិន្នន័យ

១- បុគ្គលដែលរក្សាព័ត៌មានជាលក្ខណៈឯកជនក្រោមទម្រង់អេឡិចត្រូនិក ត្រូវប្រើគ្រប់មធ្យោបាយដើម្បីធានាថា ព័ត៌មាននោះត្រូវបានការពារប្រកបដោយសុវត្ថិភាពគ្រប់កាលៈទេសៈសមហេតុផល ដើម្បីជៀសវាង ការបាត់បង់ លើកលែងតែមានការអនុញ្ញាតពីម្ចាស់នៃព័ត៌មាននោះឬពីភាគីផ្សេងទៀតដែលអនុញ្ញាដោយច្បាប់។

២- បុគ្គលទាំងឡាយមិនត្រូវជ្រៀតជ្រែកក្នុងប្រព័ន្ធអេឡិចត្រូនិក ចូលប្រើប្រាស់ ទាញយកថតចម្លង ស្រង់យក ធ្វើឱ្យបែកធ្លាយ លុបបំបាត់ ឬកែប្រែទិន្នន័យ ដែលស្ថិតក្រោមការរក្សាទុករបស់បុគ្គលផ្សេងទៀត ដោយទុច្ចរិត ឬគ្មានការអនុញ្ញាតឡើយ។

កិច្ចការពារចំពោះទិន្នន័យអ្នកប្រើប្រាស់មានសារៈសំខាន់សម្រាប់អតិថិជនដែលនិយមប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិក ដើម្បីបញ្ជារទិញទំនិញ ឬសេវាកម្ម ដោយហេតុថា ពេលខ្លះអាចមានបទល្មើសកើតមានឡើងតាមរយៈការចូលយកទិន្នន័យរបស់អាជីវករ ក៏ដូចជាអតិថិជនដើម្បីលុប ឬកែប្រែទិន្នន័យទាំងនោះជាដើម។ ចំពោះការគ្រប់គ្រងបទល្មើសដែលកើតមានពាក់ព័ន្ធនឹងកិច្ចការពារទិន្នន័យនឹងត្រូវអនុវត្តតាមមាត្រា៦០នៃច្បាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក អំពើល្មើសលើការមិនអនុវត្តកាតព្វកិច្ចកិច្ចការពារទិន្នន័យ

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំទៅ២(ពីរ)ឆ្នាំ និងត្រូវពិន័យជាប្រាក់ពី២ ០០០ ០០០(ពីរលាន)រៀលទៅ៤ ០០០ ០០០(បួនលាន)រៀល ចំពោះបុគ្គលដែលរក្សាព័ត៌មានជាលក្ខណៈឯកជនក្រោមទម្រង់អេឡិចត្រូនិក ដែលប្រព្រឹត្តអំពើផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី១នៃមាត្រា៣២។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំទៅ ២(ពីរ)ឆ្នាំ និងត្រូវពិន័យជាប្រាក់ពី ២ ០០០ ០០០(ពីរលាន)រៀលទៅ ៤ ០០០ ០០០(បួនលាន)រៀល ចំពោះបុគ្គលណាដែលប្រព្រឹត្តអំពើផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី២នៃមាត្រា៣២។

ចំណែកនៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជាមានចែងអំពី បទល្មើសក្នុងវិស័យព័ត៌មានវិទ្យាផងដែរ តាមរយៈមាត្រា៤២៧ បទចូលទៅដល់ ឬ ស្ថិតនៅនឹងប្រព័ន្ធប្រព្រឹត្តកម្មស្វ័យប្រវត្តនៃទិន្នន័យ

អំពើចូលទៅដល់ ឬស្ថិតនៅនឹងប្រព័ន្ធអេឡិចត្រូនិក ស្វ័យប្រព្រឹត្តកម្មស្វ័យប្រវត្តនៃទិន្នន័យ ដោយទុច្ចរិត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១ (មួយ)ខែ ទៅ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០ ០០០(មួយសែន)រៀល ទៅ ២ ០០០ ០០០ (ពីរលាន) រៀល។

កាលបើអំពើនោះជាហេតុបណ្តាលឱ្យមានការលុបបំបាត់ ឬកែប្រែទិន្នន័យ ដែលមាននៅក្នុងប្រព័ន្ធ ឬ ឱ្យមានការខូចខាតនូវដំណើរការនៃប្រព័ន្ធ បទល្មើសនេះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១ (មួយ) ឆ្នាំ ទៅ២ (ពីរ)ឆ្នាំ និងពិន័យជាប្រាក់ពី២ ០០០ ០០០ (ពីរលាន) រៀល ទៅ ៤ ០០០ ០០០ (បួនលាន) រៀល។

ប្រសិនបើទិន្និន័យត្រូវបានលួចចូលហើយថែមទាំងមានការលុប ឬ កែប្រែដោយទុច្ចរិតនោះនាំឱ្យជនល្មើសផ្នែកបច្ចេកវិទ្យាក៏ត្រូវទទួលខុសត្រូវបទមជ្ឈិមចំពោះបទល្មើសដែលបានកើតឡើងតាមប្រព័ន្ធអេឡិត្រូនិក នេះដោយផ្អែកតាមមាត្រា ៤២៩ នៃក្រមព្រហ្មទណ្ឌ បទបញ្ចូល លុបបំបាត់ ឬកែប្រែដោយទុច្ចរិតនូវទិន្នន័យ អំពើបញ្ចូល លុបបំបាត់ ឬកែប្រែដោយទុច្ចរិតនូវទិន្នន័យទៅក្នុងប្រព័ន្ធប្រព្រឹត្តិកម្មស្វ័យប្រវត្តិ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ២(ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ២ ០០០ ០០០ (ពីរលាន) រៀល ទៅ ៤ ០០០ ០០០ (បួនលាន) រៀល។

### ២.២.៤ ការដោះស្រាយវិវាទ

សម្រាប់កិច្ចពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកអាចប្រព្រឹត្តិទៅនៅក្នុងព្រះរាជាណាចក្រកម្ពុជាយ៉ាងស្របច្បាប់ ក៏ប៉ុន្តែនៅពេលដែលមានបញ្ហាពាណិជ្ជករត្រូវពិចារណាជាបឋមថាតើ ត្រូវទៅរកស្ថាប័នណាដែលមានសមត្ថកិច្ចក្នុងការប្តឹងតវ៉ា ហើយត្រូវតវ៉ាដូចម្តេចក្នុងករណីមិនសុខចិត្តចំពោះសេចក្តីសម្រេចរបស់សមត្ថកិច្ច។ ចំពោះទោសប្បញ្ញត្តិដែលមានក្នុងច្បាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកកម្ពុជា រួមមាន ការព្រមានជាលាយលក្ខណ៍អក្សរ ការបញ្ឈប់សកម្មភាពឬប្រតិបត្តិការអាជីវកម្ម ការព្យួរ ការដកហូត ឬការលុបចោលលិខិតអនុញ្ញាតឬអាជ្ញាបណ្ណ ការផាកពិន័យដាក់ទោសពន្ធនាគារ និងទោសពិន័យជាប្រាក់។[56] រីឯស្ថាប័នមានសមត្ថកិច្ចគ្រប់គ្រងលើសកម្មភាពពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកក្នុងករណីដែលពាណិជ្ជករបានប្រព្រឹត្តិអំពើល្មើស នឹងច្បាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក គឺ ក្រសួងពាណិជ្ជកម្ម និងក្រសួងប្រៃសណីយ និងទូរគមនាគមន៍។ យោងតាមមាត្រា៤៩ នៃច្បាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកកម្ពុជា សមត្ថកិច្ច ការព្រមានជាលាយលក្ខណ៍អក្សរ ការបញ្ចប់សកម្មភាពឬប្រតិបត្តិការអារជីវកម្ម ការព្យួរការដកហូត ឬលុបចោលលិខិតអនុញ្ញាតឬអាជ្ញាបណ្ណ និងការផាកពិន័យ ជាសមត្ថ

[56] មាត្រា៥២ នៃច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកព្រះរាជាណាចក្រកម្ពុជា ខែវិច្ឆិកា ឆ្នាំ២០១៩

កិច្ចរបស់ក្រសួងពានិជ្ជកម្មនិងក្រសួងប្រៃសណីយនិងទូរគមន៍។ ក្នុងករណីដែរបុគ្គលមិនអនុវត្តតាមវិធានការខាងលើ ក្រសួងពាណិជ្ជកម្ម និងក្រសួងប្រៃសណីយនិងទូរគមនាគមន៍ អាចធ្វើបណ្តឹងទៅតុលាការមានសមត្ថកិច្ច។ បន្ថែមពីនេះនៅក្នុងច្បាប់ ក៏បានបញ្ជាក់អំពីនីតិវិធីនៃការប្តឹងតវ៉ាក្នុងករណីបុគ្គលដែលជាប់ទាក់ទងកិច្ចពាណិជ្ជកម្មអេឡិចត្រូនិកបានផងដែរ ដោយផ្អែកតាមមាត្រា៥០នៃច្បាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកកម្ពុជា នីតិវិធីនៃការប្តឹងតវ៉ា

១- បុគ្គលដែលមិនសុខចិត្តនឹងការព្រមានជាលាយលក្ខណ៍អក្សរ ការបញ្ឈប់សកម្មភាពឬប្រតិបត្តិការអាជីវកម្ម ការព្យួរ ការដកហូត ឬការលុបចោលលិខិតអនុញ្ញាតឬអាជ្ញាបណ្ណ និងការផាកពិន័យរបស់ក្រសួងពាណិជ្ជកម្ម និងក្រសួងប្រៃសណីនិងទូរគមនាគមន៍ មាសិទ្ធិប្តឹងតវ៉ាទៅរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងក្រសួងប្រៃសណីយនិងទូរគនាគមន៍។

២- រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងក្រសួងប្រៃសណីយនិងទូរគមនាគមន៍ ត្រូវសម្រេចក្នុងរយៈពេល៣០(សាមសិប)ថ្ងៃយ៉ាងយូរ។

៣- បុគ្គលណាដែលមិនសុខចិត្ត និងសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មនិងក្រសួងប្រៃសណីយនិងទូរគមនាគមន៍ មានសិទ្ធិប្តឹងទៅតុលាការមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជាបានក្នុងរយៈពេល៣០(សាមសិប)ថ្ងៃយ៉ាងយូរ គិតចាប់ពីថ្ងៃទទួលបានសេចក្តីជូនដំណឹងនៃសេចក្តីសម្រេចនោះ។

មាត្រា៥១នៃច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកព្រះរាជាណាចក្រកម្ពុជា នីតិវិធីនៃការផាកពិន័យ ការបង់ប្រាក់ផាកពិន័យ ការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់ពិន័យ និងការចាត់ចែងប្រាក់ចំណូលដែលបានមកពីការផាកពិន័យវិញគឺត្រូវស្របតាមប្រកាសអន្តរក្រសួង រវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងរដ្ឋមន្ត្រីក្រសួងប្រៃសណីយនិងទូរគមនាគមន៍។

ជាការពិត កិច្ចពាណិជ្ជកម្មប្រភេទណាក៏ដូចប្រភេទមួយណាដែរ ពោលគឺប្រាកដជាគេមិនផុតអំពីការកើតមាននូវទំនាស់ក៏ដូចជាវិវាទដែរ។ ចំណែកចំពោះពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកវិញក៏ដូចគ្នា ហើយជាមួយគ្នានេះដែរនៅពេលដែលមានវិវាទកើតមានឡើងរវាងពាណិជ្ជករ និងអតិថិជនដែលជាអ្នកប្រើប្រាស់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក នោះ។ ត្បិតតែនៅក្នុងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកកម្ពុជាឆ្នាំ២០១៩មិនមានចែងអំពីករណីដោះស្រាយវិវាទ ក៏គេអាចក្រលេកមកមើលក្នុងអនុសាសន៍លើកិច្ចការពារអ្នកប្រើប្រាស់របស់ OECD (Consumer Protection in E-commerce OECD Recommendation) ត្រង់ចំនុចF ដែលលើកឡើងថា អ្នកប្រើ

ប្រាស់គួរតែត្រូវបានផ្តល់ឱ្យនូវការទទួលបាននូវយន្តការប្រកបដោយយុត្តិធម៌ងាយស្រួលប្រើប្រាស់តម្លាភាពនិងប្រសិទ្ធភាពដើម្បីដោះស្រាយវិវាទពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកក្នុងស្រុកនិងឆ្លងដែនឱ្យបានទាន់ពេលវេលា និងទទួលបានការដោះស្រាយតាមការសមរម្យដោយមិនចាំបាច់ចំណាយឬបន្ទុកដែលមិនចាំបាច់ ។ ទាំងនេះគួរតែរួមបញ្ចូលយន្តការក្រៅប្រព័ន្ធដូចជាការដោះស្រាយបណ្តឹងផ្ទៃក្នុង និងការដោះស្រាយវិវាទហើយ ការប្រើយន្តការក្រៅតុលាការបែបនេះ មិនគួររារាំងអ្នកប្រើប្រាស់ពីការស្វែងរកវិធីដោះស្រាយផ្សេងៗទៀតឡើយ។ ក្នុងអនុសាសន៍ណែនាំរបស់ OECD ក៏បានចែងអំពីយន្តការសម្រាប់ដោះស្រាយវិវាទនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកដូចជា យន្តការដោះស្រាយវិវាទផ្ទៃក្នុង(Internal Complaints Handling) យន្តការដោះស្រាយវិវាទចម្រុះ(Alternative Dispute resolution) និងយន្តការសំណង(Redress)។

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានឆ្លងកាត់តាមរយៈការបកស្រាយប្រធានបទស្តីអំពីពាណិជ្ជកម្មអេឡិចត្រូនិកក្នុងក្របខណ្ឌច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកកម្ពុជា រួចមកគឺ រាល់ចំណុចនីមួយៗនៃប្រធានមានលក្ខណៈពិសេសរៀងៗខ្លួនដែលចាំបាច់ត្រូវសិក្សាឱ្យបានគត់មត់ ដោយហេតុថារលកនៃសកម្មភាពពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកអាចនឹងងាយយល់ ងាយអនុវត្ត ក៏ប៉ុន្តែកម្រិតច្បាប់ដែលជាធាតុសំខាន់ក្នុងការធានារាល់សកម្មភាពពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកអាចមិននឹងមិនមានភាពងាយស្រួលយល់ឡើយ។ ចំពោះគ្រប់ចំណុចនៃប្រធានបទនេះទៀតសោតអាចចូលរួមចំណែកយ៉ាងសំខាន់ក្នុង កិច្ចពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិករបស់ប្រជាជនកម្ពុជាដែលជាប្រភេទអាជីវកម្មដែលកំពុមមានសន្ទុះគួរឱ្យកត់សម្គាល់ និងដែលមានការពេញនិយមជាខ្លាំងពីសំណាក់អ្នកប្រើប្រាស់។ ជាមួយការសិក្សាលើប្រធានបទទាក់ទងនឹងច្បាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនេះផងដែរ សង្កេតឃើញថា មានចំណុចតូចៗជាច្រើនរួមផ្សំផ្គុំគ្នារហូតបានចំណុចជារួមពីរគឺ ទីមួយទាក់ទងនឹងដំណើរវិវត្តនៃច្បាប់ស្តីពីពាណិជ្ជកម្មអេឡិចត្រូនិកកម្ពុជា និងទីពីរពាក់ព័ន្ធជាមួយតួនាទីច្បាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកក្នុងអាជីវកម្ម។

ដូចដែលបានបង្ហាញក្នុងខ្លឹមសារខាងលើ ជំពូកដែលនិយាយពី ដំណើរវិវត្តនៃច្បាប់ពាណិជ្ជកម្មអេឡិចត្រូនិកបញ្ជាក់ថា ច្បាប់ស្តីពីពាណិជ្ជកម្មអេឡិចត្រូនិកមានធាតុចូលសំខាន់ៗជាច្រើនក្នុងនោះគឺ ក្របខណ្ឌគតិយុត្តមានប្រភពមកពី អង្គការសហប្រជាជាតិ និងអាស៊ានដែលជាគំរូសម្រាប់បង្កើតជាច្បាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកមួយដែលមានស្តង់ដារខ្ពស់ ព្រមទាំងមានវិសាលភាពនៃការអនុវត្តបានទូលំទូលាយ។ បន្ថែមពីនេះនៅមានគោលនយោបាយក៏ដូចជាយុទ្ធសាស្ត្រជារួមផ្សំសម្រាប់ទ្រទ្រង់ដល់ការអនុវត្តពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកហើយជាពិសេសនោះគឺយុទ្ធពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកដែលត្រូវបានបង្កើតឡើងដើម្បីធានាសកម្មភាពពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកឱ្យកាន់តែផុសផុល និងស្របតាមក្របខណ្ឌច្បាប់នៅកម្ពុជា។ ម្យ៉ាងវិញទៀតជំពូកនេះក៏បានបង្ហាញពីវិសាលភាពនៃច្បាប់ច្បាប់ស្តីពីពាណិជ្ជកម្មអេឡិចត្រូនិកកម្ពុជាដែលគ្រប់គ្រងលើ តួនាទីនៃរាជរដ្ឋាភិបាលក្នុងកិច្ចសម្របសម្រួលពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ព្រមទាំងសកម្មភាពពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកមិនថាទំនាក់ទំនងអេឡិចត្រូនិក ឬ ភស្តុតាងសម្រាប់អះអាងចំពោះទំនាក់ទំនងនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។ ចំណែកនៅក្នុងជំពូកទីពីរវិញមានបង្ហាញឱ្យឃើញពីតួនាទីនៃច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកកម្ពុជាកិច្ចគ្រប់គ្រងលើកិច្ចប្រតិបត្តិការអាជីវកម្ម ដែលក្នុងនោះមានដូចជាការគ្រប់គ្រងលើប្រតិបត្តិករ ការទូទាត់ប្រាក់តាម

ប្រព័ន្ធអេឡិចត្រូនិក ព្រមទាំងកិច្ចការពារអ្នកប្រើប្រាស់ និងដំណោះស្រាយនានាសម្រាប់បម្រើដល់ផលប្រយោជន៍គូភាគីនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

ហេតុដូចនេះជាសេចក្ដីសន្និដ្ឋានសម្រាប់ ពាណិជ្ជកម្មក្រោមក្របខណ្ឌនៃច្បាប់ស្ដីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកបានចងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិត្រូនិកភ្ជាប់ទៅនឹងច្បាប់ដែលការណ៍នេះបង្កជាភាពងាយស្រួលសម្រាប់ការប្រកបរបរលើវិស័យពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកប្រកបដោយសុវត្ថិភាព។ ត្បិតតែតួនាទីរបស់ច្បាប់ពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកបានចូលរួមចំណែកជាច្រើន ធ្វើឱ្យប្រជាពលរដ្ឋដែលជាអ្នកប្រើប្រាស់ទទួលបាននូវភាពកក់ក្ដៅដោយថាច្បាប់នេះបានយកចិត្តទុកដាក់លើកិច្ចការពារចំពោះអ្នកប្រើប្រាស់ ផងដែរនោះវាបានសង្កត់ធ្ងន់ទៅលើពាណិជ្ជករដែលជាប្រតិបត្តិករពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ហើយនេះវាបានជាការប្រុងប្រយ័ត្នមួយដែលពាណិជ្ជករត្រូវល្បិតល្បន់ឱ្យមែនទែនចៀសវាងការខាតបង់នាពេលអនាគត។

# អនុសាសន៍

ដោយផ្អែកទៅតាមការសិក្សាស្រាវជ្រាវចំពោះប្រធានខាងលើនេះ ក៏ដូចជាភ្ជាប់ជាមួយសេចក្តីសន្និដ្ឋាន ឃើញថាពាណិជ្ជកម្មអេឡិចត្រូនិកក្រោមក្របខណ្ឌច្បាប់ពាណិជ្ជកម្មអេឡិចត្រូនិកកម្ពុជាពិតជាមានសារៈសំខាន់ ព្រមទាំងគុណតម្លៃសម្រាប់ប្រជាជនកម្ពុជាគ្រប់រូប ជាងនេះទៅទៀត ចំពោះច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកកម្ពុជាមានអត្ថប្រយោជន៍ជាច្រើនដល់ប្រជាពលរដ្ឋកម្ពុជាមិនថាពេលបច្ចុប្បន្ន និងពេលអនាគតដោយហេតុថាច្បាប់នេះមានលក្ខណៈរស់ដែលអនុវត្តបានក្នុងរយៈពេលយូរអង្វែងថ្វីបើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកត្រូវបានគេធ្វើបច្ចុប្បន្នភាពក៏ដោយ។ ក្រៅពីអត្ថប្រយោជន៍ដ៏សម្បើមនៃច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកកម្ពុជា ច្បាប់នេះក៏នូវមានចំណុចខ្វះខាតមួយចំនួនដែលត្រូវបំពេញដើម្បីធានាផលប្រយោជន៍ជូនចំពោះប្រជាពលរដ្ឋឱ្យបានជាអតិបរមា ។ អាស្រ័យហេតុនេះនាងខ្ញុំក្នុងនាមជានិស្សិតហើយក៏ជាពលរដ្ឋសាមញ្ញម្នាក់ មានជាគំនិតយោបល់មួយចំនួនកើតចេញពីចំណេះដឹងដែលបានសិក្សារៀនសូត្រកន្លងមកបន្តិចបន្តួច ប៉ុន្តែប្រកបដោយក្តីសង្ឃឹមថា នឹងអាចចូលរួមចំណែកលម្អការអភិវឌ្ឍន៍ក្នុងសង្គមកម្ពុជា ក្នុងបេសកកម្មចាប់យកកាលានុវត្តភាពនៃបដិវត្តឧស្សាហកម្ម៤.០ឱ្យខាងតែបាន ជូនចំពោះអ្នកជំនាញផ្នែកច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ធុរជនផ្នែកពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងប្រជាពលរដ្ឋកម្ពុជា ដូចតទៅនេះ៖

- **អ្នកជំនាញផ្នែកច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក** ៖ ច្បាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកមានចំណុចខ្វះខាតចំនួនពីរគឺ
  - ចំណុចចការគ្រប់គ្រងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក លើផ្នែកកម្មសិទ្ធិបញ្ញារបស់អ្នកអន្តរការី និងបុគ្គលផ្តល់សេវា
  - ចំណុចការផ្តល់ទំនុកចិត្តដល់សាធារណៈជន លើកង្វះខាតនៃយន្តការដោះស្រាយវិវាទក្នុងករណីអ្នកប្រើប្រាស់មានវិវាទជាមួយប្រតិបត្តិករ។
- **ធុរជនផ្នែកពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក**
  - គួរសិក្សាលើភាពខ្វះចន្លោះនៃច្បាប់ពាណិជ្ជកម្មអេឡិចត្រូនិកដើម្បីបង្ការភាពខាតបង់
  - គួរលើកជាដំណឹងជូនដល់រាជរដ្ឋាភិបាលក្នុងករណីមានការធ្វើបច្ចុប្បន្នភាពថ្មីៗនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកក្នុងវិស័យឯកជន។
- **ប្រជាពលរដ្ឋកម្ពុជា**

- គួរសិក្សាស្វែងយល់អំពីច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកកម្ពុជាក៏ដូចជាច្បាប់ផ្សេងៗ ឱ្យកាន់តែច្រើនដើម្បីការពារខ្លួនអំពីការខាតបង់ដោយសារមិនដឹងអំពីច្បាប់
- គួរតាមដានអំពីការវិវត្តនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅក្នុងប្រទេស តំបន់ និងអន្តរជាតិ
- គួរចូលរួមលើកកម្ពស់ និងអនុវត្តច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកកម្ពុជាជាអតិបរមា។

# ឯកសារយោង

## ១-លិខិតបទដ្ឋានគតិយុត្តជាតិ

### ក-លិខិតបទដ្ឋានគតិយុត្តជាតិ

- **ច្បាប់**

– ច្បាប់រដ្ឋធម្មនុញ្ញ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣

– ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១០

– ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧

– ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃ០២ខែវិច្ឆិកា ឆ្នាំ២០១៩

– ច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០២

- **អនុក្រឹត្យ**

– អនុក្រឹត្យលេខ ២៤៦ អនក្រ.បក ស្តីពីហត្ថលេខាឌីជីថល ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៧

– អនុក្រឹត្យលេខ ១៣៤ អនក្រ.បក ស្តីពី ការកំណត់ប្រភេទ បែបបទ និងនីតិវិធីនៃការផ្តល់លិខិតអនុញ្ញាឬអាជ្ញាបណ្ណដល់អន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជតាមប្រព័ន្ធអេឡិចត្រូនិក និងការលើកលែង ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២០

– អនុក្រឹត្យលេខ ៦៥ អនក្រ.បក ស្តីពីការអនុវត្តអាករលើតម្លៃបន្ថែមចំពោះពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២១។

- **ប្រកាស**

– ប្រកាសលេខ២៩០ ព.ណចបព.ប្រក ស្តីពី ការផ្តល់លិខិតអនុញ្ញាត ឬអាជ្ញាបណ្ណពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០២០។

- **សេចក្តីជូនដំណឹង**

– សេចក្តីជូនដំណឹងលេខ ១១៤៣ ព.ណ ចបព ស្តីពី ការផ្តល់លិខិតអញ្ញាត ឬអាជ្ញាបណ្ណពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២១។

### ខ-លិខិតបទដ្ឋានអន្តរជាតិ

- **ក្របខណ្ឌអង្គការសហប្រជាជាតិ**
  - UNCITRAL Model Law on Electronic Commerce with guide to enactment1996 with additional article5 bis as adopted in1998, United Nation 1999: https://bit.ly/3jokbI5
  - UNICITRAL Model law on Electronic Signatures with Guide to enactment, United Nation, Vienna, Austria, 2001: https://bit.ly/3ktKnzY
  - UNCITRAL Model Law on Electronic Transferable Records, United Nations, Vienna, Austria, 2017: https://bit.ly/3yfVktX
- **ក្របខណ្ឌអាស៊ាន**
  - ASEAN Agreement on Electronic Commerce 22nd January 2018

## ២-សៀវភៅ

### ក-សៀវភៅជាតិ

- ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ, ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថល ខែឧសភា ឆ្នាំ២០២១
- ក្រសួងពាណិជ្ជកម្ម, យុទ្ធសាស្រ្តពាណិជ្ជកម្ម តាមប្រព័ន្ធអេឡិចត្រូនិក, ខែវិច្ឆិកា ២០២០
- ក្រសួងពាណិជ្ជកម្ម របាយការណ៍ បូកសរុបលទ្ធផលការងារពាណិជ្ជកម្ម ឆ្នាំ២០២០ និងទិសដៅការងារពាណិជ្ជកម្ម ឆ្នាំ២០២០, ខែមីនា ឆ្នាំ២០២១

### ខ-សៀវភៅអន្តរជាតិ

- Joanna Kulesza, International Internet Law*: Routledge Research in IT and E-Commerce Law*, Translated by Magdalena Arent and WojciechWołoszyk, Routledge, 2012
- John A. Rothchild, Associate professor of law, Wayne State University Law School, USA, *Research hand book on Electronic commercial law*, Edward Elgar Publishing Limited, 2016

- Konrad Adenauer Stiftung, Digital Insight: E-Governence in Cambodia, Edited by Christopher Perera, Robert Hor,2019

## ៣-ឯកសារជំនួយស្មារតី

### ក-ឯកសារជំនួយស្មារតីជាតិ

- បណ្ឌិត មាស បូរ៉ា និងលោក រដ្ឋា ពិសិដ្ឋ ៖ កម្រិតភស្តុតាង និងបន្ទុកនៃភស្តុតាង ក្នុងរឿងព្រហ្មទណ្ឌ នៅក្នុងការផ្សព្វផ្សាយរបស់សមាគមត្រាជូ ខែកក្កដា ឆ្នាំ ២០១៨
- គង់ រតនធីតា, ស្វែងយល់ពីសេដ្ឋកិច្ចឌីជីថល, មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ ២០១៩។

### ខ-ឯកសារជំនួយស្មារតីអន្តរជាតិ

- United Nations conference on Trade and Development, UNCTAD: Cambodia Rapid Trade Readiness Assessment, United Nation, New York and Geneva, 2017
- United Nation, ETrade for all Connecting Dots: Covid-19 and E-Commerce: Global Review, 2021
- Zhen Qin, Introduction to E-Commerce, Springer-Verlag Berlin Heidelberg, Tsinghua University Press, 2009
- World Bank, *Benefiting from the digital economy*, Cambodia Policy Note, July 2018
- Hyuksoo Cho Patriya Tansuha, Electronic intermediaries: research and practice of electronic intermediaries in export marketing, 2021

## ៤, គេហទំព័រ

### ក-គេហទំព័រជាតិ

- ក្រសួងពាណិជ្ជកម្ម : www.moc.gov.kh
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍: https://www.mptc.gov.kh/

- ការិយាល័យឆ្លើយតបបន្ទាន់នៃកុំព្យូទ័រ (CamCERT) នៃនាយកដ្ឋានសន្តិសុខបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាននៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍: https://www.camcert.gov.kh/
- ធនាគារជាតិនៃកម្ពុជា: https://www.nbc.org.kh/
- កាសែត Khmer times: https://www.khmertimeskh.com/

**ខ-គេហទំព័រអន្តរជាតិ**

- OECDilibrary: https://www.oecd-ilibrary.org/
- Statista: https://www.statista.com/
- UNCITRAL: https://uncitral.un.org/
- Geospatial World: https://www.geospatialworld.net/
- E-Governement Knowledgebase : https://publicadministration.un.org/egovkb/en-us/about/unegovdd-framework
- SecurionPay: https://securionpay.com/
- GoCardless: https://gocardless.com/
- Ipleader Intelligent legal solution: https://blog.ipleaders.in/
- Ecommercenew: https://ecommercenews.eu/

# បញ្ជីឧបសម្ព័ន្ធ

**ឧបសម្ព័ន្ធទី១៖** ASEAN Agreement on Electronic Commerce , 22nd January 2019

**ឧបសម្ព័ន្ធទី២៖** ច្បាប់ស្ដីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ ២០១៩

**ឧបសម្ព័ន្ធទី៣៖** អនុក្រឹត្យលេខ ២៤៦ អនក្រ.បក ស្ដីពីហត្ថលេខាឌីជីថល ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៧

**ឧបសម្ព័ន្ធទី៤៖** អនុក្រឹត្យលេខ ១៣៤ អនក្រ.បក ស្ដីពី ការកំណត់ប្រភេទ បែបបទ និងនីតិវិធីនៃការផ្ដល់លិខិតអនុញ្ញាឬអាជ្ញាបណ្ណដល់អន្តរការីនិងបុគ្គលផ្ដល់សេវាពាណិជ្ជតាមប្រព័ន្ធអេឡិចត្រូនិក និងការលើកលែង ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២០

**ឧបសម្ព័ន្ធទី៥៖** អនុក្រឹត្យលេខ ៦៥ អនក្រ.បក ស្ដីពីការអនុវត្តអាករលើតម្លៃបន្ថែមចំពោះពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២១

**ឧបសម្ព័ន្ធទី៦៖** ប្រកាសលេខ២៩០ ព.ណចបព.ប្រក ស្ដីពី ការផ្ដល់លិខិតអនុញ្ញាត ឬអាជ្ញាបណ្ណពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០២០។

# ឧបសម្ព័ន្ធទី១

ASEAN Agreement on Electronic Commerce, 22nd January 2019

# ASEAN AGREEMENT ON ELECTRONIC COMMERCE

The Governments of Brunei Darussalam, the Kingdom of Cambodia, the Republic of Indonesia, the Lao People's Democratic Republic, Malaysia, the Republic of the Union of Myanmar, the Republic of the Philippines, the Republic of Singapore, the Kingdom of Thailand, and the Socialist Republic of Viet Nam, Member States of the Association of Southeast Asian Nations (ASEAN) (hereinafter collectively referred to as "Member States" or individually as "Member State");

**RECOGNISING** the role of electronic commerce (e-commerce) in driving economic growth and social development in the ASEAN region;

**VALUING** the contribution of e-commerce in enhancing connectivity and sectoral cooperation in the ASEAN region as embodied in the ASEAN Economic Community (AEC) Blueprint 2025 as adopted on 22 November 2015;

**BUILDING** upon Article 5 (Facilitation of the Growth of Electronic Commerce) of the *e-ASEAN Framework Agreement* signed by ASEAN Leaders on 24 November 2000 in Singapore;

**ACKNOWLEDGING** the important contribution of e-commerce in facilitating cross-border trade and investment, and in significantly lowering the barriers to entry and operating costs for businesses, particularly Micro, Small and Medium Enterprises;

**EMPHASISING** the importance of coordination and cooperation among Member States to advance the

development and use of e-commerce in the ASEAN region; and

**RECOGNISING** the need to facilitate cross-border e-commerce transactions in the ASEAN region to maximise the benefits of regional economic integration,

**HAVE AGREED AS FOLLOWS:**

## ARTICLE 1
## DEFINITIONS

For the purposes of this Agreement:

(a) **ATISA** means the *ASEAN Trade in Services Agreement*;

(b) **Computing facilities** means computer servers and storage devices for processing or storing information for commercial use;

(c) **Electronic authentication** means the process of testing an electronic statement or claim in order to establish a level of confidence in the reliability of that statement or claim;

(d) **Electronic signature** has for each Member State the meaning set out in its laws and regulations;

(e) **GATS** means the *General Agreement on Trade in Services*;

(f) **Juridical person** means any legal entity duly constituted or otherwise organised under applicable law of a Member State, whether for profit or otherwise, and whether privately-owned or governmentally-owned, including any corporation,

trust, partnership, joint venture, sole proprietorship or association;

(g) **Juridical person of another Member State** means a juridical person which is either:

(i) constituted or otherwise organised under the law of that other Member State, and is engaged in substantive business operations in the territory of that Member State or any other Member State; or

(ii) in the case of the supply of a service through commercial presence, owned or controlled by:

(1) natural persons of that Member State; or

(2) juridical persons of that other Member State identified under subparagraph (i);

(h) A juridical person is:

(i) **owned** by persons of a Member State if more than 50 per cent of the equity interest in it is beneficially owned by persons of that Member State;

(ii) **controlled** by persons of a Member State if such persons have the power to name a majority of its directors or otherwise to legally direct its actions;

(iii) **affiliated** with another person when it controls, or is controlled by, that other person; or when it and the other person are both controlled by the same person;

(i) **Natural person of another Member State** means a natural person who under the law of that Member State:

(i) is a national or citizen of that Member State; or

(ii) has the right of permanent residence in that Member State, where both that Member State and the Member State in which the person supplies services recognise permanent residents and accord substantially the same treatment to their respective permanent residents as they accord to their respective nationals in respect of measures affecting trade in services;

(j) **Personal information** means any information, including data, about an identified or identifiable individual; and

(k) **Trade administration documents** means forms issued or controlled by a Member State which must be completed by or for an importer or exporter in relation to the import or export of goods.

## ARTICLE 2
## OBJECTIVES

The objectives of this Agreement are to:

(a) facilitate cross-border e-commerce transactions in the ASEAN region;

(b) contribute to creating an environment of trust and confidence in the use of e-commerce in the ASEAN region; and

(c) deepen cooperation among Member States to further develop and intensify the use of e-commerce

to drive inclusive growth and narrow development gaps in the ASEAN region.

## ARTICLE 3
## SCOPE

1. This Agreement shall apply to measures adopted or maintained by a Member State that affect e-commerce.

2. This Agreement shall not apply to government procurement.

## ARTICLE 4
## RELATION TO OTHER AGREEMENTS

1. Nothing in this Agreement shall derogate from the existing rights and obligations of a Member State under any other relevant ASEAN agreements[1] to which it is a party.

2. In the event of any inconsistency between this Agreement and any other relevant ASEAN agreement, that ASEAN agreement shall prevail to the extent of the inconsistency.

## ARTICLE 5
## PRINCIPLES

1. In the development and promotion of e-commerce, the role of each Member State shall be geared towards providing an enabling legal and regulatory environment, providing a conducive and competitive business environment, and protecting the public interest.

2. The legal and regulatory frameworks in each Member State to support e-commerce shall take into account internationally adopted model laws, conventions, principles or guidelines.

---

[1] The ATISA shall be deemed to be a relevant ASEAN agreement under this paragraph regardless of the date of entry into force of the ATISA.

3. Each Member State shall encourage the use of alternative dispute resolution to facilitate the resolution of claims over e-commerce transactions.

4. Member States shall endeavour to recognise the importance of the principle of technology neutrality and recognise the need for alignment in policy and regulatory approaches among Member States to facilitate cross border e-commerce.

## ARTICLE 6
## COOPERATION

1. Each Member State shall cooperate in areas including:

   (a) Information and Communication Technology (ICT) infrastructure;

   (b) education and technology competency;

   (c) online consumer protection;

   (d) e-commerce legal and regulatory frameworks;

   (e) electronic transaction security, including protection of online personal information;

   (f) electronic payment and settlement;

   (g) trade facilitation;

   (h) intellectual property rights;

   (i) competition;

   (j) cybersecurity; and

   (k) logistics to facilitate e-commerce.

2. Each Member State shall undertake the following cooperation initiatives, as appropriate:

(a) sharing of information and experiences, and identifying best practices;

(b) implementing programmes or projects to provide assistance to Member States to enhance their domestic regulatory frameworks in support of e-commerce and to promote broader application of e-commerce; and

(c) establishing cooperation mechanisms among competent authorities to facilitate prompt investigation and resolution of fraudulent incidents related to e-commerce transactions and other matters agreed to by Member States.

## ARTICLE 7
## FACILITATING CROSS-BORDER E-COMMERCE

1. Paperless Trading

Each Member State shall expand the use of electronic versions of trade administration documents and facilitate the exchange of electronic documents through the use of ICT consistent with the provisions of the *ASEAN Agreement on Customs* signed on 30 March 2012 in Phnom Penh, Cambodia, and other international agreements on paperless trading to which Member States are parties.

2. Electronic Authentication and Electronic Signatures

(a) Except in circumstances otherwise provided for under its laws and regulations, a Member State shall not deny the legal validity of a signature solely on the basis that the signature is in electronic form.

Note: Cambodia, Lao PDR and Myanmar shall not be obliged to implement subparagraph (a) for a period of five years after the date of entry into force of this Agreement.

(b) Each Member State shall maintain or adopt, as soon as practicable, measures based on international norms for electronic authentication that:

(i) permit participants in electronic transactions to determine the appropriate authentication technologies and implementation models for their electronic transactions;

(ii) do not limit the recognition of authentication technologies and implementation models; and

(iii) permit participants in electronic transactions to have the opportunity to prove that their electronic transactions comply with that Member State's laws and regulations with respect to authentication.

(c) Notwithstanding subparagraph (b), each Member State may require that, for a particular category of electronic transactions, the method of authentication meet certain performance standards or be certified by an authority accredited in accordance with the laws and regulations of that Member State.

(d) Each Member State shall encourage the use of interoperable electronic authentication.

3. Online Consumer Protection

(a) Member States recognise the importance of adopting and maintaining transparent and effective

consumer protection measures for e-commerce as well as other measures conducive to the development of consumer confidence.

(b) Each Member State shall provide protection for consumers using e-commerce that affords a similar level of protection to that provided for consumers of other forms of commerce under its relevant laws, regulations and policies.

Note: Cambodia, Lao PDR and Myanmar shall not be obliged to implement subparagraph (b) for a period of five years after the date of entry into force of this Agreement.

(c) Member States recognise the importance of cooperation between their respective competent authorities in charge of consumer protection on activities related to e-commerce in order to enhance consumer protection.

4. Cross-border Transfer of Information by Electronic Means

(a) Member States recognise the importance of allowing information to flow across borders through electronic means, provided that such information shall be used for business purposes, and subject to their respective laws and regulations.

(b) Member States agree to facilitate cross-border e-commerce by working towards eliminating or minimising barriers to the flow of information across borders, including personal information, subject to appropriate safeguards to ensure security and confidentiality of information, and when other legitimate public policy objectives so dictate.

(c) Subparagraphs (a) and (b) shall not apply to financial services and financial service suppliers as defined in the *Annex on Financial Services* of GATS.

5. Online Personal Information Protection

(a) Each Member State shall adopt or maintain measures to protect the personal information of the users of e-commerce.

(b) A Member State shall not be obliged to implement subparagraph (a) before the date on which that Member State enacts laws or regulations to protect the personal information of e-commerce users.

(c) In the development of personal information protection measures, each Member State shall take into account international principles, guidelines and criteria of relevant international bodies.

6. Location of Computing Facilities

(a) Member States recognise that each Member State may have its own regulatory requirements regarding the use of computing facilities, including requirements that seek to ensure the security and confidentiality of communications.

(b) Member States agree not to require, subject to their respective laws and regulations, a juridical person of another Member State and its affiliated companies to locate their computing facilities in their respective territories as a requirement for operating a business in their respective territories.

(c) Subparagraphs (a) and (b) shall not apply to financial services and financial service suppliers as

defined in the *Annex on Financial Services of* GATS.

**ARTICLE 8**
**CYBERSECURITY**

Member States recognise the importance of:

(a) building the capabilities of their national entities responsible for cybersecurity including through the exchange of best practices; and

(b) using existing collaboration mechanisms to cooperate on matters related to cybersecurity.

**ARTICLE 9**
**ELECTRONIC PAYMENT**

1. Member States recognise the importance of safe and secure, efficient, and interoperable e-payment systems while taking into account the readiness of each Member State in terms of capacity, infrastructure, and regulation of e-payment systems.

2. Each Member State shall encourage the use of safe and secure, efficient, and interoperable e-payment systems to facilitate e-commerce in accordance with its laws and regulations.

**ARTICLE 10**
**LOGISTICS**

1. Member States recognise the importance of efficient cross-border logistics.

2. Each Member State shall endeavour to lower the cost and improve the speed and reliability of supply chains.

## ARTICLE 11
## STAKEHOLDER ENGAGEMENT

Each Member State shall regularly engage with relevant stakeholders, including the private sector, academic institutions, international organisations, and other relevant partners, to promote the exchange of information and generate feedback, inputs or proposals on the development of e-commerce.

## ARTICLE 12
## DOMESTIC REGULATORY FRAMEWORK

Each Member State shall maintain, or adopt as soon as practicable, laws and regulations governing electronic transactions taking into account applicable international conventions or model laws relating to e-commerce.

## ARTICLE 13
## TRANSPARENCY

1. Each Member State shall publish as promptly as possible or, where that is not practicable, otherwise make publicly available all relevant measures of general application pertaining to or affecting the operation of this Agreement. The form of publication shall include online publication where feasible.

2. Each Member State shall respond as promptly as possible to requests by another Member State for specific information on any of its measures of general application pertaining to or affecting the operation of this Agreement.

## ARTICLE 14
## EXCEPTIONS

Articles XIV and XIV *bis* of GATS are incorporated into and made part of this Agreement, *mutatis mutandis*.

## ARTICLE 15
## DISPUTE SETTLEMENT

1. The *ASEAN Protocol on Enhanced Dispute Settlement Mechanism* signed on 29 November 2004 in Vientiane, Lao PDR, or its successor, shall apply to the settlement of disputes concerning the interpretation or implementation of this Agreement.

2. Paragraph 1 shall not apply to Article 6 (Cooperation).

## ARTICLE 16
## INSTITUTIONAL ARRANGEMENTS

1. The ASEAN Senior Economic Officials Meeting (SEOM) shall oversee the implementation of this Agreement. SEOM shall task the ASEAN Coordinating Committee on Electronic Commerce (ACCEC) to coordinate, monitor and review the implementation of this Agreement in collaboration with other ASEAN sectoral bodies, with the support of the ASEAN Secretariat.

2. SEOM shall regularly update the ASEAN Economic Ministers Meeting on the status of implementation of this Agreement based on the status reports submitted by ACCEC.

## ARTICLE 17
## REVIEW

Member States shall undertake a joint review[2] of this Agreement no later than three years from the date of entry into force of this Agreement and every three years thereafter, unless otherwise agreed by Member States. Such review shall include considering the need for additional commitments under this Agreement.

---

[2] This review shall include, but not be limited to, paragraphs 4 and 6 of Article 7 (Facilitating Cross-Border E-Commerce), as mutually agreed by Member States.

**ARTICLE 18**
**AMENDMENTS**

The provisions of this Agreement may be amended by mutual agreement of the Member States in writing.

**ARTICLE 19**
**ENTRY INTO FORCE**

1. This Agreement shall enter into force upon the deposit of the instruments of ratification, approval or acceptance by the Member States with the Secretary-General of ASEAN.

2. The Secretary-General of ASEAN shall promptly notify the Member States of the deposit referred to in paragraph 1.

3. This Agreement shall be deposited with the Secretary-General of ASEAN, who shall promptly furnish a certified copy thereof to each Member State.

**IN WITNESS WHEREOF**, the undersigned, being duly authorised thereto by their respective Governments, have signed this Agreement.

**DONE** at Ha Noi, Viet Nam, this Twenty-Second day of January in the Year Two Thousand and Nineteen, in a single original copy in the English language.

# ឧបសម្ព័ន្ធទី២៖

ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃ
ទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩

# ព្រះរាជក្រម

នស/រកម/១១១៩/ ០១៧

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៨ ខែតុលា ឆ្នាំ២០១៩ នាសម័យប្រជុំរដ្ឋសភា លើកទី៣ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៩ នាសម័យប្រជុំជាវិសាមញ្ញ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

# ច្បាប់

# ស្ដីពី

# ពាណិជ្ជកម្មតាមប្រព័ន្ធ
# អេឡិចត្រូនិក

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .- គោលបំណង**

ច្បាប់នេះមានគោលបំណង៖

១. គ្រប់គ្រងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកក្នុងព្រះរាជាណាចក្រកម្ពុជានិងជាមួយអន្តរជាតិ។

២. បង្កើតភាពប្រាកដប្រជាផ្នែកគតិយុត្តក្នុងប្រតិបត្តិការពាណិជ្ជកម្មនិងរដ្ឋប្បវេណី តាមប្រព័ន្ធអេឡិចត្រូនិក។

៣. ផ្តល់ទំនុកចិត្តដល់សាធារណជនក្នុងការប្រើប្រាស់ទំនាក់ទំនងអេឡិចត្រូនិក។

**មាត្រា២ .- គោលដៅ**

ច្បាប់នេះមានគោលដៅដូចខាងក្រោម៖

១. កំណត់អំពីយថាភូតភាព សុក្រឹតភាព និងភាពអាចជឿទុកចិត្តបាននៃទម្រង់អេឡិចត្រូនិក។

២. ជំរុញការអភិវឌ្ឍក្របខ័ណ្ឌគតិយុត្តនិងធុរកិច្ច ដើម្បីអនុវត្តពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកប្រកបដោយសុវត្ថិភាព។

៣. បង្ការនិងបង្ក្រាបអំពើដែលបង្កការខូចខាតដល់ទិន្នន័យនិងប្រព័ន្ធព័ត៌មាន។

៤. លុបបំបាត់ឧបសគ្គទាំងឡាយដែលរាំងស្ទះដល់ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ហើយដែលកើតចេញពីភាពមិនប្រាកដប្រជានៃលក្ខខណ្ឌតម្រូវចំពោះលិខិតជាលាយលក្ខណ៍អក្សរនិងហត្ថលេខា។

៥. សម្រួលដល់ការតម្កល់ឯកសារតាមប្រព័ន្ធអេឡិចត្រូនិកជាមួយស្ថាប័នសាធារណៈ និងលើកកម្ពស់ការផ្តល់សេវាកម្មប្រកបដោយប្រសិទ្ធភាពរបស់ស្ថាប័នសាធារណៈ តាមរយៈការប្រើប្រាស់កំណត់ត្រាតាមប្រព័ន្ធអេឡិចត្រូនិកដែលអាចជឿទុកចិត្តបាន។

៦. បង្កើតវិធាន បទប្បញ្ញត្តិ និងស្តង់ដា ដែលទាក់ទងនឹងយថាភូតភាពនិងសុក្រឹតភាពរបស់កំណត់ត្រាតាមប្រព័ន្ធអេឡិចត្រូនិក។

**មាត្រា៣ .- វិសាលភាព**

ច្បាប់នេះត្រូវអនុវត្តលើសកម្មភាព ឯកសារ និងប្រតិបត្តិការពាណិជ្ជកម្មនិងរដ្ឋប្បវេណីទាំងអស់ដែលធ្វើឡើងតាមប្រព័ន្ធអេឡិចត្រូនិក លើកលែងតែសកម្មភាព ឯកសារ និងប្រតិបត្តិការទាក់ទងនឹង៖

១. ការបង្កើតឬការអនុវត្តលិខិតប្រគល់សិទ្ធិ។

២. ការបង្កើតឬការចុះហត្ថលេខាលើមតកសាសន៍ លិខិតកែមតកសាសន៍ ឬបញ្ហាផ្សេងៗទៀតទាក់ទិននឹងសន្តតិកម្ម។

៣. រាល់កិច្ចសន្យាសម្រាប់ការលក់ ការផ្ទេរ ឬការបោះបង់សិទ្ធិលើអចលនទ្រព្យឬផលប្រយោជន៍ផ្សេងៗទៀតក្នុងទ្រព្យនោះ។

៤. ការផ្ទេរអចលនវត្ថុឬផលប្រយោជន៍ណាមួយដែលពាក់ព័ន្ធនឹងអចលនវត្ថុនោះ។

៥. ករណីលើកលែងផ្សេងទៀតដែលត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៤ .- និយមន័យ**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងច្បាប់នេះត្រូវបានកំណត់និយមន័យដូចមានក្នុងសទ្ទានុក្រមដែលមានចែងក្នុងឧបសម្ព័ន្ធនៃច្បាប់នេះ។

## ជំពូកទី២
## សុពលភាពនៃទំនាក់ទំនងអេឡិចត្រូនិក

**មាត្រា៥ .- ការទទួលស្គាល់លក្ខណៈគតិយុត្តនៃទំនាក់ទំនងអេឡិចត្រូនិក**

គ្មានបុគ្គលណាម្នាក់អាចបដិសេធមិនទទួលស្គាល់សុពលភាព អានុភាពគតិយុត្ត ភាពអាចទទួលយកបានឬភាពដែលអាចយកទៅអនុវត្តបាននៃទំនាក់ទំនងអេឡិចត្រូនិក ដោយគ្រាន់តែសម្អាងលើមូលហេតុដែលថាវាធ្វើឡើងក្នុងទម្រង់អេឡិចត្រូនិកឬស្ថិតនៅក្នុងទំនាក់ទំនងអេឡិចត្រូនិកឡើយ។

**មាត្រា៦ .- លក្ខខណ្ឌតម្រូវជាលាយលក្ខណ៍អក្សរ**

១. នៅពេលដែលបទប្បញ្ញត្តិណាមួយ តម្រូវឱ្យផ្តល់ព័ត៌មានជាលាយលក្ខណ៍អក្សរ ឬធ្វើកំណត់ត្រាជាលាយលក្ខណ៍អក្សរ ត្រូវចាត់ទុកថា លក្ខខណ្ឌតម្រូវនេះត្រូវបានបំពេញប្រសិនបើព័ត៌មាននេះធ្វើឡើងក្នុងទម្រង់អេឡិចត្រូនិក ហើយអាចចូលប្រើប្រាស់បាន និងអាចទាញយកទៅប្រើប្រាស់នៅពេលក្រោយបាន។

២. នៅពេលដែលលក្ខខណ្ឌក្នុងបញ្ញត្តិនៃកថាខណ្ឌទី១ខាងលើ ត្រូវយកមកអនុវត្តលក្ខខណ្ឌតម្រូវតាមច្បាប់ដែលទាមទារឱ្យបុគ្គលណាមួយផ្តល់សំណៅចម្លងច្រើនច្បាប់ក្នុងពេលតែមួយស្តីអំពីព័ត៌មានណាមួយឬកិច្ចការណាមួយទៅឱ្យបុគ្គលមួយផ្សេងទៀត បុគ្គលដែលផ្តល់អាចបំពេញលក្ខខណ្ឌនេះដោយគ្រាន់តែផ្តល់ក្រោមទម្រង់អេឡិចត្រូនិកតែមួយច្បាប់បាន។

**មាត្រា៧ .- លក្ខខណ្ឌតម្រូវចំពោះហត្ថលេខា**

១. នៅពេលដែលមានបទប្បញ្ញត្តិណាមួយតម្រូវឱ្យមានហត្ថលេខារបស់បុគ្គលណាមួយ លក្ខខណ្ឌតម្រូវនេះត្រូវចាត់ទុកថាបានបំពេញតាមរយៈការចុះហត្ថលេខាអេឡិចត្រូនិក ប្រសិនបើហត្ថលេខាអេឡិចត្រូនិកដែលបានប្រើនោះ ត្រូវបានបង្កើតឡើងតាមរយៈមធ្យោបាយដែលៈ

ក. អាចកំណត់អត្តសញ្ញាណបុគ្គល និងបង្ហាញការឯកភាពរបស់បុគ្គលនោះលើព័ត៌មានឬកំណត់ត្រាដែលមាននៅក្នុងទំនាក់ទំនងអេឡិចត្រូនិកនោះ។

ខ. អាចជឿជាក់បាន ស្របតាមចរិតលក្ខណៈ គោលបំណង និងកាលៈទេសៈ ដែលទំនាក់ទំនងអេឡិចត្រូនិកនោះត្រូវបានបង្កើតឡើងឬត្រូវបានប្រាស្រ័យទាក់ទង។

២. ទោះបីជាបទប្បញ្ញត្តិណាមួយកំណត់អំពីលក្ខខណ្ឌតម្រូវឱ្យមានចុះហត្ថលេខា ឬគ្រាន់តែកំណត់អំពីផលវិបាកនៃការមិនចុះហត្ថលេខាក៏ដោយ ក៏បញ្ញត្តិនៃកថាខណ្ឌទី១ខាងលើត្រូវយកមកអនុវត្តផងដែរ។

**មាត្រា៨ .- លក្ខខណ្ឌតម្រូវសម្រាប់រក្សាព័ត៌មានតាមទម្រង់ដើម**

លក្ខខណ្ឌគតិយុត្តក្នុងការរក្សាព័ត៌មានដែលមិនត្រូវបានធ្វើឡើងក្នុងទម្រង់អេឡិចត្រូនិក អាចត្រូវបានបំពេញដោយការរក្សាព័ត៌មាននោះក្រោមទម្រង់អេឡិចត្រូនិក ប្រសិនបើ៖

១. ទម្រង់អេឡិចត្រូនិកនោះជាមធ្យោបាយដែលអាចជឿទុកចិត្តបានដើម្បីកំណត់ភាពពេញលេញរបស់ព័ត៌មាននោះ។ និង

២. ព័ត៌មាននោះអាចចូលយកបានដោយងាយស្រួល សម្រាប់យកទៅប្រើប្រាស់បានពេលក្រោយ។

**មាត្រា៩ .- ទម្រង់បែបបទដែលកំណត់**

នៅពេលដែលបទប្បញ្ញត្តិណាមួយតម្រូវឱ្យព័ត៌មានធ្វើឡើងក្នុងទម្រង់បែបបទណាមួយ លក្ខខណ្ឌតម្រូវនោះត្រូវជំនួសដោយការផ្តល់ព័ត៌មានតាមទម្រង់អេឡិចត្រូនិកបាន ប្រសិនបើទម្រង់អេឡិចត្រូនិកនោះត្រូវបំពេញលក្ខខណ្ឌទាំងអស់ដូចខាងក្រោម៖

១. មានផ្ទុកព័ត៌មានដូចគ្នាឬដូចគ្នាភាគច្រើនទៅនឹងទម្រង់បែបបទដែលបានកំណត់។

២. អាចចូលទៅមើលបាន អាចយល់បាន និងអាចទាញយកមកប្រើប្រាស់បាននៅពេលក្រោយ។ និង

៣. អាចឱ្យបុគ្គលដែលទទួលបានព័ត៌មាននោះរក្សាទុកបាន។

**មាត្រា១០ .- លក្ខខណ្ឌតម្រូវលើការរក្សាទុកកំណត់ត្រា**

១. នៅពេលដែលបទប្បញ្ញត្តិណាមួយតម្រូវឱ្យរក្សាទុកនូវឯកសារ កំណត់ត្រា ឬព័ត៌មានជាក់លាក់ណាមួយ លក្ខខណ្ឌតម្រូវនោះត្រូវចាត់ទុកថាបានបំពេញ ប្រសិនបើ ការរក្សាទុកនោះបំពេញលក្ខខណ្ឌទាំងអស់ដូចខាងក្រោម៖

ក. ព័ត៌មានដែលមាននៅក្នុងទំនាក់ទំនងអេឡិចត្រូនិកនោះអាចចូលប្រើប្រាស់បាន និងសម្រាប់យកទៅប្រើប្រាស់នាពេលអនាគត។

ខ. ទំនាក់ទំនងអេឡិចត្រូនិកត្រូវបានរក្សាទុកក្នុងទម្រង់ដើមដែលត្រូវបានបង្កើតឡើង ផ្ញើ ឬទទួលបាន ឬក្នុងទម្រង់ដែលអាចត្រូវបានបង្ហាញពីសុក្រឹតភាពនៃព័ត៌មាននោះ។ និង

គ. ព័ត៌មានទាំងនោះត្រូវរក្សាទុកដើម្បីឱ្យបុគ្គលណាម្នាក់អាចកំណត់បាននូវប្រភពដើម និងគោលដៅនៃទំនាក់ទំនងអេឡិចត្រូនិកនោះ កាលបរិច្ឆេទ និងពេលវេលាដែលទំនាក់ទំនងអេឡិចត្រូនិកនោះត្រូវបានផ្ញើឬទទួល។

២. កាតព្វកិច្ចក្នុងការរក្សាឯកសារ កំណត់ត្រា ឬព័ត៌មានស្របតាមកថាខណ្ឌ១ មិនរាប់បញ្ចូលព័ត៌មានណាមួយ សម្រាប់តែធ្វើការបញ្ជូនឬទទួលសារនោះឡើយ។

**មាត្រា១១ .- លក្ខខណ្ឌតម្រូវស្តីពីភស្តុតាង**

គ្មានបទប្បញ្ញត្តិណាមួយក្នុងការអនុវត្តវិធានស្តីពីភស្តុតាង អាចជំទាស់ការទទួលយកទំនាក់ទំនងអេឡិចត្រូនិកជាភស្តុតាង ដោយគ្រាន់តែឈរលើមូលដ្ឋានដែលថា៖

១. ភស្តុតាងនោះជាទំនាក់ទំនងអេឡិចត្រូនិក។ ឬ

២. ភស្តុតាងនោះមិនស្ថិតក្នុងទម្រង់ដើម។

**មាត្រា១២ .- ការបង្កើតកិច្ចសន្យានិងសុពលភាពកិច្ចសន្យា**

១. សំណើ ស្ទីការ និងកិច្ចសន្យា អាចធ្វើឡើងតាមមធ្យោបាយអេឡិចត្រូនិកបាន។

២. កិច្ចសន្យាក្នុងទម្រង់អេឡិចត្រូនិកដូចមានចែងក្នុងបញ្ញត្តិនៃកថាខណ្ឌទី១ខាងលើ មានសុពលភាព អានុភាពគតិយុត្ត និងភាពអាចអនុវត្តបាន នៅពេលដែលសំណើនិងស្ទីការត្រូវគ្នា។

**មាត្រា១៣ .- អានុភាពរវាងគូភាគី**

អ្នកផ្ញើនិងអ្នកទទួលនៃទំនាក់ទំនងអេឡិចត្រូនិក មិនត្រូវបដិសេធអានុភាពគតិយុត្ត សុពលភាព និងភាពអាចអនុវត្តបាននៃការបង្ហាញឆន្ទៈ ឬសេចក្តីថ្លែងផ្សេងៗរបស់ខ្លួនឡើយ។

**មាត្រា១៤ .- ការអនុវត្តដោយឡែកតាមការព្រមព្រៀងរបស់គូភាគី**

១. តាមការព្រមព្រៀង គូភាគីដែលចូលរួមក្នុងការបង្កើត ការផ្ញើ ការទទួល ការរក្សាទុក ឬ ដំណើរការទំនាក់ទំនងអេឡិចត្រូនិក អាចអនុវត្តផ្សេងពីបទប្បញ្ញត្តិដូចមានចែងនៅក្នុងជំពូកទី២ នៃច្បាប់នេះ លើកលែងតែមានការកំណត់ផ្សេងពីនេះ។

២. ទោះជាមានបទប្បញ្ញត្តិដូចមានចែងក្នុងជំពូកទី២ គូភាគីនៃកិច្ចសន្យា ឬប្រតិបត្តិការណាមួយអាចៈ

ក. មិនប្រើប្រាស់កំណត់ត្រាអេឡិចត្រូនិក ទំនាក់ទំនងអេឡិចត្រូនិក ឬហត្ថលេខាអេឡិចត្រូនិកក្នុងកិច្ចសន្យា ឬប្រតិបត្តិការណាមួយតាមការព្រមព្រៀងគ្នា។ ឬ

ខ. ដាក់លក្ខខណ្ឌតម្រូវបន្ថែមផ្សេងៗដែលពាក់ព័ន្ធនឹងទម្រង់ ឬយថាភូតភាពនៃកិច្ចសន្យា ឬប្រតិបត្តិការតាមការព្រមព្រៀងគ្នា។

## ជំពូកទី៣
## ដំណើរការនៃទំនាក់ទំនងអេឡិចត្រូនិក

**មាត្រា១៥ .- ពេលវេលានិងទីកន្លែងនៃការបញ្ជូនចេញនិងការទទួលព័ត៌មានក្នុងទំនាក់ទំនងអេឡិចត្រូនិក**

១. ព័ត៌មានក្នុងទំនាក់ទំនងអេឡិចត្រូនិកមួយត្រូវចាត់ទុកថា បានបញ្ជូនចេញនៅពេលដែលៈ

ក. ព័ត៌មាននោះ បានចាកចេញពីប្រព័ន្ធព័ត៌មានដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់អ្នកផ្ញើឬរបស់ភាគីដែលផ្ញើជំនួសក្នុងនាមអ្នកផ្ញើ។ ឬ

ខ. ក្នុងករណីដែលព័ត៌មាននោះ ត្រូវបានបញ្ជូនតែមិនទាន់បានចាកចេញពីប្រព័ន្ធព័ត៌មានដែលស្ថិតក្រោមការគ្រប់គ្រងរបស់អ្នកផ្ញើឬរបស់ភាគីដែលផ្ញើជំនួសព័ត៌មាន ត្រូវចាត់ទុកថា បានបញ្ជូនចេញនៅពេលដែលព័ត៌មាននោះត្រូវបានទទួលក្នុងពេលណាមួយ។

២. ព័ត៌មានក្នុងទំនាក់ទំនងអេឡិចត្រូនិកមួយត្រូវបានសន្មតថាបានបញ្ជូនចេញពីទីតាំងអាជីវកម្មរបស់អ្នកផ្ញើ ទោះបីព័ត៌មាននោះត្រូវបានផ្ញើចេញពីទីតាំងណាក៏ដោយ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL · SECRETARIAT

៣. ពេលវេលានៃការទទួលព័ត៌មានគឺពេលដែលព័ត៌មាននោះ អាចទាញយកបានដោយអ្នកទទួលនៅក្នុងអាសយដ្ឋានអេឡិចត្រូនិកដែលអ្នកទទួលបានបញ្ជាក់ជាមុន។ ព័ត៌មានត្រូវបានសន្មតថាបានទទួលនៅទីកន្លែងដែលជាទីតាំងអាជីវកម្មរបស់អ្នកទទួល។

៤. ប្រសិនបើអាសយដ្ឋានអេឡិចត្រូនិកមិនត្រូវបានផ្ដល់ដោយអ្នកទទួល នោះពេលវេលាទទួលបានព័ត៌មាន គឺជាពេលវេលាដែលអ្នកទទួលបានដឹងអំពីការផ្ញើចេញនិងអាចទាញយកព័ត៌មាននោះ តាមរយៈអាសយដ្ឋានអេឡិចត្រូនិកណាមួយ ហើយសន្មតថាបានទទួលនៅទីកន្លែងដែលជាទីតាំងអាជីវកម្មរបស់អ្នកទទួល។

៥. ប្រសិនបើអាសយដ្ឋានអេឡិចត្រូនិកត្រូវបានផ្ដល់ដោយអ្នកទទួល ព័ត៌មានក្នុងទំនាក់ទំនងអេឡិចត្រូនិកត្រូវបានសន្មតថាបានទទួលនៅពេលព័ត៌មាននោះបានទៅដល់អាសយដ្ឋានអេឡិចត្រូនិករបស់អ្នកទទួល ហើយត្រូវបានចាត់ទុកថាបានទទួលនៅទីកន្លែងដែលជាទីតាំងអាជីវកម្មរបស់អ្នកទទួល។

**មាត្រា១៦ .- សំណើបង្កើតកិច្ចសន្យា**

រាល់ការស្នើសុំចុះកិច្ចសន្យា តាមរយៈទំនាក់ទំនងអេឡិចត្រូនិកដែលមិនសំដៅតែដល់បុគ្គលណាមួយជាក់លាក់ផ្សេងទៀត ត្រូវបានចាត់ទុកថាជាការអញ្ជើញឱ្យធ្វើសំណើបង្កើតកិច្ចសន្យាតែប៉ុណ្ណោះ។ ការស្នើសុំចុះកិច្ចសន្យានោះ នឹងត្រូវចាត់ទុកថាជាសំណើបង្កើតកិច្ចសន្យា ប្រសិនបើការស្នើសុំនោះបានបង្ហាញឱ្យឃើញច្បាស់អំពីឆន្ទៈរបស់ខ្លួនថានឹងត្រូវជាប់កាតព្វកិច្ចនៅពេលមានស្ទីការពីភាគីម្ខាងទៀត។

**មាត្រា១៧ .- ការប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តសម្រាប់បង្កើតកិច្ចសន្យា**

កិច្ចសន្យាដែលបង្កើតឡើងដោយអន្តរកម្មរវាងប្រព័ន្ធស្វ័យប្រវត្តនៃបុគ្គលមួយ ជាមួយរូបវន្តបុគ្គលណាមួយឬជាមួយប្រព័ន្ធស្វ័យប្រវត្តនៃបុគ្គលផ្សេងទៀត មិនអាចត្រូវបានបដិសេធអំពីសុពលភាព អានុភាពគតិយុត្ត ឬភាពអាចអនុវត្តបាននៃកិច្ចសន្យានោះឡើយ ដោយសម្អាងលើហេតុផលអវត្តមាននៃរូបវន្តបុគ្គលក្នុងការពិនិត្យឬក្នុងការចូលធ្វើសកម្មភាពដោយផ្ទាល់ក្នុងប្រព័ន្ធស្វ័យប្រវត្តឬក្នុងការបង្កើតកិច្ចសន្យា។

**មាត្រា១៨ .- កំហុសឆ្គងនៃការបញ្ចូលព័ត៌មានក្នុងទំនាក់ទំនងអេឡិចត្រូនិក**

នៅពេលដែលបុគ្គលបញ្ចូលព័ត៌មានខុសនៅក្នុងទំនាក់ទំនងអេឡិចត្រូនិកជាមួយប្រព័ន្ធស្វ័យប្រវត្តរបស់ភាគីម្ខាងទៀត ហើយប្រព័ន្ធស្វ័យប្រវត្តនេះមិនផ្ដល់ឱកាសឱ្យបុគ្គលនោះធ្វើការកែប្រែនូវព័ត៌មានដែលខុស បុគ្គលឬភាគីដែលជំនួសមុខឱ្យបុគ្គលដែលបញ្ចូលព័ត៌មាននោះមានសិទ្ធិកែតម្រូវ ឬដកចេញនូវព័ត៌មានដែលខុសនោះបាន ក្នុងករណី៖

១. បុគ្គលនោះបានជូនដំណឹងទៅភាគីម្ខាងទៀតអំពីកំហុសដែលបានកើតឡើងឱ្យបានឆាប់បំផុត ហើយត្រូវបង្ហាញថាខ្លួនបានបញ្ចូលព័ត៌មានខុសនៅក្នុងទំនាក់ទំនងអេឡិចត្រូនិក។ និង

២. បុគ្គលនោះមិនទទួលបានផលប្រយោជន៍ណាមួយ ដោយសារការបញ្ចូលព័ត៌មានខុសនេះ មុនពេលដែលខ្លួនធ្វើការជូនដំណឹងទៅឱ្យភាគីម្ខាងទៀត ហើយមិនបង្កការខូចខាតដល់ផលប្រយោជន៍របស់ភាគីម្ខាងទៀតឬតតិយជនណាមួយ។

បញ្ញត្តិដែលមានចែងក្នុងមាត្រានេះ មិនអនុវត្តចំពោះវិស័យមូលបត្រឡើយ។

## ជំពូកទី៤

## កំណត់ត្រាអេឡិចត្រូនិកនិងហត្ថលេខាអេឡិចត្រូនិកដែលមានសុវត្ថិភាព

**មាត្រា១៩ .- កំណត់ត្រាអេឡិចត្រូនិកដែលមានសុវត្ថិភាព**

កំណត់ត្រាអេឡិចត្រូនិកមួយត្រូវបានចាត់ទុកថាជាកំណត់ត្រាអេឡិចត្រូនិកដែលមានសុវត្ថិភាព លុះត្រាតែបានអនុវត្តស្របតាមនីតិវិធីសុវត្ថិភាពត្រឹមត្រូវ ដែលធានាបានថាកំណត់ត្រាអេឡិចត្រូនិកនោះ មិនត្រូវបានកែប្រែ គិតចាប់ពីពេលវេលាកំណត់ជាក់លាក់ណាមួយរហូតដល់ពេលធ្វើការពិនិត្យផ្ទៀងផ្ទាត់។

**មាត្រា២០ .- ហត្ថលេខាអេឡិចត្រូនិកដែលមានសុវត្ថិភាព**

១. ហត្ថលេខាអេឡិចត្រូនិកដែលមានសុវត្ថិភាព លុះត្រាតែគោរពទៅតាមលក្ខខណ្ឌខាងក្រោម៖

- ក. ផ្សារភ្ជាប់ទៅកាន់ហត្ថលេខីតែម្នាក់គត់។
- ខ. កំណត់បានអត្តសញ្ញាណរបស់ហត្ថលេខី។
- គ. ត្រូវបានបង្កើតឡើងដោយប្រើប្រាស់មធ្យោបាយដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ហត្ថលេខី។
- ឃ. បញ្ជាក់អំពីពេលវេលានិងកាលបរិច្ឆេទនៃការចុះហត្ថលេខា។ និង
- ង. បញ្ជាក់អំពីស្ថានភាពដើមនៃសារ ឬកំណត់ត្រាអេឡិចត្រូនិកដែលត្រូវបានផ្សារភ្ជាប់ដោយហត្ថលេខានោះ។

២. បញ្ញត្តិនៃកថាខណ្ឌទី១ខាងលើ មិនកម្រិតលទ្ធភាពរបស់បុគ្គលណាមួយក្នុងទំនាក់ទំនងអេឡិចត្រូនិកឡើយ ក្នុងការ៖

- ក. កំណត់លក្ខខណ្ឌបន្ថែមផ្សេងទៀតពាក់ព័ន្ធនឹងភាពអាចជឿជាក់បានរបស់ហត្ថលេខាអេឡិចត្រូនិក។ ឬ
- ខ. លើកភស្តុតាងអំពីភាពមិនអាចជឿជាក់បាននៃហត្ថលេខាអេឡិចត្រូនិក។

**មាត្រា២១ .- ការសន្មតទាក់ទងនឹងកំណត់ត្រានិងហត្ថលេខាអេឡិចត្រូនិកដែលមានសុវត្ថិភាព**

១. លើកលែងតែមានភស្តុតាងផ្ទុយ ក្នុងដំណើរការដែលពាក់ព័ន្ធនឹងកំណត់ត្រាអេឡិចត្រូនិកដែលមានសុវត្ថិភាព កំណត់ត្រាអេឡិចត្រូនិកដែលមានសុវត្ថិភាពត្រូវបានសន្មតថាជាកំណត់ត្រាអេឡិចត្រូនិកដែលមិនត្រូវបានកែប្រែចាប់តាំងពីពេលជាក់លាក់ណាមួយ។

២. លើកលែងតែមានភស្តុតាងផ្ទុយ ក្នុងដំណើរការពាក់ព័ន្ធនឹងហត្ថលេខាអេឡិចត្រូនិកដែលមានសុវត្ថិភាព ហត្ថលេខាអេឡិចត្រូនិកដែលមានសុវត្ថិភាពត្រូវបានសន្មតដូចខាងក្រោម៖

ក. ហត្ថលេខាអេឡិចត្រូនិកនោះ គឺជាហត្ថលេខារបស់បុគ្គលពាក់ព័ន្ធ។ និង

ខ. ហត្ថលេខាអេឡិចត្រូនិកនោះ ត្រូវបានចុះហត្ថលេខាដោយបុគ្គលមានឆន្ទៈក្នុងការចុះហត្ថលេខា ឬបានឯកភាពលើកំណត់ត្រាអេឡិចត្រូនិកនោះ។

៣. ក្នុងករណីដែលគ្មានកំណត់ត្រាអេឡិចត្រូនិកសុវត្ថិភាព ឬហត្ថលេខាអេឡិចត្រូនិកសុវត្ថិភាព គ្មានបញ្ញត្តិណាមួយនៅក្នុងជំពូកទី៤ អាចសន្មតបានជាមុនអំពីយថាភូតភាព ឬសុក្រឹតភាពនៃកំណត់ត្រាអេឡិចត្រូនិក ឬហត្ថលេខាអេឡិចត្រូនិកនោះឡើយ។

**មាត្រា២២ .- ការលួចប្រើប្រាស់អត្តសញ្ញាណ**

បុគ្គលទាំងឡាយមិនត្រូវប្រើប្រាស់អត្តសញ្ញាណ កំណត់ត្រា ហត្ថលេខាអេឡិចត្រូនិក អាសយដ្ឋានអេឡិចត្រូនិក លេខសម្ងាត់ ឬភិនភាគសម្គាល់របស់បុគ្គលផ្សេងទៀតដោយទុច្ចរិត ឬដោយគ្មានការអនុញ្ញាត ក្នុងប្រតិបត្តិការពាណិជ្ជកម្ម ឬមិនមែនពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

**មាត្រា២៣ .- ស្ថាប័នមានសមត្ថកិច្ចគ្រប់គ្រងនីតិវិធីសុវត្ថិភាព**

១. ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ជាស្ថាប័នមានសមត្ថកិច្ចក្នុងការគ្រប់គ្រងនីតិវិធីសុវត្ថិភាព សម្រាប់កំណត់ត្រាអេឡិចត្រូនិកនិងហត្ថលេខាអេឡិចត្រូនិក។

២. ការគ្រប់គ្រងនីតិវិធីសុវត្ថិភាពសម្រាប់កំណត់ត្រាអេឡិចត្រូនិកនិងហត្ថលេខាអេឡិចត្រូនិកត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្ត។

## ជំពូកទី៥
## អន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

**មាត្រា២៤ .- ការទទួលខុសត្រូវរបស់អន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក**

១. អន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក មិនទទួលខុសត្រូវផ្នែករដ្ឋប្បវេណីឬព្រហ្មទណ្ឌពាក់ព័ន្ធនឹងព័ត៌មានដែលមានក្នុងកំណត់ត្រាអេឡិចត្រូនិកដែលពាក់ព័ន្ធនឹងការផ្តល់សេវារបស់អន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនោះឡើយ ក្នុងករណីដែលខ្លួនមិនមែនជាអ្នកធ្វើកំណត់ត្រានោះ និងក្នុងករណីដែល៖

ក. អន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនោះមិនបានដឹងថាព័ត៌មានដែលបានធ្វើនោះបង្កឱ្យមានការទទួលខុសត្រូវផ្នែករដ្ឋប្បវេណីឬព្រហ្មទណ្ឌ។

ខ. អន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនោះមិនបានដឹងអំពីអង្គហេតុឬកាលៈទេសៈដែលអាចឱ្យស្មានទុកថាព័ត៌មាននោះអាចបង្កឱ្យមានការទទួលខុសត្រូវផ្នែករដ្ឋប្បវេណីឬព្រហ្មទណ្ឌ។ ឬ

គ. អន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកបានដឹងនាពេលក្រោយថាព័ត៌មាន ឬអង្គហេតុ ឬកាលៈទេសៈដែលអាចឱ្យស្មានទុកថា ព័ត៌មាននោះ

អាចបង្កឱ្យមានការទទួលខុសត្រូវខាងផ្នែករដ្ឋប្បវេណី ឬព្រហ្មទណ្ឌ ហើយបានអនុវត្តតាមនីតិវិធីចំពោះព័ត៌មានខុសច្បាប់ និងការបរិហាកេរ្តិ៍ដូចមានចែងក្នុងមាត្រា២៥ ខាងក្រោម។

២. អន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក មិនតម្រូវឱ្យតាមដានត្រួតពិនិត្យកំណត់ត្រាអេឡិចត្រូនិកណាមួយដែលដំណើរការដោយប្រព័ន្ធអេឡិចត្រូនិកដែលស្ថិតក្រោមការគ្រប់គ្រងរបស់ខ្លួននោះឡើយ ទោះបីជាដំណើរការនៃកំណត់ត្រាអេឡិចត្រូនិកនោះអាចបង្កើតជាបទល្មើស ឬនាំឱ្យមានការទទួលខុសត្រូវរដ្ឋប្បវេណីក៏ដោយ លើកលែងតែមានការកំណត់ផ្សេងពីនេះ។

៣. បញ្ញត្តិនៃមាត្រានេះមិនត្រូវយកមកអនុវត្តដើម្បីឱ្យអន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិករួចផុតពី៖

ក. កាតព្វកិច្ចដែលបង្កើតឡើងដោយច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តនានា។

ខ. កាតព្វកិច្ចអនុលោមតាមបទបញ្ជា ឬសេចក្តីបង្គាប់របស់តុលាការ ឬអាជ្ញាធរមានសមត្ថកិច្ចផ្សេងទៀត។ ឬ

គ. កាតព្វកិច្ចតាមកិច្ចសន្យា។

**មាត្រា២៥ .- ការទទួលខុសត្រូវផ្នែកព័ត៌មានឬហេតុការណ៍**

១. ក្នុងករណីដែលអន្តរការី ឬបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកបានដឹងថាព័ត៌មានក្នុងកំណត់ត្រាអាចបង្កឱ្យមានការទទួលខុសត្រូវខាងផ្នែករដ្ឋប្បវេណីឬព្រហ្មទណ្ឌ អន្តរការី ឬបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកត្រូវចាត់វិធានការជាបន្ទាន់ដូចខាងក្រោម៖

ក. ដកព័ត៌មានចេញពីប្រព័ន្ធព័ត៌មានដែលស្ថិតក្រោមការគ្រប់គ្រង់របស់អន្តរការី និងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ហើយឈប់ផ្តល់សេវាពាក់ព័ន្ធនឹងព័ត៌មាននោះ។

ខ. រក្សាទុកព័ត៌មានជាភស្តុតាងនិងជូនដំណឹងដល់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធនានាអំពីអង្គហេតុនិងអត្តសញ្ញាណនៃជនសង្ស័យ។

២. ក្នុងករណីដែលអន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកដឹងអំពីហេតុការណ៍ណាមួយ ឬស្ថានភាពណាមួយដែលអាចបណ្តាលឱ្យមានការទទួលខុសត្រូវខាងផ្នែករដ្ឋប្បវេណីឬព្រហ្មទណ្ឌ អន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកត្រូវរក្សាទុកព័ត៌មានជាភស្តុតាងនិងជូនដំណឹងដល់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធនានា។

៣. នៅពេលបានដឹងឬទទួលដំណឹងពាក់ព័ន្ធនឹងព័ត៌មានក្នុងកំណត់ត្រាអេឡិចត្រូនិកដែលអាចបង្កឱ្យមានការទទួលខុសត្រូវផ្នែករដ្ឋប្បវេណីឬព្រហ្មទណ្ឌ ក្រសួងប្រៃសណីយ៍និង

ទូរគមនាគមន៍ ឬក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ អាចបញ្ជាឱ្យអន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក៖

ក. ដកព័ត៌មានចេញពីប្រព័ន្ធព័ត៌មានដែលស្ថិតក្រោមការគ្រប់គ្រងរបស់ខ្លួន។

ខ. ផ្អាកឬឈប់ផ្តល់សេវាដល់បុគ្គលនោះ។ ឬ

គ. ផ្អាកឬឈប់ផ្តល់សេវាពាក់ព័ន្ធនឹងកំណត់ត្រាអេឡិចត្រូនិក។

៤. អន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មអេឡិចត្រូនិកមិនត្រូវទទួលខុសត្រូវផ្នែករដ្ឋប្បវេណី តាមកិច្ចសន្យាឬក្រៅកិច្ចសន្យា ឬកំណត់ដោយច្បាប់ ចំពោះការអនុវត្តដោយសុទ្ធចិត្តតាមបញ្ជារបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ឬក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ។

៥. បុគ្គលដែលជូនដំណឹងអំពីសកម្មភាពខុសច្បាប់ទៅដល់អន្តរការីឬបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដោយដឹងថាការជូនដំណឹងនោះខុសពីការពិតឬមានលក្ខណៈបោកបញ្ឆោត ត្រូវទទួលខុសត្រូវខាងផ្នែករដ្ឋប្បវេណីឬព្រហ្មទណ្ឌពីអំពើនោះ។

**មាត្រា២៦ .- ការផ្តល់លិខិតអនុញ្ញាតឬអាជ្ញាបណ្ណ**

១. អន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវស្នើសុំការអនុញ្ញាតឬអាជ្ញាបណ្ណពីក្រសួងពាណិជ្ជកម្មនិងក្រសួងប្រៃសណីយនិងទូរគមនាគមន៍។

២. ក្រសួងពាណិជ្ជកម្មផ្តល់លិខិតអនុញ្ញាតឬអាជ្ញាបណ្ណរួមមាន៖

ក. លិខិតអនុញ្ញាតប្រកបអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិកសម្រាប់រូបវន្តបុគ្គល។

ខ. អាជ្ញាបណ្ណឱ្យប្រតិបត្តិការផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកសម្រាប់នីតិបុគ្គល។

៣. ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ផ្តល់វិញ្ញាបនបត្រសេវាអនឡាញ។

៤. ការលើកលែង ការកំណត់ប្រភេទអាជ្ញាបណ្ណ បែបបទ និងនីតិវិធីនៃការផ្តល់ការអនុញ្ញាតឬអាជ្ញាបណ្ណ ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា២៧ .- ក្រមសីលធម៌វិជ្ជាជីវៈនិងបទប្បញ្ញត្តិសម្រាប់អន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក**

១. អន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកត្រូវអនុវត្តតាមក្រមសីលធម៌វិជ្ជាជីវៈ និងបទប្បញ្ញត្តិនានាពាក់ព័ន្ធនឹងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកដែលកំណត់ដោយប្រកាសអន្តរក្រសួងរវាងក្រសួងពាណិជ្ជកម្មនិងក្រសួងប្រៃសណីយនិងទូរគមនាគមន៍។

២. ក្រមសីលធម៌វិជ្ជាជីវៈ ដែលបានលើកឡើងក្នុងបញ្ញត្តិនៃកថាខណ្ឌទី១ខាងលើត្រូវកំណត់និងរៀបរៀងឡើងដោយក្រសួងពាណិជ្ជកម្មនិងក្រសួងប្រៃសណីយនិងទូរគមនាគមន៍ដោយសហការជាមួយក្រសួង ស្ថាប័ននិងភាគីពាក់ព័ន្ធ។

**មាត្រា២៨ .- កាតព្វកិច្ចពន្ធ ការលើកទឹកចិត្ត និងការអនុគ្រោះ**

អន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវស្ថិតនៅក្រោមនីតិរបបសារពើពន្ធជាធរមាន និងទទួលបានការលើកទឹកចិត្តនិងការអនុគ្រោះនានា ស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

# ជំពូកទី៦
# កិច្ចការពារអ្នកប្រើប្រាស់

**មាត្រា២៩ .- ព័ត៌មានអប្បបរមាក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក**

១. បុគ្គលដែលប្រើប្រាស់ទំនាក់ទំនងអេឡិចត្រូនិកដើម្បីលក់ទំនិញឬសេវាទៅឱ្យអ្នកប្រើប្រាស់ត្រូវផ្តល់ព័ត៌មានត្រឹមត្រូវ ច្បាស់លាស់ និងងាយយល់បាន ហើយត្រូវមានព័ត៌មានយ៉ាងតិចដូចខាងក្រោម៖

ក. ឈ្មោះឬនាមករណ៍ស្របច្បាប់របស់បុគ្គល អាសយដ្ឋានអាជីវកម្មដែលបានចុះបញ្ជី និងមធ្យោបាយអេឡិចត្រូនិកសម្រាប់ទំនាក់ទំនងឬលេខទូរសព្ទ។

ខ. ទម្រង់ទំនាក់ទំនងដែលរហ័ស ងាយស្រួល និងមានប្រសិទ្ធភាពរវាងអ្នកប្រើប្រាស់ជាមួយអ្នកលក់។

គ. ខចែង លក្ខខណ្ឌ និងសោហ៊ុយរបស់ទំនិញឬសេវានានាដែលពាក់ព័ន្ធនឹងប្រតិបត្តិការពាណិជ្ជកម្ម ជាពិសេស ខចែង លក្ខខណ្ឌ និងមធ្យោបាយទូទាត់ប្រាក់ និងព័ត៌មានលម្អិតពាក់ព័ន្ធនឹងការដកឬលុបចោលការបញ្ជាទិញ ការបញ្ឈប់ ការប្រគល់ និងការប្តូរទំនិញ និងការសងប្រាក់មកវិញ។ និង

ឃ. ទំនិញនិងសេវាជាក់ស្តែងដែលដាក់លក់។

២. ព័ត៌មានដែលមានចែងក្នុងបញ្ញត្តិនៃកថាខណ្ឌទី១ខាងលើ ចាំបាច់ត្រូវមានលក្ខណៈគ្រប់គ្រាន់ ដើម្បីឱ្យអ្នកប្រើប្រាស់អាចធ្វើការសម្រេចចិត្តលើប្រតិបត្តិការពាណិជ្ជកម្មនិងរក្សាទុកជាព័ត៌មាន។

៣. បញ្ញត្តិនៃមាត្រានេះមិនយកមកអនុវត្តចំពោះវិស័យមូលបត្រនិងធានារ៉ាប់រងឡើយ។

**មាត្រា៣០ .- ទំនាក់ទំនងពាណិជ្ជកម្មដែលមិនបានស្នើសុំ**

បុគ្គលណាក៏ដោយ ទោះបីជាមានទីតាំងអាជីវកម្មក្នុងឬក្រៅព្រះរាជាណាចក្រកម្ពុជាដែលផ្ញើទំនាក់ទំនងពាណិជ្ជកម្មដែលមិនបានស្នើសុំទៅកាន់អ្នកប្រើប្រាស់ដែលស្ថិតនៅក្នុងឬក្រៅព្រះរាជាណាចក្រកម្ពុជា តាមរយៈប្រព័ន្ធផ្សព្វផ្សាយ ឬតាមរយៈអន្តរការី ឬអ្នកផ្តល់សេវាទូរគមនាគមន៍ ត្រូវផ្តល់ជម្រើសច្បាស់លាស់និងងាយស្រួលសម្រាប់ឱ្យអ្នកប្រើប្រាស់អាចធ្វើការបដិសេធមិនទទួលយកទំនាក់ទំនងពាណិជ្ជកម្មដែលមិនបានស្នើសុំនោះ។

**មាត្រា៣១ .- ការបង្កើតប្រព័ន្ធអេឡិចត្រូនិកក្លែងបន្លំនិងកូដព្យាបាទ**

១. បុគ្គលទាំងឡាយមិនត្រូវបង្កើតប្រព័ន្ធអេឡិចត្រូនិក ក្នុងគោលបំណងក្លែងបន្លំឬបង្កការភាន់ច្រឡំ ដើម្បីទាញយកផលប្រយោជន៍ ឬក្នុងគោលបំណងទាក់ទាញឱ្យមានការប្រើប្រាស់ឬធ្វើប្រតិបត្តិការ ហើយនាំឱ្យមានព្យសនកម្មដល់បុគ្គលដែលប្រើប្រាស់នោះឬតតិយជនឡើយ។

២. បុគ្គលទាំងឡាយមិនត្រូវបង្កើត ផ្តល់ បង្កលទ្ធភាព ចែកចាយ ឬបញ្ជូននូវលេខកូដចម្លងមេរោគ ក្នុងគោលបំណងទុច្ចរិត តាមមធ្យោបាយអេឡិចត្រូនិក ទៅក្នុងឧបករណ៍ឬប្រព័ន្ធអេឡិចត្រូនិករបស់បុគ្គលផ្សេងទៀតឡើយ។

**មាត្រា៣២ .- ការការពារទិន្នន័យ**

១. បុគ្គលដែលរក្សាព័ត៌មានជាលក្ខណៈឯកជនក្រោមទម្រង់អេឡិចត្រូនិក ត្រូវប្រើគ្រប់មធ្យោបាយដើម្បីធានាថា ព័ត៌មាននោះត្រូវបានការពារប្រកបដោយសុវត្ថិភាពគ្រប់កាលៈទេសៈសមហេតុផល ដើម្បីជៀសវាង ការបាត់បង់ ការចូល ការប្រើប្រាស់ ការកែប្រែ ការបែកធ្លាយ ឬការលាតត្រដាងព័ត៌មានទាំងនោះ លើកលែងតែមានការអនុញ្ញាតពីម្ចាស់នៃព័ត៌មាននោះឬពីភាគីផ្សេងទៀតដែលអនុញ្ញាតដោយច្បាប់។

២. បុគ្គលទាំងឡាយមិនត្រូវជ្រៀតជ្រែកក្នុងប្រព័ន្ធអេឡិចត្រូនិក ចូលប្រើប្រាស់ ទាញយក ថតចម្លង ស្រង់យក ធ្វើឱ្យបែកធ្លាយ លុបបំបាត់ ឬកែប្រែទិន្នន័យ ដែលស្ថិតក្រោមការរក្សាទុករបស់បុគ្គលផ្សេងទៀត ដោយទុច្ចរិត ឬគ្មានការអនុញ្ញាតឡើយ។

**មាត្រា៣៣ .- ការអនុវត្តបទប្បញ្ញត្តិទាក់ទងនឹងកិច្ចការពារអ្នកប្រើប្រាស់**

បុគ្គលដែលប្រើប្រាស់ទំនាក់ទំនងអេឡិចត្រូនិកក្នុងសកម្មភាពពាណិជ្ជកម្មជាមួយអ្នកប្រើប្រាស់ក៏ត្រូវអនុវត្តតាមបទប្បញ្ញត្តិនានាទាក់ទងនឹងកិច្ចការពារអ្នកប្រើប្រាស់ផងដែរ។

## ជំពូកទី៧
## សកម្មភាពនិងប្រតិបត្តិការរបស់រដ្ឋតាមប្រព័ន្ធអេឡិចត្រូនិក

**មាត្រា៣៤ .- ការទទួលស្គាល់ទំនាក់ទំនងអេឡិចត្រូនិកដោយស្ថាប័នរដ្ឋ**

១. ក្រសួងឬស្ថាប័នរដ្ឋនានាអាចប្រើប្រាស់ទម្រង់អេឡិចត្រូនិកសម្រាប់សកម្មភាពនិងប្រតិបត្តិការ ដូចខាងក្រោម៖

ក. ការទទួលចុះបញ្ជីឯកសារ ឬការបំពេញលក្ខខណ្ឌតម្រូវ សម្រាប់បង្កើតឬរក្សាទុកឯកសារ។

ខ. ការចេញអាជ្ញាបណ្ណឬលិខិតអនុញ្ញាត។

គ. ការកំណត់មធ្យោបាយនិងរបៀបក្នុងការទូទាត់ប្រាក់។ ឬ

ឃ. សកម្មភាពផ្សេងទៀតដែលកំណត់ដោយក្រសួង ឬស្ថាប័នរដ្ឋ។

២. នៅពេលដែល ក្រសួង ឬស្ថាប័នរដ្ឋសម្រេចប្រើប្រាស់ទំនាក់ទំនងអេឡិចត្រូនិកសម្រាប់សកម្មភាព ឬប្រតិបត្តិការណាមួយ ដូចមានចែងក្នុងបញ្ញត្តិនៃកថាខណ្ឌទី១ខាងលើ ក្រសួងឬស្ថាប័ននោះអាចបញ្ជាក់៖

ក. របៀបនិងទម្រង់ដែលព័ត៌មានក្នុងទំនាក់ទំនងអេឡិចត្រូនិកត្រូវទទួលចុះបញ្ជី បង្កើត រក្សាទុក ឬបោះផ្សាយ។

ខ. ប្រភេទនៃហត្ថលេខាដែលតម្រូវឱ្យធ្វើនៅពេលដែលមានការតម្រូវឱ្យចុះហត្ថលេខាក្នុងទំនាក់ទំនងអេឡិចត្រូនិកនោះ។

គ. របៀបនិងទម្រង់ដែលហត្ថលេខានោះត្រូវភ្ជាប់ក្នុងទំនាក់ទំនងអេឡិចត្រូនិក។

ឃ. ដំណើរការគ្រប់គ្រងនិងនីតិវិធីដែលសមស្របដើម្បីធានាសុក្រឹតភាព សុវត្ថិភាព និងការរក្សាការសម្ងាត់នៃទំនាក់ទំនងអេឡិចត្រូនិក ឬការទូទាត់ប្រាក់ និង

ង. លក្ខខណ្ឌកំណត់ផ្សេងទៀតដែលផ្តល់តម្លៃសមមូលរវាងឯកសារ ឬការទូទាត់ក្នុងទម្រង់អេឡិចត្រូនិក ជាមួយនឹងឯកសារ ឬការទូទាត់ក្នុងទម្រង់ជាលាយលក្ខណ៍អក្សរ។

## ជំពូកទី៨

## ភស្តុតាងអេឡិចត្រូនិក

**មាត្រា៣៥ .- ការទទួលយកជាទូទៅនូវភស្តុតាងអេឡិចត្រូនិក**

គ្មានបទប្បញ្ញត្តិនៃវិធានស្តីពីភស្តុតាងណាមួយដែលយកមកអនុវត្ត ដើម្បីបដិសេធក្នុងការទទួលយកជាទូទៅនូវកំណត់ត្រាអេឡិចត្រូនិកធ្វើជាភស្តុតាង ដោយហេតុផលគ្រាន់តែសម្អាងលើមូលដ្ឋានថា វាជាកំណត់ត្រាអេឡិចត្រូនិកនោះឡើយ ទោះបីជាភស្តុតាងនោះមិនស្ថិតក្នុងទម្រង់ដើមក៏ដោយ។

**មាត្រា៣៦ .- សុក្រឹតភាពនៃប្រព័ន្ធអេឡិចត្រូនិក**

១. នៅក្នុងដំណើរការនីតិវិធីតាមផ្លូវច្បាប់ សុពលភាពនៃភស្តុតាងអេឡិចត្រូនិកអាចត្រូវបានបញ្ជាក់តាមរយៈសុក្រឹតភាពនៃប្រព័ន្ធអេឡិចត្រូនិក ដែលបានកត់ត្រាឬរក្សាទុកនូវទិន្នន័យណាមួយ។

២. លើកលែងតែមានភស្តុតាងផ្ទុយ ប្រព័ន្ធអេឡិចត្រូនិកដែលបានប្រើប្រាស់សម្រាប់កត់ត្រា ឬរក្សាទុកកំណត់ត្រាអេឡិចត្រូនិក ត្រូវបានសន្មតថាមានសុក្រឹតភាព ក្នុងដំណើរការនីតិវិធីតាមផ្លូវច្បាប់ តាមលក្ខខណ្ឌណាមួយដូចខាងក្រោម៖

ក. ក្នុងករណីមានភស្តុតាងគាំទ្រដល់អង្គហេតុណាមួយដែលបញ្ជាក់ថាប្រព័ន្ធអេឡិចត្រូនិកឬឧបករណ៍ស្រដៀងគ្នាផ្សេងទៀត បានដំណើរការជាប្រក្រតីនៅពេលដែលកំណត់ត្រាអេឡិចត្រូនិកនោះត្រូវបានកត់ត្រាឬរក្សាទុកឬនៅពេលដែលយកទៅធ្វើជាភស្តុតាង ឬក្នុងករណីដែលប្រព័ន្ធអេឡិចត្រូនិក ឬឧបករណ៍ ស្រដៀងគ្នាផ្សេងទៀតនោះមិនបានដំណើរការជាប្រក្រតី ឬឈប់ដំណើរការទាំងស្រុង ប៉ុន្តែមិនធ្វើឱ្យប៉ះពាល់ដល់សុក្រឹតភាពនៃកំណត់ត្រាអេឡិចត្រូនិក ហើយគ្មានមូលហេតុ សមស្របណាផ្សេងយកមកជំទាស់សុក្រឹតភាពនៃកំណត់ត្រានោះ។

ខ. ក្នុងករណីមានភស្តុតាងអាចបង្ហាញបានថា កំណត់ត្រាអេឡិចត្រូនិកត្រូវបានកត់ត្រាឬរក្សាទុក ដោយភាគីដែលមានផលប្រយោជន៍ផ្ទុយគ្នាទៅនឹងភាគីម្ខាងទៀតដែលប្រើប្រាស់កំណត់ត្រាអេឡិចត្រូនិកនោះជាភស្តុតាងក្នុងដំណើរការនីតិវិធីតាមផ្លូវច្បាប់។ ឬ

គ. នៅពេលដែលមានភស្តុតាងអាចបង្ហាញបានថា កំណត់ត្រាអេឡិចត្រូនិកត្រូវបានកត់ត្រាឬរក្សាទុកជាប្រក្រតីក្នុងគោលបំណងអាជីវកម្មធម្មតាដោយបុគ្គលដែលមិនមែនជាភាគីក្នុងដំណើរការនីតិវិធីតាមផ្លូវច្បាប់ ហើយបុគ្គលនោះមិនបានកត់ត្រាឬរក្សាទុកនូវកំណត់ត្រាអេឡិចត្រូនិកក្រោមការគ្រប់គ្រងរបស់ភាគីដែលប្រើប្រាស់កំណត់ត្រាអេឡិចត្រូនិកនោះជាភស្តុតាងក្នុងដំណើរការនីតិវិធីតាមផ្លូវច្បាប់។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

**មាត្រា៣៧ ._ សុក្រឹតភាពនៃព័ត៌មាន**

១. លើកលែងតែមានភស្តុតាងផ្ទុយពីនេះ កំណត់ត្រាអេឡិចត្រូនិកដែលបានកត់ត្រាឬរក្សាទុកនៅក្នុងប្រព័ន្ធអេឡិចត្រូនិកត្រូវបានសន្មតថាមានសុក្រឹតភាពនៅក្នុងដំណើរការនីតិវិធីតាមផ្លូវច្បាប់ ប្រសិនបើកំណត់ត្រាអេឡិចត្រូនិកនោះ៖

ក. នៅពេញលេញនិងគ្មានការកែប្រែក្រៅពីការធ្វើបដិលេខបន្ថែមណាមួយ ឬការផ្លាស់ប្តូរដែលមិនសំខាន់ណាមួយដែលកើតឡើងនៅក្នុងដំណើរការជាប្រក្រតីនៃទំនាក់ទំនង ការរក្សាទុកឬការបង្ហាញ។

ខ. ត្រូវបានបញ្ជាក់ឬចុះហត្ថលេខានៅក្នុងទម្រង់អេឡិចត្រូនិក តាមរយៈមធ្យោបាយដែលផ្តល់ឱ្យដោយអ្នកផ្តល់នីតិវិធីសុវត្ថិភាពដែលមានអាជ្ញាបណ្ណត្រឹមត្រូវ។

គ. មានសុក្រឹតភាពនិងមានខ្លឹមសារដែលត្រូវបានបញ្ជាក់ដោយក្រសួងឬស្ថាប័នមានសមត្ថកិច្ច។

ឃ. ត្រូវបានកត់ត្រាទុកនៅក្នុងឧបករណ៍រក្សាទុកឬតាមមធ្យោបាយអេឡិចត្រូនិកផ្សេងទៀតដែលមិនអនុញ្ញាតឱ្យមានការកែប្រែទៅលើកំណត់ត្រាអេឡិចត្រូនិក។

ង. ត្រូវបានត្រួតពិនិត្យនិងបញ្ជាក់ពីសុក្រឹតភាព ដោយអ្នកជំនាញដែលត្រូវបានតែងតាំងដោយតុលាការ។

ច. នៅពេលដែលមានភស្តុតាងគាំទ្រដល់អង្គហេតុណាមួយ ដែលបញ្ជាក់ថាប្រព័ន្ធអេឡិចត្រូនិកឬឧបករណ៍ស្រដៀងគ្នាផ្សេងទៀតបានដំណើរការជាប្រក្រតីនៅគ្រប់រយៈពេលសំខាន់ៗ ឬក្នុងករណីដែលប្រព័ន្ធអេឡិចត្រូនិកឬឧបករណ៍ស្រដៀងគ្នាផ្សេងទៀតនោះមិនបានដំណើរការជាប្រក្រតីឬឈប់ដំណើរការទាំងស្រុង តែសុក្រឹតភាពនៃកំណត់ត្រាមិនរងការប៉ះពាល់ដោយសារស្ថានភាពទាំងនោះទេ ហើយគ្មានមូលហេតុសមស្របណាផ្សេងទៀតដែលចោទជាមន្ទិលសង្ស័យលើសុក្រឹតភាពនៃកំណត់ត្រានោះឡើយ។ ឬ

ឆ. នៅពេលដែលមានភស្តុតាងអាចបង្ហាញបានថាកំណត់ត្រាអេឡិចត្រូនិកត្រូវបានកត់ត្រាឬរក្សាទុកដោយភាគីដែលចូលរួមនៅក្នុងដំណើរការនីតិវិធីតាមផ្លូវច្បាប់នោះ ហើយដែលភាគីមានទំនាស់ផលប្រយោជន៍ផ្ទុយគ្នាទៅនឹងភាគីម្ខាងទៀត ដែលមានបំណងប្រើប្រាស់កំណត់ត្រាអេឡិចត្រូនិកនោះ។

២. នៅពេលដែលមានភស្តុតាងអាចបង្ហាញបានថាកំណត់ត្រាអេឡិចត្រូនិកត្រូវបានកត់ត្រាឬរក្សាទុកតាមធម្មតានិងក្នុងគោលបំណងអាជីវកម្មធម្មតា ដោយបុគ្គលដែលមិនមែនជាភាគីនៅក្នុងដំណើរការនីតិវិធីតាមផ្លូវច្បាប់ ហើយបុគ្គលនោះមិនបានកត់ត្រាឬរក្សាទុកនូវកំណត់ត្រាអេឡិចត្រូនិក ក្រោមការគ្រប់គ្រងរបស់ភាគីដែលមានបំណងប្រើប្រាស់កំណត់ត្រាអេឡិចត្រូនិកនោះ។

៣. នៅពេលដែលរបាយការណ៍ត្រូវបានកត់ត្រាទុកនៅក្នុងកំណត់ត្រាអេឡិចត្រូនិក ដែលត្រូវបានបង្កើតឡើងដោយប្រព័ន្ធអេឡិចត្រូនិក មិនត្រូវបានចាត់ទុកថាជាពាក្យចចាមអារ៉ាមទេនោះ របាយការណ៍ទាំងនោះអាចទទួលយកបាន ប្រសិនបើលក្ខខណ្ឌដូចដែលមានចែងនៅក្នុងបញ្ញត្តិនៃកថាខណ្ឌទី២ ទាក់ទងនឹងកំណត់ត្រាអេឡិចត្រូនិកនោះត្រូវបានបំពេញ។

**មាត្រា៣៨ .- ឯកសារដែលបានបោះពុម្ពចេញ**

ឯកសារដែលបានបោះពុម្ពចេញត្រឹមត្រូវស្របនឹងខ្លឹមសារដើមចេញពីកំណត់ត្រាអេឡិចត្រូនិក អាចយកមកប្រើប្រាស់ជាភស្តុតាងបានក្នុងដំណើរការនីតិវិធីតាមផ្លូវច្បាប់។

**មាត្រា៣៩ .- បន្ទុកក្នុងការបង្ហាញអំពីយថាភូតភាពនៃភស្តុតាងអេឡិចត្រូនិក**

១. បុគ្គលដែលស្នើសុំបង្ហាញកំណត់ត្រាអេឡិចត្រូនិកក្នុងដំណើរការនីតិវិធីតាមផ្លូវច្បាប់ណាមួយ បុគ្គលនោះត្រូវទទួលបន្ទុកបង្ហាញពីយថាភូតភាពនៃកំណត់ត្រាអេឡិចត្រូនិកដោយមានភស្តុតាងគាំទ្រដល់កំណត់ត្រាដែលបានបង្ហាញ។

២. ក្នុងករណីមានបទប្បញ្ញត្តិណាមួយការពារបុគ្គលងាយរងគ្រោះដែលរាប់បញ្ចូលទាំងអ្នកប្រើប្រាស់និងកុមារ ហើយដែលមានកំណត់អំពីបន្ទុកនៃការបង្ហាញភស្តុតាងដែលផ្តល់ប្រយោជន៍ដល់បុគ្គលទាំងនោះច្រើនជាងច្បាប់នេះ បទប្បញ្ញត្តិនោះត្រូវមានអាទិភាពជាងមាត្រានេះ។

**មាត្រា៤០ .- បទដ្ឋាននៃការកត់ត្រាឬការរក្សាទុកកំណត់ត្រាអេឡិចត្រូនិក**

ដើម្បីកំណត់បានថាកំណត់ត្រាអេឡិចត្រូនិកត្រូវទទួលយកឬមិនទទួលយកក្នុងបទប្បញ្ញត្តិផ្សេងទៀត ការបង្ហាញភស្តុតាងអាចត្រូវធ្វើឡើងដោយផ្អែកលើបទដ្ឋាន នីតិវិធី ការប្រើឬការអនុវត្តនៃការកត់ត្រាឬរក្សាទុកកំណត់ត្រាអេឡិចត្រូនិក ដោយត្រូវពិនិត្យពិចារណាអំពីប្រភេទអាជីវកម្ម ចរិតលក្ខណៈ និងគោលបំណងនៃកំណត់ត្រាអេឡិចត្រូនិកនោះ។

**មាត្រា៤១ .- ការចេញលិខិតបញ្ជាក់យថាភូតភាព**

១. ក្នុងករណីដែលបុគ្គលណាមួយមានបំណងចង់បង្ហាញយថាភូតភាពនៃកំណត់ត្រាអេឡិចត្រូនិកមួយដើម្បីធ្វើជាភស្តុតាង បុគ្គលនោះអាចស្នើសុំភស្តុតាងនោះពីអ្នកជំនាញពាក់ព័ន្ធនឹងយថាភូតភាពនៃកំណត់ត្រាអេឡិចត្រូនិកនោះក្រោមទម្រង់ជាលិខិតបញ្ជាក់។

២. លិខិតបញ្ជាក់យថាភូតភាពដូចមានចែងក្នុងបញ្ញត្តិនៃកថាខណ្ឌទី១ខាងលើត្រូវចេញដោយ៖

ក. ក្រសួង ស្ថាប័នមានសមត្ថកិច្ច ឬបុគ្គលដែលទទួលខុសត្រូវពាក់ព័ន្ធនឹងប្រតិបត្តិការ ឬការគ្រប់គ្រងអ្នកបង្កើតនីតិវិធីសុវត្ថិភាពជាក់លាក់ណាមួយ ឬអ្នកបង្កើតនីតិវិធីសុវត្ថិភាពដែលទទួលស្គាល់ដោយតុលាការ។ ឬ

ខ. អ្នកជំនាញដែលតែងតាំងឬដែលទទួលស្គាល់ដោយតុលាការ។

៣. បុគ្គលដែលមានសមត្ថកិច្ចក្នុងការចេញលិខិតបញ្ជាក់យថាភូតភាព ដូចមានចែងក្នុងបញ្ញត្តិនៃកថាខណ្ឌទី២ខាងលើ មិនត្រូវក្លែងឬចេញលិខិតបញ្ជាក់យថាភូតភាពនៃកំណត់ត្រាឬភស្តុតាងអេឡិចត្រូនិកដែលមានលក្ខណៈក្លែងបន្លំឬមិនមែនជាការពិតនោះឡើយ។

**មាត្រា៤២ .- នីតិវិធីផ្សេងទៀតក្នុងការបង្កើតភស្តុតាងអេឡិចត្រូនិក**

បន្ថែមលើមធ្យោបាយបង្ហាញភស្តុតាងដូចមានចែងក្នុងច្បាប់នេះ ភស្តុតាងអេឡិចត្រូនិក អាចត្រូវបានបង្កើតឡើង តាមបច្ចេកទេសនិងនីតិវិធីផ្សេងទៀតដូចជា ការបញ្ជាក់ដោយសារការី ឬស្ថាប័នមានសមត្ថកិច្ច កំណត់ត្រាក្នុងមធ្យោបាយអេឡិចត្រូនិកដែលមិនអនុញ្ញាតឱ្យមានការ កែប្រែបាន និងលទ្ធផលកោសល្យវិច័យលើប្រព័ន្ធអេឡិចត្រូនិកតាមការរកឃើញរបស់យុត្តាធិការ តុលាការ។

**មាត្រា៤៣ .- ការបំពានលើកូដនីយកម្ម**

បុគ្គលទាំងឡាយមិនត្រូវដាក់កូដក្នុងទំនាក់ទំនងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដែលជាភស្តុតាងអាចនាំទៅដល់ការចោទប្រកាន់ ឬការដាក់កូដលើទិន្នន័យ ឬភស្តុតាងក្នុងប្រព័ន្ធ អេឡិចត្រូនិកដែលទាក់ទិននឹងបទល្មើសឡើយ។

**មាត្រា៤៤ .- ការទទួលយកកំណត់ត្រាអេឡិចត្រូនិកពីបរទេស**

ភស្តុតាងអេឡិចត្រូនិកដែលបញ្ជាក់ដោយក្រសួងឬស្ថាប័នមានសមត្ថកិច្ចនៃបណ្តារដ្ឋបរទេស ត្រូវបានទទួលយកជាភស្តុតាង ប្រសិនបើប្រព័ន្ធអេឡិចត្រូនិកដែលកត់ត្រាឬរក្សាទុកកំណត់ត្រា អេឡិចត្រូនិកនោះមានសុក្រឹតភាពស្របតាមបទដ្ឋាន ដូចមានចែងក្នុងជំពូកទី៨នៃច្បាប់នេះ។

**មាត្រា៤៥ .- ការទទួលយកព័ត៌មានអេឡិចត្រូនិកមកពីបរទេស**

ដើម្បីកំណត់ថាព័ត៌មានក្នុងទម្រង់អេឡិចត្រូនិកមួយអាចទទួលយកឬមិនអាចទទួលយក បាន ឬអាចទទួលយកបានត្រឹមកម្រិតណាមួយនោះ មិនត្រូវគិតពីទីតាំងដែលព័ត៌មាននោះត្រូវ បានបង្កើតឡើងឬត្រូវបានប្រើប្រាស់ ឬទីតាំងអាជីវកម្មដែលបានបង្កើតឡើងនៅបរទេសនោះ ឡើយ ឱ្យតែកំណត់ត្រាអេឡិចត្រូនិកនោះអាចចូលនិងទាញយកមកប្រើបាននៅក្នុងដែនសមត្ថកិច្ច នៃព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី៩
## ការទូទាត់និង/ឬការផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក

**មាត្រា៤៦ .- ប្រតិបត្តិការទូទាត់តាមប្រព័ន្ធអេឡិចត្រូនិក**

១. បុគ្គលណាដែលធ្វើប្រតិបត្តិការប្រព័ន្ធទូទាត់ ផ្តល់សេវាទូទាត់ ចេញផ្សាយឧបករណ៍ ទូទាត់ប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក ឬផ្តល់មធ្យោបាយទូទាត់ប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក ឬ ធ្វើប្រតិបត្តិការណាដែលត្រូវបានចាត់ទុកថាជាការផ្តល់ការទូទាត់សងប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក ដល់សាធារណជនត្រូវស្នើសុំការអនុញ្ញាតឬអាជ្ញាបណ្ណជាមុនពីធនាគារជាតិនៃកម្ពុជា។

២. ធនាគារជាតិនៃកម្ពុជាជាស្ថាប័នមានសមត្ថកិច្ចក្នុងការរៀបចំបទប្បញ្ញត្តិទាក់ទងនឹង ការទូទាត់ប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក។

**មាត្រា៤៧ ._ ការទទួលខុសត្រូវរបស់បុគ្គលផ្តល់សេវាទូទាត់**

១. បុគ្គលផ្តល់សេវាទូទាត់មិនត្រូវផ្តល់ជូនអតិថិជននូវឧបករណ៍ទូទាត់ ដែលអតិថិជនមិនបានស្នើសុំនោះទេ លើកលែងតែករណីដែលបណ្ណទូទាត់នោះជាបណ្ណទូទាត់ហួសរយៈពេលប្រើប្រាស់ ឬដល់ពេលត្រូវផ្លាស់ប្តូរ។

២. មុនពេលធ្វើប្រតិបត្តិការផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក បុគ្គលផ្តល់សេវាត្រូវបញ្ជាក់ឱ្យបានច្បាស់ពីអត្តសញ្ញាណរបស់អតិថិជននិងផ្ទៀងផ្ទាត់ឡើងវិញនូវភាពត្រឹមត្រូវនៃការផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក។ បុគ្គលផ្តល់សេវាទូទាត់ត្រូវទទួលខុសត្រូវលើករណីដូចខាងក្រោម៖

ក. ប្រតិបត្តិការកើតឡើងដោយគ្មានការអនុញ្ញាតពីអតិថិជន។

ខ. ប្រតិបត្តិការកើតឡើងបន្ទាប់ពីដឹងថាមានការបន្លំ បាត់បង់ ឬចោរកម្មនៃឧបករណ៍ផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក។

គ. ប្រតិបត្តិការកើតឡើងបន្ទាប់ពីមានការជូនដំណឹងពីអតិថិជនដូចមានចែងក្នុងមាត្រា៤៨ខាងក្រោម។

ឃ. ការខកខានមិនបានប្រតិបត្តិតាមបញ្ជារបស់អតិថិជនឬការប្រតិបត្តិខុសពីបញ្ជារបស់អតិថិជន។ ឬ

ង. ភាពមិនប្រក្រតីនៃប្រព័ន្ធបច្ចេកទេស កំហុសក្នុងការប្រើប្រាស់ប្រព័ន្ធបច្ចេកទេស ឬភាពខ្វះខាតនៃឧបករណ៍ផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក។

៣. បុគ្គលផ្តល់សេវាទូទាត់អាចរួចផុតពីការទទួលខុសត្រូវបានតែក្នុងករណីប្រធានស័ក្តិ ឬជាកំហុសរបស់អតិថិជនផ្ទាល់ប៉ុណ្ណោះ។

៤. ក្នុងករណីដែលបុគ្គលផ្តល់សេវាទូទាត់ត្រូវទទួលខុសត្រូវ បុគ្គលផ្តល់សេវាទូទាត់ត្រូវសងថ្លៃខូចខាតជូនអតិថិជនក្នុងរយៈពេលមិនឱ្យលើសពី៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលការជូនដំណឹងពីអតិថិជនដូចមានចែងក្នុងមាត្រា៤៨នៃច្បាប់នេះ នូវតម្រៃប្រតិបត្តិការដែលបានខាតបង់សោហ៊ុយ និងការពិន័យក្នុងការបង់ការប្រាក់យឺតយ៉ាវដែលកើតចេញពីប្រតិបត្តិការនេះដោយ មិនទាន់គិតបញ្ចូលការសងថ្លៃខូចខាតដទៃទៀតដែលអាចកើតឡើងចំពោះអតិថិជន។

៥. បុគ្គលទាំងឡាយមិនត្រូវចេញផ្សាយបណ្ណទូទាត់ ឬកែប្រែបណ្ណទូទាត់ទៅជាទម្រង់ណាមួយដែលខុសពីទម្រង់ដើម ដោយគ្មានការអនុញ្ញាតក្នុងគោលបំណងទុច្ចរិត ឆបោក ឬក្លែងបន្លំដែលនាំឱ្យមានព្យសនកម្មដល់បុគ្គលមួយផ្សេងទៀតឡើយ។

**មាត្រា៤៨ ._ ការទទួលខុសត្រូវរបស់អតិថិជន**

១. អតិថិជនត្រូវជូនដំណឹងដល់បុគ្គលផ្តល់សេវាទូទាត់ អំពីប្រតិបត្តិការដែលកើតឡើងដោយគ្មានការអនុញ្ញាត កំហុសឆ្គង ឬភាពមិនត្រឹមត្រូវផ្សេងទៀតនៅក្នុងគណនីរបស់ខ្លួន។

២. អតិថិជនត្រូវជូនដំណឹងដល់បុគ្គលផ្តល់សេវាទូទាត់ឬគ្រឹះស្ថានដែលទទួលបានការអនុញ្ញាតពីបុគ្គលផ្តល់សេវាទូទាត់អំពីករណីបាត់បង់ឬអំពើចោរកម្មលើឧបករណ៍/មធ្យោបាយផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក ឬការលួចយកទិន្នន័យសម្រាប់ប្រើប្រាស់ជាមួយឧបករណ៍ទូទាត់។ ការជូនដំណឹងនេះអាចធ្វើឡើងជាលាយលក្ខណ៍អក្សរឬតាមមធ្យោបាយអេឡិចត្រូនិកណាមួយដែលទទួលយកដោយបុគ្គលផ្តល់សេវាទូទាត់ ហើយត្រូវជូនដំណឹងជាបន្ទាន់តាមលទ្ធភាពដែលអាចធ្វើទៅបានឬមិនឱ្យលើសរយៈពេល២(ពីរ)ថ្ងៃ បន្ទាប់ពីបានដឹងថាមានករណីចោរកម្មឬបាត់បង់ឧបករណ៍ទូទាត់កើតឡើង។

៣. ក្នុងករណីមានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថាការបាត់បង់ឬការខូចខាតក្នុងករណីខាងលើជាកំហុសរបស់អតិថិជន បុគ្គលផ្តល់សេវាទូទាត់មានសិទ្ធិទាមទារឱ្យអតិថិជនទទួលខុសត្រូវទាំងស្រុងចំពោះការបាត់បង់ឬការខូចខាតនោះ។

៤. ក្នុងករណីមិនមានភស្តុតាងបញ្ជាក់អំពីកំហុសរបស់អតិថិជនទេ បុគ្គលផ្តល់សេវាទូទាត់ត្រូវទទួលខុសត្រូវទាំងស្រុងចំពោះការបាត់បង់ឬការខូចខាតនោះ ដោយឥតលក្ខខណ្ឌ។

## ជំពូកទី១០
## សមត្ថកិច្ច ការប្តឹងតវ៉ា និងនីតិវិធីនៃការផាកពិន័យ

### មាត្រា៤៩ .- សមត្ថកិច្ច

ការព្រមានជាលាយលក្ខណ៍អក្សរ ការបញ្ឈប់សកម្មភាពឬប្រតិបត្តិការអាជីវកម្ម ការព្យួរ ការដកហូត ឬការលុបចោលលិខិតអនុញ្ញាតឬអាជ្ញាបណ្ណ និងការផាកពិន័យ ជាសមត្ថកិច្ចរបស់ក្រសួងពាណិជ្ជកម្មនិងក្រសួងប្រៃសណីយនិងទូរគមនាគមន៍។

ក្នុងករណីដែលបុគ្គលមិនអនុវត្តតាមវិធានការខាងលើ ក្រសួងពាណិជ្ជកម្មនិងក្រសួងប្រៃសណីយនិងទូរគមនាគមន៍ អាចធ្វើបណ្តឹងទៅតុលាការមានសមត្ថកិច្ច។

### មាត្រា៥០ .- នីតិវិធីនៃការប្តឹងតវ៉ា

១. បុគ្គលដែលមិនសុខចិត្តនឹងការព្រមានជាលាយលក្ខណ៍អក្សរ ការបញ្ឈប់សកម្មភាពឬប្រតិបត្តិការអាជីវកម្ម ការព្យួរ ការដកហូត ឬការលុបចោលលិខិតអនុញ្ញាតឬអាជ្ញាបណ្ណ និងការផាកពិន័យរបស់ក្រសួងពាណិជ្ជកម្មនិងក្រសួងប្រៃសណីយនិងទូរគមនាគមន៍ មានសិទ្ធិប្តឹងតវ៉ាទៅរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មនិងក្រសួងប្រៃសណីយនិងទូរគមនាគមន៍។

២. រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មនិងក្រសួងប្រៃសណីយនិងទូរគមនាគមន៍ត្រូវសម្រេចក្នុងរយៈពេល៣០(សាមសិប)ថ្ងៃយ៉ាងយូរ។

៣. បុគ្គលណាមួយដែលមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មនិងក្រសួងប្រៃសណីយនិងទូរគមនាគមន៍ មានសិទ្ធិប្តឹងតវ៉ាទៅតុលាការមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជាបានក្នុងរយៈពេល៣០(សាមសិប)ថ្ងៃយ៉ាងយូរ គិតចាប់ពីថ្ងៃទទួលបានសេចក្តីជូនដំណឹងនៃសេចក្តីសម្រេចនោះ។

**មាត្រា៥១ .- នីតិវិធីនៃការផាកពិន័យ**

នីតិវិធីនៃការផាកពិន័យ ការបង់ប្រាក់ផាកពិន័យ ការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់ពិន័យ និងការចាត់ចែងប្រាក់ចំណូលដែលបានពីការផាកពិន័យ ដូចមានចែងនៅក្នុងបទប្បញ្ញត្តិច្បាប់នេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។

## ជំពូកទី១១
## ទោសប្បញ្ញត្តិ

**មាត្រា៥២ .- ទណ្ឌកម្ម**

ទណ្ឌកម្មនៅក្នុងច្បាប់នេះរួមមាន ការព្រមានជាលាយលក្ខណ៍អក្សរ ការបញ្ឈប់សកម្មភាព ឬប្រតិបត្តិការអាជីវកម្ម ការព្យួរ ការដកហូត ឬការលុបចោលលិខិតអនុញ្ញាតឬអាជ្ញាបណ្ណ ការផាកពិន័យ ទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់។

**មាត្រា៥៣ .- អំពើល្មើសលើការលួចប្រើប្រាស់អត្តសញ្ញាណ**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦(ប្រាំមួយ)ខែទៅ៣(បី)ឆ្នាំនិងត្រូវពិន័យជាប្រាក់ពី ១ ០០០ ០០០(មួយលាន)រៀលទៅ៦ ០០០ ០០០(ប្រាំមួយលាន)រៀល ចំពោះបុគ្គលណាដែលប្រព្រឹត្តអំពើផ្ទុយនឹងបញ្ញត្តិនៃមាត្រា២២។

**មាត្រា៥៤ .- អំពើល្មើសលើការមិនរាយការណ៍អំពីព័ត៌មានឬហេតុការណ៍**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែទៅ១(មួយ)ឆ្នាំនិងត្រូវពិន័យជាប្រាក់ពី១០០ ០០០(មួយសែន)រៀលទៅ២ ០០០ ០០០(ពីរលាន)រៀល ចំពោះអំពើរបស់អន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកដែលប្រព្រឹត្តអំពើផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី១និងកថាខណ្ឌទី២នៃមាត្រា២៥។

**មាត្រា៥៥ .- អំពើផ្តល់ពត៌មានមិនពិត**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែទៅ១(មួយ)ឆ្នាំនិងត្រូវពិន័យជាប្រាក់ពី១០០ ០០០(មួយសែន)រៀលទៅ២ ០០០ ០០០(ពីរលាន)រៀល ចំពោះបុគ្គលណាដែលប្រព្រឹត្តអំពើដូចមានចែងក្នុងបញ្ញត្តិនៃកថាខណ្ឌទី៥នៃមាត្រា២៥។

**មាត្រា៥៦ .- ការធ្វើប្រតិបត្តិការដោយគ្មានការអនុញ្ញាត**

ត្រូវបញ្ឈប់សកម្មភាពឬប្រតិបត្តិការអាជីវកម្មនិងត្រូវទទួលការផាកពិន័យជាប្រាក់មិនលើសពី១០ ០០០ ០០០(ដប់លាន)រៀល ចំពោះបុគ្គលទាំងឡាយណាដែលប្រព្រឹត្តផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី១នៃមាត្រា២៦។

ក្នុងករណីធ្លាប់ទទួលរងនូវវិធានការដូចមានចែងក្នុងកថាខណ្ឌទី១ជាស្ថាពររួចហើយ ហើយបានប្រព្រឹត្តបទល្មើសដដែលនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំទៅ៣(បី)ឆ្នាំ និងត្រូវពិន័យជាប្រាក់ពី២ ០០០ ០០០(ពីរលាន)រៀលពី៦ ០០០ ០០០(ប្រាំមួយលាន)រៀល។



**មាត្រា៥៧ .- អំពើល្មើសលើការមិនអនុវត្តតាមបទប្បញ្ញត្តិស្តីពីព័ត៌មានអប្បបរមាក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក**

ត្រូវទទួលការព្រមានជាលាយលក្ខណ៍អក្សរ ចំពោះបុគ្គលណាដែលប្រព្រឹត្តអំពើផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី១និងកថាខណ្ឌទី២នៃមាត្រា២៩។

ក្នុងករណីទទួលរងនូវការព្រមានជាលាយលក្ខណ៍អក្សរម្តងរួចហើយ នៅតែបន្តប្រព្រឹត្តល្មើសដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើនេះ ត្រូវព្យួរឬដកហូតអាជ្ញាបណ្ណឬលិខិតអនុញ្ញាតជាបុគ្គលផ្តល់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

**មាត្រា៥៨ .- អំពើល្មើសលើការផ្ញើទំនាក់ទំនងពាណិជ្ជកម្មដែលមិនបានស្នើសុំ**

ត្រូវទទួលការព្រមានជាលាយលក្ខណ៍អក្សរ ចំពោះបុគ្គលណាដែលប្រព្រឹត្តអំពើផ្ទុយនឹងបញ្ញត្តិនៃមាត្រា៣០។

ក្នុងករណីទទួលរងនូវការព្រមានជាលាយលក្ខណ៍អក្សរម្តងរួចហើយ នៅតែបន្តប្រព្រឹត្តល្មើស ដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើនេះ ត្រូវព្យួរឬដកហូតអាជ្ញាបណ្ណឬលិខិតអនុញ្ញាតជាអន្តរការីឬបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ឬបិទមិនឱ្យដំណើរការនូវប្រព័ន្ធផ្សព្វផ្សាយឬមធ្យោបាយអេឡិចត្រូនិករបស់អ្នកផ្ញើ។

**មាត្រា៥៩ .- អំពើល្មើសលើការក្លែងប្រព័ន្ធអេឡិចត្រូនិកនិងកូដព្យាបាទ**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦(ប្រាំមួយ)ខែទៅ៣(បី)ឆ្នាំនិងត្រូវពិន័យជាប្រាក់ពី ១ ០០០ ០០០(មួយលាន)រៀលទៅ៦ ០០០ ០០០(ប្រាំមួយលាន)រៀល ចំពោះបុគ្គលណាដែលប្រព្រឹត្តអំពើផ្ទុយនឹងបញ្ញត្តិនៃមាត្រា៣១។

**មាត្រា៦០ .- អំពើល្មើសលើការមិនអនុវត្តកាតព្វកិច្ចការពារទិន្នន័យ**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំទៅ២(ពីរ)ឆ្នាំនិងត្រូវពិន័យជាប្រាក់ពី២ ០០០ ០០០(ពីរលាន)រៀលទៅ៤ ០០០ ០០០(បួនលាន)រៀល ចំពោះបុគ្គលដែលរក្សាព័ត៌មានជាលក្ខណៈឯកជនក្រោមទម្រង់អេឡិចត្រូនិក ដែលប្រព្រឹត្តអំពើផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី១នៃមាត្រា៣២។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំទៅ២(ពីរ)ឆ្នាំនិងត្រូវពិន័យជាប្រាក់ពី២ ០០០ ០០០(ពីរលាន)រៀលទៅ៤ ០០០ ០០០(បួនលាន)រៀល ចំពោះបុគ្គលណាដែលប្រព្រឹត្តអំពើផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី២នៃមាត្រា៣២។

**មាត្រា៦១ .- អំពើល្មើសលើការបំពានលើការចេញលិខិតបញ្ជាក់យថាភូតភាព**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែទៅ១(មួយ)ឆ្នាំនិងត្រូវពិន័យជាប្រាក់ពី១០០ ០០០(មួយសែន)រៀលទៅ២ ០០០ ០០០(ពីរលាន)រៀល ចំពោះបុគ្គលទាំងឡាយដែលប្រព្រឹត្តអំពើផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី៣នៃមាត្រា៤១។

**មាត្រា៦២ .- អំពើល្មើសលើការបំពានលើភូដនីយកម្ម**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំទៅ៣(បី)ឆ្នាំនិងត្រូវពិន័យជាប្រាក់ពី២ ០០០ ០០០ (ពីរលាន)រៀលទៅ៦ ០០០ ០០០(ប្រាំមួយលាន)រៀល ចំពោះបុគ្គលទាំងឡាយដែលប្រព្រឹត្តអំពើផ្ទុយនឹងបញ្ញត្តិនៃមាត្រា៤៣។

**មាត្រា៦៣ .- អំពើល្មើសលើការធ្វើប្រតិបត្តិការទូទាត់តាមប្រព័ន្ធអេឡិចត្រូនិក**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំទៅ៥(ប្រាំ)ឆ្នាំនិងត្រូវពិន័យជាប្រាក់ពី១ ០០០ ០០០ (មួយលាន)រៀលទៅ១០ ០០០ ០០០(ដប់លាន)រៀល ចំពោះបុគ្គលទាំងឡាយដែលប្រព្រឹត្តអំពើផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី១នៃមាត្រា៤៦។

**មាត្រា៦៤ .- អំពើល្មើសលើការក្លែងបន្លំឧបករណ៍ទូទាត់សងប្រាក់ជាអេឡិចត្រូនិក**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំទៅ៣(បី)ឆ្នាំនិងត្រូវពិន័យជាប្រាក់ពី២ ០០០ ០០០ (ពីរលាន)រៀលទៅ៦ ០០០ ០០០(ប្រាំមួយលាន)រៀល ចំពោះបុគ្គលទាំងឡាយដែលប្រព្រឹត្តអំពើផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី៥នៃមាត្រា៤៧។

**មាត្រា៦៥ .- ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល**

១. នីតិបុគ្គលអាចត្រូវប្រកាសថាត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា៤២(ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល)នៃក្រមព្រហ្មទណ្ឌ ចំពោះបទល្មើសដែលមានចែងក្នុងមាត្រា៥៣ដល់មាត្រា៥៥ កថាខណ្ឌទី២នៃមាត្រា៥៦និងមាត្រា៥៩ដល់មាត្រា៦៤នៃច្បាប់នេះ។

២. នីតិបុគ្គលត្រូវពិន័យជាប្រាក់ទ្វេដង ព្រមទាំងទោសបន្ថែមណាមួយឬច្រើន ដូចតទៅនេះ៖

- ក. ការរំលាយតាមបែបបទកំណត់ដោយមាត្រា១៧០(ការរំលាយនិងការជម្រះបញ្ជីនៃនីតិបុគ្គល)នៃក្រមព្រហ្មទណ្ឌ។
- ខ. ការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យតាមដានរបស់តុលាការ តាមបែបបទកំណត់ដោយមាត្រា១៧១(ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ)នៃក្រមព្រហ្មទណ្ឌ។
- គ. ការហាមឃាត់ចំពោះការធ្វើសកម្មភាពមួយឬច្រើន តាមបែបបទកំណត់ដោយមាត្រា១៧២ (ការហាមឃាត់ចំពោះការធ្វើសកម្មភាព)នៃក្រមព្រហ្មទណ្ឌ។
- ឃ. ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមបែបបទកំណត់ដោយមាត្រា១៨០ (ការបិទផ្សាយសេចក្តីសម្រេច)នៃក្រមព្រហ្មទណ្ឌ។
- ង. ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ សារព័ត៌មានអេឡិចត្រូនិក ឬការផ្សាយតាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ តាមបែបបទកំណត់ដោយមាត្រា១៨១(ការផ្សាយសេចក្តីសម្រេចតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ ជាអាទិ៍)នៃក្រមព្រហ្មទណ្ឌ។

## ជំពូកទី១២
## អវសានប្បញ្ញត្តិ

**មាត្រា៦៦** .- ការទុកជានិរាករណ៍

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា៦៧** .- ការអនុវត្តច្បាប់នេះ

ក្រោយពីចូលជាធរមាន ច្បាប់នេះត្រូវផ្សព្វផ្សាយរយៈពេល៦(ប្រាំមួយ)ខែ ទើបអនុវត្ត។

ថ្ងៃ សៅរ៍ ៦កើត ខែ កត្តិក ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ២០១៩

ចារល. ១៩១១. ១៦៥៤

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន សូរស័ក្តិ**

# ឧបសម្ព័ន្ធ
# និយមន័យ

វាក្យសព្ទសំខាន់ៗដែលប្រើនៅក្នុងច្បាប់នេះត្រូវបានកំណត់និយមន័យដូចតទៅ៖

**១. ការចូលប្រើប្រាស់/អាក់សេស(Access)** សំដៅដល់ការចូលទៅប្រើកម្មវិធីកុំព្យូទ័រ ប្រព័ន្ធកុំព្យូទ័រ ប្រព័ន្ធឬបណ្ដាញអេឡិចត្រូនិក ដើម្បីទាក់ទង បញ្ជូន រក្សាទុក ឬទាញយកនូវទិន្នន័យ ព័ត៌មានឬឯកសារផ្សេងៗទៀតក្នុងប្រព័ន្ធអេឡិចត្រូនិកតាមគ្រប់មធ្យោបាយ។

**២. អ្នកទទួល(Addressee)** សំដៅដល់បុគ្គលដែលទទួលទំនាក់ទំនងអេឡិចត្រូនិក ស្របតាមឆន្ទៈរបស់អ្នកផ្ញើ លើកលែងតែអន្តរការីក្នុងការប្រាស្រ័យទាក់ទងតាមប្រព័ន្ធអេឡិចត្រូនិក។

**៣. ប្រព័ន្ធស្វ័យប្រវត្តិ(Automated System)** សំដៅដល់កម្មវិធីកុំព្យូទ័រ ប្រព័ន្ធកុំព្យូទ័រ ប្រព័ន្ធ ឬបណ្ដាញអេឡិចត្រូនិក ឬមធ្យោបាយអេឡិចត្រូនិកផ្សេងទៀតដែលត្រូវបានប្រើប្រាស់សម្រាប់ជូនដំណឹងឬឆ្លើយតបដោយស្វ័យប្រវត្តិដោយគ្មានអន្តរាគមន៍ពីរូបវន្តបុគ្គលណាមួយ។

**៤. បណ្ណ/កាតទូទាត់(Card)** សំដៅដល់បណ្ណ/កាតធនាគារ បណ្ណឥណទាន/ឥណពន្ធ ស្មាតកាត (Smart Card) ឬបណ្ណ/កាតទូទាត់ ទោះបីក្នុងទម្រង់អេឡិចត្រូនិកដែលផ្ទុកតម្លៃ ហើយមានមុខងារសម្រាប់ទូទាត់។

**៥. កម្មវិធីចម្លងមេរោគ(Contaminant)** សំដៅដល់កម្មវិធីអេឡិចត្រូនិកដែលត្រូវបានបង្កើតឡើងដើម្បី៖

(ក) កែប្រែ បំផ្លាញ កត់ត្រា បញ្ជូនទិន្នន័យឬកម្មវិធីនៅក្នុងប្រព័ន្ធអេឡិចត្រូនិក ឬ

(ខ) ជ្រៀតជ្រែកតាមគ្រប់មធ្យោបាយនូវដំណើរការប្រក្រតីរបស់ប្រព័ន្ធឬបណ្ដាញអេឡិចត្រូនិក។

**៦. ម្ចាស់បណ្ណ/កាតទូទាត់(Cardholder)** សំដៅដល់បុគ្គលដែលមានឈ្មោះចារឹកនៅលើបណ្ណ/កាត និងជាបុគ្គលដែលទទួលប្រយោជន៍ពីបណ្ណ/កាតទូទាត់នោះ។

**៧. ទំនាក់ទំនង(Communication)** សំដៅដល់អំណះអំណាង សេចក្ដីថ្លែងការណ៍ ការទាមទារ សេចក្ដីជូនដំណឹង សំណូមពរ សំណើ ឬស្ទីការ ដែលគូភាគីត្រូវធ្វើឬសម្រេចចិត្តធ្វើពាក់ព័ន្ធនឹងការបង្កើតឬការអនុវត្តកិច្ចសន្យា។

**៨. បណ្ណ/កាតទូទាត់ក្លែងក្លាយ(Counterfeit card)** សំដៅដល់បណ្ណ/កាតទូទាត់ទាំងឡាយណាដែលត្រូវបានបង្កើតឡើងដោយការបង្ហាញឬការពិពណ៌នាដែលត្រូវបានប្រឌិតឡើង កែប្រែ ក្លែងបន្លំ ឬបណ្ណ/កាតទូទាត់ដែលមានសមាសធាតុណាមួយនៃបណ្ណ/កាតទូទាត់នោះមានលក្ខណៈខុសច្បាប់។

**៩. ទិន្នន័យ(Data)** សំដៅដល់បណ្ដុំលេខ អក្សរ និមិត្តសញ្ញា សារ រូបភាព សំឡេង វីដេអូ ព័ត៌មាន ឬកម្មវិធីអេឡិចត្រូនិក ដែលត្រូវបានរៀបចំក្នុងទម្រង់សមស្របសម្រាប់ប្រើប្រាស់ក្នុងមូលដ្ឋានទិន្នន័យឬប្រព័ន្ធអេឡិចត្រូនិក។

**១០. អេឡិចត្រូនិក(Electronic)** សំដៅដល់អ្វីដែលពាក់ព័ន្ធនឹងបច្ចេកវិទ្យាដែលមានចរន្តអគ្គិសនី ឌីជីថល ម៉ាញេទិច អុបទិក ជីវមាត្រ អេឡិចត្រូគីមី វ៉ាយអឺឡេស (wireless) អេឡិចត្រូម៉ាញេទិក ឬបច្ចេកវិទ្យាដែលមានមុខងារប្រហាក់ប្រហែលផ្សេងទៀត។

**១១. អាសយដ្ឋានអេឡិចត្រូនិក(Electronic Address)** សំដៅដល់លេខឬអាសយដ្ឋានប្រើប្រាស់សម្រាប់ផ្ញើឬទទួលការជូនដំណឹង ឯកសារ ព័ត៌មាន ឬទំនាក់ទំនងតាមមធ្យោបាយអេឡិចត្រូនិក។

**១២. យថាភូតភាព(Authenticity)** សំដៅដល់ភាពត្រឹមត្រូវនិងអាចជឿទុកចិត្តបាននៃទំនាក់ទំនងអេឡិចត្រូនិក។

**១៣. ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក(Electronic Commerce)** សំដៅដល់សកម្មភាពទិញ លក់ ជួល ផ្លាស់ប្តូរទំនិញឬសេវា ដោយរាប់បញ្ចូលទាំងសកម្មភាពពាណិជ្ជកម្មនិងរដ្ឋប្បវេណី ព្រមទាំងសកម្មភាពនិងប្រតិបត្តិការនានារបស់រដ្ឋ តាមប្រព័ន្ធអេឡិចត្រូនិក។

**១៤. ឧបករណ៍ទូទាត់អេឡិចត្រូនិក(Electronic Payment Instrument)** សំដៅដល់បណ្ណ/កាត ទូទាត់ ឬឧបករណ៍ទូទាត់ទាំងឡាយណាដែលមានទម្រង់ជាអេឡិចត្រូនិក ហើយមានមុខងារសម្រាប់ទូទាត់សងប្រាក់។

**១៥. ទំនាក់ទំនងអេឡិចត្រូនិក(Electronic Communication)** សំដៅដល់ព័ត៌មានដែលត្រូវបានទាក់ទង ដំណើរការ កត់ត្រាទុក បង្ហាញឡើង បង្កើតឡើង រក្សាទុក ទទួលបាន ឬបញ្ជូនតាមមធ្យោបាយអេឡិចត្រូនិក។

**១៦. ឧបករណ៍អេឡិចត្រូនិក(Electronic device)** សំដៅដល់ឧបករណ៍ទាំងឡាយណាដែលបង្កើតឡើងដើម្បីគ្រប់គ្រង បញ្ជា និងប្រតិបត្តិការតាមប្រព័ន្ធអេឡិចត្រូនិក។

**១៧. ភស្តុតាងអេឡិចត្រូនិក(Electronic evidence)** សំដៅដល់ព័ត៌មាន ទិន្នន័យ ឬឯកសារនានាដែលបានបង្កើតឡើង រក្សាទុក ផ្ញើចេញ ឬទទួលក្នុងទម្រង់ឬទំនាក់ទំនងអេឡិចត្រូនិកសម្រាប់ជាសំអាងទាក់ទងនឹងអង្គហេតុណាមួយក្នុងដំណើរការនីតិវិធីតាមផ្លូវច្បាប់ ហើយព័ត៌មាន ទិន្នន័យ ឬឯកសារនោះមានយថាភូតភាពស្របតាមច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

**១៨. ទម្រង់អេឡិចត្រូនិក(Electronic form)** សំដៅដល់ទម្រង់នៃព័ត៌មាន ទិន្នន័យ ឬឯកសារដែលបង្កើត បញ្ជូន ទទួលបាន ឬរក្សាទុកក្នុងប្រព័ន្ធអេឡិចត្រូនិក។

**១៩. ការផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក(Electronic fund transfer)** សំដៅដល់ប្រតិបត្តិការទាំងឡាយណាដែលធ្វើឡើងតាមរយៈបញ្ជរផ្ទេរប្រាក់អេឡិចត្រូនិក ឬតាមឧបករណ៍អេឡិចត្រូនិកចល័ត ឬតាមឧបករណ៍អេឡិចត្រូនិកដែលមានមុខងារស្រដៀងគ្នា ដើម្បីបញ្ជាឱ្យគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុធ្វើការចុះឥណពន្ធឬឥណទានក្នុងគណនី។

**២០. កំណត់ត្រាអេឡិចត្រូនិក(Electronic record)** សំដៅដល់កំណត់ត្រាដែលត្រូវបានបង្កើតឡើង ទាក់ទង ទទួល រក្សាទុក ឬដំណើរការក្នុងប្រព័ន្ធអេឡិចត្រូនិក ឬសម្រាប់បញ្ជូនពីប្រព័ន្ធអេឡិចត្រូនិកមួយទៅប្រព័ន្ធអេឡិចត្រូនិកមួយទៀត។

**២១. បុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក(Electronic-Commerce service provider)** សំដៅដល់បុគ្គលដែលប្រើប្រាស់មធ្យោបាយអេឡិចត្រូនិកដើម្បីផ្គត់ផ្គង់ទំនិញនិង/ឬសេវា លើកលែងគ្រឹះស្ថានធានារ៉ាប់រង។

**២២. ហត្ថលេខាអេឡិចត្រូនិក(Electronic Signature)** សំដៅដល់រាល់ហត្ថលេខាដែលត្រូវបានបង្កើតឡើងតាមមធ្យោបាយអេឡិចត្រូនិកសម្រាប់ប្រើប្រាស់កំណត់អត្តសញ្ញាណរបស់ហត្ថលេខីដែលរួមមាន ហត្ថលេខាឌីជីថល ហត្ថលេខាជីវមាត្រ និងហត្ថលេខាដទៃទៀត។

**២៣. ប្រព័ន្ធអេឡិចត្រូនិក(Electronic system)** សំដៅដល់ឧបករណ៍អេឡិចត្រូនិកឬបណ្តុំឧបករណ៍តភ្ជាប់គ្នាឬទាក់ទងគ្នា តាមរយៈកម្មវិធីអេឡិចត្រូនិក ដែលអាចធ្វើឱ្យដំណើរការជាស្វ័យប្រវត្តិនៃទិន្នន័យ ព័ត៌មាន ឬឯកសារ រួមបញ្ចូលទាំងឧបករណ៍អេឡិចត្រូនិកសម្រាប់រក្សាទុកទិន្នន័យ ព័ត៌មាន ឬឯកសារនោះ។

**២៤. ប្រព័ន្ធព័ត៌មាន(Information system)** សំដៅដល់ប្រព័ន្ធសម្រាប់បង្កើត ផ្ញើ ទទួល រក្សាទុក ឬដំណើរការកំណត់ត្រាអេឡិចត្រូនិក។

**២៥. អន្តរការី(Intermediary)** សំដៅដល់បុគ្គលដែលផ្តល់សេវា ផ្ញើ ទទួល បញ្ជូន ឬរក្សាទុកជាបណ្តោះអាសន្នឬជាអចិន្ត្រៃយ៍នូវទំនាក់ទំនងអេឡិចត្រូនិកនោះ ឬផ្តល់សេវាផ្សេងទៀតដែលពាក់ព័ន្ធនឹងទំនាក់ទំនងអេឡិចត្រូនិក រួមបញ្ចូលនូវបុគ្គលដូចខាងក្រោម៖

១. បុគ្គលដែលតំណាងឱ្យអ្នកផ្ញើ អ្នកទទួល អ្នកបញ្ជូន ឬអ្នករក្សាទុក

២. បុគ្គលផ្តល់សេវាទូរគមនាគមន៍

៣. បុគ្គលផ្តល់សេវាបណ្តាញនានា

៤. បុគ្គលផ្តល់សេវាអ៊ិនធឺណិត

៥. បុគ្គលផ្តល់មធ្យោបាយស្វែងរកទិន្នន័យណាមួយតាមប្រព័ន្ធអេឡិចត្រូនិក

៦. បុគ្គលផ្តល់សេវាទូទាត់តាមអនឡាញ

៧. បុគ្គលផ្តល់សេវាដេញថ្លៃតាមអនឡាញ

៨. បុគ្គលផ្តល់សេវាទីផ្សារអនឡាញនិងសេវាពាណិជ្ជកម្មតាមបណ្តាញអ៊ិនធឺណិត។

**២៦. បុគ្គលចេញបណ្ណ/កាតទូទាត់(Issuer)** សំដៅដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុឬបុគ្គលណាមួយដែលបានចេញបណ្ណ/កាតទូទាត់ ដែលបានទទួលការអនុញ្ញាត។

២៧. កូដព្យាបាទ(Malicious code) សំដៅដល់កម្មវិធីឬតួនាទីលាក់មុខនៃកម្មវិធីដែលចម្លងមេរោគដល់ទិន្នន័យ ព័ត៌មាន ឬឯកសារ ដោយមានឬគ្មានបន្សល់ទុកស្លាកស្នាមសម្គាល់នៃមេរោគនោះក្នុងឯកសារអេឡិចត្រូនិកដែលបានឆ្លងមេរោគ ហើយមេរោគនោះអាចចម្លងបន្តក្នុងប្រព័ន្ធដោយឯកឯងឬដោយមានអន្តរាគមន៍ពីមនុស្ស។

២៨. អ្នកផ្ញើ(Originator) សំដៅដល់ភាគីឬអ្នកតំណាងដែលបានផ្ដើមប្រតិបត្តិការបង្កើត រក្សាទុក ឬបញ្ជូនទិន្នន័យតាមមធ្យោបាយអេឡិចត្រូនិក ដោយមិនរាប់បញ្ចូលអន្តរការី។

២៩. បុគ្គលផ្ដល់សេវាទូទាត់(Payment Service Provider) សំដៅដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ឬបុគ្គលដទៃទៀតដែលបានទទួលការអនុញ្ញាតឬអាជ្ញាបណ្ណពីធនាគារជាតិនៃកម្ពុជា ឱ្យធ្វើប្រតិបត្តិការប្រព័ន្ធទូទាត់ ចេញផ្សាយឧបករណ៍ទូទាត់អេឡិចត្រូនិកឬមធ្យោបាយទូទាត់ ជាអេឡិចត្រូនិក ឬធ្វើប្រតិបត្តិការណាដែលត្រូវបានចាត់ទុកថាជាការផ្ដល់ការទូទាត់សងប្រាក់ ជាអេឡិចត្រូនិកដល់សាធារណជន។

៣០. ទីតាំងអាជីវកម្ម(Place of business) សំដៅដល់៖

ក. ទីតាំងដែលអ្នកផ្ញើឬអ្នកទទួលបានចង្អុលបង្ហាញ លើកលែងតែភាគីណាមួយបានបង្ហាញថាអ្នកអះអាងនោះ ពុំមានទីតាំងអាជីវកម្មនៅទីនោះឡើយ។

ខ. ប្រសិនបើភាគីណាមួយមិនបានចង្អុលបង្ហាញទីកន្លែងអាជីវកម្មជាក់លាក់ណាមួយ ហើយភាគីនោះមានទីតាំងអាជីវកម្មច្រើនជាងមួយកន្លែង ទីតាំងអាជីវកម្មត្រូវកំណត់ថាជាទីកន្លែងដែលមានទំនាក់ទំនងជិតស្និទ្ធជាងគេទៅនឹងកិច្ចសន្យាដែលពាក់ព័ន្ធ ដោយត្រូវពិចារណាផងដែរអំពីកាលៈទេសៈដែលបានដឹងឬពិនិត្យដោយភាគីនៅពេលណាមួយមុនឬក្នុងពេលចុះកិច្ចសន្យា។

គ. សម្រាប់រូបវន្តបុគ្គលដែលពុំមានទីតាំងអាជីវកម្មទេនោះ ទីតាំងអាជីវកម្មសំដៅដល់ទីលំនៅអចិន្ត្រៃយ៍របស់បុគ្គលនោះ។

មិនត្រូវចាត់ទុកថាជាទីតាំងអាជីវកម្មរបស់ភាគីដោយគ្រាន់តែជា៖

- ទីតាំងដែលសម្ភារៈឬឧបករណ៍បច្ចេកវិទ្យានៃប្រព័ន្ធព័ត៌មានត្រូវបានប្រើ
- អាសយដ្ឋានអេឡិចត្រូនិកឬឈ្មោះដែនកម្មសិទ្ធិ(Domain Name) ដែលភ្ជាប់ជាមួយនឹងទីតាំងរបស់ភាគី។

៣១. កំណត់ត្រា(Record) សំដៅដល់ព័ត៌មាន ទិន្នន័យ ឬឯកសារដែលត្រូវបានកត់ត្រាចូល រក្សាទុក ឬបញ្ចូលទៅក្នុងទម្រង់រូបី ឬដែលត្រូវបានរក្សាទុកក្នុងទម្រង់អេឡិចត្រូនិក ជាត្រាស្នាម ឬទម្រង់ប្រភេទផ្សេងទៀត ហើយដែលអាចទាញយកកំណត់ត្រានោះវិញបានក្នុងទម្រង់ជាក់លាក់ដែលអាចមើលបាន។

**៣២. បុគ្គលផ្ដល់សេវា( service provider)** សំដៅដល់

(ក) បុគ្គលដែលផ្ដល់សេវាព័ត៌មាននិងសេវាទំនាក់ទំនង រួមមាន ការផ្ញើ ការទទួល ការរក្សាទុក ឬដំណើរការទំនាក់ទំនងអេឡិចត្រូនិក ឬការផ្ដល់សេវាតាមប្រព័ន្ធអេឡិចត្រូនិកផ្សេងទៀត។

(ខ) បុគ្គលដែលជាម្ចាស់ បុគ្គលកាន់កាប់ បុគ្គលដំណើរការ បុគ្គលគ្រប់គ្រង ឬបុគ្គលត្រួតពិនិត្យបណ្ដាញស្វិចសាធារណៈ(Public Switched Network) ឬបុគ្គលដែលផ្ដល់សេវាទូរគមនាគមន៍។ ឬ

(គ) បុគ្គលផ្សេងទៀតដែលប្រតិបត្តិឬរក្សាទុកទិន្នន័យបម្រើឱ្យសេវាទំនាក់ទំនងអេឡិចត្រូនិកនោះ ឬអ្នកប្រើប្រាស់សេវា។

**៣៣. បុគ្គលផ្ដល់នីតិវិធីសុវត្ថិភាព( Security procedure provider)** សំដៅដល់បុគ្គលបង្កើត ឬផ្ដល់នីតិវិធីសុវត្ថិភាព។

**៣៤. នីតិវិធីសុវត្ថិភាព(Security Procedure)** សំដៅដល់នីតិវិធីដែលកំណត់ដោយច្បាប់ ឬកិច្ចសន្យា ឬការសម្រេចដោយភាគីណាមួយ ហើយដែលត្រូវបានប្រើក្នុងគោលបំណង៖

(ក) ផ្ទៀងផ្ទាត់ថាហត្ថលេខា ទំនាក់ទំនង ឬប្រតិបត្តិការក្នុងប្រព័ន្ធអេឡិចត្រូនិក ពិតជារបស់បុគ្គលនោះ។

(ខ) រកឱ្យឃើញកំហុសឆ្គងឬការកែប្រែនៅក្នុងទំនាក់ទំនងឬក្នុងកន្លែងរក្សាទុកកំណត់ត្រាអេឡិចត្រូនិក ចាប់តាំងពីពេលជាក់ណាមួយ។

នីតិវិធីសុវត្ថិភាពខាងលើអាចតម្រូវឱ្យប្រើរូបមន្តអាល់ហ្គោរីត(algorithms)ឬកូដ ពាក្យឬលេខសម្រាប់ សម្គាល់អត្តសញ្ញាណ កូដនីយកម្ម សំណួរសម្ងាត់ ឬការទទួលស្គាល់នីតិវិធីណាមួយ ឬក៏ឧបករណ៍សុវត្ថិភាពស្រដៀងគ្នាផ្សេងទៀត។

**៣៥. ព័ត៌មានឬកំណត់ត្រាជាលាយលក្ខណ៍អក្សរ(writing/written)** សំដៅដល់ព័ត៌មានឬកំណត់ត្រាផ្សេងៗទៀតដែលត្រូវបានសរសេរ ចារឹក ឬបោះពុម្ពនៅលើក្រដាសឬសម្ភារៈ ផ្សេងៗទៀត។

**៣៦. អ៊ីមែលឬសារអេឡិចត្រូនិក(E-mail or Electronic Message)** សំដៅដល់សារឬព័ត៌មានដែលត្រូវបានបង្កើតឡើង ឬបញ្ជូន ឬទទួលបានពីប្រព័ន្ធអេឡិចត្រូនិក រួមទាំងឯកសារភ្ជាប់ក្នុងអត្ថបទ រូបភាព សំឡេង វីដេអូ និងកំណត់ត្រាអេឡិចត្រូនិកណាមួយផ្សេងទៀតដែលអាចបញ្ជូនជាមួយសារបាន។

**៣៧. សន្តតិកម្ម(Will)** សំដៅដល់ការផ្ទេរនូវសិទ្ធិនិងករណីកិច្ចរបស់មតកជនទៅឱ្យសន្តតិជនម្នាក់ឬច្រើននាក់តាមឆន្ទៈឬតាមច្បាប់។

៣៨. **ស្វីការ**(Acceptance) សំដៅដល់ការសំដែងឆន្ទៈដែលបុគ្គលម្នាក់បានបញ្ចេញការយល់ព្រមរបស់ខ្លួនចំពោះសំណើដែលបុគ្គលដទៃបានស្នើមកខ្លួនដើម្បីបង្កើតកិច្ចសន្យា។

# ឧបសម្ព័ន្ធទី៣

អនុក្រឹត្យលេខ ២៤៦ អនក្រ.បក ស្តីពីហត្ថលេខាឌីជីថល ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៧

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ២៤៦ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ហត្ថលេខាឌីជីថល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៣៩ អនក្រ.បក ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ៧៤ អនក្រ.បក ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា ២៦ មាត្រា២៧ មាត្រា២៨ និងមាត្រា២៩ និងបំពេញបន្ថែមមាត្រា២៩ ស្ទួន នៃអនុក្រឹត្យលេខ ៣៩ អនក្រ.បក ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

# សម្រេច
# ជំពូកទី១
# បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះមានគោលបំណងគ្រប់គ្រងនិងជំរុញការប្រើប្រាស់ហត្ថលេខាឌីជីថលនៅក្នុងព្រះរាជាណាចក្រកម្ពុជា ប្រកបដោយសុវត្ថិភាពនិងប្រសិទ្ធភាពខ្ពស់។

**មាត្រា២ .-**

អនុក្រឹត្យនេះមានគោលដៅកំណត់អំពី៖

- គោលការណ៍នៃហត្ថលេខាឌីជីថលនិងស្ថាប័នមានសមត្ថកិច្ច
- ការផ្តល់ ការកែប្រែ ការព្យួរ ការបញ្ឈប់ និងការដកហូតអាជ្ញាបណ្ណវិញ្ញាតកម្មហត្ថលេខាឌីជីថល
- វិញ្ញាបនបត្រហត្ថលេខាឌីជីថល
- កាតព្វកិច្ចរបស់វិញ្ញាតធរហត្ថលេខាឌីជីថល
- កាតព្វកិច្ចរបស់កម្មសិទ្ធិករវិញ្ញាបនបត្រហត្ថលេខាឌីជីថល។

**មាត្រា៣ .-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះរាល់ប្រតិបត្តិការ ដែលពាក់ព័ន្ធនឹងហត្ថលេខាឌីជីថលនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៤ .-**

ពាក្យបច្ចេកទេសដែលប្រើក្នុងអនុក្រឹត្យនេះមានន័យដូចខាងក្រោម៖

**កម្មសិទ្ធិករវិញ្ញាបនបត្រហត្ថលេខាឌីជីថល** សំដៅដល់បុគ្គលដែលទទួលបានវិញ្ញាបនបត្រហត្ថលេខាឌីជីថលពីវិញ្ញាតធរហត្ថលេខាឌីជីថល។

**គន្លឹះបង្កើតហត្ថលេខាឌីជីថល** សំដៅដល់កូដនៅក្នុងប្រព័ន្ធកុំព្យូទ័រដែលត្រូវបានប្រើប្រាស់សម្រាប់បង្កើតហត្ថលេខាឌីជីថល។

**គន្លឹះផ្ទៀងផ្ទាត់ហត្ថលេខាឌីជីថល** សំដៅដល់កូដនៅក្នុងប្រព័ន្ធកុំព្យូទ័រដែលត្រូវបានប្រើប្រាស់សម្រាប់ផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃហត្ថលេខាឌីជីថល។

**ទិន្នន័យ** សំដៅដល់អត្ថបទ រូបភាព សំឡេង វីដេអូ ឬសញ្ញាណផ្សេងៗទៀតដែលត្រូវបានបង្កើត ប្រើប្រាស់ និងរក្សាទុកនៅក្នុងប្រព័ន្ធកុំព្យូទ័រ។

**ប្រព័ន្ធកុំព្យូទ័រ** សំដៅដល់រាល់ឧបករណ៍អេឡិកត្រូនិកទាំងឡាយ ទោះស្ថិតនៅដាច់ដោយឡែកតែឯង ឬជាបណ្តុំនៃឧបករណ៍អេឡិកត្រូនិកដែលតភ្ជាប់គ្នា ឬឧបករណ៍ពាក់ព័ន្ធដែលដំណើរការប្រព្រឹត្តកម្មស្វ័យប្រវត្តិនៃទិន្នន័យ ក្នុងនោះរាប់ទាំងឧបករណ៍គ្រប់ប្រភេទដែលមានសមត្ថភាពធ្វើប្រព្រឹត្តកម្មទិន្នន័យ ដោយរាប់បញ្ចូលតែមិនកំណត់ត្រឹមកុំព្យូទ័រ កុំព្យូទ័របន្ទះ និងទូរស័ព្ទ។

**លិខិតលាយលក្ខណ៍អក្សរ** សំដៅដល់លិខិតដែលមានទម្រង់ជាក្រដាសដែលមានឬតម្រូវឱ្យមាន ហត្ថលេខាឬស្នាមម្រាមដៃ, ហត្ថលេខាឬស្នាមម្រាមដៃ និងឈ្មោះ, ហត្ថលេខាឬស្នាមម្រាមដៃ និងត្រា, ឈ្មោះនិងត្រា, ឬហត្ថលេខាឬស្នាមម្រាមដៃ ឈ្មោះ និងត្រា។

**វិញ្ញាបនបត្រហត្ថលេខាឌីជីថល** សំដៅដល់កំណត់ត្រាក្នុងប្រព័ន្ធកុំព្យូទ័រមួយដែលចេញដោយវិញ្ញាតធរហត្ថលេខាឌីជីថល សម្រាប់បញ្ជាក់អត្តសញ្ញាណរបស់កម្មសិទ្ធិករវិញ្ញាបនបត្រហត្ថលេខាឌីជីថល ដែលជាម្ចាស់កម្មសិទ្ធិនៃគន្លឹះផ្ទៀងផ្ទាត់ហត្ថលេខាឌីជីថល។

**វិញ្ញាតធរហត្ថលេខាឌីជីថល** សំដៅដល់នីតិបុគ្គលដែលធ្វើវិញ្ញាតកម្មហត្ថលេខាឌីជីថល។

**វិញ្ញាតកម្មហត្ថលេខាឌីជីថល** សំដៅដល់ការចេញវិញ្ញាបនបត្រហត្ថលេខាឌីជីថល។

**វិធានរួមស្ដីពីវិញ្ញាតកម្មហត្ថលេខាឌីជីថល** សំដៅដល់វិធាននិងនីតិវិធីពាក់ព័ន្ធនឹងវិញ្ញាតកម្មហត្ថលេខាឌីជីថលរបស់វិញ្ញាតធរហត្ថលេខាឌីជីថល ដើម្បីធានាសុវត្ថិភាពនិងប្រសិទ្ធភាពនៃវិញ្ញាតកម្មហត្ថលេខាឌីជីថលនិងការប្រើប្រាស់ហត្ថលេខាឌីជីថលស្របទៅនឹងបទប្បញ្ញត្តិពាក់ព័ន្ធនឹងស្តង់ដានិងគោលការណ៍បច្ចេកទេស ដែលបានកំណត់ដោយ **ក.ប.ទ.**។

**សារអេឡិកត្រូនិក** សំដៅដល់ព័ត៌មានដែលត្រូវបានបង្កើតឡើង បញ្ជូន ទទួល ឬរក្សាទុកក្នុងទម្រង់ជាអេឡិក-ត្រូនិកនៅក្នុងប្រព័ន្ធកុំព្យូទ័រ។

**ហត្ថលេខាឌីជីថល** សំដៅដល់ទិន្នន័យដែលភ្ជាប់នឹងសារអេឡិកត្រូនិក ដើម្បីបញ្ជាក់អត្តសញ្ញាណនៃហត្ថលេខីឌីជីថលនិងផ្ទៀងផ្ទាត់ស្ថានភាពដើមនៃសារអេឡិកត្រូនិក ដែលហត្ថលេខីឌីជីថលបានចុះហត្ថលេខា។

**ហេដ្ឋារចនាសម្ព័ន្ធគន្លឹះសាធារណៈ** សំដៅដល់ហេដ្ឋារចនាសម្ព័ន្ធមួយដែលមានយន្តការនិងគ្រឿងសម្ភារៈបរិក្ខារបច្ចេកទេស បុគ្គលិក គោលនយោបាយ និងនីតិវិធីក្នុងការធានានូវសន្តិសុខនិងសុវត្ថិភាពសម្រាប់ការគ្រប់គ្រងនិងការប្រើប្រាស់ហត្ថលេខាឌីជីថល។

**អាជ្ញាបណ្ណវិញ្ញាតកម្មហត្ថលេខាឌីជីថល** សំដៅដល់អាជ្ញាបណ្ណដែលចេញដោយក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ដើម្បីផ្ដល់នីតិសម្បទាឱ្យនីតិបុគ្គលណាមួយជាវិញ្ញាតធរហត្ថលេខាឌីជីថល។

## ជំពូកទី២
## ស្ថាប័នមានសមត្ថកិច្ច

### មាត្រា៥ .-

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ (**ក.ប.ទ.**) ជាស្ថាប័នមានសមត្ថកិច្ចក្នុងការគ្រប់គ្រងលើហត្ថលេខាឌីជីថល និងផ្ដល់វិញ្ញាបនបត្រហត្ថលេខាឌីជីថលដល់ក្រសួង ស្ថាប័ន និងអាជ្ញាធរថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។

អគ្គនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន (**អ.ប.គ.ព.**) ជាសេនាធិការរបស់ **ក.ប.ទ.** ក្នុងការគ្រប់គ្រង ការផ្ដល់ ការត្រួតពិនិត្យ និងការតាមដានការអនុវត្តអាជ្ញាបណ្ណវិញ្ញាតកម្មហត្ថលេខាឌីជីថល ស្របតាមអនុក្រឹត្យនេះ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត។

### មាត្រា៦ .-

**ក.ប.ទ.** ត្រូវកំណត់ស្តង់ដានិងគោលការណ៍បច្ចេកទេសដើម្បីលើកកម្ពស់សុវត្ថិភាពនិងប្រសិទ្ធភាពនៃការគ្រប់គ្រងនិងការប្រើប្រាស់ហត្ថលេខាឌីជីថល ជាអាទិ៍៖

ក- ស្តង់ដានិងនិម្មាបនកម្មហេដ្ឋារចនាសម្ព័ន្ធគន្លឹះសាធារណៈ

ខ- គោលការណ៍ណែនាំអំពីការស្ថាបនានិងការដំឡើងហេដ្ឋារចនាសម្ព័ន្ធគន្លឹះសាធារណៈ និងការប្រើប្រាស់ហត្ថលេខាឌីជីថល។

**មាត្រា៧ .-**

**អ.ប.គ.ព.** ត្រូវបង្កើតនិងរក្សាបញ្ជីអាជ្ញាបណ្ណវិញ្ញាតកម្មហត្ថលេខាឌីជីថល ដោយចុះបញ្ជាក់នូវព័ត៌មានជាក់លាក់មួយចំនួន ជាអាទិ៍ អត្តសញ្ញាណនៃវិញ្ញាតធរហត្ថលេខាឌីជីថល កាលបរិច្ឆេទនៃអាជ្ញាបណ្ណ លក្ខខណ្ឌបច្ចេកទេសនៃហត្ថលេខាឌីជីថល និងការទទួលបានសិទ្ធិធ្វើអាជីវកម្ម ព្រមទាំងបញ្ជីឧបសម្ព័ន្ធ។

**មាត្រា៨ .-**

**អ.ប.គ.ព.** ត្រូវផ្សាយជាសាធារណៈនូវឈ្មោះវិញ្ញាតធរហត្ថលេខាឌីជីថលទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា និងឈ្មោះវិញ្ញាតធរហត្ថលេខាឌីជីថលបរទេសដែលត្រូវបានទទួលស្គាល់ដោយព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី៣
## គោលការណ៍នៃហត្ថលេខាឌីជីថល

**មាត្រា៩ .-**

ដើម្បីចាត់ទុកជាហត្ថលេខាឌីជីថលត្រូវមានលក្ខខណ្ឌដូចខាងក្រោម៖

ក- បញ្ជាក់អត្តសញ្ញាណរបស់ហត្ថលេខីឌីជីថលដោយត្រឹមត្រូវនិងជាក់លាក់

ខ- បញ្ជាក់អំពីស្ថានភាពដើមនៃសារអេឡិកត្រូនិក

គ- បញ្ជាក់អំពីពេលវេលានិងកាលបរិច្ឆេទនៃការចុះហត្ថលេខាឌីជីថល

ឃ- ចំណុចផ្សេងទៀតដែលកំណត់ដោយ **គ.ប.ឌ.**។

**មាត្រា១០ .-**

សារអេឡិកត្រូនិកដែលមានភ្ជាប់ហត្ថលេខាឌីជីថលបញ្ជាក់ដោយវិញ្ញាតធរហត្ថលេខាឌីជីថល មានតម្លៃគតិយុត្តស្មើនឹងលិខិតលាយលក្ខណ៍អក្សរ។

**មាត្រា១១ .-**

រាល់ប្រតិបត្តិការហិរញ្ញវត្ថុតាមប្រព័ន្ធអនឡាញទាំងអស់ ត្រូវប្រើប្រាស់ហត្ថលេខាឌីជីថលស្របតាមអនុក្រឹត្យនេះ លើកលែងមានការកំណត់ផ្សេងដោយប្រកាសរួមរវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងធនាគារជាតិនៃកម្ពុជា។

**មាត្រា១២ .-**

ត្រូវបានហាមឃាត់ដាច់ខាតចំពោះការផ្សព្វផ្សាយគន្លឹះបង្កើតហត្ថលេខាឌីជីថលរបស់អ្នកដទៃ។

ត្រូវបានហាមឃាត់ចំពោះការរក្សាទុកឬការប្រើប្រាស់នូវគន្លឹះបង្កើតហត្ថលេខាឌីជីថលរបស់អ្នកដទៃ ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីកម្មសិទ្ធិករវិញ្ញាបនបត្រហត្ថលេខាឌីជីថល។

**មាត្រា១៣ .-**

វិញ្ញាបនបត្រហត្ថលេខាឌីជីថលដែលចេញដោយវិញ្ញាតធរហត្ថលេខាឌីជីថលបរទេស ត្រូវបានទទួលស្គាល់ស្របតាមលក្ខខណ្ឌនៃអនុក្រឹត្យនេះ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត ក្នុងករណីដូចខាងក្រោម៖

ក- តាមការយល់ព្រមរបស់ **គ.ប.ឌ.** ឬ

ខ- តាមកិច្ចព្រមព្រៀងអន្តរជាតិទទួលស្គាល់គ្នាទៅវិញទៅមកជាមួយព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី៤
## អាជ្ញាបណ្ណវិញ្ញាតកម្មហត្ថលេខាឌីជីថល
### ផ្នែកទី១
### ការផ្តល់អាជ្ញាបណ្ណវិញ្ញាតកម្មហត្ថលេខាឌីជីថល

**មាត្រា១៤ .-**

គ្មានបុគ្គលណាអាចតាំងខ្លួនជាវិញ្ញាតធរហត្ថលេខាឌីជីថលបានទេ លុះត្រាតែបុគ្គលនោះបានទទួលអាជ្ញាបណ្ណវិញ្ញាតកម្មហត្ថលេខាឌីជីថលពី **អ.ប.គ.ព.** ក្រោយពីទទួលបានការឯកភាពពីរដ្ឋមន្ត្រី **ក.ប.ទ.** ស្របតាមការកំណត់ក្នុងអនុក្រឹត្យនេះ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត។

**មាត្រា១៥ .-**

បុគ្គលដែលមានបំណងស្នើសុំអាជ្ញាបណ្ណវិញ្ញាតកម្មហត្ថលេខាឌីជីថល ត្រូវមានជំនាញបច្ចេកទេស ធនធានហិរញ្ញវត្ថុ ប្រាក់តម្កល់ធានាអាជីវកម្ម គ្រឿងសម្ភារៈបរិក្ខារបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន និងគុណវុឌ្ឍិផ្សេងទៀត ស្របតាមការកំណត់ដោយប្រកាសរបស់ **ក.ប.ទ.**។

**មាត្រា១៦ .-**

អាជ្ញាបណ្ណវិញ្ញាតកម្មហត្ថលេខាឌីជីថលមានរយៈពេល ១០ (ដប់) ឆ្នាំ គិតចាប់ពីថ្ងៃចេញអាជ្ញាបណ្ណ។

រយៈពេលនេះអាចត្រូវបានបន្តសាជាថ្មីតាមការសម្រេចរបស់ **អ.ប.គ.ព.** ក្រោយពីទទួលបានការឯកភាពពីរដ្ឋមន្ត្រី **ក.ប.ទ.**។

**មាត្រា១៧ .-**

បុគ្គលដែលមានបំណងស្នើសុំអាជ្ញាបណ្ណវិញ្ញាតកម្មហត្ថលេខាឌីជីថល ត្រូវដាក់ពាក្យស្នើសុំមក **អ.ប.គ.ព.**។

លក្ខខណ្ឌនិងនីតិវិធីនៃការស្នើសុំនិងការស្នើសុំបន្តអាជ្ញាបណ្ណវិញ្ញាតកម្មហត្ថលេខាឌីជីថលត្រូវកំណត់ដោយប្រកាសរបស់ **ក.ប.ទ.**។

### ផ្នែកទី២
### ការផ្ទេរតាមកិច្ចសន្យា សន្តតិកម្ម ឬការរំលាយក្រុមហ៊ុនបញ្ចូលគ្នា និងការបញ្ឈប់វិញ្ញាតកម្មហត្ថលេខាឌីជីថល

**មាត្រា១៨ .-**

ការផ្ទេរតាមកិច្ចសន្យា សន្តតិកម្ម ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ឬការបញ្ឈប់វិញ្ញាតកម្មហត្ថលេខាឌីជីថល ត្រូវគោរពតាមការកំណត់ក្នុងអនុក្រឹត្យនេះ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត។

**មាត្រា១៩ .-**

ក្នុងករណីវិញ្ញាតធរហត្ថលេខាឌីជីថល មានបំណងចង់បញ្ឈប់វិញ្ញាតកម្មហត្ថលេខាឌីជីថល បុគ្គលនោះត្រូវ៖

ក- ជូនដំណឹងជាលាយលក្ខណ៍អក្សរទៅ **អ.ប.គ.ព.** យ៉ាងតិច ០៣ (បី) ខែ មុនថ្ងៃបញ្ឈប់ ដោយបញ្ជាក់អំពីមូលហេតុនៃការបញ្ឈប់ និងចុះហត្ថលេខាដោយវិញ្ញាតធរហត្ថលេខាឌីជីថល

ខ- ជូនដំណឹងជាមុនដល់អ្នកប្រើប្រាស់សេវារបស់ខ្លួនយ៉ាងតិច ០៣ (បី) ខែ មុនថ្ងៃបញ្ឈប់

គ- ផ្ទេរវិញ្ញាបនបត្រហត្ថលេខាឌីជីថល និងកំណត់ត្រាវិញ្ញាបនបត្រហត្ថលេខាឌីជីថលទាំងអស់ដែលបានចេញទៅវិញ្ញាតធរហត្ថលេខាឌីជីថលផ្សេងមួយទៀត។

**អ.ប.ឌ.** ត្រូវកំណត់អំពីនីតិវិធីនៃការជូនដំណឹងអំពីការបញ្ឈប់វិញ្ញាតកម្មហត្ថលេខាឌីជីថល។

**មាត្រា២០.-**

ការផ្ទេរតាមកិច្ចសន្យា សន្តតិកម្ម ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ឬការបញ្ឈប់វិញ្ញាតកម្មហត្ថលេខាឌីជីថលត្រូវមានការយល់ព្រមជាមុនពី **អ.ប.គ.ព.** ស្របតាមការកំណត់របស់ **អ.ប.ឌ.** ។

លក្ខខណ្ឌនិងនីតិវិធីនៃការផ្ទេរតាមកិច្ចសន្យា សន្តតិកម្ម ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ឬការបញ្ឈប់វិញ្ញាតកម្មហត្ថលេខាឌីជីថលត្រូវកំណត់ដោយប្រកាសរបស់ **អ.ប.ឌ.**។

## ផ្នែកទី៣
## ការដកហូតអាជ្ញាបណ្ណវិញ្ញាតកម្មហត្ថលេខាឌីជីថល

**មាត្រា២១.-**

អាជ្ញាបណ្ណវិញ្ញាតកម្មហត្ថលេខាឌីជីថលត្រូវបានដកហូតក្នុងករណីណាមួយដូចខាងក្រោម៖

ក- វិញ្ញាតធរហត្ថលេខាឌីជីថលត្រូវបានផ្តន្ទាទោសព្រហ្មទណ្ឌ

ខ- វិញ្ញាតធរហត្ថលេខាឌីជីថលត្រូវបានជម្រះបញ្ជីឬរំលាយក្រុមហ៊ុន

គ- វិញ្ញាតធរហត្ថលេខាឌីជីថលបានក្លែងបន្លំវិញ្ញាបនបត្រហត្ថលេខាឌីជីថល

ឃ- សកម្មភាពរបស់វិញ្ញាតធរហត្ថលេខាឌីជីថលគំរាមដល់សណ្តាប់ធ្នាប់សាធារណៈ សន្តិសុខ ឬការពារជាតិ

ង- ការផ្តល់ព័ត៌មានឬឯកសារក្លែងដោយវិញ្ញាតធរហត្ថលេខាឌីជីថលដល់ **អ.ប.គ.ព.**

ច- ការផ្ទេរកិច្ចសន្យា សន្តតិកម្ម ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ឬការបញ្ឈប់វិញ្ញាតកម្មហត្ថលេខាឌីជីថលដោយពុំគោរពតាមលក្ខខណ្ឌនិងនីតិវិធីដូចមានចែងក្នុងអនុក្រឹត្យនេះ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត

ឆ- ករណីផ្សេងទៀតដែលកំណត់ដោយ **អ.ប.ឌ.**។

សេចក្តីសម្រេចស្តីពីការដកហូតអាជ្ញាបណ្ណវិញ្ញាតកម្មហត្ថលេខាឌីជីថលត្រូវផ្សាយជាសាធារណៈ។

នីតិវិធីនៃការដកហូតអាជ្ញាបណ្ណវិញ្ញាតកម្មហត្ថលេខាឌីជីថលត្រូវកំណត់ដោយប្រកាសរបស់ **អ.ប.ឌ.**។

**មាត្រា២២.-**

ក្នុងករណីអាជ្ញាបណ្ណវិញ្ញាតកម្មហត្ថលេខាឌីជីថលត្រូវបានដកហូត វិញ្ញាតធរហត្ថលេខាឌីជីថលត្រូវជូនដំណឹងដល់កម្មសិទ្ធិករវិញ្ញាបនបត្រហត្ថលេខាឌីជីថល និងត្រូវផ្ទេរវិញ្ញាបនបត្រហត្ថលេខាឌីជីថលទៅវិញ្ញាតធរហត្ថលេខាឌីជីថលផ្សេងទៀត ស្របតាមការកំណត់ដោយប្រកាសរបស់ **អ.ប.ឌ.**។

**អ.ប.ឌ.** ត្រូវកំណត់អំពីលក្ខខណ្ឌនិងនីតិវិធីក្នុងការផ្ទេរវិញ្ញាបនបត្រហត្ថលេខាឌីជីថល ក្នុងករណីអាជ្ញាបណ្ណវិញ្ញាតកម្មហត្ថលេខាឌីជីថលត្រូវបានដកហូត។

## ផ្នែកទី៤
## កម្រៃអាជ្ញាបណ្ណវិញ្ញាតកម្មហត្ថលេខាឌីជីថល

**មាត្រា២៣ .-**

អ្នកស្នើសុំអាជ្ញាបណ្ណវិញ្ញាតកម្មហត្ថលេខាឌីជីថល ឬវិញ្ញាតធរហត្ថលេខាឌីជីថល ត្រូវបង់កម្រៃនៃការស្នើសុំកម្រៃអាជ្ញាបណ្ណ កម្រៃនៃការស្នើសុំបន្ត កម្រៃនៃការផ្ទេរតាមកិច្ចសន្យា សន្តតិកម្ម ឬការរំលាយក្រុមហ៊ុនបញ្ចូលគ្នាពាក់ព័ន្ធនឹងអាជ្ញាបណ្ណវិញ្ញាតកម្មហត្ថលេខាឌីជីថល និងកម្រៃផ្សេងទៀត ស្របតាមការកំណត់ដោយប្រកាសរួមរវាង **គ.ប.ឌ.** និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៥
## វិញ្ញាបនបត្រហត្ថលេខាឌីជីថល

**មាត្រា២៤ .-**

វិញ្ញាតធរហត្ថលេខាឌីជីថលត្រូវរៀបចំវិធានរួមស្តីពីវិញ្ញាតកម្មហត្ថលេខាឌីជីថល ស្របតាមស្តង់ដានិងគោល-ការណ៍បច្ចេកទេសស្តីពីហត្ថលេខាឌីជីថល ដែលកំណត់ដោយប្រកាសរបស់ **គ.ប.ឌ.**។

**មាត្រា២៥ .-**

វិញ្ញាតធរហត្ថលេខាឌីជីថលត្រូវផ្តល់វិញ្ញាបនបត្រហត្ថលេខាឌីជីថលដល់បុគ្គលស្នើសុំ បន្ទាប់ពីបានបំពេញតាមលក្ខខណ្ឌ ដែលត្រូវបានកំណត់ដោយអនុក្រឹត្យនេះ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត។

វិញ្ញាតធរហត្ថលេខាឌីជីថលអាចផ្អាក ឬបញ្ឈប់ការប្រើប្រាស់វិញ្ញាបនបត្រហត្ថលេខាឌីជីថល ស្របតាមការកំណត់ក្នុងអនុក្រឹត្យនេះ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត។

**គ.ប.ឌ.** ត្រូវកំណត់អំពីលក្ខខណ្ឌនិងនីតិវិធីនៃការផ្តល់ ការផ្អាក និងការបញ្ឈប់ការប្រើប្រាស់វិញ្ញាបនបត្រហត្ថលេខាឌីជីថល។

**មាត្រា២៦ .-**

វិញ្ញាបនបត្រហត្ថលេខាឌីជីថលត្រូវកំណត់និទ្ទេសដូចខាងក្រោម៖

ក- អត្តសញ្ញាណរបស់កម្មសិទ្ធិករវិញ្ញាបនបត្រហត្ថលេខាឌីជីថល

ខ- គន្លឹះផ្ទៀងផ្ទាត់ហត្ថលេខាឌីជីថលរបស់កម្មសិទ្ធិករវិញ្ញាបនបត្រហត្ថលេខាឌីជីថល

គ- ការពិពណ៌នាអំពីវិធីដែលប្រើប្រាស់ដើម្បីចុះហត្ថលេខាឌីជីថលលើវិញ្ញាបនបត្រហត្ថលេខាឌីជីថល

ឃ- លេខសម្គាល់វិញ្ញាបនបត្រហត្ថលេខាឌីជីថល

ង- រយៈពេលសុពលភាពនៃវិញ្ញាបនបត្រហត្ថលេខាឌីជីថល

ច- អត្តសញ្ញាណរបស់វិញ្ញាតធរហត្ថលេខាឌីជីថល

ឆ- វិសាលភាពនិងគោលបំណងនៃការប្រើប្រាស់វិញ្ញាបនបត្រហត្ថលេខាឌីជីថល

ជ- និទ្ទេសផ្សេងទៀតដែលកំណត់ដោយ **គ.ប.ឌ.**។

## ជំពូកទី៦
## ភារកិច្ចរបស់វិញ្ញាតធរហត្ថលេខាឌីជីថលនិងកម្មសិទ្ធិករវិញ្ញាបនបត្រហត្ថលេខាឌីជីថល

**មាត្រា២៧.-**

វិញ្ញាតធរហត្ថលេខាឌីជីថលមានកាតព្វកិច្ចដូចខាងក្រោម៖

ក- ការពារនិងរក្សាសន្តិសុខសុវត្ថិភាពពាក់ព័ន្ធនឹងការចេញវិញ្ញាបនបត្រហត្ថលេខាឌីជីថល និងការប្រើប្រាស់ហត្ថលេខាឌីជីថលស្របតាមការកំណត់របស់ **ក.ប.ទ.** និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត

ខ- មិនត្រូវរក្សាទុកគន្លឹះបង្កើតហត្ថលេខាឌីជីថលរបស់កម្មសិទ្ធិករវិញ្ញាបនបត្រហត្ថលេខាឌីជីថល លើកលែងតែមានការព្រមព្រៀងជាលាយលក្ខណ៍អក្សរ

គ- មិនត្រូវប្រើប្រាស់ឬផ្សព្វផ្សាយគន្លឹះបង្កើតហត្ថលេខាឌីជីថលរបស់កម្មសិទ្ធិករវិញ្ញាបនបត្រហត្ថលេខាឌីជីថល

ឃ- រក្សាការសម្ងាត់ព័ត៌មានឯកជនរបស់កម្មសិទ្ធិករវិញ្ញាបនបត្រហត្ថលេខាឌីជីថល

ង- រក្សាទុកគន្លឹះបង្កើតហត្ថលេខាឌីជីថលដោយសម្ងាត់និងមានសុវត្ថិភាព

ច- រក្សាទុកនិងគ្រប់គ្រងកំណត់ត្រានៃការចេញវិញ្ញាបនបត្រហត្ថលេខាឌីជីថលប្រកបដោយសុវត្ថិភាពក្នុងរយៈពេល ១០ ឆ្នាំ បន្ទាប់ពីផុតសុពលភាពនៃវិញ្ញាបនបត្រហត្ថលេខាឌីជីថល

ឆ- រាយការណ៍ភ្លាមទៅ **អ.ប.គ.ព.** ក្នុងករណីមានការអាក់រអួលនៃប្រព័ន្ធដំណើរការទិន្នន័យ ឬឧបករណ៍វិធីសាស្ត្រ និងប្រព័ន្ធវិញ្ញាតកម្ម ក្នុងរយៈពេល ២៤ (ម្ភៃបួន) ម៉ោង

ជ- ផ្តល់ជូនកម្មសិទ្ធិករវិញ្ញាបនបត្រហត្ថលេខាឌីជីថល នូវឧបករណ៍ ឬមធ្យោបាយដែលអនុញ្ញាតឱ្យជូនដំណឹងអំពីការលួច ការបាត់បង់ ឬការលាតត្រដាងនូវគន្លឹះបង្កើតហត្ថលេខាឌីជីថល

ឈ- ផ្តល់របាយការណ៍ហិរញ្ញវត្ថុ និងព័ត៌មានមិនមែនហិរញ្ញវត្ថុជាប្រចាំ ឬតាមការស្នើសុំរបស់ **អ.ប.គ.ព.**

ញ- កាតព្វកិច្ចទាំងឡាយដែលត្រូវបានកំណត់ដោយអនុក្រឹត្យនេះ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត។

**មាត្រា២៨.-**

កម្មសិទ្ធិករវិញ្ញាបនបត្រហត្ថលេខាឌីជីថលមានកាតព្វកិច្ចដូចខាងក្រោម៖

ក- រក្សាទុកគន្លឹះបង្កើតហត្ថលេខាឌីជីថលដោយសម្ងាត់និងមានសុវត្ថិភាព

ខ- ជូនដំណឹងទៅវិញ្ញាតធរហត្ថលេខាឌីជីថលជាបន្ទាន់និងទៅអ្នកទទួលទិន្នន័យដែលត្រូវបានផ្ញើនៅពេលដែលគន្លឹះបង្កើតហត្ថលេខាឌីជីថល ត្រូវបានលួច បាត់បង់ ឬលាតត្រដាង

គ- កាតព្វកិច្ចទាំងឡាយដែលត្រូវបានកំណត់ដោយអនុក្រឹត្យនេះ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត។

## ជំពូកទី៧
## ការដោះស្រាយវិវាទ

**មាត្រា២៩.-**

ក្រៅពីករណីបទល្មើសព្រហ្មទណ្ឌ គ្រប់វិវាទដែលពាក់ព័ន្ធនឹងវិញ្ញាតធរហត្ថលេខាឌីជីថល ជាអាទិ៍ វិវាទរវាងវិញ្ញាតធរហត្ថលេខាឌីជីថលនិងវិញ្ញាតធរហត្ថលេខាឌីជីថល និងរវាងវិញ្ញាតធរហត្ថលេខាឌីជីថលនិងកម្មសិទ្ធិករវិញ្ញាបនបត្រហត្ថលេខាឌីជីថល ភាគីវិវាទអាចដាក់សំណុំរឿងទៅ **ក.ប.ទ.** ដើម្បីធ្វើការផ្សះផ្សា។

លក្ខខណ្ឌនិងនីតិវិធីនៃការផ្សះផ្សាត្រូវកំណត់ដោយប្រកាសរបស់ **ក.ប.ទ.**។ កម្រៃសេវាសម្រាប់ដោះស្រាយវិវាទត្រូវកំណត់ដោយប្រកាសរួមរវាង **ក.ប.ទ.** និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

# ជំពូកទី៨
# ទោសប្បញ្ញត្តិ

**មាត្រា៣០ .—**

ក្រោយពេលផ្ដល់អាជ្ញាបណ្ណវិញ្ញាតកម្មហត្ថលេខាឌីជីថល ប្រសិនបើពិនិត្យឃើញថាវិញ្ញាតធរហត្ថលេខាឌីជីថល មិនអនុវត្តតាមលក្ខខណ្ឌណាមួយនៃអាជ្ញាបណ្ណ ឬលក្ខខណ្ឌណាមួយដែលកំណត់ដោយអនុក្រឹត្យនេះ ឬបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត **ក.ប.ឌ.** អាចចាត់វិធានការជាអាទិ៍ ដូចខាងក្រោម៖

ក- ដឹកនាំកែតម្រង់វិញ្ញាតធរហត្ថលេខាឌីជីថលឱ្យអនុវត្តតាមលក្ខខណ្ឌនិងលក្ខខណ្ឌបន្ថែម

ខ- ដាក់កំហិតលើអាជ្ញាបណ្ណវិញ្ញាតកម្មហត្ថលេខាឌីជីថល

គ- ព្យួរអាជ្ញាបណ្ណរហូតដល់វិញ្ញាតធរហត្ថលេខាឌីជីថលគោរពពេញលេញតាមលក្ខខណ្ឌ ឬលក្ខខណ្ឌបន្ថែម។

ក្នុងករណីវិញ្ញាតធរហត្ថលេខាឌីជីថលមិនអនុវត្តតាមវិធានការ ដែលបានដាក់ចេញដូចមានចែងក្នុងកថាខណ្ឌទី១ ខាងលើ ឬបានប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ ឬបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត **ក.ប.ឌ.** អាចចាត់វិធានការជាអាទិ៍ ដូចខាងក្រោម៖

ក- ព្យួរបណ្ដោះអាសន្ន ឬបញ្ឈប់ការងាររបស់អគ្គនាយក នាយកប្រតិបត្តិ សមាជិកគណៈគ្រប់គ្រង ឬបុគ្គលិកជាន់ខ្ពស់របស់វិញ្ញាតធរហត្ថលេខាឌីជីថល

ខ- ជ្រើសរើសនិងផ្ដល់អំណាចដល់បុគ្គលដែលមានសមត្ថកិច្ចសមស្រប ដើម្បីពិនិត្យមើលសកម្មភាពអាជីវកម្ម ឬសកម្មភាពពាក់ព័ន្ធផ្សេងទៀតរបស់វិញ្ញាតធរហត្ថលេខាឌីជីថល។ បុគ្គលនោះត្រូវធ្វើរបាយ-ការណ៍ជូន **ក.ប.ឌ.** តាមលក្ខខណ្ឌដែលមានចែងក្នុងកិច្ចសន្យាជាមួយ **ក.ប.ឌ.**

គ- ដាក់កំហិត ឬបញ្ឈប់សកម្មភាពជាក់លាក់ ឬទូទៅរបស់វិញ្ញាតធរហត្ថលេខាឌីជីថល ទោះបីជាសកម្មភាពទាំងនោះបានធ្វើឡើងស្រប ឬមិនស្របតាមលក្ខខណ្ឌនៃអាជ្ញាបណ្ណក៏ដោយ។

**ក.ប.ឌ.** អាចចាត់វិធានការដូចមានចែងក្នុងកថាខណ្ឌទី១ ឬកថាខណ្ឌទី២ លុះត្រាតែបានជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុនដល់វិញ្ញាតធរហត្ថលេខាឌីជីថល អំពីមូលហេតុនៃការចាត់វិធានការនេះនិងផ្ដល់ឱកាសឱ្យវិញ្ញាតធរហត្ថលេខាឌីជីថលពន្យល់។

**មាត្រា៣១ .—**

ត្រូវពិន័យអន្តរការណ៍ ចំពោះការធ្វើប្រតិបត្តិការដូចមានចែងក្នុងមាត្រា១៤ នៃអនុក្រឹត្យនេះ ដោយគ្មានអាជ្ញាបណ្ណពី **ក.ប.ឌ.** ដូចខាងក្រោម៖

- រូបវន្តបុគ្គល៖ ចំនួនទឹកប្រាក់ពី ៥ ០០០ ០០០ (ប្រាំលាន) រៀល ទៅ ១៥ ០០០ ០០០ (ដប់ប្រាំលាន) រៀល។
- នីតិបុគ្គល៖ ចំនួនទឹកប្រាក់ពី ៥០ ០០០ ០០០ (ហាសិបលាន) រៀល ទៅ ១៥០ ០០០ ០០០ (មួយរយហាសិបលាន) រៀល។

**មាត្រា៣២ .—**

រាល់ការរក្សាទុកឬការប្រើប្រាស់នូវគន្លឹះបង្កើតហត្ថលេខាឌីជីថលរបស់អ្នកដទៃ ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីកម្មសិទ្ធិករវិញ្ញាបនបត្រហត្ថលេខាឌីជីថល ត្រូវពិន័យអន្តរការណ៍ជាប្រាក់ ដូចខាងក្រោម៖

- រូបវន្តបុគ្គល៖ ចំនួនទឹកប្រាក់ពី ៣ ០០០ ០០០ (បីលាន) រៀល ទៅ ៩ ០០០ ០០០ (ប្រាំបួនលាន)រៀល។
- នីតិបុគ្គល៖ ចំនួនទឹកប្រាក់ពី ២៥ ០០០ ០០០ (ម្ភៃប្រាំលាន) រៀល ទៅ ៧៥ ០០០ ០០០ (ចិតសិបប្រាំលាន) រៀល។

**មាត្រា៣៣ .–**

ការផ្សព្វផ្សាយនូវគន្លឹះបង្កើតហត្ថលេខាឌីជីថល ត្រូវពិន័យអន្តរការណ៍ជាប្រាក់ ដូចខាងក្រោម៖

- រូបវន្តបុគ្គល៖ ចំនួនទឹកប្រាក់ពី ៣ ០០០ ០០០ (បីលាន) រៀល ទៅ ៩ ០០០ ០០០ (ប្រាំបួនលាន)រៀល។
- នីតិបុគ្គល៖ ចំនួនទឹកប្រាក់ពី ២៥ ០០០ ០០០ (ម្ភៃប្រាំលាន) រៀល ទៅ ៧៥ ០០០ ០០០ (ចិតសិបប្រាំលាន) រៀល។

**មាត្រា៣៤ .–**

វិញ្ញាតធរហត្ថលេខាឌីជីថលដែលបានផ្ទេរតាមកិច្ចសន្យា សន្តតិកម្ម ឬការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ដោយពុំមានការយល់ព្រមជាមុនពី **អ.គ.ប.ព.** ស្របតាមការកំណត់របស់ **ក.ប.ឌ.** ត្រូវពិន័យអន្តរការណ៍ជាប្រាក់ពី ២០ ០០០ ០០០ (ម្ភៃលាន) រៀល ទៅ ៦០ ០០០ ០០០ (ហុកសិបលាន) រៀល។

**មាត្រា៣៥ .–**

រាល់វិញ្ញាតធរហត្ថលេខាឌីជីថលដែលមិនអនុវត្តកាតព្វកិច្ចដូចមានចែងក្នុងមាត្រា២៧ ចំណុច (ឈ) នៃអនុក្រឹត្យនេះ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ពី ១០ ០០០ ០០០ (ដប់លាន) រៀល ទៅ ៣០ ០០០ ០០០ (សាមសិបលាន) រៀល។

**មាត្រា៣៦ .–**

រាល់ការរារាំង មិនសហការ ឬការបង្កជាឧបសគ្គដល់ការចុះត្រួតពិនិត្យការអនុវត្តអាជ្ញាបណ្ណវិញ្ញាតកម្មហត្ថលេខាឌីជីថល របស់មន្ត្រីដែលបានចាត់តាំងដោយ **ក.ប.ឌ.** ឬស្ថាប័នមានសមត្ថកិច្ចត្រូវពិន័យអន្តរការណ៍ជាប្រាក់ ដូចខាងក្រោម៖

- រូបវន្តបុគ្គល៖ ចំនួនទឹកប្រាក់ពី ៣ ០០០ ០០០ (បីលាន) រៀល ទៅ ៩ ០០០ ០០០ (ប្រាំបួនលាន)រៀល។
- នីតិបុគ្គល៖ ចំនួនទឹកប្រាក់ពី ១០ ០០០ ០០០ (ដប់លាន) រៀល ទៅ ៣០ ០០០ ០០០ (សាមសិបលាន) រៀល។

**មាត្រា៣៧ .–**

រាល់វិញ្ញាតធរហត្ថលេខាឌីជីថលដែលមិនចេញវិញ្ញាបនបត្រហត្ថលេខាឌីជីថល ឬយឺតយ៉ាវក្នុងការចេញវិញ្ញាបនបត្រហត្ថលេខាឌីជីថល ត្រូវពិន័យអន្តរការណ៍ជាប្រាក់ពី ៣ ០០០ ០០០ (បីលាន) រៀល ទៅ ៩ ០០០ ០០០ (ប្រាំបួនលាន) រៀល។

**មាត្រា៣៨ .–**

ការដាក់ពិន័យអន្តរការណ៍ជាសមត្ថកិច្ចរបស់ **ក.ប.ឌ.**។

**មាត្រា៣៩ .–**

បុគ្គលដែលបានប្រព្រឹត្តបទល្មើសដូចដែលមានចែងក្នុងមាត្រា៣១ មាត្រា៣២ មាត្រា៣៣ មាត្រា៣៤ មាត្រា៣៥ មាត្រា៣៦ និងមាត្រា៣៧ នៃអនុក្រឹត្យនេះ ត្រូវបង់ប្រាក់ពិន័យអន្តរការណ៍ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានសេចក្តីសម្រេចពិន័យ។

ក្នុងករណីជនល្មើសមិនបានបង់ប្រាក់ពិន័យអន្តរការណ៍តាមការកំណត់ដូចកថាខណ្ឌទី១ ខាងលើ **ក.ប.ឌ.** ត្រូវរៀបចំសំណុំឯកសារបញ្ជូនទៅអយ្យការអមសាលាដំបូង។

ទម្រង់បែបបទនៃការពិន័យនិងការគ្រប់គ្រងប្រាក់ ដែលបានមកពីការពិន័យត្រូវកំណត់ដោយប្រកាសរួមរវាង **ក.ប.ឌ.** និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៩
## អវសានប្បញ្ញត្តិ

**មាត្រា៤០ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៤១ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១២កើត ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍**

**ត្រាំ អ៊ីវតឹក**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៤១
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធទី៤

អនុក្រឹត្យលេខ ១៣៤ អនក្រ.បក ស្តីពី ការកំណត់ប្រភេទ បែបបទ និងនីតិវិធីនៃការផ្តល់លិខិតអនុញ្ញាឬអាជ្ញាបណ្ណដល់អន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជតាមប្រព័ន្ធអេឡិចត្រូនិក និងការលើកលែង ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២០

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ១៣៤ អនក្រ.បក

# អនុក្រឹត្យ

# ស្តីពី

# ការកំណត់ប្រភេទ បែបបទ និងនីតិវិធីនៃការផ្តល់លិខិតអនុញ្ញាតឬ អាជ្ញាបណ្ណដល់អន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្ម តាមប្រព័ន្ធអេឡិចត្រូនិក និងការលើកលែង

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៧ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មនិងរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះ កំណត់អំពីការលើកលែង ប្រភេទ បែបបទ និងលក្ខខណ្ឌនៃការផ្តល់លិខិតអនុញ្ញាត អាជ្ញាបណ្ណ និងវិញ្ញាបនបត្រសម្គាល់ទំនុកចិត្តពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ក្នុងគោលបំណងដើម្បីគ្រប់គ្រងប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក នៅក្នុងព្រះរាជាណាចក្រកម្ពុជា និងជាមួយអន្តរជាតិ។

**មាត្រា២ .-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះរូបវន្តបុគ្គល សហគ្រាសឯកបុគ្គល នីតិបុគ្គល និងសាខាក្រុមហ៊ុនបរទេសដែលធ្វើប្រតិបត្តិការនិងសកម្មភាពពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅក្នុងព្រះរាជាណាចក្រកម្ពុជា និង/ឬផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកពីព្រះរាជាណាចក្រកម្ពុជាទៅក្រៅប្រទេស ឬពីក្រៅប្រទេសចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៣ .-**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងអនុក្រឹត្យនេះ ត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

**១. ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក** សំដៅដល់សកម្មភាពទិញ លក់ ជួល ផ្លាស់ប្តូរទំនិញឬសេវា ដោយរាប់បញ្ចូលទាំងសកម្មភាពពាណិជ្ជកម្ម និងរដ្ឋប្បវេណីព្រមទាំងសកម្មភាព និងប្រតិបត្តិការនានារបស់រដ្ឋ តាមប្រព័ន្ធអេឡិចត្រូនិក។

**២. បុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក** សំដៅដល់បុគ្គលដែលប្រើប្រាស់មធ្យោបាយអេឡិចត្រូនិកដើម្បីផ្គត់ផ្គង់ទំនិញនិង/ឬសេវា លើកលែងគ្រឹះស្ថានធានារ៉ាប់រង។

**៣. អន្តរការី** សំដៅដល់បុគ្គលដែលផ្តល់សេវាផ្ញើ ទទួល បញ្ជូន ឬរក្សាទុកជាបណ្តោះអាសន្នឬជាអចិន្ត្រៃយ៍នូវទំនាក់ទំនងអេឡិចត្រូនិកនោះ ឬផ្តល់សេវាផ្សេងទៀតដែលពាក់ព័ន្ធនឹងការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

**៤. បុគ្គលផ្តល់សេវាទូទាត់** សំដៅដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ឬបុគ្គលដទៃទៀតដែលបានទទួលការអនុញ្ញាត ឬអាជ្ញាបណ្ណពីធនាគារជាតិនៃកម្ពុជា ឱ្យធ្វើប្រតិបត្តិការប្រព័ន្ធទូទាត់ ចេញផ្សាយឧបករណ៍ទូទាត់អេឡិចត្រូនិក ឬមធ្យោបាយទូទាត់ជាអេឡិចត្រូនិក ឬធ្វើប្រតិបត្តិការណាដែលត្រូវបានចាត់ទុកថា ជាការផ្តល់ការទូទាត់សងប្រាក់ជាអេឡិចត្រូនិកដល់សាធារណជន។

**៥. ប្រព័ន្ធអេឡិចត្រូនិក** សំដៅដល់ឧបករណ៍អេឡិចត្រូនិកឬបណ្តុំឧបករណ៍តភ្ជាប់គ្នា ឬទាក់ទងគ្នាតាមរយៈកម្មវិធីអេឡិចត្រូនិក ដែលអាចធ្វើឱ្យដំណើរការជាស្វ័យប្រវត្តិនៃទិន្នន័យ ព័ត៌មាន ឬ ឯកសារ រួមបញ្ចូលទាំងឧបករណ៍អេឡិចត្រូនិកសម្រាប់រក្សាទុកទិន្នន័យ ព័ត៌មាន ឬឯកសារនោះ។

## ជំពូកទី២
## ស្ថាប័នមានសមត្ថកិច្ច អាជ្ញាបណ្ណ លិខិតអនុញ្ញាត ការលើកលែង និងវិញ្ញាបនបត្រ

**មាត្រា៤ .-**

១. ក្រសួងពាណិជ្ជកម្ម ជាស្ថាប័នមានសមត្ថកិច្ចក្នុងការគ្រប់គ្រងនិងផ្តល់លិខិតអនុញ្ញាតឬអាជ្ញាបណ្ណដល់អន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងវិញ្ញាបនបត្រសម្គាល់ទំនុកចិត្តពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

២. ការរៀបចំគោលនយោបាយនិងយុទ្ធសាស្ត្រពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ក្នុងកម្រិតជាតិនិងអន្តរជាតិជាសមត្ថកិច្ចរបស់ក្រសួងពាណិជ្ជកម្មនិងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ដោយធ្វើការសម្របសម្រួលជាមួយនឹងក្រសួង ស្ថាប័ន និងភាគីពាក់ព័ន្ធ។

**មាត្រា៥ _**

១_ អាជ្ញាបណ្ណសម្រាប់ប្រតិបត្តិការផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវផ្តល់ឱ្យនីតិបុគ្គល និងសាខាក្រុមហ៊ុនបរទេសដែលនឹងធ្វើប្រតិបត្តិការនិងសកម្មភាពពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកដូចខាងក្រោម៖

ក_ សេវាគេហទំព័រពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

ខ_ សេវាថ្នាលពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

គ_ សេវាទីផ្សារអនឡាញ។

ឃ_ សេវាគេហទំព័រដេញថ្លៃអនឡាញ។

ង_ សេវាស្រដៀងគ្នាផ្សេងទៀតដែលផ្តល់តាមរយៈកម្មវិធីកុំព្យូទ័រឬឧបករណ៍វៃឆ្លាតសម្រាប់ការជំរុញធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

២_ លិខិតអនុញ្ញាតប្រកបអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវផ្តល់ឱ្យរូបវន្តបុគ្គលឬសហគ្រាសឯកបុគ្គលដែលនឹងប្រកបអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិកក្នុងព្រះរាជាណាចក្រកម្ពុជា រួមទាំងរូបវន្តបុគ្គលឬសហគ្រាសឯកបុគ្គលដែលប្រើប្រាស់បណ្តាញសង្គមឬប្រព័ន្ធអេឡិចត្រូនិកជាមធ្យោបាយក្នុងការផ្គត់ផ្គង់ឬទិញ-លក់ទំនិញ និង/ឬសេវា។

៣_ ត្រូវបានលើកលែងការតម្រូវឱ្យស្នើសុំលិខិតអនុញ្ញាតប្រកបអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិក ចំពោះរូបវន្តបុគ្គល ឬសហគ្រាសឯកបុគ្គលដែលធ្វើសកម្មភាពឬប្រតិបត្តិការដូចខាងក្រោម៖

ក_ ការផ្សព្វផ្សាយពាណិជ្ជកម្មអំពីទំនិញឬសេវារបស់ខ្លួន រួមបញ្ចូលទាំងការផ្សព្វផ្សាយលក់ទំនិញឬសេវាដែលមិនមែនជាសំណើបង្កើតកិច្ចសន្យា។

ខ_ ការបម្រុងទុកសេវាដែលមិនមានការកក់ប្រាក់ ឬទូទាត់កម្រៃ ដោយអតិថិជនឬអ្នកប្រើប្រាស់។

គ_ ការលក់ទំនិញឬសេវារបស់រូបវន្តបុគ្គលឬសហគ្រាសឯកបុគ្គល ដែលមានផលរបរនៅក្រោមកម្រិតផលរបរជាអ្នកជាប់ពន្ធតូច។

ឃ_ ការលក់ទំនិញ ឬសេវាដែលមានលក្ខណៈគ្រួសារ ឬតាមរដូវកាលប្រមូលផល។

ង_ ការលក់ទំនិញ ឬសេវាដែលជាស្នាដៃសិល្បៈផ្ទាល់ខ្លួនសុទ្ធសាធ។

ច_ ការបង្ហាត់បង្រៀនដោយឯកជនផ្ទាល់ខ្លួន។

ឆ_ ការបង្ហាត់បង្រៀន ឬអប់រំអំពីសាសនារបស់រដ្ឋ។

ការបង្ហាត់បង្រៀនដោយសមាគមឬអង្គការមិនមែនរដ្ឋាភិបាល ដែលមិនរកប្រាក់ចំណេញដោយផ្ទាល់ឬប្រយោលនិងសកម្មភាពឬប្រតិបត្តិការដោយស្ថាប័នរដ្ឋក្នុងការផ្តល់សេវាសាធារណៈ ក៏ត្រូវបានលើកលែងការតម្រូវឱ្យស្នើសុំលិខិតអនុញ្ញាតផងដែរ។

៤_ ក្នុងគោលបំណងស្រង់ទិន្នន័យ និងការពារអ្នកប្រើប្រាស់ បុគ្គលដែលត្រូវបានលើកលែងការតម្រូវឱ្យស្នើសុំលិខិតអនុញ្ញាត ដូចបានកំណត់ក្នុងកថាខណ្ឌទី៣ខាងលើ ត្រូវជូនដំណឹងមកក្រសួងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកអំពីព័ត៌មានដូចខាងក្រោម៖

ក_ ប្រភេទប្រតិបត្តិការ។

ខ_ ឈ្មោះអាជីវកម្ម។

គ_ មធ្យោបាយអេឡិចត្រូនិកដែលបានប្រើប្រាស់។

ឃ_ មធ្យោបាយទូទាត់របស់ខ្លួន។ និង

ង. អត្តសញ្ញាណម្ចាស់ លេខទូរសព្ទ និងអាសយដ្ឋានសម្រាប់ទំនាក់ទំនង។

គំរូលិខិតជូនដំណឹងមានភ្ជាប់ក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

៥. បុគ្គលដែលទទួលបានលិខិតអនុញ្ញាត ឬអាជ្ញាបណ្ណ ដូចបានកំណត់ក្នុងកថាខណ្ឌទី១ និងទី២ខាងលើ អាចស្នើសុំវិញ្ញាបនបត្រសម្គាល់ទំនុកចិត្តពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅក្រសួងពាណិជ្ជកម្ម ដើម្បីបញ្ជាក់អំពីអនុលោមភាព សុវត្ថិភាព និងទំនុកចិត្ត។

៦. រូបវន្តបុគ្គលឬសហគ្រាសឯកបុគ្គល នីតិបុគ្គល និងសាខាក្រុមហ៊ុនបរទេសដូចបានកំណត់នៅក្នុងកថាខណ្ឌទី១ កថាខណ្ឌទី២ និងកថាខណ្ឌទី៣នៃមាត្រានេះត្រូវស្ថិតក្រោមនីតិរូបនៃច្បាប់ស្តីពីសារពើពន្ធជាធរមាន។

## ជំពូកទី៣
## ការផ្តល់លិខិតអនុញ្ញាត អាជ្ញាបណ្ណ ឬវិញ្ញាបនបត្រ ដល់អន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

**មាត្រា៦.-**

ការផ្តល់លិខិតអនុញ្ញាតប្រកបអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវបានកំណត់ដូចខាងក្រោម៖

១.រូបវន្តបុគ្គលដែលមានសិទ្ធិស្នើសុំលិខិតអនុញ្ញាតប្រកបអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិក លុះត្រាតែទទួលបានលិខិតអនុញ្ញាតប្រកបអាជីវកម្មឬចុះបញ្ជីពាណិជ្ជកម្ម និងបានចុះបញ្ជីពន្ធដារ ស្របតាមបទប្បញ្ញត្តិជាធរមាន។

២. រូបវន្តបុគ្គលដែលបានកំណត់ក្នុងកថាខណ្ឌទី១ខាងលើ ត្រូវស្នើសុំលិខិតអនុញ្ញាតប្រកបអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅក្រសួងពាណិជ្ជកម្ម មុនពេលចាប់ផ្តើមអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

៣. ពេលធ្វើអាជីវកម្ម ត្រូវផ្តល់ព័ត៌មានអប្បបរមា ដូចមានចែងក្នុងកថាខណ្ឌទី១និងទី២នៃមាត្រា២៩នៃច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក នៃព្រះរាជាណាចក្រកម្ពុជា។

៤. សុពលភាពនៃលិខិតអនុញ្ញាតប្រកបអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិក មានរយៈពេល២(ពីរ)ឆ្នាំ គិតចាប់ពីថ្ងៃផ្តល់លិខិតអនុញ្ញាតដោយក្រសួងពាណិជ្ជកម្ម ហើយអាចស្នើសុំបន្តសុពលភាពបាន។

៥. បែបបទ ឯកសារតម្រូវ ការបន្តសុពលភាព ការកែប្រែព័ត៌មាន និងលក្ខខណ្ឌក្នុងការផ្ទេរលិខិតអនុញ្ញាត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។

**មាត្រា៧.-**

១. នីតិបុគ្គលឬសាខាក្រុមហ៊ុនបរទេស ដែលជាអន្តរការីឬបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវស្នើសុំអាជ្ញាបណ្ណសម្រាប់ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅក្រសួងពាណិជ្ជកម្ម មុនពេលចាប់ផ្តើមប្រតិបត្តិការ ហើយត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- ក. បានចុះបញ្ជីពាណិជ្ជកម្ម និងចុះបញ្ជីពន្ធដារក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ហើយមានកម្មវត្ថុអាជីវកម្មសម្រាប់ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។
- ខ. មានវិញ្ញាបនបត្រសេវាអនឡាញ និងឈ្មោះដែនកម្មសិទ្ធិពីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។
- គ. ប្រើមធ្យោបាយឬកម្មវិធីអេឡិចត្រូនិក សម្រាប់ធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

ឃ. ប្រព័ន្ធអេឡិចត្រូនិកដែលនឹងត្រូវបានប្រើប្រាស់ ត្រូវមានសុក្រឹត្យភាពដូចមានកំណត់ក្នុងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

ង. មានការបញ្ជាក់អំពីមធ្យោបាយទូទាត់។

ច. មានគំរូអាជីវកម្មនិងទម្រង់នៃកិច្ចការពារអ្នកប្រើប្រាស់។

ឆ. ក្នុងករណីនីតិបុគ្គលឬសាខាក្រុមហ៊ុនបរទេសដែលជាអន្តរការី ត្រូវធ្វើកិច្ចសន្យាជាមួយបុគ្គលផ្តល់សេវាពាណិជ្ជកម្ម អំពីការតម្រូវឱ្យផ្តល់ព័ត៌មានអប្បបរមា អនុលោមតាមកថាខណ្ឌទី១និងទី២នៃមាត្រា ២៩ និងមាត្រា៣៣នៃច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក នៃព្រះរាជាណាចក្រកម្ពុជា។

២. សុពលភាពនៃអាជ្ញាបណ្ណសម្រាប់ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក មានរយៈពេល៣(បី)ឆ្នាំ គិតចាប់ពីថ្ងៃផ្តល់អាជ្ញាបណ្ណដោយក្រសួងពាណិជ្ជកម្ម ហើយអាចស្នើសុំបន្តសុពលភាពបាន។

៣. បែបបទ ឯកសារតម្រូវ ការបន្តសុពលភាព ការកែប្រែព័ត៌មាន និងលក្ខខណ្ឌក្នុងការផ្ទេរអាជ្ញាបណ្ណ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។

**មាត្រា៨.-**

១. អន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដែលទទួលបានលិខិតអនុញ្ញាតប្រកបអាជីវកម្មឬអាជ្ញាបណ្ណសម្រាប់ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិករួចហើយ អាចស្នើសុំវិញ្ញាបនបត្រសម្គាល់ទំនុកចិត្តពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកពីក្រសួងពាណិជ្ជកម្ម តាមការស្ម័គ្រចិត្ត។

២. បែបបទ ឯកសារតម្រូវ លក្ខណៈវិនិច្ឆ័យ កម្រិតអនុលោមភាពនៃគោលការណ៍ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។

**មាត្រា៩.-**

បែបបទនិងនីតិវិធីនៃការព្រមានជាលាយលក្ខណ៍អក្សរ ការបញ្ឈប់សកម្មភាពឬប្រតិបត្តិការអាជីវកម្ម ការព្យួរ ការដកហូត ឬការលុបចោលលិខិតអនុញ្ញាតឬអាជ្ញាបណ្ណ ត្រូវកំណត់ដោយប្រកាសរួមរវាងរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។

## ជំពូកទី៤

## អន្តរប្បញ្ញត្តិ

**មាត្រា១០.-**

រូបវន្តបុគ្គល សហគ្រាសឯកបុគ្គល នីតិបុគ្គល ឬសាខាក្រុមហ៊ុនបរទេស ដែលបានធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកមុនអនុក្រឹត្យនេះចូលជាធរមាន ត្រូវស្នើសុំលិខិតអនុញ្ញាតឬអាជ្ញាបណ្ណ ដូចបានកំណត់ក្នុងជំពូកទី៣ នៃអនុក្រឹត្យនេះ ក្នុងរយៈពេលយ៉ាងយូរបំផុត៦(ប្រាំមួយ)ខែ ក្រោយពេលអនុក្រឹត្យនេះចូលជាធរមាន។

## ជំពូកទី៥

## អវសានប្បញ្ញត្តិ

**មាត្រា១១.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងខ្លឹមសារនៃអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៨កើត ខែ ភទ្របទ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ សីហា ឆ្នាំ២០២០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន សូរស័ក្តិ**

**រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍**

**ជា វ៉ាន់ដេត**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធទី៥

អនុក្រឹត្យលេខ ៦៥ អនក្រ.បក ស្តីពីការអនុវត្តអាករលើតម្លៃបន្ថែមចំពោះ
ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២១

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៦៥ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការអនុវត្តអាករលើតម្លៃបន្ថែមចំពោះពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៧ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- អនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីអាករលើតម្លៃបន្ថែម
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

# សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

### មាត្រា១.- គោលបំណងនិងគោលដៅ

អនុក្រឹត្យនេះ កំណត់អំពីលក្ខខណ្ឌពិសេស និងដាក់ចេញនូវយន្តការអនុវត្តអាករលើតម្លៃបន្ថែមលើទំនិញឌីជីថល និងសេវាឌីជីថលដែលធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក សម្រាប់ប្រើប្រាស់ក្នុងព្រះរាជាណាចក្រកម្ពុជា និងធ្វើការផ្គត់ផ្គង់ដោយអ្នកជាប់ពន្ធអនិវាសនជនដែលមិនមានគ្រឹះស្ថានអចិន្ត្រៃយ៍នៅព្រះរាជាណាចក្រកម្ពុជា ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តស្របតាមមាត្រា៧៥ នៃច្បាប់ស្តីពីសារពើពន្ធ ។

### មាត្រា២.- វិសាលភាព

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះការផ្គត់ផ្គង់ទំនិញឌីជីថល ឬសេវាឌីជីថលតាមប្រព័ន្ធអេឡិចត្រូនិក ឬរាល់សកម្មភាពពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកដែលធ្វើឡើងដោយអ្នកផ្គត់ផ្គង់អនិវាសនជននៅក្រៅព្រះរាជាណាចក្រកម្ពុជាមកក្នុងព្រះរាជាណាចក្រកម្ពុជា។ ដោយឡែកចំពោះសកម្មភាពពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវអនុវត្តតាមបទប្បញ្ញត្តិស្តីពីអាករលើតម្លៃបន្ថែមជាធរមាន។

### មាត្រា៣.- និយមន័យ

វាក្យសព្ទសំខាន់ៗ ដែលប្រើក្នុងអនុក្រឹត្យនេះ ត្រូវបានកំណត់និយមន័យ ដូចខាងក្រោម÷

១. ពាក្យ "ការផ្គត់ផ្គង់ទំនិញ ឬសេវា ពីអាជីវកម្មទៅអាជីវកម្ម (Business to Business - B2B)" សំដៅដល់ការផ្គត់ផ្គង់ទំនិញ ឬសេវា ពីសហគ្រាសមួយទៅសហគ្រាសមួយទៀត។

២. ពាក្យ "ការផ្គត់ផ្គង់ទំនិញ ឬសេវា ពីអាជីវកម្មទៅអ្នកប្រើប្រាស់ (Business to Consumer - B2C)" សំដៅដល់ការផ្គត់ផ្គង់ទំនិញ ឬសេវា ពីសហគ្រាសទៅអ្នកប្រើប្រាស់។

៣. ពាក្យ "ទំនិញឌីជីថល" សំដៅដល់ទំនិញអរូបីដែលត្រូវបានបញ្ជាទិញ ផ្គត់ផ្គង់ និងបញ្ជូនទាំងស្រុងតាមប្រព័ន្ធអេឡិចត្រូនិក។

៤. ពាក្យ "សេវាឌីជីថល" សំដៅដល់សេវាដែលត្រូវបានធ្វើប្រតិបត្តិការតាមប្រព័ន្ធអេឡិចត្រូនិក។

៥. ពាក្យ "ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក" (Electronic Commerce) សំដៅដល់សកម្មភាពទិញ លក់ ជួល ផ្លាស់ប្តូរទំនិញ ឬសេវា ដោយរាប់បញ្ចូលទាំងសកម្មភាពពាណិជ្ជកម្ម និងរដ្ឋប្បវេណីតាមប្រព័ន្ធអេឡិចត្រូនិក។ ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក រួមមានសកម្មភាព ឬប្រតិបត្តិការអាជីវកម្មដោយមិនកម្រិតត្រឹមតែទម្រង់ដូចមានក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

៦. ពាក្យ "វិធីគិតអាករជំនួស" (Reverse Charge) សំដៅដល់វិធីសាស្ត្រដែលបុគ្គលទទួលការផ្គត់ផ្គង់ទំនិញឌីជីថល ឬសេវាឌីជីថលតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវគិតអាករលើតម្លៃបន្ថែមជំនួសបុគ្គលដែលផ្គត់ផ្គង់លើតម្លៃជាប់អាករ។

៧. ពាក្យ "អ្នកជាប់ពន្ធនិវាសនជន" សំដៅដល់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសដែលបានចុះបញ្ជីតាមច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារ និងធ្វើការផ្គត់ផ្គង់ទំនិញឌីជីថល ឬសេវាឌីជីថលតាមប្រព័ន្ធអេឡិចត្រូនិក ឬធ្វើសកម្មភាពអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

៨. ពាក្យ "អ្នកជាប់ពន្ធអនិវាសនជន" សំដៅដល់បុគ្គលណាមួយដែលមិនមែនជាអ្នកជាប់ពន្ធនិវាសជនតាមចំណុចទី៧ នៃមាត្រានេះ ដែលធ្វើការផ្គត់ផ្គង់ទំនិញឌីជីថល ឬសេវាឌីជីថល តាមប្រព័ន្ធអេឡិចត្រូនិកពីក្រៅប្រទេសមកក្នុងព្រះរាជាណាចក្រកម្ពុជា។

៩. ពាក្យ "អាករ" សំដៅដល់ អាករលើតម្លៃបន្ថែម។

## ជំពូកទី ២
## កាតព្វកិច្ចសារពើពន្ធ

### មាត្រា៤.- ការចុះបញ្ជីពន្ធដារ

រាល់អ្នកជាប់ពន្ធអនិវាសនជនដែលមិនមានគ្រឹះស្ថានអចិន្ត្រៃយ៍នៅព្រះរាជាណាចក្រកម្ពុជា ដែលធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវមានកាតព្វកិច្ចចុះបញ្ជីពន្ធដារដោយផ្អែកតាមចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ការចុះបញ្ជីនេះត្រូវបានអនុវត្តសម្រាប់គោលដៅអាករលើតម្លៃបន្ថែមតែប៉ុណ្ណោះ។

### មាត្រា៥.- ការផ្គត់ផ្គង់ទំនិញ ឬសេវា ពីអាជីវកម្មទៅអ្នកប្រើប្រាស់

អ្នកជាប់ពន្ធអនិវាសនជនដែលបានផ្គត់ផ្គង់ទំនិញឌីជីថល ឬសេវាឌីជីថល ឬរាល់សកម្មភាពពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកមកអ្នកប្រើប្រាស់ក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវមានកាតព្វកិច្ចដាក់លិខិតប្រកាសនិងបង់ប្រាក់អាករលើតម្លៃបន្ថែមមករដ្ឋបាលសារពើពន្ធ យ៉ាងយឺតបំផុតត្រឹមថ្ងៃទី២០ នៃខែបន្ទាប់ ពីខែដែលបានទូទាត់។

### មាត្រា៦.- ការផ្គត់ផ្គង់ទំនិញ ឬសេវា ពីអាជីវកម្មទៅអាជីវកម្ម

អ្នកជាប់ពន្ធនិវាសនជនដែលទទួលការផ្គត់ផ្គង់ទំនិញឌីជីថល ឬសេវាឌីជីថល ឬរាល់សកម្មភាពពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកពីអ្នកជាប់ពន្ធអនិវាសនជន ត្រូវប្រមូលអាករតាមវិធីគិតអាករជំនួស (Reverse Charge) ហើយធ្វើការប្រកាសនិងបង់អាករលើតម្លៃបន្ថែមមករដ្ឋបាលសារពើពន្ធ តាមច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារជាធរមាន។

### មាត្រា៧.- អាករលើធាតុចូល

អាករលើធាតុចូលដូចមានកំណត់ក្នុងមាត្រា៦ នៃអនុក្រឹត្យនេះ ត្រូវបានអនុញ្ញាតជាឥណទានអាករលើធាតុចូលដោយផ្អែកតាមច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារជាធរមាន។

### មាត្រា៨.- វិធាននិងនីតិវិធីលម្អិត

វិធាននិងនីតិវិធីលម្អិតនៃការអនុវត្តអនុក្រឹត្យនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី ៣
## ទោសប្បញ្ញត្តិ

**មាត្រា៩.- ទោសទណ្ឌ**

អ្នកជាប់ពន្ធនិវាសនជន និងអនិវាសនជន ដែលមិនបានបំពេញកាតព្វកិច្ចតាមស្មារតីនៃអនុក្រឹត្យនេះ ត្រូវទទួលរងទោសទណ្ឌស្របតាមច្បាប់និងបទប្បញ្ញត្តិស្ដីពីពន្ធដារជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី ៤
## អវសានប្បញ្ញត្តិ

**មាត្រា១០.- និរាករណ៍**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១១.- ការអនុវត្ត**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១១រោច ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៨ ខែមេសា ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន

សម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្ដម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១១
- រាជកិច្ច

**ឧបសម្ព័ន្ធ**

**នៃអនុក្រឹត្យលេខ៦៥ អនក្រ.បក ស្តីពីការអនុវត្តអាករលើតម្លៃបន្ថែមចំពោះពាណិជ្ជកម្មតាមប្រព័ន្ធ អេឡិចត្រូនិក ចុះថ្ងៃទី ៨ ខែ មេសា ឆ្នាំ២០២១**

**ឧទាហរណ៍នៃសកម្មភាព ឬប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងសេចក្តីពន្យល់**

១. ដំណើរការនៃការបញ្ជាទិញទំនិញរូបីតាមប្រព័ន្ធអេឡិចត្រូនិក (Electronic Order Processing of Tangible Products) ៖

អតិថិជនជ្រើសរើសទំនិញរូបីក្នុងបញ្ជីមុខទំនិញតាមអ៊ីនធឺណិត និងបញ្ជាទិញទំនិញទាំងនោះដោយផ្ទាល់តាមប្រព័ន្ធអេឡិចត្រូនិកពីអ្នកផ្គត់ផ្គង់ ហើយទំនិញរូបីត្រូវបានបញ្ជូនទៅអតិថិជនតាមមធ្យោបាយផ្សេងៗ។ ជាទូទៅ អតិថិជនមិនត្រូវបានតម្រូវឱ្យមានការគិតថ្លៃដាច់ដោយឡែកទៀតទេ សម្រាប់ការប្រើប្រាស់បញ្ជីមុខទំនិញតាមអ៊ីនធឺណិត។

២. ការបញ្ជាទិញនិងការទាញយក (Download) ទំនិញឌីជីថលតាមប្រព័ន្ធអេឡិចត្រូនិក (Electronic Ordering and Downloading of Digital Products)

អតិថិជនជ្រើសរើសសូហ្វវែរ (Software) ក្នុងបញ្ជីមុខទំនិញតាមអ៊ីនធឺណិត ឬផលិតផលឌីជីថលផ្សេងៗទៀត និងបញ្ជាទិញទំនិញទាំងនោះដោយផ្ទាល់តាមប្រព័ន្ធអេឡិចត្រូនិកពីអ្នកផ្គត់ផ្គង់ ហើយទំនិញឌីជីថលត្រូវបានទាញយកដាក់ក្នុងឧបករណ៍ផ្ទុកទិន្នន័យ (Hard Disk) របស់អតិថិជន ឬបញ្ជូនតាមមធ្យោបាយផ្សេងទៀត។ ជាទូទៅ អតិថិជនមិនត្រូវបានតម្រូវឱ្យមានការគិតថ្លៃដាច់ដោយឡែកទៀតទេ សម្រាប់ការប្រើប្រាស់បញ្ជីមុខទំនិញតាមអ៊ីនធឺណិត។

៣. ការបញ្ជាទិញនិងការទាញយកទំនិញឌីជីថលដែលមានសិទ្ធិអ្នកនិពន្ធតាមប្រព័ន្ធអេឡិចត្រូនិកសម្រាប់ប្រើប្រាស់ក្នុងគោលដៅពាណិជ្ជកម្ម (Electronic Ordering and Downloading of Digital Products for Purposes of Commercial Exploitation of the Copyright)

អតិថិជនជ្រើសរើសសូហ្វវែរ (Software) ក្នុងបញ្ជីមុខទំនិញតាមអ៊ីនធឺណិត ឬផលិតផលឌីជីថលផ្សេងៗទៀត និងបញ្ជាទិញទំនិញទាំងនោះដោយផ្ទាល់តាមប្រព័ន្ធអេឡិចត្រូនិកពីអ្នកផ្គត់ផ្គង់ ហើយទំនិញឌីជីថលត្រូវបានទាញយកដាក់ក្នុងឧបករណ៍ផ្ទុកទិន្នន័យ (Hard Disk) របស់អតិថិជន ឬបញ្ជូនតាមមធ្យោបាយផ្សេងទៀត។ ជាទូទៅ អតិថិជនមិនត្រូវបានតម្រូវឱ្យមានការគិតថ្លៃដាច់ដោយឡែកទៀតទេ សម្រាប់ការប្រើប្រាស់បញ្ជីមុខទំនិញតាមអ៊ីនធឺណិត។ អតិថិជនទទួលបានសិទ្ធិប្រើប្រាស់សិទ្ធិចម្លងទំនិញឌីជីថលក្នុងគោលដៅពាណិជ្ជកម្ម (ឧទាហរណ៍៖ អ្នកបោះពុម្ពសៀវភៅទទួលបានសិទ្ធិប្រើប្រាស់រូបភាព សម្រាប់យកទៅបោះពុម្ពលើក្របសៀវភៅ)។

៤. ការធ្វើបច្ចុប្បន្នភាព និងបន្ថែមមុខងារថ្មីៗទៅលើសូហ្វវែរ (Updates and Add-Ons)

អ្នកផ្គត់ផ្គង់សូហ្វវែរ (Software) ឬទំនិញឌីជីថលផ្សេងទៀត យល់ព្រមផ្តល់ជូនអតិថិជននូវការធ្វើបច្ចុប្បន្នភាព (Updates) និងបន្ថែមមុខងារថ្មីៗ (Add-Ons) ទៅលើសូហ្វវែរ ដោយពុំមានកិច្ចព្រមព្រៀងដើម្បីផលិតកម្មវិធីធ្វើបច្ចុប្បន្នភាព ឬបន្ថែមមុខងារជាក់លាក់ណាមួយសម្រាប់ឱ្យអតិថិជននោះទេ។ អតិថិជនពុំមានសិទ្ធិប្រើប្រាស់ ឬធ្វើអាជីវកម្មនូវកម្មសិទ្ធិបញ្ញាលើផលិតផលឌីជីថល ឬបន្ថែមមុខងារថ្មីៗ ក្នុងគោលដៅពាណិជ្ជកម្មនោះទេ។

## ៥. អាជ្ញាបណ្ណប្រើប្រាស់សូហ្វវែរមានកាលកំណត់ និងព័ត៌មានឌីជីថលផ្សេងៗ (Limited Duration Software and Other Digital Information Licenses)

អតិថិជនទទួលបាននូវសិទ្ធិក្នុងការប្រើសូហ្វវែរ (Software) ឬផលិតផលឌីជីថលផ្សេងទៀត សម្រាប់រយៈពេលកំណត់មួយ ដែលមានរយៈពេលតិចជាងអាយុកាលរបស់ផលិតផលនោះ។ ផលិតផលនោះអាចទាញយកតាមប្រព័ន្ធអេឡិចត្រូនិក ឬតាមរយៈមធ្យោបាយផ្សេងៗ ដូចជាស៊ីឌី (CD) ជាដើម។ គ្រប់ផលិតផលឌីជីថល ត្រូវបានលុបចោល ឬមិនអាចប្រើបាននៅពេលផុតកំណត់នៃអាជ្ញាបណ្ណ។

## ៦. សិទ្ធិប្រើប្រាស់តែមួយដងនូវសូហ្វវែរ ឬផលិតផលឌីជីថលផ្សេងៗ (Single-Use Software or Other Digital Product)

អតិថិជនទទួលបាននូវសិទ្ធិតែមួយដងក្នុងការប្រើសូហ្វវែរ (Software) ឬផលិតផលឌីជីថលផ្សេងទៀត ដែលផលិតផលទាំងនោះអាចទាញយក ឬប្រើប្រាស់ពីចម្ងាយ (ឧទាហរណ៍÷ ការប្រើសូហ្វវែរដែលត្រូវបានរក្សាទុកដោយម៉ាស៊ីនមេពីចម្ងាយ)។ អតិថិជនមិនទទួលបានសិទ្ធិចម្លងបន្តលើផលិតផលឌីជីថលទាំងនោះ លើសពីលក្ខខណ្ឌប្រើប្រាស់ដែលបានកំណត់។

## ៧. ការផ្គត់ផ្គង់សេវាបង្ហោះកម្មវិធីសូហ្វវែរ-អាជ្ញាបណ្ណដាច់ដោយឡែកពីគ្នា (Application Hosting-Separate License)

អតិថិជនម្នាក់មានអាជ្ញាបណ្ណអចិន្ត្រៃយ៍សម្រាប់ការប្រើកម្មវិធីសូហ្វវែរមួយ។ អតិថិជនត្រូវចុះកិច្ចសន្យាជាមួយក្រុមហ៊ុនផ្តល់សេវា ដើម្បីដំឡើងកម្មវិធីនោះនៅលើម៉ាស៊ីនមេដែលគ្រប់គ្រងដោយក្រុមហ៊ុនផ្តល់សេវា។ ក្រុមហ៊ុនផ្តល់សេវាបង្ហោះកម្មវិធីសូហ្វវែរជាអ្នកគាំទ្របច្ចេកទេស និងការពារភាពមិនដំណើរការនៃប្រព័ន្ធរបស់អ្នកផ្តល់សេវា។ អតិថិជនអាចចូល, ប្រតិបត្តិ, និងបញ្ជាលើកម្មវិធីសូហ្វវែរពីចម្ងាយ។ កម្មវិធីនេះជាប្រតិបត្តិការលើកុំព្យូទ័ររបស់អតិថិជន បន្ទាប់ពីបានទាញយកទៅក្នុងអង្គចងចាំ (RAM) ឬពីម៉ាស៊ីនមេរបស់ក្រុមហ៊ុនផ្តល់សេវា។ ការរៀបចំប្រភេទនេះអាចអនុវត្ត ឧទាហរណ៍÷ ការផ្គត់ផ្គង់ហិរញ្ញវត្ថុ, ការគ្រប់គ្រងសារពើភណ្ឌ, ការគ្រប់គ្រងធនធានមនុស្ស ឬការគ្រប់គ្រងធនធានសហគ្រាស នៃកម្មវិធីសូហ្វវែរ។

## ៨. ការផ្គត់ផ្គង់សេវាបង្ហោះកម្មវិធីសូហ្វវែរ-កិច្ចសន្យាជាកញ្ចប់ (Application Hosting-Bundled Contract)

អតិថិជនត្រូវចុះកិច្ចសន្យាជាមួយក្រុមហ៊ុនផ្តល់សេវា ដើម្បីប្រើប្រាស់កម្មវិធីផ្សេងៗនៅលើម៉ាស៊ីនមេដែលគ្រប់គ្រងដោយក្រុមហ៊ុនផ្តល់សេវាដោយផ្ទាល់។ ក្រុមហ៊ុនផ្តល់សេវាបង្ហោះកម្មវិធីសូហ្វវែរជាអ្នកគាំទ្របច្ចេកទេស និងការពារភាពមិនដំណើរការនៃប្រព័ន្ធរបស់អ្នកផ្តល់សេវាទាំងហាដវែរ(Hardware) និងសូហ្វវែរ (Software)។ អតិថិជនអាចចូល, ប្រតិបត្តិ, និងបញ្ជាលើកម្មវិធីសូហ្វវែរពីចម្ងាយ។ អតិថិជនអាចប្រើប្រាស់កម្មវិធីដោយប្រតិបត្តិលើកុំព្យូទ័ររបស់ខ្លួន បន្ទាប់ពីបានទាញយកដាក់ក្នុងអង្គចងចាំ (RAM) ឬប្រើនៅលើម៉ាស៊ីនមេរបស់ក្រុមហ៊ុនផ្តល់សេវា។ កិច្ចសន្យានេះអាចបន្តជារៀងរាល់ឆ្នាំជាមួយកម្រៃសេវាបន្ថែម។

## ៩. អ្នកផ្តល់សេវាប្រើប្រាស់កម្មវិធីសូហ្វវែរតាមអនឡាញ (Application Service Provider-ASP)

អ្នកផ្តល់សេវាប្រើប្រាស់កម្មវិធីសូហ្វវែរតាមអនឡាញ ត្រូវមានអាជ្ញាបណ្ណសម្រាប់ផ្តល់សេវាប្រើប្រាស់កម្មវិធីសូហ្វវែរដល់អតិថិជនរបស់ខ្លួន។ អ្នកផ្តល់សេវាអាចអនុញ្ញាតឱ្យអតិថិជនចូលប្រើនូវកម្មវិធីសូហ្វវែរតាមរយៈកុំព្យូទ័រមេរបស់ខ្លួន។ កម្មវិធីសូហ្វវែរត្រូវបានដំណើរការដោយស្វ័យប្រវត្តិនូវមុខងារអាជីវកម្មរបស់អតិថិជន។ ឧទាហរណ៍÷ កម្មវិធីសូហ្វវែរ អាចធ្វើស្វ័យប្រវត្តិកម្មស្វែងរកប្រភព, បញ្ជាទិញ, ទូទាត់ប្រាក់, និងបញ្ជូនទំនិញឬ

សេវា ដែលត្រូវបានប្រើប្រាស់ក្នុងអាជីវកម្មរបស់អតិថិជន។ អ្នកផ្តល់សេវាប្រើប្រាស់កម្មវិធីសូហ្វវែរតាមអនឡាញ មិនមែនជាអ្នកផ្គត់ផ្គង់ទំនិញឬសេវាកម្មទេ គឺគ្រាន់តែជាការផ្តល់ជូនអតិថិជននូវមធ្យោបាយស្វ័យប្រវត្តិកម្មភ្ជាប់ទៅភាគីទីបីដែលជាអ្នកផ្គត់ផ្គង់ទំនិញនិងសេវានោះ។ អតិថិជនពុំមានសិទ្ធិថតចម្លងកម្មវិធីសូហ្វវែរ ឬប្រើប្រាស់សូហ្វវែរលើសពីការអនុញ្ញាតរបស់អ្នកផ្តល់សេវាប្រើប្រាស់កម្មវិធីសូហ្វវែរតាមអនឡាញ។

**១០. កម្រៃលើអាជ្ញាបណ្ណដែលអ្នកផ្តល់សេវាប្រើប្រាស់កម្មវិធីសូហ្វវែរតាមអនឡាញត្រូវបង់ (ASP License Fees)**

អ្នកផ្តល់សេវាប្រើប្រាស់កម្មវិធីសូហ្វវែរតាមអនឡាញ ត្រូវទូទាត់ទៅឱ្យអ្នកផ្គត់ផ្គង់កម្មវិធីសូហ្វវែរនូវកម្រៃអាជ្ញាបណ្ណដោយគិតជាភាគរយនៃចំណូលដែលប្រមូលបានពីអតិថិជនតាមកិច្ចសន្យា។

**១១. សេវាបង្ហោះគេហទំព័រ (Website Hosting)**

អ្នកផ្តល់សេវាបង្ហោះគេហទំព័រ ផ្តល់ទំហំផ្ទុកទិន្នន័យនៅលើម៉ាស៊ីនមេរបស់ខ្លួនសម្រាប់បង្ហោះគេហទំព័រ។ អ្នកផ្តល់សេវាបង្ហោះគេហទំព័រមិនមានសិទ្ធិលើកម្មសិទ្ធិបញ្ញានៃមាតិកាគេហទំព័រដែលអ្នកអភិវឌ្ឍកម្មវិធីបានបង្កើតឡើយ។ ម្ចាស់គេហទំព័រមានសិទ្ធិផ្លាស់ប្តូរ កែប្រែគេហទំព័រ រួមទាំងការកែប្រែមាតិកានៃគេហទំព័រ។ អ្នកផ្តល់សេវាបង្ហោះគេហទំព័រ ទទួលបានកម្រៃតាមរយៈការចូលប្រើប្រាស់របស់អតិថិជន។

**១២. សេវាថែទាំលើកម្មវិធីសូហ្វវែរ (Software Maintenance)**

កិច្ចសន្យាថែទាំកម្មវិធីសូហ្វវែរជាកញ្ចប់ រួមមាន ការធ្វើបច្ចុប្បន្នភាពនិងការគាំទ្របច្ចេកទេស។ កម្រៃប្រចាំឆ្នាំសម្រាប់កិច្ចសន្យានេះត្រូវបានរួមបញ្ចូលទាំងការធ្វើបច្ចុប្បន្នភាពនិងការគាំទ្របច្ចេកទេស។ ករណីភាគច្រើន កម្មវត្ថុចម្បងនៃកិច្ចសន្យាគឺផ្តោតលើការផ្តល់សេវាធ្វើបច្ចុប្បន្នភាពកម្មវិធីសូហ្វវែរ។

**១៣. សេវាផ្ទុកទិន្នន័យ (Data Warehousing)**

អតិថិជនអាចផ្ទុកទិន្នន័យកុំព្យូទ័ររបស់ខ្លួននៅលើម៉ាស៊ីនមេដែលគ្រប់គ្រង និងបញ្ជាដោយអ្នកផ្តល់សេវាផ្ទុកទិន្នន័យ។ អតិថិជនអាចចូលប្រើប្រាស់, ផ្ទុក, ទាញយក និងរៀបចំទិន្នន័យពីចម្ងាយ ដោយចាំបាច់មានអាជ្ញាបណ្ណពីអ្នកផ្តល់សេវា។ ប៉ុន្តែអតិថិជនត្រូវមានកិច្ចសន្យាអំពីការប្រើប្រាស់នេះជាមួយអ្នកផ្តល់សេវា។

**១៤. សេវាគាំទ្របច្ចេកទេសតាមបណ្តាញកុំព្យូទ័រ (Customer Support over a Computer Network)**

អ្នកផ្តល់សេវានេះ ផ្តល់ឱ្យអតិថិជននូវការគាំទ្រខាងបច្ចេកទេសតាមបណ្តាញអ៊ីនធឺណិត រួមទាំងការប្រឹក្សាយោបល់ដើម្បីដំឡើងកម្មវិធីសូហ្វវែរ និងការផ្តល់ព័ត៌មានដើម្បីដោះស្រាយបញ្ហាបច្ចេកទេស។ សេវាគាំទ្រនេះអាចផ្តល់ជូនតាមរយៈឯកសារបច្ចេកទេសអនឡាញ និងទំនាក់ទំនងជាមួយអ្នកបច្ចេកទេសតាមរយៈអ៊ីម៉ែល ឬទូរសព្ទ។

**១៥. ការទាញយកទិន្នន័យ (Data Retrieval)**

អ្នកផ្តល់សេវានេះ បង្កើតឃ្លាំងផ្ទុកនូវរាល់ព័ត៌មានផ្សេងៗសម្រាប់ឱ្យអតិថិជនធ្វើការស្វែងរកនិងទាញយក។ សារប្រយោជន៍ចម្បងសម្រាប់អតិថិជន គឺលទ្ធភាពក្នុងការស្វែងរក និងស្រង់យកទិន្នន័យជាក់លាក់ណាមួយក្នុងចំណោមទិន្នន័យជាច្រើនទៀតដែលអាចទាញយកបាន។

**១៦. ការផ្តល់ទិន្នន័យផ្តាច់មុខ ឬទិន្នន័យមានតម្លៃខ្ពស់ដទៃទៀត (Delivery of Exclusive or Other High-Value Data)**

អ្នកផ្ដល់សេវានេះ រៀបចំប្រមូលទិន្នន័យនិងធ្វើការវិភាគលើទិន្នន័យទាំងនោះដើម្បីធ្វើជារបាយការណ៍ឬទិន្នន័យបំប្លែងមានលក្ខណៈពិសេសណាមួយសម្រាប់ផ្ដល់ជូនអតិថិជន (ឧទាហរណ៍÷ របាយការណ៍ទាក់ទិនទៅនឹងវិស័យឧស្សាហកម្មឬវិនិយោគ)។ អតិថិជនអាចធ្វើការបង់ប្រាក់ដើម្បីទាញយកនូវទិន្នន័យឬរបាយការណ៍ទាំងនោះតាមរយៈអនឡាញ។

**១៧. ការផ្សាយពាណិជ្ជកម្ម (Advertising)**

អ្នកចង់ផ្សព្វផ្សាយពាណិជ្ជកម្មអាចធ្វើការបង់ប្រាក់ ដើម្បីឱ្យសាធារណជនអាចមើលឃើញនូវផ្ទាំងផ្សព្វផ្សាយរបស់ខ្លួនតាមរយៈគេហទំព័រណាមួយ។ អត្រាតម្លៃសម្រាប់ការផ្សព្វផ្សាយនេះ ត្រូវបានគិតថ្លៃជាចំនួនដងនៃការបង្ហាញ ឬចំនួនដងនៃការចុចមើលផ្ទាំងផ្សព្វផ្សាយនោះ (ឧទាហរណ៍÷ គិតតម្លៃរៀងរាល់ការបង្ហាញមួយពាន់ដងម្តង ឬចុចមើលម្តងគិតប្រាក់ម្តង)។

**១៨. សេវាពិគ្រោះយោបល់តាមប្រព័ន្ធអេឡិចត្រូនិក (Electronic Access to Professional Advice)**

អ្នកប្រឹក្សាយោបល់, មេធាវី, វេជ្ជបណ្ឌិត និងអ្នកជំនាញអាជីពផ្សេងទៀត អាចផ្ដល់សេវាពិគ្រោះយោបល់ជូនអតិថិជនតាមរយៈអ៊ីម៉ែល, ការពិភាក្សាតាមរយៈវីដេអូ (Video Conferencing) ឬតាមរយៈការទាក់ទងពីចម្ងាយផ្សេងទៀត។

**១៩. ព័ត៌មានបច្ចេកទេស (Technical Information)**

ព័ត៌មានបច្ចេកទេសសម្ងាត់ដែលទាក់ទិនទៅនឹងផលិតផល ឬកិច្ចដំណើរការផលិតត្រូវបានផ្ដល់ជូនអតិថិជន (ឧទាហរណ៍÷ រូបមន្ត និងដ្យាក្រាមសម្ងាត់នៃដំណើរការផលិត)។

**២០. ការបញ្ជូនព័ត៌មាន (Information Delivery)**

អ្នកផ្ដល់សេវាបញ្ជូនទិន្នន័យតាមប្រព័ន្ធអេឡិចត្រូនិកទៅអតិថិជន តាមកាលកំណត់ស្របតាមការជ្រើសរើសផ្ទាល់ខ្លួន។ សារប្រយោជន៍ចម្បងសម្រាប់អតិថិជនគឺភាពងាយស្រួលនៃការទទួលបាននូវព័ត៌មានទូលំទូលាយ តាមកញ្ចប់សេវាកម្មដែលខ្លួនបានជ្រើសរើស។

**២១. ការចូលទៅគេហទំព័រមានលក្ខណៈអន្តរសកម្ម (Access to an Interactive Website)**

អ្នកផ្ដល់សេវាជូនដល់អតិថិជននូវគេហទំព័រដែលមានលក្ខណៈជាមាតិកាឌីជីថល រួមបញ្ចូលនូវព័ត៌មាន, តន្ត្រី, វីដេអូ, ល្បែងកម្សាន្ត និងសកម្មភាពផ្សេងៗ។ អតិថិជនបង់នូវកម្រៃកំណត់ណាមួយដើម្បីចូលប្រើប្រាស់សេវាកម្មនោះតាមកាលកំណត់ដែលបានជ្រើសរើស។

**២២. ផ្សារលក់ទំនិញតាមប្រព័ន្ធអ៊ីនធឺណិត (Online Shopping Portals)**

ប្រតិបត្តិករគេហទំព័របង្ហោះនូវបញ្ជីមុខទំនិញ តាមប្រព័ន្ធអេឡិចត្រូនិករបស់ពាណិជ្ជករជាច្រើនផ្សេងគ្នានៅលើម៉ាស៊ីនកុំព្យូទ័រមេរបស់ប្រតិបត្តិករនោះ។ អ្នកទិញអាចប្រើប្រាស់គេហទំព័រដើម្បីជ្រើសរើសផលិតផលពីបញ្ជីមុខទំនិញទាំងនោះនិងធ្វើការបញ្ជាទិញតាមអ៊ីនធឺណិត។ ប្រតិបត្តិករគេហទំព័រមិនមានទំនាក់ទំនងកិច្ចសន្យាជាមួយនឹងអ្នកទិញទំនិញទេ។ ប្រតិបត្តិករគេហទំព័រគ្រាន់តែបញ្ជូនការបញ្ជាទិញទៅឱ្យពាណិជ្ជករដែលជាអ្នកទទួលខុសត្រូវក្នុងការទទួលសំណើ និងបំពេញកាតព្វកិច្ចតាមការបញ្ជាទិញផ្សេងៗ។ ពាណិជ្ជករបង់ប្រាក់កម្រៃជើងសាទៅតាមបរិមាណនៃការបញ្ជាទិញ។

**២៣. ការដេញថ្លៃតាមប្រព័ន្ធអ៊ីនធឺណិត (Online Auctions)**

អ្នកផ្តល់សេវាបង្ហោះមុខទំនិញជាច្រើនសម្រាប់ការទិញដោយដេញថ្លៃ។ អ្នកទិញទំនិញអាចទិញដោយផ្ទាល់ពីម្ចាស់ដើមដោយមិនមែនទិញពីអ្នកផ្តល់សេវាកម្មបង្ហោះមុខទំនិញទេ។ អ្នកលក់បង់ថ្លៃសេវាដល់អ្នកផ្តល់សេវាបង្ហោះមុខទំនិញដោយគិតជាមួយភាគរយនៃតម្លៃទំនិញឬតម្លៃថេរណាមួយ។

**២៤. កម្មវិធីណែនាំបន្តការលក់ទំនិញ និងសេវា (Sales Referral Programs)**

អ្នកលក់ផលិតផលតាមប្រព័ន្ធអ៊ីនធឺណិត បង់កម្រៃជើងសាទៅឱ្យប្រតិបត្តិករគេហទំព័រដែលបានជួយណែនាំបន្តទៅអតិថិជន ដោយប្រតិបត្តិករគេហទំព័របង្ហោះផលិតផលនោះនៅលើគេហទំព័ររបស់ខ្លួន។ ប្រសិនបើអ្នកប្រើប្រាស់ចុចលើតំណភ្ជាប់ផលិតផលណាមួយក្នុងចំណោមផលិតផលទាំងនោះ អ្នកប្រើប្រាស់នឹងបានចូលទៅកាន់គេហទំព័ររបស់អ្នកលក់ផលិតផលដើម្បីធ្វើការបញ្ជាទិញ។ អ្នកលក់ផលិតផលអាចកំណត់អត្តសញ្ញាណប្រភពតំណភ្ជាប់នៃការណែនាំការលក់ដើម្បីធ្វើការបង់នូវកម្រៃជើងសារជូនប្រតិបត្តិករគេហទំព័រ ប្រសិនបើអ្នកប្រើប្រាស់ទិញនូវផលិតផលនោះ។

**២៥. ប្រតិបត្តិការទិញមាតិកាព័ត៌មាន (Content Acquisition Transactions)**

ប្រតិបត្តិករគេហទំព័រធ្វើការបង់ប្រាក់កម្រៃជូនផលិតករដែលបានផលិតមាតិកាផ្សេងៗ ដូចជា អត្ថបទព័ត៌មាន ការជូនដំណឹង ដែលបានបង្ហោះនៅលើគេហទំព័ររបស់ខ្លួនក្នុងគោលបំណងទាក់ទាញអ្នកប្រើប្រាស់ឱ្យចូលប្រើគេហទំព័រនោះ។ ប្រតិបត្តិករគេហទំព័រអាចជួលផលិតករ ដើម្បីបង្កើតនូវមាតិកាព័ត៌មានជាក់លាក់ណាមួយសម្រាប់គេហទំព័ររបស់ខ្លួន។

**២៦. ការផ្សព្វផ្សាយផលិតផលសោតទស្សន៍តាមរយៈគេហទំព័រ [Streamed (Real Time) Web Based Broadcasting]**

អ្នកប្រើប្រាស់ចូលប្រើបណ្ណាមាតិកានៃផលិតផលសោតទស្សន៍ដែលមានការរក្សាសិទ្ធិ។ ប្រតិបត្តិករផ្សព្វផ្សាយបានទទួលប្រាក់ចំណូលពីការជាវប្រចាំ ឬតាមរយៈការផ្សព្វផ្សាយពាណិជ្ជកម្ម។

**២៧. កម្រៃសេវាផ្សាយមាតិកាព័ត៌មាន (Carriage Fees)**

អ្នកផលិតមាតិកាបង់ប្រាក់កម្រៃសេវាជូនប្រតិបត្តិករគេហទំព័រ ដើម្បីអាចបង្ហាញនូវមាតិកាព័ត៌មានរបស់ខ្លួននៅលើគេហទំព័ររបស់ប្រតិបត្តិករ។

**២៨. ការចុះឈ្មោះប្រើប្រាស់ឬទាញយកផលិតផលឌីជីថលតាមគេហទំព័រ (Subscription to a Website Allowing the Downloading of Digital Products)**

អ្នកផ្តល់សេវាផ្គត់ផ្គង់នូវផលិតផលឌីជីថល ផ្តល់នូវសិទ្ធិប្រើប្រាស់ឬទាញយកផលិតផលឌីជីថលដែលមានការរក្សាសិទ្ធិជូនអតិថិជនដែលបានចុះឈ្មោះតាមគេហទំព័ររបស់ខ្លួន។ អតិថិជនបង់ប្រាក់កម្រៃក្នុងរយៈពេលកំណត់ណាមួយដើម្បីចូលប្រើប្រាស់គេហទំព័រនោះ។ សារប្រយោជន៍ចម្បងរបស់អ្នកប្រើប្រាស់ គឺមានលទ្ធភាពអាចទាញយកនូវផលិតផលឌីជីថលទាំងនោះ។

# ឧបសម្ព័ន្ធទី៦

ប្រកាសលេខ២៩០ ព.ណចបព.ប្រក ស្ដីពី ការផ្ដល់លិខិតអនុញ្ញាត ឬអាជ្ញាបណ្ណពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០២០

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងពាណិជ្ជកម្ម**

លេខ ២៩០ ព.ណ.....ប្រក

# ប្រកាស
## ស្តីពី
## ការផ្តល់លិខិតអនុញ្ញាត ឬអាជ្ញាបណ្ណពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៤ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៥/០១៩ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៧ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក
- បានឃើញអនុក្រឹត្យលេខ៣៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ១៣៤ អនក្រ.បក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២០ ស្តីពីការកំណត់ប្រភេទបែបបទ និងនីតិវិធីនៃការផ្តល់លិខិតអនុញ្ញាត ឬអាជ្ញាបណ្ណដល់អន្តរការី និងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងការលើកលែង
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម

## សម្រេច

**ប្រការ១.-**

ប្រកាសនេះមានគោលបំណងកំណត់បែបបទ ឯកសារតម្រូវក្នុងការផ្តល់ ការបន្តសុពលភាព ការធ្វើបច្ចុប្បន្នភាព និងការកែប្រែព័ត៌មាន លិខិតអនុញ្ញាត ឬអាជ្ញាបណ្ណពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដើម្បីមានតម្លាភាព និងបង្កលក្ខណៈងាយស្រួលដល់ការស្នើសុំ និងផ្តល់លិខិតអនុញ្ញាត ឬអាជ្ញាបណ្ណសម្រាប់ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។



ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារ: (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469

**ប្រការ២.-**

វាក្យសព្ទសំខាន់ៗ ដែលប្រើក្នុងប្រកាសនេះ ត្រូវបានកំណត់និយមន័យ ដូចខាងក្រោម៖

១- **លិខិតអនុញ្ញាត** សំដៅដល់លិខិតអនុញ្ញាតប្រកបអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

២- **អាជ្ញាបណ្ណ** សំដៅដល់អាជ្ញាបណ្ណសម្រាប់ប្រតិបត្តិការផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

៣- **បុគ្គលស្នើសុំ** សំដៅដល់រូបវន្តបុគ្គល សហគ្រាសឯកបុគ្គល នីតិបុគ្គល និងសាខាក្រុមហ៊ុនបរទេស ដែលដាក់ពាក្យស្នើសុំលិខិតអនុញ្ញាត ឬអាជ្ញាបណ្ណ។

៤- **មន្ត្រីត្រួតពិនិត្យ** សំដៅដល់មន្ត្រីរបស់ក្រសួងពាណិជ្ជកម្ម ដែលមានភារកិច្ចទទួល និងពិនិត្យពាក្យស្នើសុំលិខិតអនុញ្ញាត ឬអាជ្ញាបណ្ណ។

៥- **បុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក** សំដៅដល់បុគ្គលដែលប្រើប្រាស់មធ្យោបាយអេឡិចត្រូនិក ដើម្បីផ្គត់ផ្គង់ទំនិញ និង/ឬសេវា លើកលែងគ្រឹះស្ថានធានារ៉ាប់រង។

**ប្រការ៣.-**

បែបបទ និងនីតិវិធីនៃការស្នើសុំលិខិតអនុញ្ញាត ត្រូវបានកំណត់ដូចខាងក្រោម៖

១. រូបវន្តបុគ្គល សហគ្រាសឯកបុគ្គល ដែលនឹងប្រកបអាជីវកម្ម ធ្វើប្រតិបត្តិការ ឬសកម្មភាពពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវដាក់ពាក្យស្នើសុំលិខិតអនុញ្ញាត នៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម អគ្គនាយកដ្ឋានសេវាពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម ដោយត្រូវផ្តល់ព័ត៌មាន និងភ្ជាប់ឯកសារតម្រូវដូចខាងក្រោម៖

**ក- សម្រាប់រូបវន្តបុគ្គល**

- លិខិតអនុញ្ញាតប្រកបអាជីវកម្មចេញដោយអង្គភាពច្រកចេញចូលតែមួយរាជធានី-ខេត្ត
- ប័ណ្ណប៉ាតង់ (ប្រសិនបើមាន)
- អត្តសញ្ញាណបណ្ណដែលនៅមានសុពលភាពរបស់បុគ្គលស្នើសុំ
- រូបថត ៤x៦ របស់រូបវន្តបុគ្គល ដែលថតមិនលើសពី៣ខែមុន
- មានគណនីនៅគ្រឹះស្ថានហិរញ្ញវត្ថុណាមួយ
- ឯកសារគំរូអាជីវកម្ម (Business Model) និងទម្រង់កិច្ចការពារអ្នកប្រើប្រាស់ សម្រាប់ការធ្វើពាណិជ្ជកម្ម តាមប្រព័ន្ធអេឡិចត្រូនិក
- វិញ្ញាបនបត្រសេវាអនឡាញនិងឈ្មោះដែនពីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍(ប្រសិនបើមាន)
- បុគ្គលស្នើសុំត្រូវបំពេញពាក្យស្នើសុំដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធទី១ នៃប្រកាសនេះ។

**ខ- សម្រាប់សហគ្រាសឯកបុគ្គល**

- វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម ដែលមានកម្មវត្ថុអាជីវកម្មសម្រាប់ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក
- ប័ណ្ណប៉ាតង់
- មានគណនីនៅគ្រឹះស្ថានហិរញ្ញវត្ថុណាមួយ
- ឯកសារគំរូអាជីវកម្ម (Business Model) និងទម្រង់កិច្ចការពារអ្នកប្រើប្រាស់ សម្រាប់ការធ្វើពាណិជ្ជកម្ម តាមប្រព័ន្ធអេឡិចត្រូនិក
- វិញ្ញាបនបត្រសេវាអនឡាញ និងឈ្មោះដែនពីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ (ប្រសិនបើមាន)
- បុគ្គលស្នើសុំត្រូវបំពេញពាក្យស្នើសុំដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធទី២ នៃប្រកាសនេះ។

២.បន្ទាប់ពីទទួលបានពាក្យស្នើសុំ មន្ត្រីត្រួតពិនិត្យត្រូវពិនិត្យលើភាពត្រឹមត្រូវនៃលក្ខខណ្ឌតម្រូវ ព័ត៌មាន និងឯកសារភ្ជាប់ដែលបានបំពេញ ហើយត្រូវឆ្លើយតបដល់បុគ្គលស្នើសុំ ក្នុងរយៈពេលយ៉ាងយូរ ៥(ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ។

**ប្រការ៤.-**

១.ត្រូវបានលើកលែងការតម្រូវឱ្យស្នើសុំលិខិតអនុញ្ញាតប្រកបអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិក ចំពោះរូបវន្តបុគ្គល ឬសហគ្រាសឯកបុគ្គលដែលធ្វើសកម្មភាពឬប្រតិបត្តិការ ដូចខាងក្រោម៖

ក-ការផ្សព្វផ្សាយពាណិជ្ជកម្មអំពីទំនិញ ឬសេវារបស់ខ្លួន រួមបញ្ចូលទាំងការផ្សព្វផ្សាយលក់ទំនិញឬសេវាដែលមិនមែនជាសំណើបង្កើតកិច្ចសន្យា។

ខ-ការបម្រុងទុកសេវាដែលមិនមានការកក់ប្រាក់ ឬទូទាត់កម្រៃ ដោយអតិថិជនឬអ្នកប្រើប្រាស់។

គ-ការលក់ទំនិញ ឬសេវារបស់រូបវន្តបុគ្គលឬសហគ្រាសឯកបុគ្គល ដែលមានផលរបប នៅក្រោមកម្រិតផលរបរជាអ្នកជាប់ពន្ធតូច។

ឃ-ការលក់ទំនិញ ឬសេវាដែលមានលក្ខណៈគ្រួសារ ឬតាមរដូវកាលប្រមូលផល។

ង-ការលក់ទំនិញ ឬសេវាដែលជាស្នាដៃសិល្បៈផ្ទាល់ខ្លួនសុទ្ធសាធ។

ច-ការបង្ហាត់បង្រៀនដោយឯកជនផ្ទាល់ខ្លួន។

ឆ-ការបង្ហាត់បង្រៀន ឬអប់រំអំពីសាសនារបស់រដ្ឋ។

ការបង្ហាត់បង្រៀនដោយសមាគមដែលមិនរកប្រាក់ចំណេញដោយផ្ទាល់ ឬប្រយោល និងសកម្មភាពប្រតិបត្តិការដោយស្ថាប័នរដ្ឋ ក្នុងការផ្តល់សេវាសាធារណៈក៏ត្រូវបានលើកលែងការតម្រូវឱ្យស្នើសុំលិខិតអនុញ្ញាតផងដែរ។

២.បុគ្គលស្នើសុំ ត្រូវជូនដំណឹងតាមរយៈគេហទំព័រ www.ecommercelicensing.moc.gov.kh ឬបញ្ជូនមកនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម អគ្គនាយកដ្ឋានសេវាពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម ដែលមានព័ត៌មានដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធទី៣ នៃប្រកាសនេះ។

**ប្រការ៥.-**

១.នីតិបុគ្គល និងសាខាក្រុមហ៊ុនបរទេស ដែលនឹងប្រកបអាជីវកម្ម ធ្វើប្រតិបត្តិការ ឬសកម្មភាពពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ នៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម អគ្គនាយកដ្ឋានសេវាពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម ដោយត្រូវផ្តល់ព័ត៌មាន និងភ្ជាប់ឯកសារតម្រូវដូចខាងក្រោម៖

ក- វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម ដែលមានកម្មវត្ថុអាជីវកម្មសម្រាប់ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

ខ- ប័ណ្ណប៉ាតង់

គ- វិញ្ញាបនបត្រសេវាអនឡាញ និងឈ្មោះដែនពីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

ឃ- ឯកសារអំពីមធ្យោបាយទូទាត់ប្រាក់ផ្តល់ ដោយបុគ្គលផ្តល់សេវាទូទាត់ ដែលទទួលស្គាល់ដោយធនាគារជាតិនៃកម្ពុជា

ង- ឯកសារគំរូអាជីវកម្ម ( Business Model ) និងទម្រង់កិច្ចការពារអ្នកប្រើប្រាស់ សម្រាប់ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

ច- គំរូកិច្ចសន្យារវាងអន្តរការី និងបុគ្គលផ្តល់សេវាពាណិជ្ជកម្ម អំពីការតម្រូវការព័ត៌មានអប្បបរមា (សម្រាប់អន្តរការី)

ឆ- បុគ្គលស្នើសុំត្រូវបំពេញព័ត៌មាន នៅក្នុងតារាងនៃពាក្យស្នើសុំដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធទី៤ នៃប្រកាសនេះ។

២. បន្ទាប់ពីទទួលបានពាក្យស្នើសុំ មន្ត្រីត្រួតពិនិត្យត្រូវពិនិត្យលើភាពត្រឹមត្រូវនៃលក្ខខណ្ឌតម្រូវព័ត៌មាន និងឯកសារភ្ជាប់ដែលបានបំពេញ ហើយត្រូវឆ្លើយតបដល់បុគ្គលស្នើសុំក្នុងរយៈពេលយ៉ាងយូរ១០(ដប់)ថ្ងៃនៃថ្ងៃធ្វើការ។

**ប្រការ៦.-**

១. ក្នុងករណីព័ត៌មាន ឬឯកសារតម្រូវមិនគ្រប់គ្រាន់ និង/ឬមិនត្រឹមត្រូវ បុគ្គលស្នើសុំត្រូវធ្វើការកែតម្រូវ ឬផ្តល់នូវព័ត៌មាន ឬឯកសារតម្រូវបន្ថែមក្នុងអំឡុងពេល ៣០ (សាមសិប) ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីទទួលបានការជូនដំណឹងពីមន្ត្រីត្រួតពិនិត្យ។ រយៈពេលនៃការពិនិត្យ និងផ្តល់លិខិតអនុញ្ញាត ឬអាជ្ញាបណ្ណ ត្រូវគិតចាប់ពីថ្ងៃដែលបុគ្គលស្នើសុំបានកែតម្រូវ ឬបំពេញបន្ថែមគ្រប់គ្រាន់។

២. ក្នុងករណីបុគ្គលស្នើសុំ បានដាក់ព័ត៌មានមិនពិត និង/ឬឯកសារក្លែងបន្លំ ឬខកខានមិនបានកែតម្រូវព័ត៌មាន ឬផ្តល់ឯកសារតម្រូវបន្ថែម ក្នុងរយៈពេលដូចបានកំណត់ក្នុងកថាខណ្ឌទី១ មន្ត្រីត្រួតពិនិត្យអាចបដិសេធក្នុងការផ្តល់លិខិតអនុញ្ញាត ឬអាជ្ញាបណ្ណដល់បុគ្គលស្នើសុំ។

**ប្រការ៧.-**

លិខិតអនុញ្ញាត និងអាជ្ញាបណ្ណមានសុពលភាព ដូចខាងក្រោម៖

- លិខិតអនុញ្ញាតមានសុពលភាព ០២(ពីរ)ឆ្នាំ គិតចាប់ពីថ្ងៃផ្តល់លិខិតអនុញ្ញាតដោយក្រសួងពាណិជ្ជកម្ម។
- អាជ្ញាបណ្ណមានសុពលភាព ០៣ (បី) ឆ្នាំ គិតចាប់ពីថ្ងៃផ្តល់អាជ្ញាបណ្ណដោយក្រសួងពាណិជ្ជកម្ម។

**ប្រការ៨.-**

១- បុគ្គលស្នើសុំបន្តសុពលភាពលិខិតអនុញ្ញាត ឬអាជ្ញាបណ្ណ ត្រូវដាក់ពាក្យស្នើសុំមកនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម អគ្គនាយកដ្ឋានសេវាពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្មឱ្យបានយ៉ាងតិច ៣០ (សាមសិប) ថ្ងៃ មុនពេលអស់សុពលភាព។ ទម្រង់នៃពាក្យស្នើសុំបន្តលិខិតអនុញ្ញាតដូចភ្ជាប់ក្នុងឧបសម្ព័ន្ធទី៥.១ និងបន្តអាជ្ញាបណ្ណដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធទី៥.២ នៃប្រកាសនេះ។

២- ក្នុងករណីបុគ្គលដែលបានទទួលលិខិតអនុញ្ញាត ឬអាជ្ញាបណ្ណរួចហើយ តែខកខានមិនបានស្នើសុំបន្តសុពលភាពលិខិតអនុញ្ញាត ឬអាជ្ញាបណ្ណដូចបានកំណត់ក្នុងកថាខណ្ឌទី១ ខាងលើ នោះត្រូវបានចាត់ទុកថាបោះបង់ចោលលិខិតអនុញ្ញាត ឬអាជ្ញាបណ្ណ ហើយបុគ្គលនោះត្រូវដាក់ពាក្យស្នើលិខិតអនុញ្ញាត ឬអាជ្ញាបណ្ណឡើងវិញ ដូចបានកំណត់ក្នុងប្រការ៣ និងប្រការ៥ ខាងលើ ក្រោយពេលអស់សុពលភាព។

**ប្រការ៩.-**

១- រូបវន្តបុគ្គល សហគ្រាសឯកបុគ្គល នីតិបុគ្គល ឬសាខាក្រុមហ៊ុនបរទេស ដែលបានផ្លាស់ប្តូរ កែប្រែព័ត៌មាន ឬឯកសារក្នុងរយៈពេល ១៥(ដប់ប្រាំ)ថ្ងៃ ក្រោយពេលធ្វើការកែប្រែ ត្រូវដាក់ពាក្យស្នើសុំប្តូរលិខិតអនុញ្ញាត ឬអាជ្ញាបណ្ណនៅក្រសួងពាណិជ្ជកម្ម ដូចខាងក្រោម៖

- ឈ្មោះ និងអាសយដ្ឋានអាជីវកម្ម សហគ្រាស ឬក្រុមហ៊ុន
- កម្មវត្ថុអាជីវកម្ម ឬគំរូអាជីវកម្ម (Business Model)
- វិញ្ញាបនបត្រសេវាអនឡាញ និងឈ្មោះដែន
- គំរូកិច្ចសន្យារវាងអន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្ម
- មធ្យោបាយអេឡិចត្រូនិកសម្រាប់ទំនាក់ទំនងជាមួយអតិថិជន។

ការស្នើសុំប្តូរលិខិតអនុញ្ញាត ឬអាជ្ញាបណ្ណ ត្រូវបំពេញពាក្យស្នើសុំដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធទី៦.១។

២- រាល់ការផ្លាស់ប្តូរ ឬកែប្រែព័ត៌មាន ឬឯកសារភ្ជាប់ក្រៅពីចំណុចដែលបានចែងក្នុងកថាខណ្ឌទី១ខាងលើ រូបវន្តបុគ្គល សហគ្រាសឯកបុគ្គល នីតិបុគ្គល ឬសាខាក្រុមហ៊ុនបរទេស ត្រូវធ្វើបច្ចុប្បន្នភាពជូននាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម អគ្គនាយកដ្ឋានសេវាពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ ក្រោយពេលធ្វើការកែប្រែ តាមរយៈការបំពេញព័ត៌មាន និងឯកសារដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធទី៦.២ ឬតាមរយៈគេហទំព័រ www.ecommercelicensing.moc.gov.kh។

**ប្រការ១០.-**

ក្នុងករណីដែលបុគ្គលបានទទួលលិខិតអនុញ្ញាត ឬអាជ្ញាបណ្ណរួចហើយ មានបំណងផ្អាកជាបណ្ដោះអាសន្ននូវសកម្មភាព ឬបញ្ឈប់ប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវដាក់ពាក្យស្នើសុំ មកនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម អគ្គនាយកដ្ឋានសេវាពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម ហើយត្រូវបំពេញពាក្យស្នើសុំដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធទី៧។

**ប្រការ១១.-**

កម្រៃសេវាដែលត្រូវបង់ចូលជាថវិការដ្ឋ ត្រូវផ្អែកតាមការកំណត់ក្នុងប្រកាសរួមរវាងរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ១២.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១៣.-**

នាយកខុទ្ទកាល័យ គ្រប់អគ្គនាយកនៃអគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន គ្រប់ប្រធាននាយកដ្ឋាន គ្រប់ប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងពាណិជ្ជកម្ម ត្រូវអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ៧ រោច ខែ អស្សុជ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៩ ខែ តុលា ឆ្នាំ២០២០

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន សូរស័ក្តិ**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ឧបនាយករដ្ឋមន្ត្រីប្រចាំការ
- រដ្ឋបាលរាជធានី ខេត្ត
- អគ្គនាយកដ្ឋានពន្ធដារ
- ដូចប្រការ១៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ